វេជ្ជសាស្ត្របសុព្យាបាលទាក់ទងទៅនឹងការព្យាបាលជម្ងឺ និងការពារជម្ងឺ។ វេជ្ជសាស្ត្របសុព្យាបាល គឺជាផ្នែកមួយនៃ វិទ្យាសាស្ត្រសត្វ ដែលពាក់ព័ន្ធទៅនឹងការធ្វើរោគវិនិច្ឆ័យ ការព្យាបាល ការការពារ និង ការសិក្សាទូទៅនៃជម្ងឺសត្វជាពិសេសសត្វស្រុក។

ក្នុងការអនុវត្តន៍លើការត្រួតពិនិត្យសត្វ ត្រូវមានចំណេះដឹងដ៏រឹងមាំ លើកាយវិភាគវិទ្យា សរីរវិទ្យា ប៉ារ៉ាស៊ិតសាស្ត្រ រោគសាស្ត្រ អតិ សុខុមប្រាណ និង ឱសថសាស្ត្រ។ បន្ថែមពីលើនេះ ការត្រួតពិនិត្យសត្វ ត្រូវមានចំណេះដឹងគ្រប់គ្រាន់ដើម្បីធ្វើការតាមដាន និងយល់ច្បាស់អំពីទម្លាប់ និងអត្តចរិកសត្វមានសុខភាពល្អធម្មតា ដើម្បីមានសមត្ថភាពញែកឲ្យដាច់រវាងសត្វមានជម្ងឺ និងសត្វមានសុខភាពល្អ។

ការត្រួតពិនិត្យសត្វ និងវេជ្ជសាស្ត្របសុព្យាបាល( Veterinary Medicine ) អាចចែកចេញជា:

១.១.១_ Clinical Veterinary Medicine -- គឺជាការពិនិត្យ សិក្សារោគវិនិច្ឆ័យ និងធ្វើសកម្មភាពប្រឆាំងជម្ងឺ និងជម្ងឺសត្វ។

១.១.២_ preventive Veterinary Medicine -- ជាការអនុវត្តន៍សកម្មភាព ថែរក្សាសុខភាពសត្វ នៅពេលមានជម្ងឺរាតត្បាត។ វាពាក់ព័ន្ធជាមួយការត្រួតពិនិត្យ និងការពារជម្ងឺសត្វ។

១.១.៣- សុខភាព គឺជាភាពសុខសាន្តទាំងផ្លូវកាយ និងផ្លូវចិត្ត ដែលធ្វើឲ្យការរស់រានមានជីវិតជំធាត់ និងការការពារខ្លួនពីការរាតត្បាតនៃជំងឺផ្សេងៗ ដើម្បីពន្លឿននូវសក្តានុពល សម្រាប់ផលិតកម្ម និង បន្តពូជ។

១.១.៤ -ជម្ងឺ គឺជាភាពមិនប្រក្រតី ឬសភាពប្រែប្រួលខុសប្លែកពីធម្មតា ដែលជាលទ្ធផលបង្កឡើងពីការរាតត្បាតនៃមេរោគ ការចុះខ្សោយ ឬពីបំរែបំរួលនៃបរិស្ថាន ។

ជំងឺបង្អាក់នូវមុខងារធម្មតារបស់សរីរាង្គ អាចបង្កឲ្យថាមពលនៅខាងក្នុងខ្លួនចុះខ្សោយ ផលិតផលសត្វថយចុះ រហូតបណ្តាលឲ្យសត្វងាប់បាន ។

នៅក្នុងប្រព័ន្ធចិញ្ចឹមសត្វ អ្នកចិញ្ចឹមមានការបារម្ភណ៍ ដូច្នេះគេបង្កើនការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅពេលដែលខឿនផលិតកម្មមានទំហំធំ និងមានសត្វច្រើន ។ ជម្ងឺអាចលេចឡើងជាលក្ខណៈសមីជម្ងឺ (Individual) ឈឺតែសត្វមួយដោយឡែក ហើយមិនបង្កអោយមានការរាតត្បាតទៅសត្វដ៏ទៃ វាជា

បញ្ហាមិនសូវសាំញ៉ាំប៉ុន្តែក្នុងករណីជម្ងឺរាតត្បាតព្រមគ្នាលើងហ្វូងសត្វ ឫលើសសត្វមួយក្រុមដូចជាជម្ងឺ បណ្តាលមកពីខ្វះសារជាតុគីមី ជម្ងឺបង្កដោយប៉ារ៉ាស៊ីត វីរុសផ្សេងៗ អាចបង្កអោយមានការខាតបង់យ៉ាងធំធេងជាកង្វល់គំរៀមកំហែងសេដ្ឋកិច្ច ។ ដើម្បីចៀសវៀសនូវការខាតបង់ និងបរាជ័យក្នុងការចិញ្ចឹមសត្វគេត្រូវផ្តែកលើការយកចិត្តទុកដាក់ជាចំបង កត្តាសុខភាពទូទៅតាមរយៈការអនុវត្ត វិធានការការពារលើសត្វនិមួយៗក៏ដូចជាហ្វូងដើម្បីប្រឆាំងទប់ស្កាត់ជម្ងឺ ដែលអាចផ្ទុះឡើងដោយវិធានការណ៍ចាក់ថ្នាំការពារការថែបំប៉ន ផ្តល់ចំណី និងរក្សាអនាម័យ។

## ១.១ គោលបំណងនៃការសិក្សាការត្រួតពិនិត្យសត្វ

ការត្រួតពិនិត្យសត្វសិក្សាពីសាខានៃជីវសាស្រ្ត ដែលទាក់ទងនិងការសិក្សានៃជម្ងឺ

( Disease ) ។ អ្វីជាជម្ងឺ គឺជាការប្រែប្រួលនៃសារពាង្គកាយ ( Organism ) ប្លែកខុសពីប្រក្រតីដែលបណ្តាលមកពីកត្តាផ្សេងៗ។ ការសិក្សារោគសាស្រ្តទាក់ទងទៅនិងការសិក្សាសរីរៈវិទ្យា (Physiology) កាយវិភាគវិទ្យា ( Anatomy )។ បរិយាកាសវិទ្យា (Environment ) និងមរតពូជ (Genetic ) ។

អ្វីទៅជាសុខភាព និងជម្ងឺ ( What is health and disease ?)

**ក. សុខភាព** (Health): គឺជាភាពសុខសាន្តនិងភាពរស់រវើកនៃសារពាង្គដែលឯករាជ្យ។ ក្នុងផលិតកម្មចិញ្ចឹមសត្វ ( Livestock Production ) _ សុខភាពសត្វជាកត្តាជះឥទ្ធិពលផ្ទាល់ដល់ផលចំណេញ ពោលគឺការចិញ្ចឹមសត្វ និងការលូតលាស់អាស្រ័យលើសត្វមានសុភាពល្អ (Health) animale)។ មានកត្តាជាច្រើនដែលទាក់ទងដល់ផលចំណេញនៃផលិតកម្មនោះ គឺសុខភាពដែលជាមូលដ្ឋានគ្រឹះ។ ហើយសត្វអាចមានសុខភាពល្អលុះត្រាតែមានការចាត់ចែង ( Management ) និងធ្វើអនាម័យបានល្អ (Good Hygiene) ។

**ខ. ជម្ងឺ** (Disease): ជម្ងឺបានត្រូវគេកំណត់និយមន័យយ៉ាងងាយថា ជាការផ្ទុះឡើងនូវបាតុភូតខុសពីប្រក្រតីទៅលើជីវសាស្រ្តនៃសារពាង្គកាយ (Physiological Function )។ និយមន័យនេះរួមបញ្ចូលទាំងបុព្វហេតុផ្សេងៗ ដែលបណ្តាលអោយប៉ះពាល់ដល់អាយុជីវិត និងបុព្វហេតុឲ្យមានការប៉ះទង្គិចដល់សារៈពាង្គកាយ។

នៅក្នុងប្រព័ន្ធចិញ្ចឹមសត្វ អ្នកចិញ្ចឹមមានការបារម្ភណ៍ ដូច្នេះគេបង្កើនការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅពេលដែលខឿនផលិតកម្មមានទំហំធំ និងមានសត្វច្រើន ។ ជម្ងឺអាចលេចឡើងជាលក្ខណៈសមីជម្ងឺ (Individual) ឈឺតែសត្វមួយដោយឡែក ហើយមិនបង្កអោយមានការរាតត្បាតទៅសត្វដ៏ទៃ វាជាបញ្ហាមិនសូវសាំញ៉ាំប៉ុន្តែក្នុងករណីជម្ងឺរាតត្បាតព្រមគ្នាលើងហ្វូងសត្វ ឫលើសសត្វមួយក្រុមដូចជាជម្ងឺ បណ្តាលមកពីខ្វះសារជាតុគីមី ជម្ងឺបង្កដោយប៉ារ៉ាស៊ីត វីរុសផ្សេងៗ អាចបង្កអោយមានការ

ខាតបង់យ៉ាងធំធេងជាកង្វល់គំរៀមកំហែងសេដ្ឋកិច្ច។ ដើម្បីចៀសវៀសនូវការខាតបង់ និងបរាជ័យក្នុងការចិញ្ចឹមសត្វគេត្រូវផ្អែកលើការយកចិត្តទុកដាក់ជាចំបង កត្តាសុខភាពទូទៅតាមរយៈការអនុវត្ត វិធាមការការពារលើសត្វនិមួយៗក៏ដូចជាហ្វូងដើម្បីប្រឆាំងទប់ស្កាត់ជម្ងឺ ដែលអាចផ្ទុះឡើងដោយវិធានការណ៍ចាក់ថ្នាំការពារការថៃបំប៉ន ផ្តល់ចំណី និងរក្សាអនាម័យ។

## ១.២ ជម្ងឺមានរោគសញ្ញា ( Clinical Disease )

ក្នុងករណីនេះ គេសម្គាល់ឃើងថាសត្វមានរោគសញ្ញាបង្ហាញអោយឃើញដូចជា រាគ ( Diarrhoea ) ការមិនស៊ីចំណី ( Anorexia ) ការចុះខ្សោយ (Weakness )ការថយទម្ងន់( Weight loss ) មានឡើងកម្តៅ (Fever ) មានការឈឺចាប់ ( pain )ជាដើម។

## ១.៣ គ្មានរោគសញ្ញាជម្ងឺ ( Subclinical Disease )

មានការសណ្ធានជាច្រើន ដែលឈឺគ្មានរោគសញ្ញាហើយបន្ថយសម្ថភាពបន្តពូជរបស់សត្វ និងការលូតលាស់បរបស់វា ដូចជាការចុះថយនៃអត្រាបង្កកំណើតកូនសត្វ និងការលូតលាស់ធំធាត់យឺត។ល។ ក្នុងសភាពធម្មតាកូនសត្វត្រូវលូតលាស់ក្នុងអត្រាសមាមាត្រកំណត់មួយ ( និយាម- Standard ) ច្បាស់លាស់

អាស្រ័យទៅពូជនិងប្រភេទរបស់សត្វ។ ឧទាហរណ៍ កូនជ្រូកក្នុងករណី ជម្ងឺគ្មានរោគសញ្ញាស៊ីចំណីច្រើន ប៉ុន្តែធំធាត់យឺត បើប្រៀបធៀបជាមួយកូនជ្រូកដ៏ទៃទៀត ដូច្នេះវាបណ្តាលអោយមានការខាតបង់យ៉ាងធំធេងលើការផ្តល់ចំណី ពេលវេលា និងកម្លាំងពលកម្ម។

$$\text{ជំងឺ} = \frac{\text{ប្រពលភាពនៃសារពាង្គ (Potential Of Organism)} \times \text{ភាពសាហាវនៃមេរោគ (Virulence of Germ)} \times \text{ស្ត្រេស (Stress)}}{\text{ភាពធន និង ភាពស៊ាំ}}$$

Stress- អាចបណ្តាលពីកត្តារូបសាស្ត្រ បរិស្ថានជុំវិញ ចំណីអាហារ ការប្រើប្រាស់ ។ល។

## ១.៤ សញ្ញាណទូទៅនៃការត្រួតពិនិត្យជម្ងឺសត្វ ( Definitions of Animal Disease Control )

ការត្រួតពិនិត្យរោគសាស្ត្រសត្វគឺជាវិទ្យាសាស្ត្រសិក្សាអំពីបម្រែបម្រួល និងកំហូចទ្រង់ទ្រាយនៃ Micro និង Macro Structures។ នៅលើសរីរាង្គ និងជាលិកាពេលមានជម្ងឺ។ រោគសាស្ត្រកាយវិភាគវិទ្យា និងរោគសាស្ត្រសរីរៈវិទ្យាជាផ្នែកដ៏ធំពីរក្នុងមុខវិទ្យារោគសាស្ត្រ។ Pathology មានន័យថា Pathos ការឈឺចាប់ដែលសិក្សាអំពីគ្រប់បម្រែបម្រួល និងការបាត់បង់មុខងារព្រមទាំងខូចខាតទ្រង់ទ្រាយនៅក្នុងសារពាង្គកាយ។ បម្រែបម្រួលមុខងារសរីរាង្គ និងទ្រង់ទ្រាយមានទំនាក់ទំនងគ្នាទៅ

វិញទៅមក ហើយ ការត្រួតពិនិត្យសត្វ ទាក់ទងទៅនឹងសិក្សាអំពីការវិវត្តនៃរោគសាស្ត្រសត្វ និង សិក្សាពីជម្ងឺតាមសញ្ញានៃបុព្វហេតុ បង្កជម្ងឺនោះជម្ងឺឆ្លងដែលបង្កឡើងដោយពពួកបាតុរី វីរុស ពពួក Fungus ជាដើម។

ជម្ងឺបង្កដោយប៉ារ៉ាស៊ីតដែលបង្កឡើងដោយពពួក Trematode (ព្រូនសំប៉ែត ), Cestoate (ពពួកតេនញ៉ា) Nematode (ព្រូនមូល), Carditis, Preicatitis,Anemia ។ល។

បុព្វហេតុបីខាងលើ ព្រមទាំងកត្តាគីមី និងកម្តៅ ពន្លឺ ព្រមទាំងមជ្ឈដ្ឋានជុំវិញមានមុខងារយ៉ាងសំខាន់ធ្វើអោយបាត់បង់មុខងារបណ្តូលរូបធាតុក្នុងសារពាង្គកាយភាវរស់។ ម្យ៉ាងវិញទៀតផ្នែកនេះសិក្សាផងដែរនូវទ្រង់ទ្រាយសរីរាង្គ និងប្រពន្ធសរីរាង្គពេលមានជម្ងឺផ្សេងៗ។ Pathoanatomy អាចអោយយើងដឹង និងកំណត់បាននូវរយៈពេលដែលសត្វងាប់ តាមរយៈការវិវត្តន៍នៃសាកសព។

មូលដ្ឋានគ្រឹះនៃការសិក្សាការត្រួតពិនិត្យជម្ងឺសត្វ គឺការសិក្សាពីភាព Normal Amatomy និង Normal Physiology ព្រោះថា ការត្រួតពិនិត្យជម្ងឺសត្វសិក្សាការធ្វើរោគវិនិច្ឆ័យជាបែបហើយដើម្បីសម្រេចការងារនេះបានគឺ យើងត្រូវចេះដឹងអំពីអ្វីដែលស្ថិតនៅក្នុងភាពធម្មតាជាបឋមសិន។ Patho-anatomy ផ្តល់នូវការសិក្សាពីការផ្លាស់ប្តូររោគសាស្ត្រនៅក្នុងសារពាង្គកាយ ពេលមានជម្ងឺផ្សេងៗកើតឡើង។ ខ្លឹមសារទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ ចំពោះវិទ្យាសាស្ត្រសត្វ ព្រោះថាវាជាគន្លឹះសម្រាប់ធ្វើការវិនិច្ឆ័យអោយបានត្រឹមត្រូវឈានទៅដល់ការព្យាបាល និងការពារជម្ងឺមានប្រសិទ្ធភាព។ ដើម្បីសិក្សា Patho-anatomy: យើងត្រូវអនុវត្តតាមរបៀបនៃការសិក្សារបស់វា ដែលមានដូចជា:

១. ការវះកាត់សាកសព ដើម្បីសិក្សាសរីរាង្គដែលមានជម្ងឺ

២. Biopsy ដើម្បីសិក្សាលើផ្នែកខ្លះ នៃខ្លួនសត្វពេលសត្វនៅរស់

៣ .រៀបចំធ្វើកញ្ចក់ដាំពណ៌ ដើម្បីសិក្សា Histological Process

៤ .ការមើល Microscop ប្រើពន្លឺ និងអេឡិចត្រូនិច

## ១.៥ ការស្លាប់ និងការផ្លាស់ប្តូរក្រោយពេលស្លាប់ ( Death and its Postmortem ):

គ្រប់ភាវៈរស់ទាំងអស់ តែងតែកើតឡើងនូវបាតុភូតនៃការស្លាប់ និងបម្រែបម្រួលក្រោយពេលស្លាប់ជានិច្ច។ ការសិក្សា និងបម្រែបម្រួលពីការស្លាប់ ផ្តល់អោយយើងអាចដឹងបានថាតើសាកសពដែលងាប់ នេះបណ្តូលពីបុព្វហេតុអ្វី។

១. Death: ជាការបញ្ឈប់មិនត្រឡប់វិញនូវសកម្មភាពសរីរាង្គ និងសារពាង្គកាយ។ គេចែកការស្លាប់ជា:

a) Physiological កើតឡើងជាបន្តបន្ទាប់ ហើយជីវិតទាំងអស់ចុះថយ បន្តិចម្តងៗរហូតដល់បាត់បង់សម្មភាព ច្រើតែកើតឡើងលើសត្វ ឬមនុស្សចាស់។

b) Pathological: កាលណាកើតឡើងបណ្តាលពីជម្ងឺ ឬ ក៏បណ្តលពីកត្តានៃអំពើខាងក្នុង ឬខាងក្រៅ។ការវិវត្តនៃការចុះខ្សោយបន្តិចម្តងៗ ហៅថា Agony បន្តក្នុងរយៈពេលខ្លី ពេលនោះចលនាដង្ហើម ចលនាបេះដូងត្រូវផ្លាសប្តូរបាត់បង់រំញោច កើងឡើងនូវ Agony ព្រមទាំងបញ្ឈប់ចលនាបេះដូង និងដង្ហើម។

c) Clinical: កាលណាចលនាបេះដូងត្រូវបានបញ្ឈប់ក្នុងរយៈពេលណាមួយ បន្ទាប់មកបន្តចលនាបន្តិចទៀតដែលនៅពេលនោះសរីរាង្គទាំងណាយកន្រ្តាក់កើតឡើងវិញនោះវាឈានទៅរកការរឹងហើយរលួយបន្តទៀត។ ការរឹងអាចមានឡើង ២០ នាទីបន្ទាប់ពីបញ្ឈប់ចលនាបេះដូងហើយរយៈពេលនេះវាកើនឡើង ប្រសិនបើគេយកសារពាង្គកាយទៅដាក់នៅកន្លែងត្រជាក់។

d) Bioloogical: គឺជាដំណើរចុះថយសកម្មភាពសារពាង្គកាយ ហើយបន្តសញ្ញាជីវិតត្រូវបានបញ្ឈប់អស់តែម្តង។

e) Cause of Death

១. Parelysis and Collapse of Heart

២. Respiratory Collapse ដោយសារមាន Paralysis នៃប្រដាប់ដកដង្ហើម សរសៃប្រសាទ។ ការបញ្ឈប់ចលនាបេះដូង និងដង្ហើមអាចបណ្តាលមកពីដាច់សរសៃឈាម Infact នៃសាច់ដុំបេះដូង។

គេពិនិត្យឃើញតាមរយៈការបាត់បង់ជីពចរ និងរំញោចគ្មានលក្ខខ័ណ្ឌ។

- ការវិវត្តមានដូចតទៅ៖

១. ការចុះសីតុណ្ហភាព

២. ការកករឹង

៣. ការជាំ

៤. ការរលួយ

ក. ការចុះសីតុណ្ហភាព ប្រែប្រួលជាបន្តបន្ទាប់ ១ អង្សាសេចុះថងក្នុងរយៈពេល ១ ម៉ោងរហូតដល់សីតុណ្ហភាពសាកសពស្មើនឹងសីតុណ្ហភាព នៃមជ្ឈដ្ឋានខាងក្រៅ

ខ. ការរឹងនៃសាកសព: គឺជាការហាប់ណែននៃសាច់ដុំ និងសន្លាក់កើតឡើង ១-២ម៉ោង បន្ទាប់ពីសត្វស្លាប់។ ដំបូងសាកសពស្ថិតនៅកន្លែងមួយមិនផ្លាស់ប្តូរសាច់ដុំទៅជាទន់ សន្លាក់ទន់អាច បត់បានរយៈពេល

៣-៤ ម៉ោងបន្ទាប់មកសាច់ដុំក្លាយជារឹង ពីព្រោះ Glycogen បានបំផ្លាញ ហើយបំផ្លែងជាស្ករដែលធ្វើ អោយសាច់ដុំហាប់ណែនរឹង។ បម្រែបម្រួលទៅជារឹងបន្តដល់ ២០-២៤ម៉ គឺវាចាប់ផ្តើមពីសាច់ដុំក្បាល និងបញ្ឈប់នៅសាច់ដុំកន្ទុយមានន័យថា ការវិវត្តន៍ របស់វិវត្តពីក្បាលទៅកន្ទុយ។ បន្ទាប់មកដំណើរការ នេះបញ្ចប់ទៅវិញនៅក្នុងទិសដៅផ្ទុយគឺពីកន្ទុយមកក្បាលវិញ។

គ. ការជាំនៃសាកសព: កើតឡើងក្នុងរយៈពេល ៣-៦ម៉ បន្ទាប់ពីសត្វងាប់។ ឈាមតាមវ៉ែន បានទៅផ្តុំគ្នានៅបាតសរសៃវ៉ែន ពីព្រោះសរសៃឈាមពេលនេះឈប់កន្រ្ទាក់ទៀតហើយ គឺចលនាឈាម នៅនឹងមួយកន្លែងក្នុងសរសៃឈាមបាតុភូតនេះហៅថា Hypostasis ដែលជាដំណាក់កាលទី ១។ ស្នាម ជាំយើងអាចពិនិត្យឃើញបន្ទាប់ពីយើងបកស្បែកចេញ រយៈពេល ៨-១០ម៉ បន្ទាប់ពីស្លាប់ទឹកងងៃក៏ បានត្រូវប្រមូលផ្តុំនៅបាតសរសៃឈាម ជាមួយនិងកំណកឈាមក្នុងសរសៃឈាមនោះដែរហើយគោលិ កាក្រហមបែក (អេម៉ូក្លូបីន) ចេញសរសៃឈាមនេះជាដំណាក់កាលឈាមនៅក្នុងសាកសពមាន សភាពផ្សេងៗគ្នា ឈាមកក និងបង្កើតជាដុំនៅក្នុងបេះដូង និង សរសៃឈាម។ សាកសពស្លាប់ដោយ ពិឃាដាឈាមពុំកកទេ។ ដូចច្នេះសភាពឈាមគួបផ្សំនឹងការវិវត្តន៍នៃសាកសពសត្វនេះអាចអោយគេ សិក្សារកបុព្វហេតុ ដែលបណ្តាលអោយសត្វស្លាប់បាន។

ឃ. ការរលួយនៃសាកសព: កើតឡើងពីព្រោះអង់ស៊ីមបំពេញតួនាទីរបស់វា។ បរិមាណអង់ស៊ី មដែលច្រើនស្ថិតនៅក្នុងពោះវៀន ហើយការរលួយចាប់ផ្តើមពីកន្លែងណាដែលសម្បូរដោយអង់ស៊ីម។ ការធ្វើឡើងជាមួយពពួកបាតុរី មីក្រូផ្លរ៉ា ពពួកអតិសុខមប្រាណដទៃទៀតក្នុងសារពាង្គកាយសត្វបាន ត្រូវបំបែកដែបណ្តាលអោយសាច់ផុយរលួយ។ ពពួកបាតុរីដូចជា B. pulrificus, B. perfringeus , Coli ។ល។ បំបែកធ្វើអោយសាច់រលួយហើយបង្កើតជាសារជាតុដូចជា៖

- ប្រូតេអ៊ីន
- អាស៊ីត
- ឧស្ម័ន មេតាន....អម៉ូនីញ៉ាក់ ,
- ឧស្ម័នរបស់សាកសពមានក្លិនស្អុយខ្លាំងឬក៏ក្លិនរលួយ។ ការរលួយមានដំណើរប្រព្រឹត្តទៅលឿន ប្រសិនបើមានសំណើមនិងកំដៅ។ H2s ផ្សំជាមួយអេម៉ូក្លូបីនបង្កើតបានជា Sulphohemoglobine ដែលមានពណ៌លឿង ឬ លឿងទំ។ ហេតុច្នេះហើយបានជាការជាំដំបូងមានពណ៌ក្រហម បន្ទាប់មកមាន ពណ៌លឿងទំទៅវិញ។ ការលួយនៃសាកសពប្រព្រឹត្តទៅជាមួយការបង្កើតឧស្ម័ន និង ការប៉ោងរលួយ។ ការរលួយនេះបញ្ចប់ដោយការបំបែកសារជាតុគីមីនៃសារពាង្គកាយ។

អត្ថប្រយោជន៍នៃការល្វេយនៃសាកសព

១.កំណត់រយៈពេលនៃសត្វស្លាប់

២.កំណត់ស្ថានភាពនៃសត្វស្លាប់ ( វាដួលដេកទៅស្ដាំ ឬឆ្វេង )

៣. ស្លាកស្នាមជាំអាចសម្គាល់បាននូវការសំលាប់សត្វ

**១.៦ កត្តាមានឥទ្ធិពលលើសុខភាពសត្វ** ( FACTORSINFULENCING ANIMAL HEALTH )

មានកត្តា២ដែលជះឥទ្ធិពលដោយផ្ទាល់ និង ប្រយោល ត្រូវលើកមកសិក្សាៈ

- កត្តាមានឥទ្ធិពលផ្ទាល់( Direct Affected Factor )ដូចជាការបង្កឡើងដោយ អតិសុខុមប្រាណ បរ៉ាស៊ិត កត្តារូប កត្តាចំណី ការខ្វះជាតិគីមី ជីវជាតិ ការពុលជាដើម។
- កត្តារួមផ្សំផ្សេងៗដែលបង្កជម្ងឺ ( Predisposing Facto ) ជាកត្តារួមផ្សំផ្សេងៗ ដែលបង្កឲ្យសាព៌ាង្គកាយសត្វចុះខ្សោយគេចែលចេញជាកត្តារួមផ្សំខាងក្នុង Intrinsic និងកត្តារួមផ្សំខាងក្រៅ Extrinsic ។

ជម្ងឺនិងមិនអាចរាតត្បាតបានទេនៅពេលដែលសត្វមានភាពសាំនិងជម្ងឺ។ ភាពសាំ និង ភាពធន់នេះបានមកដោយការចាក់វ៉ាក់សាំង ឬការជាសះស្បើយពីជម្ងឺ។ សត្វដែលអាចទទួលជម្ងឺ ( Susceptible Animal ) ជាសត្វគ្មានភាពធន់ ( Resistance ) ឬភាពសាំជម្ងឺ ( Immunity ) ។




គំនូសសញ្ញាព្រួញ១: កត្តាមានឥទ្ធិពលលើសុខភាព

**១.៦.១- កត្តាមានឥទ្ធិពលផ្ទាល់**( Direct Affected Factors ):

ការបង្កជម្ងឺត្រូវបានចាក់ថ្នាំទៅតាមប្រភេទនៃសកម្មភាព ឬ អតិសុខុមប្រាណទាំងឡាយ ដែលបណ្តោយឲ្យមានបម្រែបម្រួលក្នុងសាព៌ាង្គកាយ។ នៅពេលមានជម្ងឺកើតឡើង បណ្តាលដោយកត្តាសំញាំច្រើន។ ករណីខ្លះជម្ងឺទាក់ទងផ្ទាល់ទៅនឹងលក្ខណៈជីវសាស្ត្ររបស់សត្វនីមួយផ្ទាល់ រីឯខ្លះទៀតមានកត្តារួមផ្សំទាំងឡាយដែលជួយគាំទ្រដល់ភ្នាក់ងារបង្កជម្ងឺ ឲ្យមានសកម្មភាពលើសារពាង្គកាយ ដែលអាចការពារបាន។ បុព្វហេតុផ្ទាល់បង្កជម្ងឺគឺ:

**១.៦.២- ភាពខូចរូបរាងពីកំណើត**( Congenital Deformity )

ជម្ងឺមានពីកំណើតដែលបណ្តាលមកពីការលូតលាស់មិនប្រក្រតី( Abnormal Development ) នៃអំប្រីយ៉ុង ( Fetus ) នៅពេលសត្វផើម( Pregnancy ) ។ ករណីនេះភាគច្រើនបណ្តាលមកពីការខូច

ខាត ឬ ជាឥទ្ធិពលតំណពូជ ដែលផ្តល់ដោយមេ-បា។ វាគឺជាការខូចទ្រង់ទ្រាយ (Malformation) រួមផ្សំជាមួយការលូតលាស់មិនប្រក្រតីនៃអំប្រីយ៉ុង(Abnormal Development of fetus) នៅក្នុងស្បូនមេ។ ករណីជាច្រើន ការខូចខាតរូបរាងពីកំណើត អាចស្រាយបញ្ជាក់អំពីបុព្វហេតុ បណ្តាលពីជម្ងឺ របស់មេពេលផើម។ សត្វអាចរលូត នៅពេលមានផ្ទុះជម្ងឺឆ្លង (Outbreak of Infectious Disease) ឬ មិនរលូត ហើយករណីនេះកូនសត្វ ដែលកើតមក អាចមានការខូចខាតរូបរាង ដូចជាខ្វាក់ភ្នែក ខូចជើង គ្មានប្រដាប់បន្តពូជ។ល។ ជួនកាលទៀតការខូចខាតរូបរាងនៃអំប្រីយ៉ុងអាចបណ្តាលមកពីការប្រើថ្នាំទៅលើសត្វមេពេលផើម។ដូច្នេះការប្រើប្រាស់ថ្នាំព្យាបាលត្រូវតែមានការយកចិត្តទុកដាក់ ចំពោះសត្វផើម (ក្នុងដំណាក់កាលដំបូង១ទៅ៣ខែ)។ ការប្រើថ្នាំនៅពេលសត្វផើម អាចជាបុព្វហេតុបណ្តាលឲ្យលេចឡើងនូវភាពមិនប្រក្រតីនៃកូនសត្វពេលកើត ហើយមួយទៀតការប្រែប្រួលសីតុណ្ហភាពខ្លួនសត្វពេលសត្វផើម ក៏ជះឥទ្ធិពលអាក្រកដល់ការលូតលាស់នៃអំប្រីយ៉ុងដោយសារសីតុណ្ហភាពខ្លួនសត្វឡើងខ្ពស់វាបណ្តាលឲ្យប្រព័ន្ធប្រសាទ (Nervous System) អសកម្ម ឬ បន្ថយការលូតលាស់ របស់អំប្រីយ៉ុង (Malfunction) ។ ការឡើងសីតុណ្ហភាពខ្លួនសត្វភាគច្រើនបណ្តាលមកពីការវត្បាតដោយពពួកអតិសុខុមប្រាណហើយដែលបណ្តាលឲ្យអំប្រីយ៉ុងលូតលាស់ខ្សោយ ឬ អាចងាប់នៅក្នុងពោះមេ។

ឧទាហរណ៍ៈ កូនគោដែលកើតមកពីមេ រាតត្បាតដោយវីរុស Azkaban នៅរវាងអាទិត្យទី៤ និងទី៨ នៃរយៈពេល ចាប់មានគភ៌ និងបណ្តាលឲ្យមានការបំផ្លាញសាច់ដុំ (Limb Deformity) ឬគ្មានជាលិកាខួរក្បាល (Non brain tissue) ហើយដែលបន្ទាប់មក ប្រអប់ខួរក្បាលត្រូវបានបំពេញដោយវត្ថុរាវ (Fluid)។ បរិមាណវត្ថុរាវកើនឡើងយ៉ាងច្រើន ហើយបន្តរាលដាលដល់ផ្នែកខាងលើនៃខួរក្បាលទៀត។ កូនគោបែបនេះនៅមានជីវិត ប៉ុន្តែពុំមានអាចធ្វើចលនា និងទំពៀអៀងបានឡើយ ហើយកូនគោនឹងស្លាប់ដោយដាច់ពោះ។ គេជួបប្រទះញឹកញាក់នូវករណីរូបភាពខ្លួនមួយក្បាល២ ឬ ខ្លួន១មានជើង៦ឬ ៨ ហើយកូនសត្វមានសភាពខ្សោយ។ ទាំងនេះជាភាពមិនប្រក្រតីនៃការលូតលាស់ ដែលភាគច្រើនបណ្តាលពីការកែប្រែប្រួលនៃសាព៌ាង្គកាយមេពេលផើម។ ត្រូវថែរក្សា និង ពិនិត្យសត្វផើមឲ្យបានល្អដើម្បីជៀសវាង ករណីនេះ ព្រោះវាបំផ្លាញសេដ្ឋកិច្ចផលិតកម្មយ៉ាងធំធេង។

### ១.៦.៣-ជម្ងឺផ្តល់ដោយមេបាតាមសែន(Hereditary Disease)

ជម្ងឺផ្តល់ដោយមេបា ជាជម្ងឺទាំងឡាយណាដែលមានមូលដ្ឋានចំលងពីមេ-បា។ វាជាការចំលងតាម មរតកតំណពូជ (Genetic) ឬ (Gene) ។ វាក៏អាចបណ្តាលពីកត្តារួមផ្សំមួយចំនួនផងដែ ដែលធ្វើឲ្យសត្វខ្សោយងាយទទួលជម្ងឺ (Susceptibility) ។ ជួនកាលជម្ងឺបណ្តាលពីការបង្កាត់ពូជ។ ភាពងាយទទួលជម្ងឺមហារីកភ្នែកជាលក្ខណៈតំណពូជតាមសែន ហើយវាប្រែប្រួលទាក់ទងទៅនិងលក្ខខ័ណ្ឌធម្មជាតិប្រែប្រួលពិសេសណាមួយដូចជា កំដៅ និង សំណើម---សត្វបង្ហាញសញ្ញា មហារីកភ្នែកដែលអាចពិនិត្យឃើញយ៉ាងច្បាស់។

### ៦.៤.១កង្វះសារធាតVitamin and miniral deficiency

ជម្ងឺបណ្តាលពីការខ្វះសារធាតុ ( Defi-ciency Deseases ) ជាប្រភេទជម្ងឺពិសេស ដូចជា ការខ្វះសារជាតុគីមី ទង់ដែង ( Copper/Cu deficiency ) កង្វះវីតាមីន A ( Vitamin-A Deficency ) កង្វះអ៊ីយ៉ុងដែក និងកង្វះសារជាតុជាច្រើនទៀត ដោយសារចំណីអាហារ មិនមានតុល្យភាព ហើយដែលបណ្តាលឲ្យសត្វពុំឃ្លានចំណីអាហារ ( Anorexia ) ។ ការមិនឃ្លានចំណីអាចបណ្តាលមកពីបុព្វហេតុពីរផ្សេងទៀត: ចំណីអាហារសត្វពុំមានជីវជាតិ និង ពុំមានសារជាតុ -- ខនិចគ្រប់គ្រាន់ឬ សត្វគ្មានលទ្ធភាពស៊ីចំណីអាហារ ដោយសារជម្ងឺ ឬ ការរាត្បាតបន្ត (Secondary Inchon ) ដែលរាំងស្ទះដល់ដំណើរការនៃ ប្រព័ន្ធជីវសាស្ត្រ និង ការរំលាយអាហារ( Metabolism )។ ជម្ងឺបណ្តាលពីការខ្វះសារជាតុគីមីនេះកើតឡើងជាញឹកញាប់ ហើយដែលបណ្តាលឲ្យ សត្វថយទំងន់ និង លូតលាស់យឺត ( គ្រិន ) ។ ជម្ងឺជាច្រើនប្រភេទទៀតដូចជា ដំបៅរលួយ សត្វដើបឈរពុំរួច ។ល។ ការខ្វះ Ca និង P បណ្តាលឲ្យសត្វទន់ឆ្អឹងខ្នង ( Rachit ) កង្វះទង់ដែង ( CU,Co ) -- សត្វពុំឃ្លានចំណី កង្វះអ៊ីយ៉ុងដែក ( Fe )--សត្វមានសភាពស្លេកស្លាំង ( Anemia ) ខ្វះវីតាមីន E -- ការបន្តពូជរបស់សត្វចុះខ្សោយ។ល។ កត្តាទាំងនេះធ្វើឲ្យមានការខាតបង់សេដ្ឋកិច្ច យ៉ាងធ្ងន់ធ្ងរ។

*រាតត្បាតដោយអតិសុខុមប្រាណ ( Infection by Micro-organism )*

អតិសុខុមប្រាណជាភ្នាក់ងារបង្កជម្ងឺយ៉ាងសំខាន់ និង ចំពោះមុខ។ អតិសុខុមប្រាណ ដែលមិនបង្កជម្ងឺហៅថា Non-Pathogenic microorganism ហើយអតិសុខុមប្រាណដែលបង្កជម្ងឺហៅថា Pathogenic Microorganism – Pathos-gen ។Pathogen សំដៅទៅលើអតិសុខុមប្រាណទាំងឡាយណា ដែលបង្កជម្ងឺចំពោះមុខ និង ផ្ទាល់ទៅលើសត្វ។ ប្រភេទនៃ Pathogen នីមួយៗ ខុសគ្នាដោយសមត្ថភាពបង្ករោគ (Virulence) របស់វា។ Virulence គឺជាសមត្ថភាព បង្កជម្ងឺរបស់មេរោគដែល ពេលនោះមេរោគទាំងនេះអាចធ្វើសកម្មភាពដូចជា:

- លូតលាស់លឿន ( Multiplication )
- បញ្ចេញសារជាតុពុល -- Toxin( Exotoxin ឬ Endotoxin )
- ធ្វើឲ្យមានរបួស ( Migration )

*ជម្ងឺបានត្រូវគេ ចែកចេញជាក្រុម ទៅតាមប្រភេទភ្នាក់ងារបង្កជម្ងឺ:*

- ជម្ងឺបង្កដោយបាក់តេរី ( Bacterial Disease )
- ជម្ងឺបង្កដោយពពួកផ្សិត ( Fungal Disease )
- ជម្ងឺបង្កដោយប្រូតូសូអា ( Protozoal Disease )

### ១.៦.៥- ការរាតត្បាតដោយប៉ារ៉ាសិត (Infestation/Parasitism)

Parasitism ជាការរស់នៅនៃសាព៌ាង្គកាយមួ ដោយពឹងអាស្រ័យទៅនឹងសាព៌ាងកាយមួយទៀត និង មានសកម្មភាពបំផ្លាញសាព៌ាង្គកាយដែលពឹងអាស្រ័យនោះ។ ការរាតត្បាត នៃពពួកប៉ារ៉ាសិតនេះ អាចមាន ពីរយ៉ាង: Internal infestation --ជាការរាតត្បាតដោយពពួកប៉ារ៉ាសិតខាងក្នុងខ្លួនដូចជាពពួកព្រូនមូល (Thelminth) ព្រូនសំប៉ែតវែង (Trematod) និង ព្រូនសំប៉ែតខ្លី (Cestode) ។

External Infestation - ជាការរាតត្បាតដោយពពួកប៉ារ៉ាស៊ីតខាងក្រៅខ្លួនដូចជា: ពពួកតុតកែចៃ មេមក ។ល។

ចំនួនប៉ារ៉ាស៊ីតតិចតួចមិនអាចបង្កឲ្យមាន Clinical disease បានទេ ប៉ុន្តែសត្វអាចចុះខ្សោយ ហើយងាយទទួលជម្ងឺផ្សេងៗ និង មានលូតលាស់ពុំសមាមាត្រ និងការចំណាយ។

ដើម្បីអាចធ្វើការរាតត្បាតបានពពួកប៉ារ៉ាស៊ីតភាគច្រើនជាពិសេសពពួកCestodeនិងTrematode ត្រូវការ វដ្តជីវិតរបស់វាដោយពឹងពាក់សាព៌ាង្គកាយសត្វមួយទៀត (Intermediate Host) ដើម្បីស្នាក់អាស្រ័យ និង ធ្វើការបំលែងពីស៊ុត ទៅជា កូនដង្កូវ ដែលអាច រាតត្បាតទៅសាព៌ាង្គកាយ សត្វមួយទៀត (Definitive Host)។

#### វដ្តជីវិតនៃបា៉រ៉ាស៊ីត (Lyfe Cycle or Parasitism)




គំនូសសញ្ញាព្រួញ២: វដ្តជីវិតនៃបា៉រ៉ាស៊ីត

**១.៧.១-ការបំផ្លាញដោយកត្តារូប** (Physical Injurry and Irritants)

សត្វអាចថវងគ្រោះដោយបណ្តាលពីការមុត (Trauma) ។ ដំបៅជើងពុំអាចដើរបាន ជួនកាលប្រភេទរបួសអាចជាប្រហោង (Preforation) ដែលងាយរាតត្បាតដោយពពួក Anacrobic Bacteria ដូចជាពពួក Tetanii ឬ Welchii ។ ជាលិកាអាចហែក ឬ របេក (Laceration) ឬអាចខ្លាំងដោយប៉ះទង្គិច (Concussion) ឬពេលសត្វជល់គ្នា។ ជួនកាលសត្វច្រើនគ្រិច (Sprain) ជើង ឬភ្លាត់ឆ្អឹង (Fracture)។

សត្វនៅហាលវាលក្រោមពន្លឺព្រះអាទិត្យយូរ បណ្តាលឲ្យមានការបំផ្លាញដោយកាំរស្មីព្រះអាទិត្យ និងកំដៅ (Injurry by Sun Radiation and Heat)។ កាំរស្មីអុលត្រាវីយ៉ូឡែត (Ultraviolct Ray) កាំរស្មី X (X-Ray)និងកំដៅ (Heat)បណ្តាលឲ្យសត្វរលាកស្បែក។ ការចុះត្រជាក់ខ្លាំង ការកើនឡើន និង ចុះថយសំពាធ បរិយាកាស (Increase and Decrease Atmospheric Pressure ) បណ្តាលឲ្យភាពធន់និង ភាពស៊ាំរបស់សត្វចុះខ្សោយ។

**១.៧.២-ការបំផ្លាញដោយធាតុគីមី**(Chemical Irritants)

**ក- ការពុលដោយធាតុគីមី:** ធាតុគីមីជាដើមហេតុ នៃការបំផ្លាញសព៌ាង្គកាយក្នុងករណីលើសលប់ ហើយវាជះឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាព ឬ អាចបំផ្លាញ និង សំលាប់ជីវិតសត្វបានយ៉ាងឆាប់រហ័ស ។ សារធាតុគីមីមានពីរប្រភេទ:

- សារធាតុគីមីសរីរាង្គ (Organic)

- សារធាតុគីមីអសរីរាង្គ (Inorganic/Miniral)

ORGANIC : ដូចជាពពួកថ្នាំសំលាប់សត្វល្អិត (Insecticide) ថ្នាំសំលាប់សត្វកកេរ (Rodenticide)ថ្នាំសំលាប់ពូកផ្សិត (Fungicide) ថ្នាំសំរាប់ព្យាបាល ក្លរ៉ូហ្វម (Chloroform) ពពួកអាល់កាឡូអ៊ីត (Alka-loides) និង រុក្ខជាតិពុល (Poisoning Plants) និងពពួក Vitamins ក៏ពុលយ៉ាងសាហាវដែរ នៅពេលគេឲ្យសត្វផឹកលើសកំរិត។ សារធាតុគីមី ដូចជា GasIutelah: បាលលោហៈ ធ្ងន់ ព្រមទាំងអំបិលរបស់វា (Ag , P, Hg , …..etc ។) បង្កឲ្យមាន ការពុលយ៉ាងធ្ងន់ធ្ងរចំពោះសត្វ ដែលលេប សមាសធាតុគីមីទាំងអស់នេះ។

**ខ- ការខ្វះសារធាតុ និងធាតុគីមីបណ្តាលឲ្យពុល:** កង្វះសារធាតុគីមីបណ្តាលឲ្យសត្វបាត់បង់ជីវហារ សត្វអាចស៊ីចំណីដែលវាពុំធ្លាប់ស្គាល់ ហើយ បណ្តាលឲ្យពុល។ កង្វះសារធាតុគីមី នាំឲ្យសត្វបាត់បង់នាទីជីវហរិញ្ញណ ដែលធ្វើឲសត្វដឹងចំណីត្រូវស៊ី ឬមិនត្រូវស៊ី។ ជួនកាលសត្វស៊ីប៉ះបន្លាឬ ដែលបណ្តាលឲ្យមុតមាត់ អណ្តាត ដំបៅហើយ សត្វពុំអាចស៊ីចំណីបាន។

សត្វបាត់បង់ជីវិហារ (Anorexia) អាចសង្កេតឃើញ នៅពេលមានការខ្វះកាល់ស្យូមផូស្វ័រ សូដ្យូម អីយ៉ុងដែក ទង់ដែង សង្កសី ម៉ាញ៉េស្យូម (Mn) អីយ៉ូត (1) ប៉ូតាស្យូម (K) ម៉ង់កាណែស (Mg) ជាដើម ។ សត្វ ខ្វះវីតាមីន ខ្លាញ់ កាបូអ៊ីដ្រាត (Carbohydrate) និង ប្រូតេអ៊ីន (Protein) គេសង្កេតឃើញសរីរាង្គរបស់វា បាត់បង់បណ្តូររូបធាតុ (Metabolism) ។

ដើម្បីការពារនូវការខ្វះសារជាតុទាំងនេះសំរាប់គោ គេមានផលិតដុំអំបិលខនិចសមាសសំរាប់គោលិត បន្ថែមក្រៅពីការផ្តល់ចំណី ។ សត្វដើម និង សត្វចិញ្ចឹមយកទឹកដោះ មានបញ្ហា ខ្លួនសារជាតុ គីមីជាញឹកញាប់ ។

**១.៧.៣- (Predisposing Factors) :**

Predisposing factor --ជាកត្តាបង្កឱ្យសត្វងាយទទួលជម្ងឺ ។ កត្តារួមផ្សំនេះជាបុព្វហេតុបង្កជម្ងឺ ប្រយោល ដែលមានអំពីយើតទៅលើសព៌ាង្គកាយ ។ គត្តាទាំងនេះ --គឺជាបរិយាកាសនៅជុំវិញលក្ខខ័ណ្ឌទឹក-ដី អាកាសធាតុ ដែលមានឥទ្ធិពលលើសត្វ ហើយបណ្តាលឱ្យសត្វចុះខ្សោយ (Stress) សុខភាព និង ភាពធន់នឹង ជម្ងឺ ។ កត្តារួមផ្សំនេះចែកចេញជាពីរ:

- កត្តារួមផ្សំបង្កជម្ងឺខាងក្នុង (Intrinsic)
- កត្តារួមផ្សំបង្កជម្ងឺខាងក្រៅ (Extrinsic)

## ១.៨ កត្តារួមផ្សំបង្កជម្ងឺខាងក្នុង (Intrinsic Predisposing factor) :

**ខ- អាយុ** (Age): មានជម្ងឺមួយចំនួនរាតត្បាតលើសត្វក្មេងៗខ្លាំងក្លា ធៀបទៅនឹងសត្វធំទង់។ នេះជាលក្ខណៈពិសេសដោយសព៌ាង្គកាយសត្វក្មេងពុំទាន់មានភាពធន់ និង ភាពស៊ាំបានល្អនៅឡើយ ។ កូនសត្វតូច ១ទទួលភាពស៊ាំពីមេរបស់វាតាមរយៈ ការបៅកូឡូស្ទ្រូម (Colo-strum) -- ទឹកដោះ ដំបូងរបស់មេបន្ទាប់ពីកើតកូនរួច ។ ចំពោះសត្វចាស់ភាពទទួលជម្ងឺកាន់ តែមានកំរិតខ្ពស់ អាស្រ័យ ដោយការចុះខ្សោយនៃប្រព័ន្ធភាពធន់ និងកំលាំងប្រឆាំងរបស់សព៌ាង្គកាយទល់នឹងការច្រៀត ចូលពីខាងក្រៅ ។ ការខ្វះសមត្ថភាពធ្វើចលនា និងការលោកសន្លាក់ ធ្វើឱ្យការរក្សាស្ថេរភាព កំដៅក្នុងខ្លួនពុំអាចជានាបាន ។

គ.ប្រភេទ (Genus/Spcies): ជំងឺមួយចំនួនមានលក្ខណៈពិសេស សំរាប់ប្រភេទសត្វមួយ ដែលខណៈនោះសត្វប្រភេទផ្សេងទៀត ពុំឈឺជំងឺនោះឡើយ ដូចជា:មនុស្សពុំឈឺជំងឺ បេស្ត គោក្របី (Rinderpest) ប៉ុន្តែសត្វគោក្របីពុំឈឺជំងឺអាសន្នរោគមនុស្សទេ ។គោក្របីឈឺជម្ងឺអតក្តាម

( Food and Mouth Disease ) ប៉ុន្តែសត្វសត្វពុំឈឺជំងឺអុតក្តាមឡើង ។ ជំងឺកញ្ជ្រិលជ្រូក ប៉េស្តជ្រូកឈឺចំពោះតែសត្វជ្រូកប៉ណ្ណោះ ។

**ឃ.ពូជ** (Breed): ពូជសត្វមួយចំនួនមានលក្ខណៈពិសេស ចំពោះជម្ងឺមួយចំនួន ដែកខុសប្លែកពីសត្វពញជគោសាច់ និងគោសំរាប់កំលាំងអូសទាញ។គោពូជទឹកដោះ ច្រើនមានជម្ងឺរលាកកម្សោមដោះ(Mastitis)និងរលាកស្បូន(Endometritis) ។

**ង.ភេទ**(Sex): ភេទនីមួយៗញី និង ឈ្មោល មានជំងឺដោយឡែកនៅប្រដាប់បន្តពូជរបស់វា។ រលាកស្បូនឈើតែចំពោះសត្វញីតែប៉ុណ្ណោះ។ ជាទូទៅភេទនាំទៅរកភាពទន់ខ្សោយងាយទទួលជំងឺ ភេទឈ្មោល ងាយទទួលជំងឺខ្វះមាន់ (Night Blindness) និងរលាកតំរងនោម (Nrphritis) ផ្ទុយទៅវិញ ភេទញីងាយឈឺ ជំងឺថ្លើម (Liver Disease) ច្រើនជាងភេទឈ្មោល ។

## ១.៩ កត្តារួមផ្សំបង្កជម្ងឺខាងក្រៅ (Extrinsic Predisposing factor)

**ក. លក្ខខ័ណអាកាសធាតុ (Climatic Condition):** ជាធម្មតាសត្វអាចសំរបខ្លួនទៅនឹងការប្រែប្រួលនៃបិយោកាសដោយខ្លួនឯង។ ការប្រែប្រួលសីតុណ្ហភាព.សំពាធ និង សំណើមនៃមជ្ឈដ្ឋាន ភាពថប់អាប់អួរ ចង្អៀតខ្វះខ្យល់ចេញចូល ជះឥទ្ធិពលដល់ភាពធន់របស់ញិង្គកាយសត្វ។ឧទាហរណ៍ៈ ការចុះត្រជាក់ បណ្តាលឲសត្វមានជម្ងឺប្រដាប់ដកដង្ហើម (Respiratory Disease) ដូចជារលាកសួត (Pneumonia) រលាកបំពង់ក(Laryngo_TraCheitis) ។

បំរែបំរួលនៃកត្តាបរិស្ថាន (Environmental Factor) បណ្តាលឲសត្វងាយទទួលជំងឺដូចករណីរាតត្បាត នៃបរាសិតខាងក្រៅ (Ectoparasite) ពុំសូវមានទេនៅរដូវរំហើយ ព្រះស្បែកសត្វស្ងួត ផ្ទុយទៅវិញពេលមានកម្តៅ និងសំណើមគ្រប់គ្រាន់ការរាតត្បាតឲពពួក ចៃ តុកកែ មេកម មានសភាពខ្លាំងខ្លា ។

**ខ. ខ្យល់អាប់អួរ (Polluted ait):** ភាពអាប់អួរនៃខ្យល់បណ្តាលពីចូលីឧស្ម័នជាដើម ជាមូលហេតុបណ្តាលឲសួតខ្សោយដែលងាយរលាក។ ការចុះខ្សោយនេះជំរុញឲបាក់តេរីបង្ករោគចូលពីខាងក្រៅ ឬ មាននៅក្នុងសួតស្រាប់ក្លាយជា Pathogene។ការសាងសង់ទ្រុងត្រូវតែគិតដល់ដំណើរខ្យល់បក់ចេញចូលបានល្អ។ដង់ស៊ីតេសត្វក្នុងទ្រុងត្រូវមានចំនួនសមស្រប។ភាពអាប់អួរនេះក៏បណ្តាលមកពីទឹកនោម លាមកសត្វ និងការប្រើប្រាស់ ថ្នាំសំលាប់មេរោគផងដែរ។ដូច្នេះការយកចិត្តទុកដាក់ របាយសំអាតលាង និងថែរក្សាអនាម័យជាកត្តាសំខាន់បើម្បីការពារជម្ងឺ។

**គ. លក្ខខ័ណ្ឌ ដី (Soil Condition):** សត្វដែលចិញ្ចឹមក្នុងទ្រុងផ្ទាល់ដី មានលាមក សំណើម និង ទឹកមាត់ ជាញឹកញយបណ្តាយឲសត្វមានជំងឺក្រចកជើងជាញឹកញយ ។ ភាពកង្វក់ កំដៅ សំណើមនេះផ្តល់លក្ខខណ្ឌ លូតលាស់យ៉ាងប្រសើរដល់ពពួកបាក់តេរីបង្ករោគ ។

**ឃ. ការផ្តល់ចំណី (Nutrition):** ចំណីជាសារជាតុសំរាប់លូតលាស់របស់សត្វ ប៉ុន្តែតាមរយៈចំណីមានគុណភាពមិនល្អ និងផ្តល់ច្រើនហួស ឬទិចហួស សត្វអាចមានបម្រែបម្រួលនៅលើប្រព័ន្ធរំលាយអាហារ និងបណ្តូររូបធាតុ (Metabolism) បណ្តាលឲមានរបួសរលាក ឬ រហែកក្រពះ។ ចំណីស្ងួតហុយ សត្វដកដង្ហើមចូលសួត ចំណីដើមអាចផ្អូមជូរ ដោយមានមេរោគវីសាយ និងធ្វើ Fermentation។ ចំណីប្រភេទនេះនាំឲសត្វអាចក្អក រលាកសួត និងហើមពោះ ។ ចំណីមួយចំនួន ជាពិសេសចំណីដែលមានជាត់សៃលុយឡូសទិចអាចបង្កើតឲបានឧស្ម័ននៅក្នុងក្រពះធំនៃសត្វទំពារអៀង

បណ្តាលឲហើមពោះ (Bloat / Timpania)។ ដើមហេតុនៃចំណីគ្មានគុណភាពអាចបណ្តាលឲសត្វស្លាប់ ដោយសារការហើមពោះ សង្កត់ទៅលើសន្ទះទ្រូង និង សួតសត្វ សត្វដាច់ដង្ហើម និងតាមរយះចំណីសត្វអាចពិល ឬ រោគផងដែរ ។ ចំណីជាយាន្តចំបង ប្រភពមេរោគច្រើនប្រភេទពីស្ថានីយមួយទៅមួយទៀត ។

**ង. ទឹក (Water):** កង្វះទឹកបន្ថយភាពធន់របស់សត្វ ផ្ទុយទៅវិញទឹកក្រខ្វក់ និងទឹករឹង (មានអំបិលរ៉ែច្រើន) បណ្តាលប៉ះពាល់ដល់សុខភាពសត្វ ។ ទឹកជាប្រភព និង ជំរករបស់មេរោគច្រើនប្រភេទ ។

**ច. កង្វះចលនា និង ខ្លាញ់លើស (Lack of Movemcat and Over Fatness):** ករណីនេះកើតឡើងចំពោះសត្វមួយភាគធំដែលគេចិញ្ចឹមក្នុងទ្រុង ជាពិសេសមេជ្រូក។សត្វដែលខ្វះចលនាភាគច្រើន

**ឆ. ស្ត្រេស (Strees):** ដឹកនាំដោយឆ្លងកាត់ក្រពេញអាដ្រេណាលីន (Adrenaline Gland)។នៅពេលមានការភិតភ័យ ឬ ភ្ញាក់ផ្អើល ពិតមាននេះបានបញ្ជូនទៅក្រពេញអាដ្រេណាល់ ដោយប្រព័ន្ធសរសៃប្រសាទ ហើយបង្កើតអោយមានអាដ្រេលីនចូលទៅក្នុងចរន្តឈាមរត់ បេះដូងលោតញាប់ដើម្បីទប់ទល់ និងធានាដល់សកម្មភាពនៃសរីរាង្គទាំងឡាយក្នុងរយៈពេលខ្លីប៉ុន្តែប្រសិនបើ Strees នេះនៅតែបន្តមានរយៈពេលយូរ ប្រព័ន្ធសរីរាង្គសត្វត្រូវចុះខ្សោយ។ Strees អាចបណ្តាលពី ធាតុអាកាសផ្លាស់ប្តូរ ការប្តូរចំណីលឿន ការយក ទកដោះច្រើនហួស ការប្រើសត្វ ច្រើនហួស។ល។ ដែលមានអំពើធ្វើឲមានភាពទ្រុឌទ្រោម នៃសពាង្គកាយ។

មានជាលីកាខ្លាញ់ដុះហុំព័ន្ធសរីរាង្គមួយចំនួនដូចជា ក្រពេះ ថ្លើម បេះដូង ដែលបណ្តាលឲសរីរាង្គទាំង នោះថយនាទី និង រួញស្វិត (Atrophy) ប្រការនេះសត្វមានភាពទន់ខ្សោយផ្នែកការពារសាពាង្គកាយ។ជាលិកាខ្លាញ់រុំព័ន្ធសរសៃឈាម និង បេះដូង ប៉ះពាល់ដល់ចលនាឈាមរត់ និង សុខភាពទូទៅជាពិសេសធ្វើអោយមានការខ្សោយចុះនៃដំណើរបង្កើតអង់ទីករការពារខ្លួន។អតុល្យភាពនៃទម្ងន់ខ្លួនសត្វបណ្តាលមកពីលើសជាលិការខ្លាញ់បណ្តាលឲសាច់ដុំរួញស្វិត (Atrophy) និង សាច់ដុំទន់ខ្សោយ (Limb Weakness)។

## ១.១០.ភ្នាក់ងារបង្កជំងឺ ( CAUSATIVE AGENTS )

ភ្នាក់ងារបង្កជំងឺរួមមាន:

### ១.១០.១ . បាក់តេរី : ( Bacteria )

គេជួបប្រទះបាត់តេរីមាននៅគ្រប់កន្លែងក្នុងធម្មជាតិ។ បាក់តេរីមួយចំនួនធំ ជាសាប្រូហ្វិត (Saprophytic Bacteria) ដែលរស់នៅលើរុក្ខជាត់ងាប់ ឬសាកសព្វសត្វ ។ មួយចំនួនទៀតរស់នៅក្នុងសារពាង្គកាយ ក្នុងពោះវៀន (Intestine) រន្ធច្រមុះ (Nostril) មាត់ (Mouth) ១. (Non-Pathogenic) ចំនែកមួយចំនួនទៀតជាអ្នកបង្ករោគ (Pathogenic)។ បាក់តេរីគឺជាឯកកោសិកា ហើយគេអាចពិនិត្យដោយមីក្រូទស្សន៍ តាមការដាក់ព័ណ៌ (Staining) ។ ការលូតលាស់ (Multiplication) មិនមានភេទ (Asexual) ។ បាក់តេរីមានទំរង់ (Form) ដូចជា :

_ Coccus : រាងមូលតំរៀបគ្នាជាខ្សែ ឬ ចង្កោម : Streptococcus , Strephulcoccus

_ Rod : រាងពងក្រពើដូចជា : Brucella , Pasteurella , Salmonella

_ Bacillus : រាងជាដំបងដូចជា : Bacillus Anthracis , Clostridium

_ Spiral : មានរាងអង្កាញ់ ដូចជា : Leptospira, Treponema

_ Vibrio : មានរាងជាចំណិតខែដូចជា : Vibrio Jujuni , Vibrio Cholerae

គេចែកបាត់តេរីទាំងអស់ជា២ក្រុមគឺ: (១) ក្រហមក្រាមវិជ្ជមាន ( Gram negative ) ដែលមានពណ៌ផ្កាឈូក ឬក្រហម និង(២) ក្រហមក្រាមវិជ្ជាមានក្រាម ( Gram Positive ) ដែលមានពណ៌ខៀវ ឬស្វាយពេលគេដាក់ពណ៌តាមក្រាម (Gram Stain) .

### ១.១០.២ . វីរុស (Virus)

ជាសារពាង្គកាយងាយធ្វើការចំលង ហើយលូតលាស់តែក្នុងកោសិការស់ (Living Cell) ។ ណ្វៃយ៉ូអាស៊ីត Nucleic របស់វាអាចបំបែកទិសនៃការសំយោគរបស់កោសិកា ឲទៅជាការបង្កើតកោសិការវីរុសថ្មីៗ ទៀត ។ ជំងឺបង្កដោយវីរុស ភាគច្រើនណ្វៃយ៉ូ (Nucleus) ឬ ស៊ីតូប្លាស (Cytoplasm) នៃកោសិការងការរិតត្បាតឃើញមានសារជាតុមូល ឬពងក្រពើដែលគេហៅថា(Inclusion Bodies)។ ការផ្តុំគ្នានៃកោកសិការងាប់បណ្តាលដោយវីរុស គេហៅថា (Negri-Bodies) ហើយដែលត្រូវគេពិនិត្យឃើញ Inclusion Dody nig nig Negri- body បានតាមរយះនៃការសិក្សាជាលិកាវិទ្យា( Hystology )។ គួរគាត់សំគាល់ថា វីថិសពអាច បានត្រូវសំលាប់ដោយថ្នាំសំលាប់មេរោគទេ ។

**១.១០.៣ . រីកេតស៊ីន** ( Rickettsias ) :

ជាក្រុមមួយនៃអតិសុខុប្រាណដែលមានលក្ខណៈប្រហាក់ប្រហែលទៅនិងបាក់តែរី និងស្រដៀងទៅនិងវីរុស ។ វាមានទំហំតូចជាងបាក់តេរី ( ប្រវែង 0.2-0.3 មីក្រុង និង មានទំហំ 0.៤មីក្រុង )។ ភាគច្រើននៃរីកេតស៊ីធ្វើការចម្លងតាមរយៈ ពពួកអាត្រូប៉ូដ ( Arthropod ) គឺជាក្រហមសត្វល្អិត ( Insect ) ពពួកសំបកខ្លនរឹង ( Crustacean ) ដូចជា បង្កង ក្តាម ខ្យង ខ្ចៅនិងពពួក អារាក់ឃីណូអ៊ីដ ( Arachnoid ) ដូចជា ពីងពាង ( Spider ) ខ្ទួយ ខ្ទាដំរី ( Scorpion )។ រីកេតស៊ីរស់នៅក្នុង កោសិកានិងជាលិការស់ ហើយមានទម្រង់មូល ( Coccus ) ពងក្រពើ ( Rod ) និងខ្លះទៀតជាសសៃធ្មា( Filament ) ។ ពពួកនេះជាពួកក្រាមអវិជ្ជមាន ។ វាងាយប់នៅពេលប៉ះសាជាតុគីមី ភាពស្ងួត និងកម្តៅ ហើយការលូតលាស់របស់វាត្រូវអេសកម្ម ក្រោមអំពើនៃថ្នាំសម្លាប់មេរោគ ( ពពួកអង់ទីប៊ីយ៉ូទិក ) ។

ការចម្លងរបស់រីកេតស៊ី ប្រព្រឹតទៅតាមរយៈ ការចជញ្ជក់ឈាម នៃពពួកចៃ តុកែ រុយ ល្អាម។ ការចម្លងតាមរយៈអាត្រូប៉ូដ ប្រែប្រួលអាស្រ័យទៅនិង រីតេកស៊ី និងអាត្រូប៉ូដនោះ។ លក្ខណៈពិសេសនៃពពួកអាត្រូប៉ូដនោះ ដូចជា ទិច ខាំជញ្ជក់ឈាម ពាក់ព័ន្ធដល់ កំរិត និងប្រភេទខុសគ្នារបស់ រីកេតស៊ីដូចជាករណីជំងឺ Herato-Conjunctivitis និង Ornithosis បក្សីជាដើម ។

**១.១០.៤ . ពពួកផ្សិត** ( Dingus )

ជាសមាជិករជ្ជសត្វ ( Kingdom ) ពពួកបន្លែ ។ ប៉ុន្តែពពួកនេះពុំមានក្លរ៉ូហ្វីលទេ ( Chlorophenol ) វាជាបរាសិត ឬ សាប្រូហ្វីត ហើយវាគ្មានឫស ( Root ) និងស្លឹក ( Leaves ) ទេ ។ វាមានរូបរាងជាមែកជាង ( Vegetative ) ឬជា Mycelium ដែលផ្គុំដោយមែក ( Filament / Hyphae )។ មែក ( Branch ) វានីមួយៗមានឬគ្មានផ្សំដោយកោសិកាដាច់ៗពីគ្នា។ ករណីខ្លះដូចជាផ្សិត ( Yeast ) មាន Hyphae តិចតួច ។ ការបន្តពូជអាចមានភេទ ( Sexual ) ឬគ្មានភេទ ( Asexual ) ។ ណ្វៃយោនៃស្ព័រ ( Spore ) មាននាទីក្នុងការលូតលាស់ និង សាយភាយការបង្ករោគ ។ Fungi មួយចំនួនធំ ដែលសិក្សាក្នុងផ្នែកបាយពេទ្យ គឺពពួកថ្នាក់ Phphomycetes ឬ Fungi Imperfecti ។

**១.១០.៥ . ពពួកប្រូតូសូអា** ( Protozoa )

ជាសមាជិកនៃក្រុម កោសិកានៃទំរង់ដូចគ្នា ( Unicellular )។ វាខុសពីបាក់តេរីដែលជា Unicellular ដែរដោយប្រូតូសូអា មានលក្ខណៈ ( Characteristic ) ដោយមានសរីរាង្គ Cilia ដែលជាសសៃធ្មាខ្លី ( Hair-Like Structure ) មានចំនួនច្រើននៅលើភ្នាសខ្លួនរបស់វា ហើយវាធ្វើចលនាដោយការពត់ពេនដងខ្លួន។ ក្រុមផ្សេងទៀតមានព្រុយ ប្រម៉ោយ ( Flagella ) រាងដូចរំពាត់ខ្សែតីយ៍( Wipe-Like Structure )

មាននៅក្នុងភ្នាសស្តើង (Membrane) ដែលផុះចេញមកតាមភ្នាស ហើយដែលជាជំនួយក្នុង ការធ្វើចលនា ។

ប្រូតូសូអា ស៊ីចំណីអាហារដោយមារលេវដូចពួក Amoral ឬ តាមរយៈភ្នាសកោសិកាហើយដែលមាន Cilia ជាអ្នកដឹងនាំចំណីអាហារទៅក្នុង Cystostome និងមួយចំនួនផ្សេងទៀតស៊ីអាហារដោយស្រូវផ្ទាល់ ឆ្លងកាត់ភ្នាសកោសិកា ។

ការបន្តពូជ (Reproduction) របស់ប្រូតូសូអាប្រព្រឹតទៅដោយមាននិងគ្មានភេទ។ ប៉ុន្តែការបន្តពូជដោយភេទ មានភាគច្រើនចំពោះប្រូតូសូអា ហើយគេឲឈ្មោះថា Conjugation ដោយមានគូរនៃសារពាង្គកាយ ធ្វើការប្តូរសារជាតុណ្វៃយ៉ូ បន្ទាប់មកធ្វើការចែក និង ផ្តាច់ចេញ (Division / Separate) កើតឡើង ។ ការបន្តពូជដោយភេទមួយទៀតដែលគេហៅថា Syngamy គឺមួយឈ្មោល (Micro gmete) និងមួយទៀតជាពី (Macro gamete) ផ្សំចូលគ្នាបង្កើតជា Zygote ហើយការវិវឌ្ឍន៍បន្តដោយគ្មានភេទ គឺជាការបំបែក Zygote ឬ Sporogony ដែលផ្សំឡើងដោយបរិមាណដ៏ច្រើននៃ Sporozoites ។

ការបន្តពូជដោយគ្មានភេទទាក់ទងទៅនិងការបង្កជំងឺ (Pathogenicity) របស់ប្រូតូសូអា និងភាពធន់នៃសត្វ (Resistance of the Host) ព្រមទាំងសមត្ថភាពបង្កជំងឺរបស់វា (Virulence) ។ ប្រសិនបើវារស់នៅក្នុងកោសិការរស់ (Vital Cell) នោះការធ្វើការលូតលាស់របស់វានិងប្រព្រឹតទៅបានល្អ និងឆាប់រហ័សហើយក៏បង្កជំងឺយ៉ាងលឿនផងដែរ ។ ករណីសត្វ Host មានភាពធន់ល្អនៃការលូតលាស់របស់ប្រូតូសូអាក្នុងសារពាង្គកាយសត្វត្រូវចុះខ្សោយ រីឯការបង្ករោគត្រូវចុះខ្សោយ។ ខួបជីវិត (Life Cycle) របស់ប្រូតូសូអាមួយចំនួនមានជីវិតសាមញ្ញវាធ្វើការលូតលាស់ផ្ទាល់នៅក្នុងសារពាង្គកាយសត្វឈឺ។ មួយចំនួនផ្សេងទៀតមានសភាពសាំញាំទាក់ទងទៅនិងការបន្តពូជរបស់វារវាងសត្វ(Cerebrate)សត្វមានឆ្អឹងកង និង Invertebrate សត្វគ្មានឆ្អឹងកង ។

### ១.១០.៦ . **ប៉ារ៉ាស៊ីត** (Parasite)

ជារួមបរ៉ាស៊ីតចែកចែញជាពីរក្រុម :

_ បរ៉ាស៊ីតក្នុងខ្លួន (Endoparasite / Internal Parasite)

_ បរ៉ាស៊ីតក្រៅខ្លួន (Ectoparasite / External Parasite)

**ក. បរ៉ាស៊ីតក្នុងខ្លួន :** គឺជាពពួកព្រូន Helminthe ដែលមាន :

_ ព្រូនសំប៉ែតវែង (Phylum Platyhelminthes / Cestod)

_ ព្រូនមូល (Phylum Nemahelminth / Nemateod)

_ ព្រូនសំប៉ែតខ្លី ( Phylum Tremahelminthe / Trematod )

ព្រូនសំប៉ែតខ្លីជាពពួកបន្តពូជតាមភេទ( Sexual )។ ប៉ុន្តែពួកនេះមួយចំនួនធំជា Monosexual សារពាង្គកាយមួយរួមភេទពីរ គឺញីផងនិងឈ្មោលផង។ ដូចជាពពួកបង្គួរថ្លើម ( Liver Fluk ) ជាដើម។ ព្រូនមូលជាទូទៅ មានការបង្កកំណើតដោយមានភេទពីរដោយឡែកពីគ្នាគឺមានព្រូនញី និងឈ្មោល។ ជាទូទៅព្រូនឈ្មោលតូចជាងព្រូនញី។ ដូចជា Ascaris ជាដើម។

ព្រូនសំប៉ែតមានដងខ្លួនផ្សំឡើងដោយកង់ ( Segment / Glottis ) ដែលជាកង់ៗបន្តគ្នាបង្កើតជាសារពាង្គកាយ ។ ក្នុងកង់របស់វានីមួយៗមានប្រដាប់រំលាយអាហារ និងប្រដាប់បន្តពូជពីរភេទ ដូច្នេះពួកនេះជា Monosexual ។ ការលូតលាស់របស់ព្រូនវែងនោះ ទាមទាខួបជីវិត ( Live Cycle ) ហើយដែលមាន Host ជាមួយសត្វមានឆ្អឹងកង ( Intermediate Host ) ដូចជាពពួកគេញ៉ាជាដើម ។

**ខ. ប៉ារ៉ាស៊ីតក្រៅខ្លួន** : ជាពពួកដែលរស់នៅ និងវាតត្បាតនៅផ្នែកខាងក្រៅ នៃសារពាង្គកាយរបស់ Host ។ ប៉ារ៉ាស៊ីតក្រៅខ្លួនស្ថិតនៅក្នុង Phylum Arthropod ហើយដែលមាន :

_ ពពួកសត្វល្អិត ( Insect )

_ ពពួកអារ៉ាក់ណូអ៊ីដ ( Arachnoid ) ដូចជាពីងពាង ខ្ទួយ ខ្យាដំរី ជាដើម ។

ពួកប៉ារ៉ាស៊ីតក្រៅខ្លួននេះ មានសរីរាង្គរបស់វាផ្គុំឡើងដោយ ជើងសំបកខ្លួនរឹងដែលជាផ្នែកបង្កើតរូបរាង្គ និងដងខ្លួន ក្បាល ( Head ) ទ្រូង ( Thorax ) និងពោះ ( Abdomen ) ហើយមានតែរូបផ្គុំខាងក្រៅ និងគ្មានរូបផ្គុំក្នុងទេ ( No Endoskeleton ) ។

ពពួកសត្វល្អិតមានលក្ខណៈដូចជា មានជើងគូរ ហើយខ្លួនវាចែកចេញជាបីផ្នែក គឺក្បាល ទ្រូង និងពោះ ។ ពពួកនេះមួយចំនួនធំមានស្លាបពីរគូរ មួយចំនួនទៀតមានស្លាបមួយគូរដូចជា Dragonflies ហើយខ្លះទៀតគ្មានស្លាបទេ ដូចជាចៃ ( Flea ) និងស្រម៉ោច។ ពពួកតុកកែ( Tick ) មានខ្លួនរឹងនិងទន់ ហើយមេកមរមាស់ ( Mite ) ពេញវ័យមានជើង៤គូរ និងមានមាត់ច្បាស់លាស់ ជំនួយការមានផលិតភាពខាំសត្វ ។ នៅតូចតុកកែមានលក្ខណៈដូចសត្វល្អិតហើយមានជើង៣គូរគត់ ។

## ១.១០.៧ . មូលហេតុបង្កជំងឺផ្សេងទៀត

ជាចំណេះដឹងទាក់ទងទៅនិងការយល់ដឹងអំពីកត្តាប៉ះពាល់ដល់សុខភាពពិតប្រាកដមួយដើម្បីបកស្រាយនៃជំងឺ




គំនូសសញ្ញាព្រួញ២: បុព្វហេតុដែលបង្កជម្ងឺ

ក. បុព្វហេតុដែលបង្កដោយខ្លួនឯង ឬខាងក្នុង មានជម្ងឺជាច្រើន ដែលធ្វើការចម្លងតាមសែន ។ វាអាចជាការចម្លងតាមសែនរបស់ពូជ មេ - បាដែលផ្តល់ដល់កូនជាមរតកខ្សោយក្នុងការធន់នឹង ការរាតត្បាតដូចជាករណី Canine haemophila ឬផ្តល់ទៅឱ្យកូនជាមរតកលប់ (dominant inheritance) ដូចជាករណី (Curced limbs) សាច់ដុំកោង។ ករណីជាច្រើនទៀត ដែលជួបប្រទះនៅក្នុងការបង្កាត់ពូជជានឈាម (Homozygons) ដែលបណ្តាលឱ្យអំប្រ៊ីយុង ឬកូនសត្វស្លាប់ជាច្រើន ហើយករណីខ្លះទៀត បណ្តាលឱ្យមានការលូតលាស់មិនប្រក្រតី នៃអំប្រ៊ីយ៉ុងជាដើម ។ បុព្វហេតុបង្ករោគបែបនេះ ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងអាយុសត្វ. ពូជ. ប្រភេទ សត្វ ពណ៌សំបុរ. ព្រមទាំងលក្ខខ័ណ្ឌវិភាគវិទ្យា សរីរៈវិទ្យា របស់សត្វនីមួយផ្ទាល់ ។

ខ. ហេតុដែលបង្កពីខាងក្រៅខ្លួន ហើយដំណើរវិវត្តន៍ នៃការចម្លងរោគ បានបង្កឡើងដោយសមត្ថភាព និងកម្លាំងរបស់មេរោគ ៨ដូចជា វីរុស, បាក់តេរី បរាសិត និងពពួកផ្សិតផ្សេងៗទៀតជាដើម។លក្ខណៈពិសេស នៃដំណើរវិវត្តន៍របស់ការចម្លងរោគនេះ គឺបណ្តាលពីខាងក្រៅសុទ្ធសាធ ដែលបង្កគ្រោះថ្នាក់ ក្នុងសារពាង្គកាយសត្វ។ ពពួកភ្នាក់ងារបង្ករោគធ្វើការជ្រៀតចូលក្នុងសារពាង្គកាយសត្វ និង ធ្វើការជ្រើសរើសកន្លែងរាតត្បាត និងរស់នៅ (Tropism) ហើយដែល

បង្កើតឱ្យមានការប្រែប្រួល និងរោគសញ្ញាគ្លីនិច នៃជម្ងឺដោយមានការចូលរួម នៃប្រតិកម្មរបស់សារពាង្គកាយ ក្នុងអំពើបង្កើត ភាពសាំផងដែរ ។ លក្ខណៈ និង ភាពខុសគ្នានៃភ្នាក់ងារបង្ករោគនីមួយៗ បានត្រូវរកឃើញដោយ ការស្រាវជ្រាវលើរូបរាង, សមាសជាតុផ្សំ, សារធាតុពុល និង ការបង្ករោគរបស់វា តាមរយៈការធ្វើ តេស្តនៅមន្ទីរពិសោធន៍ និង ការវិភាគរោគសញ្ញាព្រមទាំងពត៌មារាតត្បាតរបស់វា។ កត្តាជាបុព្វហេតុបង្ករោគមួយចំនួន ទៀតក្រៅពីក្រុម អតិសុខុមប្រាណ (Animate) ទាំងឡាយ ជាភ្នាក់ងារបង្ករោងមិនចម្លង (Non-inffective Agent)។ ពពួកទាំងនេះ មានដូចជា កត្តាចំណីចំណីអាហារ អាកាសធាតុ (Climate) អំពើមេកានិច (Mechanical Act) អំពើរូប (Physical)ដូចជាកំដៅ (Heat) ត្រជាក់ (Cold) ពន្លឺ (Radiation) ។ល ។ ធ្វើឱ្យប៉ះពាល់ដល់ សុខភាពសត្វ ។

គ. បុព្វហេតុដែលបង្កដោយអំពើនៃរូបសាស្ត្រប៉ះពាល់ដល់អារម្មណ៍ ដែលធ្វើឲ្យប្រព័ន្ធប្រសាទមានមុខនាទី និងសកម្មភាពជាយាន្តការពារ សារពាង្គកាយ(Mechanical defense of organism)។ ប្រព័ន្ធសរសៃប្រសាទបានត្រូវគេចាត់ទុកចាសកម្មភាពសរីសាស្ត្រទប់ទល់ប្រឆាំងនិងជម្ងឺ។ ជម្ងឺអាចបង្ករឡើងដោយការប៉ះទង្គិច(Impact) ទៅលើអារម្មណ៍បណ្តាលអំពីរូបផ្សេងៗ។ ដូចជាករណីស្ត្រេសកើតឡើងផ្ទួនៗឫ ញឹកញាប់ចូលរួមបង្កអោយមានជម្ងឺរលាកក្រពះ(Gastric ulcer Gastritis)សត្វជ្រូក"ឯកសាររោគសាស្ត្រទូទៅ"

## ១.១០.៨ ការព្យាបាលតាមអារម្មណ៍ (Psychologic Therapy)

ជាការព្យាបាលពាក់ព័ន្ធនឹងចិត្តសាស្ត្រ ការបង្ហាត់ហ្វឹកហ្វឺន និងការរៀបចំចាត់ចែងសត្វដើម្បការពារស្ត្រេសពីការផ្អើល ភ័យខ្លាច និងសំលេងផ្សេងៗ ។

### ក. ការព្យាបាលតាមរោគសញ្ញា (symptomatic treatment)

ជាការព្យាបាលដោយផ្តល់ថ្នាំ ដើម្បីបន្ថយឬព្យាបាលរោគសញ្ញាមួយចំនួន ដែលបណ្តាលឲ្យសត្វកាន់តែចុះខ្សោយផ្នែកសុខភាព ។

ឧទាហរណ៍: ការព្យាបាល Gastroenteritis ដោយការផ្សំនៃថ្នាំ Astringent ជម្ងឺប្រព័ន្ធដង្ហើមដោយថ្នាំ Expectorant និងការព្យាបាលការហើមពោះធំនៃសត្វទំពារអៀងដោយ Carminative mixture។

### ខ. ការព្យាបាលពិសេស (specific treatment)

គឺជាការផ្តល់ឱសថពិសេសដើម្បីព្យាបាលជម្ងឺ។ វិធីនេះត្រូវបានគេអនុវត្តនៅពេលដែលបុព្វហេតុបង្កជម្ងឺបានត្រូវគេដឹងច្បាស់។ ការព្យាបាលប្រភេទនេះមានបំណងបំផ្លាញ ឬកាត់ផ្តាច់ភ្នាក់ងារបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពសត្វ ។

ឧទាហរណ៍

| ថ្នាំព្យាបាល | ប្រឆាំង | ជម្ងឺ |
| --- | --- | --- |
| 1. specific Antidole | → | Aoisoning |
| 2. Anthelmintic | → | Helminthiasis |
| 3. Antibacterial drug | → | Bacteria |

ការព្យាបាលតាមវិធីនេះ បានត្រូវគេអនុវត្តដូចក្នុងករណី Axiological treatment ។l

### គ. ការផ្តល់ថ្នាំ ដើម្បីសំរាប់ជម្ងឺ ( Paliative )

ការព្យាបាលប្រភេទនេះ ធ្វើឡើងពុំមានបំណងធ្វើឲ្យសុខភាពសត្វ វិវត្តមករកធម្មតាទាំងស្រុកនោះទេ ប៉ុន្តែគ្រាន់តែដើម្បីពន្យាពេលស្លាប់របស់សត្វតែប៉ុណ្ណោះ។ ដូចជាការចាក់ Insulin (ជា Hormone បញ្ចេញដោយលំពែង) ដែលជំនួយសារពាង្គកាយក្នុងការប្រើប្រាស់ carbohydrates ដើម្បីព្យាបាលជម្ងឺទឹកនោមផ្អែម Diabetes ( Insulin Deficiency ) ។

### ឃ. ការផ្តល់ថ្នាំតាមរបបចំណី ( Rational Treatment )

ជាវិធីព្យាបាលដោយផ្តល់ថ្នាំលាយជាមួយរបបចំណី ដែលផ្តល់ឲ្យសត្វស៊ី ដែលផ្អែកទៅលើការយល់ដឹងនៃរោគសាស្ត្រសរីរៈវិទ្យា និងការវិវត្តន៍នៃជម្ងឺព្រមទាំងអំពីរបស់ថ្នាំ ។

ឧទាហរណ៍ៈ ផ្តល់Sodium bicarbonate ដើម្បីបន្សាបអាស៊ីតក្រពះ ផ្តល់ Atropine Sulphate ដើម្បីសំរាលការចុកស្នះឈាមពោះវៀនសត្វសេះ Spasmodic colic ។

### ង. ការផ្តល់ថ្នាំដើម្បីការពារជម្ងឺ ( Propliylactive )

ជាការអនុវត្តន៍ ដើម្បីការពារការរាតត្បាតនៃជម្ងឺ នៅពេលមានលក្ខខ័ណ្ឌ មានការឆ្លងរាលដាលនៃជម្ងឺដូចជាការផ្តល់ Ant microbe, Anthelmine និងវីតាមីនទៅក្នុងចំណី ឬទឹកផ្តល់ឲ្យសត្វ ។ ការការពារមួយទៀតដ៏មានប្រសិទ្ធិភាពប្រឆាំងនិងជម្ងឺរាតត្បាត គឺការធ្វើ Immunization ដោយការចាក់វ៉ាក់សាំង General immunology )

### ១.១០.៩ សេដ្ឋកិច្ច និងការព្យាបាល ( Economic and treatment /therapy )

ក្នុងវិស័យចិញ្ចឹមសត្វ ការព្យាបាលត្រូវតែធ្វើការប៉ាន់ស្មាន ប្រៀបធៀបរវាងតម្លៃចំណាយលើការព្យាបាល និងតម្លៃសត្វដែលលក់ ។ ជូនកាលតម្លៃចំណាយលើការព្យាបាលខ្ពស់ជាងតម្លៃចំណូលបានពីការលក់សត្វ ករណីនេះគេថាការព្យាបាល ពុំគប្បីធ្វើឡើយ ។ វិធីតែមួយគត់ដែលប្រសើរ គឺការចាត់ចែងវិធានការណ៍គ្រប់គ្រងសមស្រប និង ការការពារ។ ខ្លឹមសារនៃការព្យាបាល គឺជាចំណេះដឹងស្តីពីការប្រើប្រាស់ឱសថក្នុងការព្យាបាលជម្ងឺ ។ បំណងនៃការព្យាបាលគឺ ដើម្បីសំរេចឲ្យបាននូវការនាំមកវិញនៃសុខភាពទៅឲ្យសត្វឈឺ ។

## ក. មូលហេតុនៃជំងឺ

១- ភ្នាក់ងារចម្លងជំងឺៈ វីរុស បាក់តេរី ផ្សិត ប្រូតូសូអ៊ែ

២- បរាសិតៈ ខាងក្នុង និងខាងក្រៅ៣- កង្វះអាហារូបត្ថម្ភ

៤- ការឈឺចាប់ (Distress) ពុល និងរបួស

៥-ការតានតឹងអារម្មណ៍( ស្ត្រេស)



### ភ្នាក់ងារចម្លងជំងឺ

**វីរុស**

- វីរុស ជាអតិសុខុមប្រាណដ៏តូចបំផុត អាចបង្កជំងឺ មិនអាច មើលឃើញដោយមីក្រូទស្សន៍ធម្មតាបានទេ។




រូបភាពទី ១.១ការមើលមីក្រូទូស្សន៍ វីរុសអុិតក្តាម

- គំរូរបស់វីរុសអុតក្តាមដែលគូសដោយកុំព្យូទ័រដើម្បីបង្ហាញពីផ្ទៃរបស់វាផ្សំឡើងដោយប្រូតេអ៊ីនដ៏ស្មុគស្មាញ។




- ពេលវីរុសនៅក្រៅខ្លួនសត្វ វាមិនអាច បំបែកខ្លួនបានទេ វាស្ថិតក្នុងសភាពនឹងថ្កល់ ប៉ុន្តែពួកវាអាចរស់បានច្រើនខែនៅក្នុង បរិយាកាសដូចជាៈ មេរោគញ៉ីវកាសអាច រស់នៅបានច្រើនអាទិត្យនៅក្នុង បរិយាកាសក្តៅ និងសើម និងនៅរោមបក្សី លាមក និងសម្ភារៈដ៏ទៃទៀត។



- វីរុសមួយចំនួនដូចជាមេរោគជំងឺផ្តាសាយបក្សី អាចវិវត្តន៍ក្នុងខ្លួនសត្វពិសេសសត្វទា ដោយមិនបញ្ចេញរោគសញ្ញា។ ប៉ុន្តែមេរោគបំបែកខ្លួនក្នុងខ្លួនសត្វទា ហើយ ទាបញ្ចេញវីរុសជាច្រើនតាមលាមក។ មាន់ ងាយទទួលរងជំងឺនេះខ្លាំងណាស់។
  ជំងឺដែលបង្កដោយវីរុសអាចអាស្រ័យទៅលើប្រភេទសត្វដែលត្រូវបានចម្លង។



- សញ្ញាគ្លីនិកអាស្រ័យលើសរីរាង្គអ្វីដែលវីរុសបានរាតត្បាត ឧទាហរណ៍ ជំងឺប៉េស្ត ដែលវីរុសរាតត្បាត និងធ្វើឲ្យខូចខាត កោសិការបស់សរសៃឈាមតូចៗដែលធ្វើឲ្យបែកគ្រាប់ឈាមកក្នុងសរីរាង្គ ឬលើ ស្បែក។

រូបភាពទី ១.២ រោគសញ្ញាជំងឺប៉េស្ត

- វីរុសមិនអាចលូតលាស់ ឬបន្តពូជក្រៅ កោសិកាសត្វបានទេ។
- វីរុសរាតត្បាត លើកោសិកាមានជីវិត




ថ្នាំអង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធភាពប្រឆាំងវីរុសទេ។

- **បាក់តេរី**

បាក់តេរីជាអតិសុខមប្រាណ អាចបង្កជំងឺ មិនអាចមើលឃើញដោយភ្នែកទទេ តែអាចមើលឃើញដោយមីក្រូទស្សន៍អុបទិច។បាក់តេរីរស់នៅលើ ឬក្នុងគ្រប់សម្ភារៈនិងបរិស្ថាន។ ប៉ុន្តែបាក់តេរីចំនួនតិចតួចប៉ុណ្ណោះក្នុងចំណោមបាក់តេរីរាប់លានប្រភេទ ដែលជា ប្រភេទបង្កជំងឺ។ ប៉ុន្តែមានបាក់តេរី ដែលមានប្រយោជន៍រាប់លានកោដ នៅក្នុងពោះគោ

ក្របី ដែលចាំបាច់សម្រាប់ការចិញ្ចឹមរាង្គកាយ។

បាក់តេរីមានកោសិកាតែមួយ និងមានទំហំ ជាមធ្យមប្រហែល ០,០០១ម.ម (ធំជាងវីរុស ៣០០០ដង)

➢ កោសិកាបាក់តេរីមានទម្រង់បីប្រភេទគឺ៖ រាងមូល(កុកស៊ី) រាងដំបងដូច(បាក់ស៊ីលិស) និងរាងជាកង់ៗ(ដូចរឺស័រ)។



ពពួកស្ត្រិបតូកុកដែលមានរាងមូល



រាងដំបង(បាក់ស៊ីលីរបស់អឺកូលី

➢ បាក់តេរីមានរចនាសម្ពន្ធ័គ្រឹះដូចគ្នា៖

- ជញ្ជាំងកោសិកាមួយនិងភ្នាសស្រោបកោសិកាដែលអាចការពារ និងធ្វើឲ្យ មានរូបរាង

-ស៊ីតូប្លាសៈ ជាសមាសជាតុម្យ៉ាងផ្សំឡើង ដោយទឹកដែលផ្ទុកដោយសារជាតុចិញ្ចឹម បាក់តេរី

-ឧបករណ៍សេនេទិច (DNA) ដែលអណ្តែត ជុំវិញស៊ីតូប្លាស

-កន្ទុយធ្វើឲ្យវាបំលាស់ទីក្នុងបរិស្ថាន

-ភីលី(Pili) ជាប្រភេទរោមភ្ជាប់ទៅនឹង សរីរាង្គរបស់បាក់តេរី។




រូបភាពទី ១.៣រូបរាងរបស់បាតុរី



បាក់តេរី ក៏ដូចជាកោសិកាដ៏ទៃទៀត ត្រូវការចំណីជាមូលដ្ឋាន។ ពួកបាក់តេរី ត្រូវការ ប្រភពថាមពល អាសូត និងកាបូន (សារធាតុសរីរាង្គ មានក្នុងកំរាលទ្រុង សាកសពសត្វ សម្រាម...ពួកវាទាំងនេះអាចផ្ដល់សារជាតុ ចិញ្ចឹម)។ ទឹក,សារជាតុដ៏ទៃទៀត និងអុកស៊ីសែនក៏ចាំបាច់ផងដែរ



រូបភាពទី ១.៤កន្លែងរស់នៅរបស់បាតុរី

ការបំបែកខ្លួនរបស់បាក់តេរី




- ការបន្តពូជរបស់បាក់តេរីធ្វើឡើងតាមការបំបែកខ្លួន៖ កោសិការីកធំធាត់បង្កើត DNA ស្ទួនហើយនៅពេលដែលវារីកធំស្មើទំហំខ្លួនវាពីរដង វានឹងបំបែកចេញជាបាក់តេរីពីរដូចគ្នា។



- បាក់តេរីអាចបង្កកំណើតយ៉ាងលឿន។

ឧទាហរណ៍ : អីកូលីអាចបំបែកខ្លួនរៀងរាល់២០នាទី ប្រសិនបើមានបាក់តេរីអីកូលីចំនួន១០ នៅក្នុងបរិស្ថានសមស្របសម្រាប់ការបំបែកខ្លួន នោះ ១២ ម៉ោង ក្រោយ អីកូលីនឹងមានចំនួន៦០០ពាន់លាន។ សំណាងល្អដោយបាក់តេរីជាច្រើនត្រូវងាប់ទៅវិញដោយប្រព័ន្ធរាងកាយសត្វ




រូបភាពទី ១.៥កូនជ្រូករាគដោយអីការលី

ប្រឆាំងនឹងបាក់តេរីទាំងនោះ។ ប៉ុន្តែ ត្រូវច្បាស់ថាព្យាបាលរាគដែលបង្កដោយអឺកូលី ត្រូវតែធ្វើឲ្យ បាន ឆាប់តាមដែលអាចធ្វើទៅបាន។ មានបាក់តេរីមួយចំនួនតែប៉ុណ្ណោះដែលបង្កឲ្យមាជំងឺ។ គ្រប់សត្វ និង មនុស្សត្រូវបានឆ្លងដោយបាក់តេរី ពួកវារស់នៅលើរាងកាយ (ស្បែក សួត ពោះវៀន) ហើយបញ្ចេញ បាក់តេរីទៅក្នុង (បរិយាកាស,ទឹក,ដី និងចំណី)។

មានបាក់តេរីមួយចំនួនតែប៉ុណ្ណោះដែលបង្កឲ្យមានជំងឺ។ គ្រប់សត្វ និងមនុស្សត្រូវបានឆ្លង ដោយបាក់តេរី ពួកវារស់នៅលើរាងកាយ (ស្បែក សួត ពោះវៀន) ហើយបញ្ចេញបាក់តេរីទៅក្នុង (បរិយាកាស,ទឹក,ដី និងចំណី)។

ជាទូទៅសត្វមានអង្គបដិបក្ខ(អង្គទីគ័រ) ពីធម្មជាតិ ដូចនេះបាក់តេរីមិនសូវធ្វើឲ្យសត្វគ្រោះថ្នាក់ នោះទេ ។ការចម្លង អាចមើលឃើញចំនុចតូចៗដែលកើតមានដោយការប្រយុទ្ធគ្នារវាងបាក់តេរី និង សារពាង្គកាយសត្វ នៅពេលដែលអង្គបដិបក្ខ(អង្គទីគ័រ) ពីធម្មជាតិរបស់សត្វចុះខ្សោយ ដោយសារ ស្ត្រេស ខ្សោយ អស់កម្លាំង បរាសិត ឬជំងឺដទៃទៀត.....)ឬនៅពេលបាក់រីនៅក្នុងបរិស្ថានច្រើន (សត្វ ឈឺបញ្ចេញបាក់តេរីនៅក្នុងក្រុមរបស់វា) ឬនៅពេល បាក់តេរីមានសកម្មភាពខ្លាំង(ការចម្លងខ្លាំង) នោះការចម្លងនឹងចាប់ផ្តើមភ្លាម។

ជំងឺបង្កដោយបាក់តេរីកើតមាននៅពេលដែលវាចូលទៅក្នុងខ្លួន ការភ្ជាប់ទៅនឹងសរីរាង្គ រួចចាប់ផ្តើម បំបែកខ្លួន និងចូលទៅក្នុងឈាម។

- **ផ្សិត**

➢ ប្រភេទផ្សិតដែលបង្កឲ្យកើតជាជំងឺគឺជាពួក
➢ ដែលមានសសៃជាលិកាច្រើន។ផ្សិតផ្សំឡើង ដោយសសៃឆ្មារ។ អាចឲ្យយើងមើលឃើញពេលវាលូតលាស់ក្នុងកែវបណ្តុះ។



រូបភាពទី ១.៦ ជំងឺបង្ករពីផ្សិត



ក្រោមមីក្រូទស្សន៍ផ្សិតមានទំហំ ប្រហែល០,០០៥ម ម=ធំជាងបាក់តេរីដដង

➢ ជាទូទៅ ជំងឺដែលបង្កឡើងដោយពពួកផ្សិត អាស្រ័យដោយ សុខភាពសត្វចុះខ្សោយ ឬ ដោយជំងឺ ផ្សេងៗ ឬដោយភាពស៊ាំសត្វថយចុះ។ ផ្សិតមាននៅគ្រប់ទីកន្លែង សត្វអាចប្រឈមនឹងពួកផ្សិត។ តែនៅលក្ខខណ្ឌធម្មតា នឹងសត្វការពារទប់ទល់នឹងពពួកផ្សិត។

➢ ផ្សិត មានឈ្មោះថា អាស្ពែស៊ីលុស (Aspergillus) ដែលមានឥទ្ធិពល លើសុខភាពសត្វតាម របៀប សំខាន់ៗ

- តាមរយៈផលិតកម្មនៃមីកូតុកស៊ីនៈ អាផ្លាតុស៊ីន ត្រូវបានឃើញនៅក្នុងវត្ថុធាតុដើមដែលដុះផ្សិត ជាពិសេសពោត។ ការឲ្យសត្វស៊ីវត្ថុធាតុដើម ទាំងនោះ ជាទៀតទាត់ ធ្វើឲ្យខូចថ្លើម និងបំផ្លាញ ភាពស៊ាំ (សមត្ថភាព ធ្វើឲ្យពួកមេរោគចុះខ្សោយ)



រូបភាពទី ១.៧ អាស្ពែស៊ីលុស

- តាមរយៈការចម្លងដោយកន្លែងៈ ស្រែងនៅលជ្រូក ឬគោ គឺជាការចម្លងនៅស្បែកដោយពួកផ្សិត



រូបភាពទី ១.៨ អាស្ពែស៊ីលុសបង្កលើគោ

ឬតាមរយៈការចម្លងជាលក្ខណៈប្រពន្ធ័ៈ ជំងឺបង្កដោយពួកផ្សិតលើកូនមាន់ ជាជំងឺទូទៅបន្ទាប់ពីវាលេបពួកផ្សិត



រូបភាពទី ១.៩ អាស្ពែស៊ីលុសលើបេះដូង

- **បរាសិត**

បរាសិតជាសរីរាង្គដែលអាចរស់នៅក្នុងរាង្គកាយសត្វដែលយើងហៅថាបរាសិតខាងក្នុង ឬ រស់នៅខាងក្រៅលើស្បែក ឬក្នុងស្បែក យើងហៅថាបរាសិតខាងក្រៅ។ ជាទូទៅបរាសិតមាន គ្រោះថ្នាក់ចំពោះសត្វ យើងចាំបាច់ត្រូវត្រួតពិនិត្យវា ព្រោះវាជះឥទ្ធិពលដល់សុខភាពសត្វ។

- ឥទ្ធិពលទូទៅរបស់បរាសិត

➢ ឡើងទម្ងន់យឺត ដោយសារបរាសិតខាងក្នុងស្រូបសារជាតុចិញ្ចឹមដែលមានក្នុងចំណីនៅក្នុងពោះវៀនសត្វ ហើយបរាសិតខាងក្រៅបឺតឈាមធ្វើឲ្យសត្វស្លេកស្លាំង ខ្សោយ ឬបង្កឲ្យសត្វរមាស់ និងធ្វើឲ្យសត្វកើតដំបៅដែលរំខានដល់សត្វ

- ការបង្កជំងឺបរាសិតខាងក្នុងមួយចំនួនអាចធ្វើឲ្យខូចសរីរាង្គ(ថ្លើម)ឬខូះមុខងាររបស់សរីរាង្គដែលធ្វើឲ្យកើតជាជំងឺរាគ
- ការឆ្លងជំងឺពេលដែលបរាសិតខាងក្រៅ បានខាំសត្វអាចចម្លងជំងឺឆ្លង







រូបភាពទី ១.១០ រោគសញ្ញាបរាសិត

- វដ្តបរាសិត

បរាសិត មានវដ្តជីវិតពីស៊ុតរហូតដល់ពេញវ័យ (សម្រាប់ការបន្តពូជ) ដែលមានតំណាក់កាលទូទៅផ្សេងៗគ្នា៖

- ស៊ុត - កូនដង្កូវ - ដង្កូវពេញវ័យ





រូបភាពទី ១.១១ ការវិវដ្តរបស់បរាសិត

វដ្តរបស់បរាសិតអាចកើតមានដោយផ្ទាល់នៅក្នុងខ្លួនសត្វតែមួយ គឺគ្រប់តំណាក់កាលនៃការវិវត្តពីស៊ុតទៅពេញវ័យ ឧទាហរណ៍: វដ្តជីវិតរបស់ព្រូនអាស្ការីស។

វដ្តរបស់បរាសិតអាចកើតមានដោយមិនផ្ទាល់នៅពេលដែលការវិវត្តរបស់បរាសិតកើតមាននៅក្នុងខ្លួនសត្វពីរផ្សេងគ្នា ឧទាហរណ៍: វដ្តជីវិតរបស់ដង្កូវថ្លើម(Fasciola)។

- **បរាសិតខាងក្រៅ** អង្កែ ដង្កែ ចៃ រុយ ជាបរាសិតខាងក្រៅ។ដែលមានឥទ្ធិពលអាក្រក់លើសុខភាពសត្វបណ្តាលឲ្យ៖



ស្លាកស្នាមជាំចំណុចក្រហមៗ និងការគ្រេដុស

រូបភាពទី ១.១២ ស្លាកស្នាមជាំចំណុចក្រហមៗ

➢ ការបាត់បង់ឈាមៈ ប្រភពសារធាតុចិញ្ចឹមដែលដង្កែត្រូវការគឺឈាមដែលបឺតពីសត្វ។



រូបភាពទី ១.១៣ កន្ត្រាបង្កអោយកើតអង្កែ

ដង្កែញីមួយក្បាលបឺតឈាមបានរហូតដល់២ម.ល



រូបភាពទី ១.១៤ ដង្កែកើតលើសត្វ

➢ រំខាន និងធ្វើឲ្យសត្វស្ត្រេស ជាពិសេសបង្កឡើងដោយសាររុយនៅពេលវាមានចំនួនច្រើន។



➢ ការឆ្លងជំងឺៈ បរាសិតខាងក្រៅជាភ្នាក់ងារចម្លង និងពេលខ្លះជាអ្នកផ្ទុកជំងឺផងដែរ

- រុយទុំលើលាមកអាចនាំអឺកូលី សាល់ម៉ូណេឡា កុកស៊ីឌីយ៉ា
- ដង្កែអាចចម្លងជំងឺ ដូចជា បាបេស្យា អាណាផ្លាស្មា
- មូស ជាអ្នកចម្លងជំងឺអុត

• **បរាសិតខាងក្នុង**

ព្រូនអាស្ការីស តុសូការ៉ា ព្រូនក្រហម តេញ៉ា កុកស៊ីឌីយ៉ូ ជាបរាសិតខាងក្នុង។ សត្វដើររក ស៊ីចំណីដោយសេរី ងាយឆ្លងចូល បរាសិតខាងក្នុង ព្រោះវាងាយលេបស៊ុត និងកូនដង្កូវដែលមាននៅលដី។

ឥទ្ធិពលអាក្រក់ លើសុខភាពសត្វបង្កដោយបរាសិតខាងក្នុងបណ្តាលឲ្យៈ

- ព្រូនស្រូបយកសារធាតុចិញ្ចឹមសំខាន់ៗ ធ្វើឲ្យស្ថានភាពខ្លួនសត្វ មិនល្អ
- កូនគោនិងកូនក្របីអាចងាប់បានដោយព្រូនតុកសូការ៉ា
- បរាសិតខាងក្នុងខ្លួនអាចបំផ្លាញសរីរាង្គដូចជាថ្លើម ពោះវៀន សួត ដែលធ្វើឲ្យរាគ និងក្អក
- បរាសិតខាងក្នុងអាចចម្លងទៅមនុស្ស និង ធ្វើឲ្យប៉ះពាល់ដល់សុខភាពមនុស្ស ដូចជាតេញ៉ា និងទ្រីជីណេឡា









រូបភាពទី ១.១៥ តេនញ៉ា

- **កង្វះអាហារូបត្ថម្ភ**

ជំងឺមួយចំនួនកើតឡើងដោយកង្វះចំណីអាហារ ដូចជាកូនជ្រូកដែលមិនទទួលបានជាតិដែកគ្រប់គ្រាន់ធ្វើឲ្យវាស្លេ កស្លាំង។ជាទូទៅរាល់កង្វះខាតចំណីអាហារធ្វើឲ្យសមត្ថភាពរបស់សត្វ ប្រឆាំងនឹងជំងឺថយចុះ ហើយរិតតែប៉ះពាល់ដល់ការលូតលាស់ និងបន្តពូជ។

សារជាតុចិញ្ចឹមចំបងចាំបាច់សម្រាប់សត្វមានសុខភាពល្អគឺ:



ចាំបាច់ត្រូវផ្តល់ទឹកស្អាតឲ្យបានគ្រប់គ្រាន់

រូបភាពទី ១.១៦ ការផ្តល់ទឹកមាន់

ទឹកទឹកផ្តល់នូវមូលដ្ឋានគ្រឹះនៃសារជាតុរាវទាំងអស់របស់រាង្គកាយ សត្វឈាមរត់ត្រូវការជាតិទឹកដើម្បីបំលាស់ទី ការរំលាយអាហារ ត្រូវការជាតិសើមដើម្បីបំបែកចំណី។ ទឹកត្រូវការចាំបាច់

- ដើម្បីផលិតទឹកដោះនិងទឹកនោម។ការផ្តល់ទឹកមិនគ្រប់គ្រាន់ធ្វើឲ្យសត្វមិនឃ្លានចំណី បង្កើនការគ្រោះថ្នាក់លើតំរងនោម និងរាងកាយមិនអាចបញ្ចេញជាតិពុលបានត្រឹមត្រូវ។

➢ បរិមាណទឹកដែលផ្តល់ឲ្យសត្វក៏សំខាន់ផងដែរ ទឹកអាចធ្វើឲ្យកខ្វក់ដោយបាក់តេរី ថ្នាំសម្លាប់សត្វល្អិត ឬអាចចម្លងជំងឺដូចជា ផ្តាសាយបក្សី នៅពេលសត្វទាបញ្ចេញលាមកនៅក្នុងទឹកស្រះ។

- **ថាមពល:** រាង្គកាយត្រូវការថាមពលដើម្បីទ្រទ្រង់ជីវិត និងធ្វើសកម្មភាព។ ប្រភពថាមពលសំខាន់បានមកពីស្ករ ឧទាហរណ៍មើមដំឡូងមី សំបូរជាតិម្សៅ (ករណីខ្វះថាមពល សត្វនឹងប្រើខ្លាញ់បម្រុងរបស់វា និងធ្វើឲ្យ វាស្រកទម្ងន់ ឧទាហរណ៍ មេជ្រូកក្នុងកំឡុងពេលបំបៅដោះ ត្រូវការថាមពលច្រើនដើម្បីផលិតទឹកដោះឲ្យកូនជ្រូកបៅ ប្រសិនបើវាមិនបានស៊ីចំណីគ្រប់គ្រាន់ទេវានឹងស្គមនៅពេលផ្តាច់ដោះ ព្រមទាំងមានបញ្ហាសុខភាពច្រើន នឹងការរក ឈ្មោលលើកក្រោយត្រូវយឺតយ៉ាវច្រើនអាទិត្យ។ ផ្ទុយទៅវិញ បើសត្វស៊ីចំណីមានថាមពលច្រើនពេក វា ធាត់ខ្លាំងនឹងជួបបញ្ហាក្រោកឈរនិងពិបាកកើតកូន។



ប្រូតេអ៊ីនមិនគ្រប់គ្រាន់=កំណើនទម្ងន់




១៦ ប្រូតេអ៊ី

រូបភាពទី ១.១៧ ការផ្តល់ប្រូតេអ៊ីនលើជ្រូក

- ប្រូតេអ៊ីនប្រូតេអ៊ីនជាមូលដ្ឋានគ្រឹះសម្រាប់កសាងរាង្គកាយសត្វ។ ប្រូតេអ៊ីន កើតឡើងដោយសារអាស៊ីតអាមីណេ វាជា អ្នកផ្គត់ផ្គង់វត្ថុនានាដើម្បីបង្កើតជាលិការាងកាយ ជាពិសេសសាច់ដុំ។ ជ្រូកនិងបក្សីត្រូវការអាស៊ីតអាមីណេ ចាំបាច់ដូចជា (លីស៊ីន មេទីយ៉ូនីនដែលសារជាតុទាំងនេះ ត្រូវផ្ដល់តាមរយៈចំណី) ប៉ុន្តែសត្វពាហនៈអាចសំយោគ រាល់អាស៊ីតអាមីណេបាន។




រូបភាពទី ១.១៨ មេជ្រូកពេលផ្ដាច់ដោះ និង កូនជ្រូកចាក់ជាតិដែក

➢ ចំពោះបក្សី និងជ្រូកត្រូវផ្ដល់ប្រូតេអ៊ីនតាមរយៈចំណី (ម្សៅត្រីមានប្រូតេអ៊ីនច្រើនជាង ៥០% សណ្ដែកសៀង៤០% ពោត៨% ស្រូវ២%) ប៉ុន្តែសត្វពាហនៈអាចផលិតប្រូតេអ៊ីន ពីជាតិសសៃបាន។

➢ កង្វះប្រូតេអ៊ីនធ្វើឲ្យសត្វធំជាត់យឺត ដោយសារសាច់ដុំមិន អាចលូតលាស់ និងផលិតកម្មទឹកដោះថយចុះដែលធ្វើឲ្យ កូនជ្រូកនិងកូនគោ ក្របីខ្សោយ។

- សារជាតុរ៉ែៈ កាល់ស្យូម ផូស្វ័រនិងម៉ង់កាណែសជាអ្នកផ្គត់ផ្គង់វត្ថុនានា ដើម្បី បង្កើតឆ្អឹង ធ្មេញនិងជាលិកា។ សារជាតុរ៉ែផ្សេងទៀតមានបរិមាណតិចតួច តែចាំបាច់សម្រាប់ ដំណើរការរាង្គកាយ ឧទាហរណ៍វាចាំបាច់ណាស់ត្រូវចាក់ជាតិ ដែកឲ្យកូនជ្រូកទើបកើតដើម្បីបង្ការការស្លេកស្លាំង។

➢ កង្វះជាតិកាល់ស្យូម ធ្វើឲ្យឆ្អឹងសត្វក្មេងមិនលូតលាស់ ឬ សំបកស៊ុតស្តើង។

➢ កង្វះជាតិផូស្វ័រ ធ្វើឲ្យសាច់ដុំខ្សោយ និងការបង្ក កំណើត ទាប។

- វីតាមីនវីតាមីន ជាសារជាតុសំខាន់ធ្វើឲ្យមានតុល្យភាពចំណីអាហារ ហើយវាមានមុខងារចំបងគឺបំលែងអាហារទូទៅជាថាមពល និងការប្រើប្រាស់សារជាតុចិញ្ចឹមតម្រូវការវីតាមីនមានចំនួនតិចតួចតែប៉ុណ្ណោះ (ដែលគេហៅថាជាសមាសជាតុត្រួសត្រាយផ្លូវ) ប៉ុន្តែមុខងាររបស់វាចាំបាច់បំផុត។ ទិដ្ឋភាពស្បែកសត្វជា សន្ទស្សន៍ដើម្បីឲ្យយើងសង្ស័យពីកង្វះជាតិវីតាមីន រោមភ្លឺរលោង ស្បែកល្អបញ្ជាក់ថាសត្វមានសុខភាពល្អ និងមានការផ្ដល់ វីតាមីនបានគ្រប់គ្រាន់។



រូបភាពទី ១.១៩ សត្វដែលមានសុខភាពល្អ

## ១.១១-ការឈឺចាប់(Distress)

### ១.១១.១ របួស

របួស ជាមូលហេតុចម្បងធ្វើឲ្យមានជំងឺ និងមានផលអាក្រក់លើសុខភាពសត្វទៅតាមស្ថានភាពផ្សេងៗគ្នា:

របួសលើស្បែក និងក្រោមស្បែកដែលធ្វើ ឲ្យមានការឆ្លងមេរោគនៅបរិវេណនោះ។ការជាសះស្បើយឡើងវិញនូវមុខរបួស ត្រូវការពេល យូរ បើមិនបានព្យាបាលឲ្យបានត្រឹមត្រូវនោះទេ។ ត្រូវ កាត់រោមជុំវិញដំបៅ រួចលាងទឹកនិងដុស កន្លែង នោះឲ្យស្អាត ត្រូវសម្អាតរៀងរាល់ថ្ងៃជាមួយទឹក និង សាប៊ូ ដើម្បីបំបាត់ការហៀរខ្ទុះ បើដំបៅជ្រៅត្រូវចាក់ ថ្នាំអង់ទីប៊ីយ៉ូទិក ដូចជា អាម៉ុកស៊ីស៊ីលីន ដែល មានរយះពេលវែង (Amoxicillin LA)។

- មេរោគឆ្លងចូលក្នុងរាងកាយ តាមរយះ

- ការខាំៈ ត្រូវប្រុងប្រយ័ត្ននិងស្វែងយល់ពីគ្រោះថ្នាក់នៃជំងឺឆ្កែឆ្កួត នៅពេលសត្វត្រូវបានឆ្កែខាំ។
- បច្ចេកទេសមិនត្រឹមត្រូវៈ ពេលខ្លះមេរោគអាចចូល ក្នុងខ្លួនសត្វ និងធ្វើការចម្លងដោយសារការអនុវត្ត មិនបានត្រឹមត្រូវដូចជារបួសឬដំបៅបន្ទាប់ពីការចាក់ថ្នាំ ការកាត់ធ្មេញ កាត់កន្ទុយ។ល។
- ➢ ដំបៅៈ មេរោគផ្សេងៗឆ្លៀតឱកាសជ្រាតចូលក្នុង ខ្លួនសត្វតាមមុខរបួសលើស្បែកឬក្នាសស្តើងនិងបង្កជំងឺទូទៅដូចជាស្ត្រិបតូកុក តេតាណូស។ល។








កម្រាលមិនល្អធ្វើឲ្យមានដំបៅលើជង្គង់=ងាយស្រួលជ្រាប ចូលពីពពួកស្ត្រិបតូកុក



រូបភាពទី ១.២០ ភាពពកដែលបណ្តាលមកពីការចាក់ថ្នាំ

**ការឈឺចាប់**

ការឈឺចាប់ច្រើនថ្ងៃធ្វើឲ្យការស៊ីចំណីនិងផឹកទឹកថយ ចុះ។ សត្វចុះខ្សោយនៅពីរទៅបីថ្ងៃបន្ទាប់មក និងងាយ ទទួលរងជំងឺផ្សេងៗ

- ការឈឺកែងជើងៈ ឈឺចាប់នៅសន្លាក់ឬលើជើង ធ្វើ ឲ្យសត្វពិបាកដើរទៅផឹកទឹកនិងស៊ីចំណីបង្កជាឥទ្ធិពលធ្ងន់ធ្ងរដល់សុខភាពសត្វ។
- ភ្នែកៈ ស្លាកស្នាមដំបៅលើភ្នែកបង្ហាញសភាព ក្រហមលើភ្នាសស្តើងភ្នែក ហូរទឹកភ្នែក និងសញ្ញានៃការបុករបស់អ្វីមួយ ឬរបួសលើកែវភ្នែក ដែលធ្វើឲ្យ សត្វឈឺចាប់ខ្លាំង និងមិនបំលាស់ទី ហើយស្ថិតតែនៅក្រោមម្លប់។ ចាំបាច់ត្រូវចាក់ថ្នាំ ដែលបន្ថយ ការឈឺចាប់ដើម្បីជួយសុខភាពវា (ដូចជាថ្នាំប៉ារ៉ាសេតាម៉ុល(Paracetamol) ផេនីលប៊ុយតាសូន

- **ថ្នាំពុល ឬសារធាតុពុល**

គ្រោះថ្នាក់នៃការពុលកើតមានខ្ពស់ចំពោះសត្វដើរដោយសេរី ការពុលជាទូទៅបង្កឡើងដោយៈ

- ការពុលដោយជីអ៊ុយរេៈ គោស៊ីជីអ៊ុយរេ ដែលនៅសល់ក្នុងបាវ។ រោគសញ្ញារួមមានៈ
  - ហើមពោះខ្លាំង
  - កន្ត្រាក់សាច់ដុំធ្វើឲ្យសត្វបាត់បង់ជំហរ (ដើរដូចស្រវឹង)
  - ងាប់ក្នុងកំឡុងពេល២ម៉ោង

  ការព្យាបាលត្រូវធ្វើជាបន្ទាន់ ដោយប្រើទឹកខ្មេះលាយទឹក ២-៥លីត្រឲ្យសត្វផឹក។



រូបភាពទី ១.២១ គោស៊ីជីអ៊ុយរ៉េ

- ពុលដោយថ្នាំសំលាប់សត្វល្អិតៈ រោគសញ្ញា គឺសត្វចេញទឹកមាត់ខ្លាំង (ប៉ុន្តែ វាមិនអាចច្រលំជាមួយជំងឺអុតក្តាមទេព្រោះវាមានសភាពស្រួចស្រាវជាង) សត្វនៅមិន សុខ អស់កំលាំង អាច ងាប់បើវាស៊ីថ្នាំនោះច្រើន។ ត្រូវព្យាបាល វាដោយចាក់ថ្នាំអាត្រូពីន (Atropine) ចាក់សាច់ដុំ។



រូបភាពទី ១.២២ គោពុលជីអ៊ុយរ៉េ

- រុក្ខជាតិមួយចំនួនមិនប្រាកដជាធ្វើឲ្យសត្វ

➢ ពុលទេ ប៉ុន្តែវាបង្កឲ្យរលាករោល (allergy) នៅប្រទេសយើងច្រើនកើតការរលាករោលដោយពន្លឺថ្ងៃ។ បន្ទាប់ពីស៊ីចំរុក្ខជាតិខ្លះ ហើយ
➢ វានៅក្រោមកំដៅថ្ងៃខ្លាំង គោអាច បង្ហាញស្លាកស្នាមដំបៅលើស្បែកដែលអាចធ្វើឲ្យកាន់តែធ្ងន់ធ្ងរ។ នៅពេលដែល រោគសញ្ញាលេចឡើង យើងត្រូវទុកគោឲ្យ នៅក្នុងម្លប់និងចាក់ថ្នាំជិចសាមេតាសូន។



រូបភាពទី ១.២៣ ស្នាមដំបៅលើស្បែក

### ១.១១.២ ការតានតឹងអារម្មណ៍(ស្រ្តេស)

ស្រ្តេស ជាលក្ខខ័ណ្ឌកើតឡើងនៅពេល

ដែលការគ្រប់គ្រងមិនបានត្រឹមត្រូវ និងបរិស្ថានមិនអំណោយផល ដែលធ្វើឲ្យភាពស៊ាំរបស់សត្វចុះខ្សោយ និងងាយរងនូវជំងឺផ្សេងៗ។

- ឥទ្ធិពលរបស់ស្រ្តេសមានច្រើន ប៉ុន្តែអ្វីដែលសំខាន់នោះគឺ៖

➢ ពេលកូនជ្រូកផ្តាច់ដោះ កូនជ្រូកងាយរងនូវជំងឺផ្សេងៗ រាគ ក្អក និងស្រកទម្ងន់។ល។ក្នុងអំឡុង១០ថ្ងៃដំបូងបន្ទាប់ពីផ្តាច់ដោះ អាស្រ័យដោយការផ្លាស់ប្តូរចំណី ការផ្លាស់ប្តូរទីកន្លែង ទ្រុងថ្មី ការខាំគ្នាជាមួយកូនជ្រូកដទៃ។ដូចនេះ ផ្តល់ថ្នាំអង់ទីប៊ីយ៉ូទិកលាយទៅក្នុងចំណីកូនជ្រូកទើបផ្តាច់ដោះ។
➢ ចំនួនសត្វច្រើនហួស គឺជាកត្តាមិនត្រឹមត្រូវ និងសត្វគ្មានផាសុខភាពនៅទ្រុងដែលធ្វើឲ្យវាស្រ្តេស។

សីតុណ្ហភាពប្រែប្រួលខ្លាំងដូចជា ពេលថ្ងៃ ក្តៅខ្លាំង ហើយពេលយប់ត្រជាក់ខ្លាំងធ្វើឲ្យ សត្វងាយទទួលការឆ្លងចម្លងលើប្រព័ន្ធដង្ហើម និងស្រ្តេសដោយការសម្របទៅនឹងការ ផ្លាស់ប្តូរបរិស្ថានច្រើនលើកក្នុងមួយថ្ងៃ។

➢ ការប្តូរទៅកាន់ទ្រុងថ្មី វាធ្វើឲ្យសត្វស្រ្តេសខ្លាំង ឧទាហរណ៍ការប្តូរមេជ្រូកទៅកាន់ ទ្រុងកើតកូន មេជ្រូកស៊ីតិច មិនចង់ក្រោក ឈរ ហើយច្រើនកើតបញ្ហាក្តៀន។ ការដាក់សត្វចូលរួមគ្នានិងការខាំ វាកើតជាទូទៅចំពោះជ្រូកនៅពេលផ្តាច់ដោះ ឬចាប់ផ្តើមបំប៉ន។ កសិករចងដាក់ជ្រូកដែល មានទំហំប៉ុនៗគ្នានៅក្នុងក្រុមដែលមកពី សំបុកផ្សេងៗគ្នានោះពួកវានឹងខាំគ្នាហើយ បណ្តាលឲ្យស្រ្តេស ធ្វើឲ្យវាស៊ីចំណីតិចនិងថយទម្ងន់។

- ចំណីមិនគ្រប់គ្រាន់ និងគុណភាពមិនល្អៈសត្វមានអារម្មណ៍ឃ្លាន ហើយមើលទៅវាស្រេកឃ្លាន ចំណីខ្លាំងក៏ជាមូលហេតុស្ត្រេសផងដែរ។
- 


មាន់មានកន្លែងគ្រប់គ្រាន់ដើម្បីដើរ ក្រាបដេក


ការខាំគ្នាធ្វើឲ្យវាឈឺ ចាប់មានការចម្លងតាមស្បែកនិង


តើគោនេះរីករាយឬទេ?

រូបភាពទី ១.២៤ ភាពស្រេស្ត្រនៃសត្វ

## ខ. ការរាតត្បាតនៃជំងឺ

១. តើភ្នាក់ងារចម្លងជំងឺសាយភាយយ៉ាងដូចម្តេច?

តើជំងឺអាចចូលទៅក្នុងកសិដ្ឋាន ឬភូមិមួយយ៉ាងដូចម្តេច? ប្រសិនបើយើងដឹងពីវិធីផ្សេងៗ ដែលជំងឺសាយភាយ នេះយើងនឹងអាចកាត់បន្ថយគ្រោះថ្នាក់ការចម្លងទៅកាន់កសិដ្ឋាន ឬភូមិបាន។

- សត្វឈឺៈ-មេរោគអាចសាយភាយតាមរយៈ៖
- លាមក
  ទឹកសំបោរ មានន័យថានៅពេលមានការប៉ះពាល់ជិតស្និតជាមួយសត្វឈឺ វីរុស បាក់តេរី ផ្សិត ឬ បរាសិត ត្រូវបានចម្លងចូល ទៅសត្វមានសុខភាពល្អ នឹងធ្វើឲ្យសត្វឈឺ។ក្នុងដំណាក់កាលសម្ងំនៃមេរោគ សត្វហាក់ដូចជាមានសុខភាពល្អ។

**ការសំងំនៃមេរោគៈ** ជាពេលវេលាដែលសត្វត្រូវបានឆ្លងជំងឺ រហូតដល់ការបង្ហាញរោគសញ្ញាជាលើក ដំបូង។ សត្វមើលទៅមានសុខភាពល្អ ប៉ុន្តែ បញ្ចេញវីរុស និងចម្លងទៅសត្វដ៏ទៃ។

- មនុស្សអាចនាំ និងបញ្ចេញមេរោគតាមរយៈ៖
- ស្បែកជើងជាប់ប្រឡាក់ដីនៅពេលកសិករដើរទៅទីផ្សារបក្សីរស់។សារធាតុសរីរាង្គលាមកដែលមានមេរោគតោងជាប់ស្បែក ជើងដែលពាក់ត្រឡប់មកកាន់ផ្ទះវិញ ហើយអាចចម្លងទៅកាន់មាន់របស់ពួកគាត់
- ស្បែកជាពិសេសដៃដែលមានកំដៅសមល្មម និងសំណើម ដែលជាបរិស្ថានល្អបំផុត សម្រាប់មេរោគលូតលាស់។ ពេលយើងប៉ះ សត្វ ឬសម្ភារៈ ដែលប៉ះជាមួយសត្វ ដៃរបស់យើងដែលនាំមេរោគតាម

រយៈ ទឹកសំបោរ លាមកជាដើមដែលសត្វ បញ្ចេញមកក្រៅ ដូចនេះត្រូវលាងដៃ ជាមួយទឹក នឹងសាប៊ូដើម្បីឲ្យ ដៃស្អាត។







រូបភាពទី ១.២៥ ការចម្លងជំងឺ

- រថយន្ត និងសម្ភារៈប្រើប្រាស់៖

➢ កង់រថយន្តប្រឡាក់ ជាពិសេសលាមក សារធាតុសរីរាង្គពីកសិដ្ឋាន ដែលអាចចម្លងពីកសិដ្ឋានមួយទៅកសិដ្ឋានមួយ។

➢ សម្ភារៈដូចជាកញ្ជ្រែងដាក់ស៊ុតអាចចម្លងនៅពេលយកត្រឡប់ពីផ្សារវិញ ឬស្នូកទឹក ស្នូកចំណីនៅពេលដែលទិញពីកន្លែង
លក់ដែលបានជួបជាមួយអ្នកចិញ្ចឹមជាច្រើននៅទីនោះ។

- សត្វចង្រៃ

➢ សត្វល្អិត ជាភ្នាក់ងារចម្លងជំងឺដូចជា មូស ចម្លងជំងឺអុត។

➢ សត្វកកេរ ចម្លងជំងឺសាល់ម៉ូណែឡា អីកូលី និងធ្វើឲ្យចំណីនិងទឹកកខ្វក់។ សត្វកកេរ ជា អ្នកផ្ទុកជំងឺឡឹបតូស្ពីរ៉ូ ដែលចម្លងមកកាន់ មនុស្ស និងសត្វ។

- ទឹក

មុខងារសំខាន់របស់ទឹក គឺការចម្លងជំងឺ ផ្តាសាយបក្សី។ បក្សីទឹកដូចជាទា មើល ទៅមានសុខភាពល្អ ប៉ុន្តែវាបញ្ចេញវីរុស ច្រើនក្នុងស្រះទឹក។ វីរុសអាចរស់នៅបាន ច្រើនថ្ងៃ ហើយអាចចម្លងមកមនុស្ស និង សត្វពេលពួកគេប្រើប្រាស់ទឹកស្រះនោះ។




រូបភាពទី ១.២៦ ការចម្លងជំងឺមកកាន់សត្វ

២. មូលដ្ឋានគ្រឹះនៃជីវសុវត្ថិភាព នៅពេលយើងដឹងពីរបៀបនៃការសាយភាយជំងឺ ចាំបាច់ត្រូវអនុវត្តឲ្យបានល្អនូវវិធានការដែលកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីជំងឺ នោះគឺជីវសុវត្ថិភាព។ វាប្រាកដណាស់ថា ជីវសុវត្ថិភាពមានភាពងាយស្រួលអនុវត្តនៅកសិដ្ឋានពាក់កណ្តាលឧស្សាហកម្មដែលសត្វត្រូវបានដាក់ក្នុងទ្រុង ជាងនៅ ក្នុងភូមិដោយសត្វលែងឲ្យដើរសេរី។

- ការការពារការឆ្លងជំងឺពីសត្វឈឺ
- គ្រោះថ្នាក់ខ្ពស់ ពេលទិញមាន់ពីផ្សារ ឬកូនជ្រូកពីឈ្មួញកណ្តាលព្រោះយើងមិនដឹងប្រភពរបស់សត្វ។
- ត្រូវទិញសត្វមើលទៅមានសុខភាពល្អ។ ការតថ្លៃទិញសត្វដែលមានសភាពមិនល្អដើម្បីបានតំលៃថោកមិនជាការត្រឹមត្រូវទេ។
- បង្ខាំងសត្វទើបទិញថ្មីទោះបីមើលទៅវាមានសុខភាពល្អក៏ដោយព្រោះវាអាច មានជំងឺសំងំ។រយៈសំងំជំងឺអាចពី២ទៅ១៥ថ្ងៃ។ បើអ្នកបំបែកវា បង្ខាំង១៤ ថ្ងៃ ដើម្បីពិនិត្យមើលសុខភាពសត្វ តែបើសត្វឈឺ ក៏មិនអាចចម្លងទៅសត្វដ៏ទៃទៀតក្នុងកសិដ្ឋាននោះទេ។
- គ្រោះថ្នាក់ខ្លាំងនៅពេលដាក់បាផ្ទាល់ ព្រោះយើងមិនដឹងសុខភាពបាវាយ៉ាងណានិង បានពាក់នៅកន្លែងណាពីមុននេះ។ ដូចនេះ ត្រូវបំផុសឲ្យបង្កាត់ដោយសិប្បនិម្មិត ព្រោះមេជ្រូកគ្មានប៉ះពាល់-ជាមួយបាផ្ទាល់។



ទ្រុងដាច់ដោយឡែកផ្តល់ភាពងាយស្រួលក្នុងការបំបែកជ្រូកទើបទិញ



មាន់បំបែកដាក់ក្នុងទ្រុងបែបប្រពៃណី ដាក់នៅកន្លែងឆ្ងាយនិងស្អាត



បំពង់តូចនេះផ្ទុកទឹកកាមដែលយកពីបា

- គោអាចបញ្ចេញពងបរាសិតដោយគ្មានរោគសញ្ញា ពេលកសិករទិញគោ ចាំបាច់ត្រូវទម្លាក់ព្រូនជាមួយអាល់បង់ដាសុល (albendazole)។



រូបភាពទី ១.២៧ ការការពារជំងឺឆ្លង

- ការការពារការសាយភាយមេរោគតាមរយៈមនុស្ស : ត្រូវកំហិតការចូលមកមើលកសិដ្ឋាន ឬ កន្លែងចិញ្ចឹម។ កសិករ ភ្នាក់ងារសុខភាពសត្វភូមិ បសុពេទ្យ ម្ចាស់សត្វ ម្ចាស់កសិដ្ឋាន ឬម្ចាស់កន្លែង

ចិញ្ចឹម ដែលមកពីផ្សារ ជាមនុស្សដែលមានគ្រោះថ្នាក់ព្រោះពួកគាត់ មកពីកន្លែងដែលមានមេរោគប្រមូលផ្តុំ។ដូចនេះត្រូវៈ

➢ លាងដៃគឺជាការសំខាន់ព្រោះស្បែកដៃក្តៅនិងសើមជាមជ្ឈដ្ឋានល្អសម្រាប់មេរោគរស់នៅនិងវិវត្ត។
➢ ផ្លាស់ប្តូរស្បែកជើងដែលមេរោគតោងជាប់ពេលអ្នកទៅកន្លែងណាមួយ។
➢ ឈ្មួញកណ្តាលត្រូវរង់ចាំច្រកចូលខាងក្រៅកសិដ្ឋាន
➢ ភ្នាក់ងារសុខភាពសត្វភូមិ បសុពេទ្យ ត្រូវប្តូរសម្លៀកបំពាក់បើសិនគាត់មកពីកន្លែងដែលមានជំងឺ។



មាន់ត្រូវបានប្រមូល និងដាក់ក្នុងទ្រុងដោយម្ចាស់ ហើយឈ្មួញមិនត្រូវចូលក្នុងកសិដ្ឋានទេ



• ការការពារការការរាតត្បាតមេរោគ ដោយរថយន្ត និងសម្ភារៈប្រើប្រាស់ៈ

➢ ម៉ូតូដែលមកពីផ្សារដឹកស៊ុតឬមាន់ត្រូវតែលាងសម្អាត
➢ រថយន្តឈ្មួញកណ្តាល និង បសុពេទ្យ មិនអាចចូលទៅក្នុង កសិដ្ឋានឬផ្ទះ

ទើបមកពីផ្សារ នេះជាការអនុវត្តមិនត្រឹមត្រូវ






ទើបមកពីផ្សារ នេះជាការអនុវត្តត្រឹមត្រូវ

រូបភាពទី ១.២៨ ប្រភពមេរោគបង្កជំងឺ

➢ ស្នូកទឹក ចំណីដែលទិញមកពីហាងលក់ត្រូវលាងនិងរម្ងាប់មេរោគមុនប្រើ ព្រោះមានកសិករជាច្រើនជួបគ្នានៅទីនោះហើយនាំមេរោគទៅជាមួយ។ចាំបាច់ត្រូវលាងស្នូកទឹក ចំណីឲ្យទៀងទាត់ដើម្បីការពារការរីកលូតលាស់នៃមេរោគក្នុងចំណីដែលសល់។










រូបភាពទី ១.២៩ លាងសំអាតស្នូកទឹក ស្នូកចំណី

## ការការពារសត្វចង្រៃ

- **សត្វកកេរ** សំខាន់ត្រូវត្រួតពិនិត្យ កណ្តុរ នៅពេលឃើញវា១យើងអាចប៉ាន់បានថាវាអាចមាន ៥០ រស់នៅទីនេះ។







រូបភាពទី ១.៣០ ការចម្លងជំងឺពីសត្វកកេរ

- **សត្វល្អិត** ចំនួនរុយនិងមូស អាស្រ័យលើ-ការសម្អាតនិងការធ្វើអនាមយ័

  - ចាំបាច់ត្រូវត្រួតពិនិត្យកន្លែងរុយរស់នៅ។ រុយពេញវយ័មួយក្បាលពងបាន៥០០ស៊ុត ហើយវដ្ត ពេញវយ័ មានរយៈពេលតែ៨ថ្ងៃ។ ដូចនេះត្រូវប្រមូល និងសម្ងួតលាមក សម្អាតកំទិចចំណីនៅក្នុង ទ្រុង លាងសម្អាតស្នូកទឹកចំណីគឺជាវិធានការដ៏មានប្រសិទ្ធភាព

ដើម្បី បំបាត់មូសចាំបាច់ ត្រូវកាត់ស្មៅជុំវិញរោងចិញ្ចឹម លុបថ្លុក ក្រឡុក មិនឲ្យមានដក់ទឹកកខ្វក់។







រូបភាពទី ១.៣១ ការចម្លងជំងឺពីសត្វល្អិត

- អនាមយ័ជាទូទៅសំខាន់សំដៅការពារសត្វចង្រៃ និងការបំបែកខ្លួនរបស់មេរោគ ។ទីកន្លែងសើម និងក្តៅល្មមដែលមានសារធាតុកខ្វក់ជាមជ្ឈដ្ឋានដ៏ល្អសម្រាប់ការលូតលាស់។ បទពិសោធន៍សម្អាត ភូមិចំនួន៣ដែលបានអនុវត្តដោយគម្រោងមួយ និងឥទ្ធិពលគួរឲកត់សម្គាល់លើសុខភាពសត្វគ អត្រាងាប់របស់ទានិងមាន់មានប្រហែល៣០% មុនគម្រោងចូល បន្ទាប់ការសម្អាតរយៈពេល ៦ខែ អត្រាងាប់របស់មាន់ធ្លាក់មក ៣% និង អត្រាងាប់របស់ទាធ្លាក់មក០.១៥%។










រូបភាពទី ១.៣១ ការធ្វើអនាម័យ

- ការការពារការឆ្លង ទៅក្នុងទឹក

ពេលទឹកបូមពីអណ្តូងយើងត្រូវគ្របពាង ឬធុងនិងដាក់ក្លរីន (chlorine)ក្នុងទឹកដើម្បីសម្លាប់វីរុស និងបាក់តេរី។ ទឹកត្រូវថ្លាស្អាតដោយដាក់ក្លរីនក្នុងទឹករយៈពេល២០នាទី មុនពេលយកមកប្រើ។




- **ថ្នាំរំងាប់មេរោគ**

អ្វីជាថ្នាំរំងាប់មេរោគ?

ថ្នាំរំងាប់មេរោគជាសារធាតុគីមីដែលអាចសម្លាប់មេរោគ (បាក់តេរី វីរុស និងផ្សិត) តាម ការប៉ះពាល់ ។

- ប្រភេទថ្នាំរំងាប់មេរោគៈ

-**ក្រេស៊ីល** (cresyl) មានសកម្មភាពសកម្មប្រឆាំង បាក់តេរី និងវីរុស ហើយមានសកម្មភាពជាច្រើនថ្ងៃ។ **ក្រេស៊ីល** មិនសូវជាគ្រោះថ្នាក់ទេ ជាទូទៅគេប្រើក្នុងកំរិត ៥%។

**អ៊ីយ៉ូឌីន** (Iodine) ជាថ្នាំរំងាប់មេរោគដ៏ល្អនិង មិនធ្វើឲ្យមានគ្រោះថ្នាក់ ប៉ុន្តែការប្រើលើកាកសំណល់មិនមាន ប្រសិទ្ធភាព និងបាត់បង់ប្រសិទ្ធភាពបើប្រើក្រោមកំដៅថ្ងៃ







រូបភាពទី ១.៣២ ថ្នាំសម្លាប់មេរោគ

**កំបោររស់** វាមានប្រសិទ្ធភាពលើសារធាតុសរីរាង្គហើយអាចកំទិចកាកសំណល់ និងមេរោគ ប្រើសម្រាប់ដាក់លើសាកសព (ក្រោមលក្ខខ័ណ្ឌសំណើម)។

**ធីអេច៤+** (TH4+) ជាប្រភេទនៃថ្នាំរំងាប់មេរោគជំនាន់ថ្មី ត្រូវបានគេសាកល្បងជាមួយមេរោគច្រើនប្រភេទ កំរិតទូទៅដែលគេប្រើគឺ ០.៥%។

ថ្នាំរំងាប់មេរោគប្រភេទថ្មីមានប្រសិទ្ធភាពច្រើនថ្ងៃ បើទោះបីពេលរំងាប់មាននៅសល់សារធាតុសរីរាង្គខ្លះក៏ដោយ ហើយវាមានសុវត្ថិភាពសម្រាប់អ្នកប្រើ។




រូបភាពទី ១.៣៣ ការបាញ់ថ្នាំសម្លាប់មេរោគ

# ជំពូក២

# ផ្លូវចំលងរោគ

# ROUTE OF INFECTION

មេរោគបង្កជម្ងឺអាចប្រៀតចូលទៅក្នុងសព៌ាង្គកាយតាមផ្លូវ (Route) ជាច្រើនដូចជា:

**២.១- ស្បែក** (Skin) :

ស្បែកជាជាលិកាដ៏ធំ ដែលគ្របដប់ខ្លួនសត្វ ហើយជាកន្លែងស្នាក់នៅរបស់បាក់តេរីគ្រប់ប្រភេទ។ មាន បាក់តេរីមួយចំនួនរស់នៅជាអចិន្ត្រៃ។ ប៉ុន្តែស្បែកអាចការពារនូវរាល់ការប្រៀតចូលរបស់ពពួកបាក់តេរីទាំងនេះ ដោយ អាចការពារនូវរាល់ការប្រៀតចូលរបស់ពពួកបាក់តេរីទាំងនេះ៖ ដោយសារប្រព័ន្ធការពារមេការនិច (Epithelium) របស់ស្បែក ។

ការចំលងមេរោគមួយចំនួនធំប្រព្រឹត្តទៅតាមស្បែក។ នៅពេលស្បែកមានរបួស (Trauma) គឺប្រព័ន្ធការ ពារមេកានិចរបស់ស្បែកបានត្រូវបំផ្លាញមេរោគអាចជ្រៀតចូលទៅក្នុងសព៌ាង្គកាយបានយ៉ាងងាយ ដូចជាពពួក Staphylococcus, Streptococcus, Psedomonas, Corynebacterium, Leptospira, Clostridium និង ជាពិសេស Bacillus Anthracis ដែលអាចធ្វើសកម្មភាពរាតត្បាតក្នុងសព៌ាង្គកាយបានយ៉ាងឆាប់រហ័ស ។

ការចំលងតាមស្បែកដែលគ្មានរបួសអាចជាពពួក ប៉ារ៉ាស៊ីត (Parasitic Infestation) ដូចជាពពួកដង្កូវ Strongyl អាចជ្រៀតចូលតាមស្បែកគ្មានរបួស ។

ការខំ ទិច ជញ្ជក់ឈាម នៃពពួក រុយ (Flies) មូស (Mosquitoes) តុកកែ (Tick) មេកម (Mite) សង្កើច (Bug) ជាដើមហេតុនៃការចំលងរោគតាមស្បែក ដូចករណីជម្ងឺ Babesiosis ឆ្លងពីសត្វមួយទៅសត្វ មួយទៀត តាមរយៈការទិច ឬខាំរបស់ Vector ។

**២.២- ប្រដាប់រំលាយអាហារ** (Alimentary Tract/Digestive Tract) :

**២.២-១- មាត់** (Mouth): ដូចស្បែកដែរ គេបានឃើញមេរោគមួយចំនួន ដែលប្រៀតចូលទៅក្នុងកោ សិកាតាមមុខរបួសនៃសាច់ដុំមាត់ (Buccal Mucosa) ដែលបណ្ដាលពីការមុតអង្គធាតុរឹងដុំចំណីរង បណ្ដាល ឱ្យរលាក និង អាចបណ្ដាលពីការដុះមិនស្មើនៃធ្មេញ។ ធ្មេញមិនស្មើនេះ ធ្វើឱ្យមានរបួសក្នុងមាត់ពេលទំពៀអា ហារ -ករណីនេះ ផ្ដល់លទ្ធភាពងាយស្រួលដល់ការរាតត្បាត ពីសំណាក់មេរោគក្នុងមាត់ ។

**២.២.២-ពោះវៀន** (Intestine): អតិសុខុមប្រាណអាចបង្កជម្ងឺតាមមធ្យោបាយពីរ:

- ការលូតលាស់នៃមេរោគក្នុងពោះវៀន (Multiplication of intestinal bacteria)
- ការបង្កើតសារជាតុពុលរបស់មេរោគ (Toxin) ដែលបំផ្លាញភ្នាសសរសៃឈាម និង ប្រៀតចូលទៅក្នុងឈាម ពីពោះវៀន ។ ពួក Bacillus អាចប្រៀតចូល និងលូតលាស់ នៅក្នុងពោះវៀនបានយ៉ាងប្រសើរ ហើយបណ្ដាលឱ្យមានការរលាកនៅក្នុងពោះវៀន (Enteritis) រលាកភ្នាសសរ សឈាម (Inflammation of blold vessel) និង រលាកជាលិកាក្រពេញទឹករងៃ

(Lymphangitis) ។ មេរោគអាចរាតត្បាត ពេញសព៌ាង្គកាយ តាមរយៈឈាម (Septicemia) ។

**២.៣-ត្របកភ្នែក** (Conjunctiva)៖ បាក់តេរីមួយចំនួនដូចជា Brucella, Cryptococcus អាចចំ លងផ្ទាល់តាម ត្របកភ្នែកគ្មានរបួស ។

**២.៤ប្រដាប់ដង្ហើម** (Respiratory Tract): តាមរយៈការដកដង្ហើមចូល (Inhalation) មេរោគ ចូលទៅដល់ជាលិកាសួត ។ ដូច្នេះផ្លូវដង្ហើមជាច្រកសំខាន់នៃការចំលងរោគប្រសិនបើប្រព័ន្ធការពារមេកានិចនៃ ប្រព័ន្ធដង្ហើមចុះខ្សោយជាពិសេសចំពោះសត្វស្គមៗ។ ការចំលងជម្ងឺរបេង (Tuberculossis) និង ជម្ងឺឆ្លងផ្សេង ទៀត ជាពិសេសជម្ងឺបង្កដោយវីរុស --ការចំលងតាមប្រដាប់ ដង្ហើមកើតឡើងជាញឹកញាប់ ។

**២.៥-ប្រដាប់បន្តពូជ និងប្រព័ន្ធទឹកម៉ូត** (Genito-Urinary Tract)៖ ជម្ងឺ Brucellosis ជ្រូក ជម្ងឺ Trichomoniasis គោក្របី បានធ្វើការចំលងតាមរយៈការសេពមេថុន Coitus) ។ ការរលាកនៅស្បូន (Endometritis/ Metritis) និង ទ្វារបន្តពូជញី (Vaginitis) ពេលសត្វកើតកូនជាលក្ខខ័ណ្ឌអំណោយផល ដល់ការរាតត្បាតនៃមេរោគគ្រប់ប្រភេទ។

**២.៦ កន្សោមដោះ** (Mammary Gland)៖ ការចំលងភាគច្រើននៃករណីនេះបណ្តាលពីមានការ រលាកកន្សោមដោះ (Mastitis) ឬ ការចំលងប្រព្រឹត្តទៅតាមរយៈក្បាលដោះ (Teat) ។

**២.៧. របៀបចំលងរោគ (MODE OF INFECTION)**

ការចំលងរោគអាចប្រព្រឹត្តតាមច្រើនរបៀបដូចជា៖

**២.៧.១ *ការប៉ះផ្ទាល (Direct Contact) :***

**២.៧.២ ប្រដាប់បន្តពូជ** (Genital Tract): ជម្ងឺ Brucellosis និង Trichomoniasis ធ្វើ ការចំលង តាមរបៀបបំផ្ទាល់នៃប្រដាប់បន្តពូជសត្វញី និង ឈ្មោល ពេលបង្កាត់ពូជ ។ ឬអាចចំលង តាមប្រដាប់ប្រដារ ប្រើប្រាស់សំរាប់បង្កត់ពូជមិនស្អាត ។

**២.៧-៣ ស្បែក-ហ្វាសស្តើង** (Skin/Epithelium)៖ ការខិនៃសត្វឈឺជម្ងឺឆ្កួតចំលងទៅសត្វផ្សេង ទៀតតាមរយៈស្បែក ។ ជម្ងឺឈាមខ្មៅគោក្របី (Anthrax) អាចឆ្លងទៅមនុស្សតាមរយៈការប៉ះពាល់សាកសព សត្វស្លាប់ផ្ទាល់ ឬ ដោយប្រយោល តាមរយៈការប្រើប្រាស់សំភារៈធ្វើអំពីស្បែកសត្វស្លាប់ដោយជម្ងឺឈាម ខ្មៅ ដូចជាអ្នកស្បែកជើងខ្សែក្រវាត់ ក្រួយរោមសត្វ ។ល ។

**២.៧.៤ ឆ្លងតាមរបួស** (Wound Infection): ជម្ងឺតេតាណុស ដែលបង្កដោយ Clostridium Tetani ធ្វើការចំលងតាមការមុត ឬតាមរបួសផ្សេងៗ ។

**២.៧.៥ ឆ្លងតាមតំណក់** (Droplet Infection): នៅពេលសត្វឈឺក្អក ឬ ក្រដាសមេរោគចំលងបាន ត្រូវព្រួសចេញមកក្រៅទៅក្នុងខ្យល់ជាមួយទឹកសំបោរ ។ វាជាតំណក់មេរោគ ដែលមានសមត្ថភាពចំលងខ្ពស់ ។ តំណក់មេរោគនេះបានទៅប្រឡាក់ប្រឡូសនឹងចំណី ទឹក វាលស្មៅ ដែលសត្វផ្សេងទៀតលេបចូលទៅសព៌ាង្គ កាយ ហើយទទួលការចំលងរោគ ។ ភាគច្រើននៃការចំលងប្រភេទនេះ៖ មានចំពោះជម្ងឺរលាកស្រោមសួត (Pleuro-Pneumonia) និង សួត (Pneumonia) ជម្ងឺអុតក្តាម

(Foot and Mouth Disease) ជម្ងឺសារទឹកគោ ក្របី (Haemorrhagic Septicemia) ជម្ងឺរបេង (Tuberculosis) ជម្ងឺញៀវកាសបក្សី (Newcastle Disease) ជម្ងឺអាសន្នរោគបក្សី (Folw Cholera) ។ល ។

**២.៨ *ដោយមានពីកំណើត (Congenital Transmission)*** :

មេរោគអាចចំលងទៅអំប្រីយ៉ុងតាមផ្លូវពីរៈ

**២.៨.១ តាមអូវ៉េ** (Oval Route/Vertical Infection): ជំងឺរាគសបក្សី(Bacillary White Diarrhoea) ដែលបង្កដោយ Salmonella Pullorum --មេរោគធ្វើការចំលងពីកន្សោមពងមេ (Ovum) ទៅ ស៊ុត/ អំប្រីយ៉ុង និងតាមរយៈទឹកកាម នៃសត្វឈ្មោលទៅក្នុងបំពង់អូវ (Oviduct) ។

**២.៨.២-តាមទងសុខ** (Placenta): មេរោគចំលងតាមរយៈឈមមេតាមទងសុខចំលងទៅអំយ៉ុង ។ មរោគកាចសាហាវមួយចំនួនធំ ដូចជា Brucella, Bacillus Anthracis និង វីរុសជម្ងឺប៉េស្តជ្រូក (Swine Fever) អាចចំលងតាមទងសុក ទោះបីវាជារបាំងការពារយ៉ាងរឹងមាំក៏ដោយ ។

**២.៩ ដោយប្រយោល (Indirect Contact) :**

**២.៩.១.ពាមរយៈទឹក និងចំណី**: ចំណីអាហារ និងទឹកកខ្វក់ជាប្រភពនៃមេរោគបង្កជម្ងឺ។ ជម្ងឺ បើស្តគោ-ក្របី (Rinderpest) សារទឹក (HS) របេង (IB) របេងពោះវៀន (Paratuberculosis) ជម្ងឺដង្កូវថ្លើម (Fasciosis) ជាដើមធ្វើការចំលងតាមរយៈទឹក ចំណីអាហារ ។

**២.៩.២.តាមរយៈទឹកដោះ**: ជម្ងឺរបេង និង អុតក្តាម មេរោគមានក្នុងទឹកដោះសត្វឈឺ ។ សត្វផឹកទឹក ដោះសត្វឈឺបណ្តាលឱ្យមានការឆ្លងជម្ងឺ ជម្ងឺរបេងគោក្របីបានចំលងទៅមនុស្សភាគច្រើន តាមរយៈការផឹក ទឹកដោះសត្វឈឺ ។

**២.៩.៣.តាមរយៈសំភារៈប្រើប្រាស់** : សំភារៈប្រើប្រាស់ដែលពុំបានធ្វើការសំលាប់មេរោគល្អក្លាយ ជាប្រភពចំលង ។ តាមរយៈការធ្វើពេគវិនិច្ឆ័យការព្យាបាលមេរោគអាចចំលងទៅសត្វមួយទៀតបានយ៉ាង ងាយ ដូចជាតាមម្ជុលចាក់ថ្នាំ (Needle) កាំបិទវកាត់ ស្រោមដៃ ។ល ។

# ជំពូក៣
# ចំណាត់ថ្នាក់នៃជម្ងឺ
CLASSIFICATION OF DISEASE

មានការចែកថ្នាក់ជម្ងឺតាមរបៀបផ្សេងៗពីគ្នា ប៉ុន្តែជាទទូទៅការចែកថ្នាក់នេះ បានត្រូវគេធ្វើឡើងដោយ ផ្អែកលើ គោលការណ៏ដូចខាងក្រោមៈ

ជម្ងឺបានត្រូវចែកជាប្រភេទជម្ងឺទាក់ទងទៅនឹង :

## ៣.១ ជំងឺប៉េស្តជ្រូក CSF

### ៣.១. ១ មូលហេតុ

-ជំងឺប៉េស្តជ្រូកបង្កដោយវីរុសមិនអាចព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិកបានទេ

-វីរុសនេះរាតត្បាតតែលើជ្រូក

- យើងអាចឃើញវីរុសនេះសន្ទឹកសន្ទាប់ក្នុងអាមីដាល់ ដែលបង្ហាញថាការចម្លងរបស់ជំងឺនេះវីរុសបានបញ្ចេញតាមមាត់ ប្រមុះ និងភ្នែក។




រូបភាពទី ៣.១ អាមីដាល់ដែលបញ្ចេញតាមមាត់

ពេលបច្ចុប្បន្ននេះករណីជំងឺប៉េស្តជ្រូកស្ថិតនៅក្រោមការធ្វើរោគវិនិច្ឆយ័ព្រោះក្នុងពេលប៉ុន្មានឆ្នាំនេះជំងឺត្រចៀកខៀវ PRRS ត្រូវបានផ្សព្វផ្សាយខ្លាំងក្លា។ រោគសញ្ញាអាចដូចគ្នាជាមួយវិធីសាស្ត្រលឿន ប៉ុន្តែការធ្វើអង្កេតឲ្យបានល្អនិងការត្រួតពិនិត្យគ្លីនិកដោយសង្កេតលើស្លាកស្លាមលើផ្ទាំងសាច់នឹងជួយឲ្យការធ្វើរោគវិនិច្ឆ័យបានល្អ។ ម្យ៉ាងវិញទៀតករណីការបង្កជំងឺខ្លាំងក្លារបស់ជំងឺ ត្រចៀកខៀវជាការពិតវាមានការរួមបញ្ចូលរវាងជំងឺប៉េស្តជ្រូក និងជំងឺត្រចៀកខៀវ។

### ៣.១.២. លទ្ធភាពបង្កជំងឺ (វីរុឡង់) Virulence

វាគឺជាល្បឿនរបស់វីរុសបំបែកខ្លួន ពេលដែលចម្លងចូលក្នុងជ្រូក ជាការបំបែកខ្លួនរបស់វីរុសអាចផ្លាស់ប្តូរពីលឿនខ្លាំងទៅជាយឺត។ ក្នុងកសិដ្ឋានជំងឺនឹងផ្លាស់ប្តូរពីស្រួចស្រាវ(ជ្រូកនឹងងាប់យ៉ាងលឿន) ទៅជាមិនសូវស្រួចស្រាវដែលជារឿយៗជ្រូកមិនងាប់ ប៉ុន្តែវាចុះខ្សោយ និងធំលូតលាស់យឺត។

### ៣.១.៣ ការចម្លងជំងឺ

- ជ្រូកអាចឆ្លងតាមរយៈការប៉ះពាល់ពីមាត់ ទៅមាត់ជាមួយជ្រូកឈឺ

-តាមរយៈទឹកកាមពេលបង្កាត់ជាមួយជ្រូកឈឺ

- ចម្លងក្នុងសុកទៅគភ៌ (Fetuses) មេជ្រូកអាចចម្លងទៅគភ៌ក្នុងពេលផើម

- ពេលផ្តល់ចំណីឲ្យជ្រូក ដោយប្រើកាកសំណល់ដែលមានសាច់ចំអិនមិនបានត្រឹមត្រូវល្អ ឬសរីរាង្គរបស់ជ្រូកឈឺ។

- តាមរយៈមនុស្សនិងសម្ភារៈដូចជាកសិករ ភ្នាក់ងារសុខភាពសត្វភូមិ និងបសុពេទ្យ ដែលទស្សនៈកិច្ចកសិដ្ឋាន បន្ទាប់ពីបានប៉ះពាល់ជ្រូកឈឺដែលវីរុសតោងជាប់លើស្បែកជើង និងសម្លៀក បំពាក់និងអាចសាយភាពជំងឺប៉េស្តជ្រូក។







រូបភាពទី ៣.២ ការប៉ះពាល់ជ្រូកឈឺ




រូបភាពទី ៣.៣ ជ្រូកបាដែលបង្ក

## ៣.១.៤. រោគសញ្ញា

-ជាទូទៅសញ្ញាគ្លីនិកលេចឡើងរយះពេលពី៥ទៅ១០ថ្ងៃ បន្ទាប់ពីការចម្លងជំងឺ

-សញ្ញាជាអចិន្ត្រៃយ៍មួយគឺសីតុណ្ហភាពលើសពី៤១អង្សាសេ និងថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពបញ្ចុះគ្រុនក្តៅបានទេ

-ជ្រូកអាចបញ្ចេញវីរុសមុនពេលបង្ហាញរោគសញ្ញាមានន័យថាវាអាចសាយភាយជំងឺពេលដែលវាមើលទៅមានសុខភាពល្អ។

ក្តៅខ្លាំងនិងគ្រុនយូរត្រូវតែគិតដល់ជំងឺប៉េស្ត



រូបភាពទី ៣.៤ ការវាស់កម្តៅជ្រូក

ជំងឺស្រួចស្រាវ

ច្រើនឃើញចំពោះជ្រូកសាច់ទម្ងន់ពី៣០ទៅ៦០គីឡូក្រាម

- គ្រុនក្ដៅខ្លាំង

- អស់កម្លាំង និងចុះខ្សោយ

- ឈឺភ្នែកឡើងក្រហម

- ទ្រេតទ្រោតពេលដើរ

- ចេញពណ៌ស្វាយលើស្បែក

- ការរាតត្បាតផ្សេងទៀតអាចកើតមានដូចជារាគពណ៌បៃតង (សាល់ម៉ូណែឡា) និងរោគសញ្ញាផ្លូវដង្ហើម

អត្រាងាប់ខ្ពស់ក្នុងរយៈពេល១ទៅ២អាទិត្យ បន្ទាប់ពីចេញរោគសញ្ញាដំបូង។




រូបភាពទី ៣.៥ រោគសញ្ញាស្រួចស្រាវលេចលើខ្លួនសត្វ

❖ ជំងឺមិនសូវស្រួចស្រាវ

វាកើតឡើងពេលដែលប្រភេទមេរោគមានអនុភាពខ្សោយ ឬពេលដែលជ្រូក បានចាក់ថ្នាំការពារ ជាមួយវ៉ាក់សាំងមានគុណភាពមិនប្រាកដប្រជា ឬពេលដែលប្រពន្ធ័ត្រជាក់ខូច។ មូលហេតុមួយទៀតអាចជាកម្មវិធីចាក់វ៉ាក់សាំងមិនបានគ្រប់គ្រាន់ ឬខុសបច្ចេកទេសក្នុងការចាក់ជ្រូក (ចាក់នៅក្នុងខ្លាញ់ ហើយមិនចាក់នៅក្នុងសាច់ដុំ)

- គ្រុនក្ដៅអាចជាសញ្ញាតែមួយ ប៉ុន្តែក្ដៅឡើងខ្ពស់ដែលមិនអាចបញ្ចុះកំដៅដោយ

- ថ្នាំអង់ទីប៊ីយ៉ូទិកបានទេ ដូច្នេះត្រូវគិតដល់ជំងឺប៉េស្តជ្រូក

- មានចំណុចតូចៗដែលបែកគ្រាប់ឈាមក្រោមស្បែក

- ជ្រូកប្រមូលផ្ដុំគ្នានិងមិនស្វាហាប់ហើយស៊ីតិច

ជារឿយៗមានការរាតត្បាតដោយជំងឺឱកាសនិយម ដែលបង្កដោយបាក់តេរីបណ្ដាលឲ្យទៅជាជំងឺធ្ងន់ធ្ងរដូចជាជំងឺសាល់ម៉ូណែឡា សារទឹក (Pasteurella)ដែលច្រើនវិវត្តលើជ្រូកទាំងនេះ និងបង្កជារាគបៃតង និងឬមានក្អកធ្ងន់ធ្ងរហើយទស្វះដង្ហើម។




រូបភាពទី ៣.៦ រោគសញ្ញាមិនស្រួចស្រាវលេញលើខ្លួនសត្វ

- ❖ រោគសញ្ញាចំពោះមេជ្រូក
- ❖ កូនកើតមកងាប់
- ❖ កូនងាប់ក្នុងពោះឡើងក្រៀម
- ❖ រលូត
  កូនជ្រូកកើតមកតូចៗនិងខ្សោយ




រូបភាពទី ៣.៧ កូនជ្រូកមិនប៉ុនគ្នា និងខ្សោយ

រោគសញ្ញាទាំងនេះដូចគ្នានឹងករណី ដែលគេសង្កេតឃើញលើជំងឺត្រចៀកខៀវ ប៉ុន្តែរោគសញ្ញា

ពិសេសមួយគឺកូនជ្រូកដែលទើបនឹងកើតញាក់ញ័របន្ទាប់ពីកើតវាជាសញ្ញាយ៉ាងច្បាស់ពីអនុភាពខ្សោយរបស់វីរុស ដែលមានក្នុងកសិដ្ឋាន ឬការធ្វើវ៉ាក់សាំងមិនបានគ្រប់គ្រាន់។

1.5 ស្លាកស្នាម

រោគសញ្ញាពេលខ្លះមិនសូវច្បាស់ លើកលែងតែសីតុណ្ហភាពឡើងខ្ពស់ ដែលមិនអាចបញ្ចុះកំដៅដោយប្រើថ្នាំអង់ទីប៊ីយ៉ូទិក ប៉ុន្តែស្លាកស្នាមជាក់លាក់ អាចមើលឃើញលើសាកសព។ សញ្ញាជាទូទៅដែលសង្កេតឃើញបំផុតគឺ

- មានពណ៌ក្រហមចាស់នៅលើគែមផាល
- ស្នាមក្រហមអុចៗលើសួត
- ហូរឈាម )បែកគ្រាប់ឈាម( ក្នុងក្រពេញទឹករងៃ




រូបភាពទី ៣.៨ ស្លាកស្នាមបង្កលើ ផាល ថ្លើម និងសួត

### ៣.១.៥ ការព្យាបាល

ជំងឺបង្កដោយវីរុស ដូច្នេះមិនមានថ្នាំព្យាបាលទេពេលដែលការធ្វើរោគវិនិច្ឆ័យជំងឺប៉េស្តជ្រូកបានបញ្ជាក់ច្បាស់លាស់ហើយ មិនត្រូវធ្វើការព្យាបាលទេ ពីព្រោះក្រោយ១០ថ្ងៃនៃការចាក់ថ្នាំអង់ទីប៊ីយ៉ូទិក ជ្រូកអាចនៅរស់ ប៉ុន្តែវាធំលូតលាស់យឺតខ្លាំង ដែលទីបំផុតគឺជាការខាតបង់ប្រាក់។

សម្រាប់មេជ្រូកក្រមុំ ជ្រូកបាក្មេង ឬមេជ្រូក មានមូលដ្ឋានសម្រាប់ការព្យាបាលគឺ៖

-បញ្ចុះកំដៅដើម្បីជួយឲ្យសត្វស៊ីចំណី ត្រូវចាក់ថ្នាំប៉ារ៉ាសេតាម៉ុល Paracetamol

-ការពារជ្រូកកុំឲ្យមានការរាតត្បាតជំងឺឪកាសនិយម ដោយចាក់ថ្នាំផ្លរ័ហ្វេនីកុល Florfenicol ថ្នាំដុកស៊ីស៊ីគ្លីនDoxycycline ក្នុងករណីមានរាគដូចទឹកពណ៌បៃតង។ ចាក់ថ្នាំទីឡូស៊ីនTylosine

ជាមួយថ្នាំហ្សង់តាមីស៊ីនGentamycine ឬមធ្យោបាយចុងក្រោយគឺចាក់ថ្នាំអង់រ៉ូហ្លុកសាក់ស៊ីន Enrofloxacin។

-ជម្រុញបង្កើនភាពស៊ាំតបនឹងជំងឺ និងឲ្យធាប់ជាសះស្បើយ ត្រូវចាក់វីតាមីននិងថ្នាំកម្លាំង (Stimulant)។

### ៣.១ .៦.ការការពារ

ចំណុចសំខាន់ត្រូវការពារជំងឺប៉េស្តជ្រូក ដោយការចាក់វ៉ាក់សាំងឲ្យបានត្រឹមត្រូវ។ ការចាក់វ៉ាក់សាំងមានសារៈសំខាន់បំផុតទោះបីជាក្នុងចំនួនសត្វតិចក៏ដោយ។ វាមិនអាចទៅរួចចំពោះកសិដ្ឋានចិញ្ចឹមជ្រូកតូចឬធំទទួលបានជោគជ័យ ដោយមិនអនុវត្តកម្មវិធីចាក់វ៉ាក់សាំងជំងឺប៉េស្តជ្រូកឲ្យបានត្រឹមត្រូវនោះទេ។ ត្រូវជ្រើសរើសវ៉ាក់សាំងដែលមានគុណភាពទទួលស្គាល់ពីរោងចក្រល្បីដូចជា សេវ៉ា (Ceva) អាំងទែវេត (Intervet) ឬហ៊ីប្រា (Hipra)។

កម្មវិធីចាក់វ៉ាក់សាំងអាចមានដូចជា៖

-កូនជ្រូកចាក់នៅពេលមានអាយុ ៣ទៅ៧ និង១១អាទិត្យ ចំពោះការចាក់វ៉ាក់សាំងនៅ៣អាទិត្យមានសារៈសំខាន់តែចំពោះមេជ្រូកមិនបានចាក់ទៀងទាត់តែបើមេជ្រូកចាក់បានទៀងទាត់ ជាពិសេសមួយខែមុនពេលកើតកូននោះទឹកដោះដំបូង(Colostrum) និងទឹកដោះនឹងមានអង្គការពារប្រឆាំងនឹងជំងឺប៉េស្តជ្រូក ហើយនឹងជួយការពារកូនជ្រូករហូតដល់៧អាទិត្យ

- មេជ្រូកត្រូវចាក់វ៉ាក់សាំងនៅពេលមួយខែមុនពេលកើតកូនដើម្បីបង្កើនអង្គការពារនៅក្នុងទឹកដោះ

- មេក្រមុំត្រូវចាក់វ៉ាក់សាំងឡើងវិញនៅ៦ខែ (ប្រសិនបើមេក្រមុំទិញមកពីខាងក្រៅ ដែលមិនប្រាកដថាមានកម្មវិធីចាក់វ៉ាក់សាំងត្រឹមត្រូវ ពេលពួកវានៅតូច ដូចនេះចាំបាច់ត្រូវចាក់វ៉ាក់សាំងប៉េស្តជ្រូកលើកទីពីរនៅ៧ខែ)

- ជ្រូកបាត្រូវចាក់វ៉ាក់សាំងរៀងរាល់៦ខែ

## ៣.២. ជំងឺអុតក្ដាម FMD

### មូលហេតុ

-ជំងឺអុតក្ដាមបង្កដោយវីរុស ដូច្នេះថ្នាំអង់ទីប៊ីយ៉ូទិកមិនអាចព្យាបាលជំងឺនេះបានទេ

-មានប្រភេទវីរុសនេះចំនួន៧កំពុងមានក្នុងពិភពលោកយើងនេះ។ ក្នុងប្រទេសកម្ពុជាមានប្រភេទគឺអូ អា និងអេស៊ី១ (O, A, Asia1 )ត្រូវបានគេរកឃើញ។

.ការចម្លងជំងឺ

-វីរុសមានភាពធន់នឹងបរិយាកាស និងអាចផ្លាស់ទីដោយសារខ្យល់

-ការចម្លងចម្បងកើតមានតាមខ្យល់ដកដង្ហើមមានន័យថាដំណក់តូចៗចេញជាមួយខ្យល់តាមច្រមុះ ហើយផ្ទុកវីរុស នេះជាផ្លូវសំខាន់សម្រាប់ការសាយភាយជំងឺពីជ្រូកឈឺទៅជ្រូកជា។

-មនុស្សអាចនាំវីរុសលើស្បែកជើង សំលៀកបំពាក់ ដៃ សក់ វីរុសជំងឺអុតក្ដាមអាចរស់បាន១ទៅ២ថ្ងៃក្នុងបំពង់ដកដង្ហើមរបស់មនុស្ស ដូច្នេះក៏ចម្លងទៅសត្វ

ជំងឺអុតក្ដាមលើជ្រូកឆ្លងរាលដាលខ្លាំង និងមានការលំបាកខ្លាំង ក្នុងការការពារកសិដ្ឋានកុំឲ្យមានការចម្លងជំងឺ ប៉ុន្តែជ្រូកបញ្ចេញវីរុសក្នុងរយៈពេលខ្លី វាមិនមែនជាអ្នកផ្ទុកជំងឺនេះរយៈពេលយូរទេ។ ការផ្ទុះជំងឺអុតក្ដាមរាលដាលលឿនប៉ុន្តែកើតមានរយៈពេលពីរ បីអាទិត្យ។

### ៣.២.១ រោគសញ្ញា

-ជាទូទៅជ្រូកនឹងបង្កើតរោគសញ្ញាក្នុងរយៈពេល៣ទៅ៥ថ្ងៃ បន្ទាប់ពីប៉ះពាល់ជាមួយសត្វឈឺ។

-គ្រុនក្ដៅ និង ពងដោរលើជើង មាត់ និងដោះជាស្លាកស្នាមសំគាល់របស់ជំងឺអុតក្ដាម

-ជ្រូកមានដំបៅធ្ងន់ធ្ងរលើក្រចកជើងនិងពងដោរលេចធ្មេញជើង វាមិនអាចដើរ និងស៊ីបានទេ វាមានការឈឺចាប់ខ្លាំងពួកវាស្រែកទាំងយប់ទាំងថ្ងៃ

-ពងដោរច្រើនសង្កេតឃើញនៅលើច្រមុះ



រូបភាពទី ៣.៩ រោគសញ្ញាជំងឺអ៊ុតក្ដាម

### ៣.២.២ ការព្យាបាល

ការព្យាបាលអាចធ្វើ ដើម្បីការពារការចម្លងជំងឺឪកាសនិយម ចំពោះដំបៅជើង និងកាត់បន្ថយការឈឺចាប់តែប៉ុណ្ណោះ។

- ចាក់ថ្នាំប៉ារ៉ាសេតាម៉ុល( Paracetamol )អាចកាត់បន្ថយការរលាក ការឈឺចាប់និងគ្រុនក្ដៅ

- ចាក់ថ្នាំទ្រីមេតូព្រីម( TMP+Sulfa )ជាមួយស៊ុលហ្វា ឬថ្នាំតេត្រាស៊ីគ្លីន( Tetracycline )អាចការពារប្រឆាំងនឹងការចម្លងរបស់បាក់តេរីលើជើង




រូបភាពទី ៣.១០ ពីរសប្ដាហ៍បន្ទាប់ពីព្យាបាល

- ការព្យាបាលដោយកន្លែងអាចអនុវត្តទៅបានបន្ទាប់ពីលាងដំបៅលើជើងជាមួយសាប៊ូថ្នាំរម្ងាប់មេរោគខាងក្រៅ ដែលផ្សំដោយថ្នាំពណ៌ស្វាយ ( Methylen blue ) ឬ សង់ទីយ៉ានវីយ៉ូលេ( Gentiane violet ) ជាមួយថ្នាំតេត្រាស៊ីគ្លីន( Tetracycline )ដោយបាញ់ពីលើដំបៅពីរដងក្នុងមួយថ្ងៃ។ ជ្រូកឈឺមិនអាចដើរព្រោះឈឺចាប់ ចាំបាច់ត្រូវជានាឲ្យជ្រូកនិមួយៗផឹកទឹក និងចំណីគ្រប់គ្រាន់។

### ៣.២.៣ ការការពារ

- មានវ៉ាក់សាំងពីរប្រភេទគឺ៖ វ៉ាក់សាំងវ៉ាឡង់មួយ ( monovalent ) គឺជាវ៉ាក់សាំងដែលអាចប្រឆាំងប្រភេទអូ (ដែលកើតមានជាទូទៅលើជ្រូកក្នុងប្រទេសកម្ពុជា ) និងវ៉ាក់សាំងវ៉ាឡង់បីប្រឆាំងនឹងប្រភេទអូ អា និងអាស៊ី១។

- ការចាក់វ៉ាក់សាំងមានប្រសិទ្ធភាពចំពោះជ្រូក លុះត្រាតែវាបានចាក់វ៉ាក់សាំងទៀងទាត់។ សត្វគោក្របីអាចការពារខ្លួនវាបាន នៅពីរទៅបីថ្ងៃបន្ទាប់ពីចាក់វ៉ាក់សាំងអុតក្តាម។ ប៉ុន្តែជ្រូកមិនបានបង្ហាញភាពស៊ាំឆ្លើយតបនឹងជំងឺខ្លាំងនោះទេ។

-ត្រូវចាក់វ៉ាក់សាំងអុតក្តាមប្រភេទវ៉ាឡង់បី(Trivalent)ឲ្យមេជ្រូកពីរដងក្នុងមួយឆ្នាំនិងចាក់រំលឹកក្នុងករណីមានផ្ទុះជំងឺនៅក្នុងខេត្ត។

-កូនជ្រូក និងជ្រូកដែលកំពុងលូតលាស់អាចចាក់វ៉ាក់សាំងវ៉ាឡង់មួយ(Monovalent) ប៉ុន្តែវាជារឿយៗបង្ហាញសញ្ញាជំងឺអុតក្តាម។

## ៣.៣ ជំងឺត្រចៀកខៀវ PRRS

### ៣.៣.១ មូលហេតុ

វីរុសវាយលុកនិងបំផ្លាញម៉ាក្រូហ្វា(Macrophages)ដែលទទួលខុសត្រូវក្នុងការចាប់ និងបំផ្លាញមេរោគ(Microbe)ដែលចូលក្នុងរាងកាយ ជាពិសេសតាមសួត។ ការវិវត្តរបស់ជំងឺមានការពាក់ព័ន្ធយ៉ាងជិតស្និតនឹងការចម្លងជំងឺឱកាសនិយមបង្កដោយបាក់តេរី និងមុខងាររបស់វីរុសដ៏ទៃទៀតដូចជាជំងឺប៉េស្តជ្រូក។

### ៣.៣.២. ការចម្លងជំងឺ

- ទឹកមាត់ លាមក ទឹកនោម ទឹកដោះដំបូងរបស់សត្វឈឺ សាយភាយវីរុស
- មនុស្សជាមួយស្បែកជើង សម្លៀកបំពាក់ និងដៃអាចពាំនាំវីរុស
- ម្ជុលប្រើសម្រាប់ចាក់ថ្នាំអាចចម្លងទៅជ្រូក
- ទឹកកាមរបស់ជ្រូកបាអាចចម្លងវីរុស
- ទាត្រូវបានគេសង្ស័យជាវិចទរ័របស់ជំងឺ

### ៣.៣.៣ រោគសញ្ញា

រោគសញ្ញាប្រែប្រួលអាស្រ័យនឹងអនាមយ័ និងស្ថានភាពសុខភាពរបស់ជ្រូក។ ប្រភេទខ្លះត្រូវគេហៅថា"ភ្នាក់ងារចម្លងជំងឺកម្រិតខ្ពស់Highly Pathogenic"និងបង្កជាជំងឺធ្ងន់ធ្ងរដែលមានអត្រាងាប់ខ្ពស់។

❖ មេជ្រូក

នៅប្រទេសកម្ពុជារោគសញ្ញាលើមេជ្រូកគឺជាសញ្ញាជំងឺដែលមានសភាពជាក់លាក់និងច្បាស់លាស់

- មេជ្រូកមួយចំនួនឈប់ស៊ីចំណី។ ការមិនឃ្លានចំណី )anorexia )នេះនឹងមានរយៈពេលពី៧ទៅ១០ថ្ងៃ
- សីតុណ្ហភាពខ្ពស់ ៤០អង្សាសេ ចំ )ពោះប៉េស្តជ្រូកសីតុណ្ហភាពលើសពី៤១អង្សាសេ
- មានមេជ្រូកជាច្រើនរលូតកូន
- ការកើតកូនមានរយៈពេល១០៨ទៅ១១១ថ្ងៃ
- ពេលកើត កូនជ្រូកខ្សោយ និងយើងអាចឃើញកូនជ្រូកងាប់ក្រៀមជាច្រើន
- អត្រាងាប់ពេលកើតកូនខ្ពស់ និងយើងអាចឃើញមេជ្រូកជាច្រើនមានកូនតែ២ ៣ ឬ ៤តែប៉ុណ្ណោះ
- កូនជ្រូកបៅដោះភាគច្រើនរាគ ដែលមានការលំបាកក្នុងការបញ្ឈប់វាណាស់
- មេជ្រូកខ្លះងាប់

-មេជ្រូកខ្លះបង្ហាញពណ៌ខៀវលើត្រចៀក ដូចនេះហើយបានជាគេហៅវាថា"ជំងឺត្រចៀកខៀវ" តាមពិតទៅវាជាការកម្រ និងយើងមិនអាចធ្វើរោគវិនិច្ឆ័យជាមួយនឹងសញ្ញានេះបានទេ។




រូបភាពទី ៣.១១ រោគសញ្ញាជំងឺត្រចៀកខៀវ

❖ កូនជ្រូកក្រោយពេលផ្ដាច់ដោះ

-វីរុសជំងឺត្រចៀកខៀវបំផ្លាញម៉ាក្រូហ្វាសួតនិងកូនជ្រូកផ្ដាច់ដោះមិនត្រូវបានការពារដោយអង្គការពាររបស់មេទៀតទេ។

- ក្អកខ្លាំង និងពិបាកដកដង្ហើម

-ចុះស្គម រោមស្រអាប់ រលាកស្បែកចេញទឹក (exudative dermatitis)

-អត្រាងាប់មានកម្រិត ពេលដែលកូនជ្រូកបានព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក ដើម្បីកម្រិត

-ឥទ្ធិពលរបស់ការចម្លងជំងឺឱកាសនិយម។ ប៉ុន្តែវានឹងធំលូតលាស់យឺតរួមជាមួយបញ្ហាសុខភាព

-ជាច្រើនក្នុងដំណាក់កាលបំប៉ន។

❖ ការលូតលាស់ និងជ្រូកសាច់

- គ្រុនក្តៅ និងក្អក ជាពិសេសក្នុងកសិដ្ឋាន ដែលមានបញ្ហាជំងឺមីកូប្លាស្មា
- ហើមភ្នែកនឹងមានហូរទឹកភ្នែក
- ស្បែកឡើងក្រហមដូចជាដេកសំដិលក្រោមពន្លឺព្រះអាទិត្យ
- ស៊ីចំណីថយចុះ និងស្រកទម្ងន់




រូបភាពទី ៣.១២ រោគសញ្ញាកូនជ្រូកកើតជំងឺត្រចៀកខៀវ

### ៣.៣.៤ការវិវត្តរបស់ជំងឺ

-មេជ្រូកនិងជ្រូកបាបញ្ចេញវីរុសជំងឺត្រចៀកខៀវ ក្នុងកំឡុងពេលពីរអាទិត្យប៉ុណ្ណោះ ប៉ុន្តែជ្រូកសាច់បញ្ចេញវីរុសជាមធ្យម២ខែ

-កូនក្នុងពោះ(Fetus)ឆ្លងជំងឺ កំឡុងពេលផើម (ជាពិសេសប្រសិនបើមេជ្រូកចាប់ឈឺបន្ទាប់ពី ៧៥ថ្ងៃនៃពេលផើម) ប្រសិនបើពួកវានៅរស់រាន វានឹងបញ្ចេញវីរុសក្នុងកំឡុងពេល៥ខែ។ កូនជ្រូកទាំង

នេះនឹងខ្សោយពេលកើត ជាអនុសាសន៍គេត្រូវយកវាចេញ (ត្រូវប្រុងបយ័ត្នពេលទិញកូនជ្រូក ដែលមិនដឹងប្រភពច្បាស់លាស់!)

-កូនជ្រូកនៅក្រោយពេលផ្តាច់ដោះរក្សាការចម្លងក្នុងកសិដ្ឋាន ភាពស៊ាំរបស់វាទាបព្រោះវាមិនបានការពារដោយអង្គការពារពីម្តាយទៀតទេ។ វាត្រូវចម្លងដោយជ្រូកសាច់ដែលបញ្ចេញវីរុសរយៈពេលពីរខែ ដោយគ្មានរោគសញ្ញា។ វីរុសបំបែកខ្លួនយ៉ាងច្រើនលើកូនជ្រូកក្រោយពេលផ្តាច់ដោះដែលខ្សោយទាំងនេះ។

### ៣.៣៥. ការធ្វើរោគវិនិច្ឆ័យ

មន្ទីរពិសោធន៍របស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលអាចបញ្ជាក់ពីជំងឺនេះជាមួយនឹងការវិភាគជាក់លាក់ការវិភាគមិនជាធាប់ដឹងនោះទេ វាចាំបាច់ត្រូវយកឈាមពីជ្រូកយ៉ាងតិច១២ក្បាលដើម្បីប្រាកដថាវាវិជ្ជមាន ឬអវិជ្ជមាន។ ការវិភាគមិនអាចធ្វើការញែកឲ្យខុសគ្នារវាងជ្រូក ដែលកើតជំងឺត្រចៀកខៀវ និងជ្រូកដែលបានចាក់វ៉ាក់សាំងនឹងជំងឺត្រចៀកខៀវនេះទេ។

### ៣.៣ការព្យាបាល.៦.

ជំងឺបង្កដោយវីរុស ដូចនេះវាមិនមានការព្យាបាលទេ ប៉ុន្តែការប្រើប្រាស់ថ្នាំបានត្រឹមត្រូវ អាចជួយកាត់បន្ថយឥទ្ធិពលយ៉ាងខ្លាំងរបស់ជំងឺ

-ជ្រូកបំបៅដោះ ត្រូវចាក់ថ្នាំតេត្រាស៊ីគ្លីន(Tetracycline)ដែលមានសកម្មភាពវែងនៅ២ថ្ងៃមុនពេលកើតកូន។ នៅថ្ងៃកើតកូន និងក្រោយមកទៀតត្រូវលាយថ្នាំដុកស៊ីស៊ីគ្លីន(Doxycycline)ក្នុងចំណីរយៈពេលមួយខែ។

- មេជ្រូកធើម ត្រូវលាយថ្នាំដុកស៊ីស៊ីគ្លីន(Doxycycline)ក្នុងចំណីរយៈពេល៦អាទិត្យសម្រាប់ជ្រូកធើម

ទាំងអស់ ប្រសិនបើជ្រូកខ្លះមិនស៊ី ត្រូវចាក់ថ្នាំតេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង។

-កូនជ្រូកនៅពេលផ្តាច់ដោះ ត្រូវលាយថ្នាំផ្លរ៉ហ្វេនីកុល(Florfenicol)ក្នុងចំណីគ្រាប់ នៅមួយអាទិត្យ មុនពេលផ្តាច់ដោះ និងបន្តពីរអាទិត្យទៀតបន្ទាប់ពីផ្តាច់ដោះ។

-កូនជ្រូកក្រោយពេលផ្តាច់ដោះ និងជ្រូកសាច់ ត្រូវព្យាបាលអាស្រ័យលើរោគសញ្ញា។ ប្រើថ្នាំអង់ទីប៊ីយ៉ូទិកប្រឆាំងនឹងជំងឺផ្លូវដង្ហើម និងប្រឆាំងគ្រុនក្តៅ។

### ៣.៣.៧. ការការពារ

-ជីវសុវត្ថិភាពគឺជាបញ្ហាសំខាន់បំផុត ច្បាប់របស់វាជាមូលដ្ឋានមាន៖

-ត្រូវកម្រិតការទស្សនាក្នុងកសិដ្ឋាន ជាពិសេសប្រុងប្រយត្ន័ចំពោះពេទ្យសត្វ កសិករដទៃទៀត

-គ្មាននរណាម្នាក់អាចចូលមើលកសិដ្ឋាន ដោយមិនបានផ្លាស់ប្តូរសម្លៀកបំពាក់ ស្បែកជើង និងលាងដៃទេ

-មិនត្រូវទិញកូនជ្រូកក្រោយពេលផ្តាច់ដោះ ពីកន្លែងដែលមិនស្គាល់ប្រភពច្បាស់លាស់នោះទេ

-ប្រើប្រាស់ម្ជុលផ្សេង និងស្អាត សម្រាប់ចាក់ឲ្យជ្រូកក្រុមផ្សេងគ្នាក្នុងកសិដ្ឋាន

-ការធ្វើវ៉ាក់សាំង

-វីរុសជំងឺត្រចៀកខៀវប្រែក្លាយ(អាចផ្លាស់ប្តូរ)យ៉ាងស្រួល ពួកវាមានប្រភេទវីរុសផ្សេងៗគ្នាច្រើន

-ក្នុងពេលផ្ទុះជំងឺត្រចៀកខៀវបង្កឲ្យមានអត្រាងាប់ វ៉ាក់សាំងមិនអាចប្រើ ដើម្បីត្រួតពិនិត្យការផ្ទុះជំងឺបានទេ

-វ៉ាក់សាំងជាប្រភេទវ៉ាក់សាំងរស់ដែលកែប្រែរួច វាមានន័យថាការចាក់វ៉ាក់សាំងគឺបញ្ចូលវីរុសនៅក្នុងកសិដ្ឋាន ហើយវីរុសអាចសាយភាយពីជ្រូកទៅជ្រូក និងផ្លាស់ប្តូររូបរាង

-វ៉ាក់សាំងជំងឺត្រចៀកខៀវអាចប្រើបានតែនៅក្នុងកសិដ្ឋាន ដែលបានឆ្លងមេរោគរួច ដើម្បីជម្រុញការជួយសង្គ្រោះកូនជ្រូកទើបកើត និងជម្រុញទិន្នផលបន្តពូជ។វ៉ាក់សាំងមិនអាចប្រើ ដើម្បីត្រួតពិនិត្យការផ្ទុះជំងឺស្រួចស្រាវបានទេ។

## ៣.៤ ជំងឺផ្លូវដង្ហើម

### ៣.៤ .១. ក្អកអូសបន្លាយពេល

- **មីកូប្លាស្មា** Mycoplasma

-វាគឺជាមូលហេតុចម្បងទូទៅរបស់ការក្អកនៅប្រទេសកម្ពុជា

-មីកូប្លាស្មាបំផ្លាញផ្លូវដង្ហើម និងការចម្លងជំងឺឱកាសនិយម អាចកើតឡើងជាមួយពួកប៉ាស្ទឺរ៉ែឡា ធ្វើឲ្យមានជំងឺហើមសួតធ្ងន់ធ្ងរ

-សីតុណ្ហភាពខុសគ្នាខ្លាំងរវាងពេលថ្ងៃនឹងពេលយប់(>១០អង្សាសេ)វានឹងសម្រួលដល់ការលូតលាស់របស់ពពួកមីកូប្លាស្មា។

### ៣.៤.២. រោគសញ្ញា

-ក្អករន្ថើន ពី៧ទៅ៨ដងក្នុងពេលក្អកម្តង

-ក្អកមានសភាពខ្លាំងនៅពេលព្រឹក

-គ្រុនក្តៅជាមធ្យមគឺ៣៩.៥អង្សាសេ

-ថយចុះចំណង់ស៊ីចំណីប៉ុន្តែជ្រូកនៅបន្តការស៊ី




រូបភាពទី ៣.១៣ ជ្រូកកើតជំងឺផ្លូវដង្ហើម

-ជារឿយៗមីកូប្លាស្មាចរាចរណ៍ក្នុងកសិដ្ឋាននិងធ្វើឲ្យជ្រូកចាប់ផ្តើមក្អក ពេលពួកវាមានអាយុ២ខែ បន្ទាប់ពីព្យាបាលក្អកត្រូវបានកាត់បន្ថយ ប៉ុន្តែវាជារឿយៗនឹងលេចឡើងវិញ រហូតដល់ពេលលក់ទៅទីសត្តឃាត។

-ជ្រូកចាប់ផ្តើមក្អកនៅអាយុ២ខែ ប៉ុន្តែវាបានឆ្លង ក្នុងកំឡុងពេលថ្ងៃដំបូងក្រោយពេលផ្តាច់ដោះ

ការព្យាបាល

ត្រូវប្រើ ថ្នាំអុកស៊ីតេត្រាស៊ីគ្លីន ដុកស៊ីស៊ីគ្លីន ទីឡូស៊ីន ផ្លរហ្វេនីកុល (Oxytetracycline, Doxycycline, Tylosin, Florfenicol)។

អាម៉ុកស៊ីស៊ីលីន (Amoxicilline) មិនមានប្រសិទ្ធភាពប្រឆាំងនឹងមីកូប្លាស្មាទេ។ ពេលដែលប្រើអាម៉ុកស៊ីស៊ីលីន ជារឿយៗជ្រូកមានសភាពគ្រាន់បើក្នុងពេលព្យាបាល ព្រោះថ្នាំ អង់ទីប៊ីយ៉ូទិកនេះសម្លាប់បាក់តេរីផ្សេងៗទៀតដូចជាប៉ាស្ទឺរ៉ែឡា ប៉ុន្តែក្រោយមកពីរបីថ្ងៃបន្ទាប់ពីការព្យាបាលបានបញ្ចប់ ក្អកចាប់ផ្តើមឡើងវិញ និងខ្លាំងជាងមុន។

### ៣.៤.៣.ការការពារ

លាយថ្នាំអង់ទីប៊ីយ៉ូទិកក្នុងចំណីៈ

រយៈពេល១០ទៅ១៥ថ្ងៃភ្លាមៗ បន្ទាប់ពីការផ្តាច់ដោះ ព្រោះកូនជ្រូកឆ្លងពេលពួកវាអស់អង្គការពារដែលទទួលបានពីទឹកដោះមេ។ ត្រូវលាយថ្នាំដុកស៊ីស៊ីគ្លីន និងផ្លរហ្វេនីកុលក្នុងចំណី។ ពេលដែលប្តូរជ្រូកពីទ្រុងក្រោយពេលផ្តាច់ដោះ ទៅទ្រុងបំប៉ន ពួកវាទទួលរងការស្ត្រេស ហើយពពួកមីកូប្លាស្មាអាចលូតលាស់ ដូច្នេះត្រូវលាយក្នុងចំណីនូវថ្នាំតេត្រាស៊ីគ្លីន ដុកស៊ីស៊ីគ្លីន ទីឡូស៊ីនឬ ផ្លរហ្វេនីកុលរយៈពេលពី៥ទៅ៧ថ្ងៃ។

❖ ផ្តាសាយជ្រូក(បង្កដោយវីរុស) Swine Flu (virus)

ជំងឺផ្តាសាយជ្រូកបានធ្វើឲ្យមានការភ័យខ្លាចលើការផ្ទុះជំងឺនេះលើមនុស្សដែលបង្កដោយវីរុស ហាស១អិន១(H1N1) ។ មកទល់ពេលនេះវីរុសនេះមិនត្រូវបានរកឃើញក្នុងប្រទេសកម្ពុជាទេ។

### ៣.៤.៤. រោគសញ្ញា

ជំងឺស្រួចស្រាវបំផុតគឺមួយថ្ងៃមុនជ្រូកមានសុខភាពល្អ និង

នៅពេលព្រឹកឡើងជ្រូក៩០%ចាប់ឈឺៈ

-ក្អកធ្ងន់ធ្ងរ និងដកដង្ហើមខ្លាំង

-សីតុណ្ហភាពលើសពី៤០អង្សាសេ

ជ្រូកនឹងជាឡើងវិញ ក្នុងរយៈពេល៥ថ្ងៃ។



ក្នុងករណីផ្តាសាយ ជ្រូក៩០%ឈឺ ពួកវាមិនសកម្មនិង ក្រោកឈរពេលក្អកតែប៉ុណ្ណោះ

រូបភាពទី ៣.១៤ កូនជ្រូកកើតជំងឺផ្សាសាយ

ការព្យាបាល  មិនមានទេ ព្រោះផ្តាសាយបង្កដោយវីរុសត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិក ដើម្បីការពារការចម្លងជំងឺឱកាសនិយមបង្កដោយបាក់តេរីដូចជាពួកប៉ាស្ទឺរ៉ែឡា  មីកូប្លាស្មា...ដូច្នេះត្រូវចាក់អុកស៊ីតេត្រាស៊ីគ្លីនរយៈពេល៣ទៅ៥ថ្ងៃ។

### ៣.៤.៥. ពិបាកដកដង្ហើម និងហូរវត្ថុរាវ

❖ ជំងឺសារទឹក Pasteurellosis

ជារឿយៗការចម្លងមានរួមជាមួយជំងឺមីកូប្លាស្មា

រោគសញ្ញា

-ខ្ទុះហូរចេញពីច្រមុះ

-ក្អក ប៉ុន្តែក្អកអាចខ្លី និងអាចមានការឈឺចាប់

-ដកដង្ហើមលឿន

-គ្រុនក្តៅលើសពី៤០អង្សាសេ

-ស្បែកប្រែពណ៌ជាខៀវ ជាពិសេសនៅផ្នែកចុងត្រចៀក



រូបភាពទី ៣.១៥ ជ្រូកកើតជំងឺសាទឹក

### ៣.៤.៦. ការព្យាបាល

-ថ្នាំតេត្រាស៊ីគ្លីន ផ្លរហ្វេនីកុល អង់រ៉ូផ្លុកសាក់ស៊ីន(Tetracycline, Florfenicol, Enrofloxacine) អាចប្រើក្នុងករណីធ្ងន់ធ្ងរ ប៉ុន្តែមិនត្រូវភ្លេចថាការប្រើប្រាស់ថ្នាំអង់រ៉ូផ្លុកសាក់ស៊ីនបណ្តាលឲ្យមានភាពស៊ាំ និងបន្ទាប់មកទៀតថ្នាំអង់ទីប៊ីយ៉ូទិកនេះនឹងមិនមានប្រសិទ្ធភាពការការពារ

-ការការពារល្អបំផុតគឺត្រូវធ្វើការត្រួតពិនិត្យឲ្យបានត្រឹមត្រូវពួកមីកូប្លាស្មា(Mycoplasam)

-ការចាក់វ៉ាក់សាំងប្រឆាំងជំងឺសារទឹក(Pasteurella) មិនមានសារៈសំខាន់ទេ ព្រោះប៉ាស្ទឺរ៉ែឡារស់នៅក្នុងបំពង់ដកដង្ហើម ពួកវានឹងបំបែកខ្លួន និងរាតត្បាតសួត នៅពេលជ្រូកចុះខ្សោយតែប៉ុណ្ណោះ។

❖ អាក់ទីណូបាក់ស៊ីលុស (បង្កដោយបាក់តេរី)Actinobacillus (bacteria)

### ៣.៤.៧. រោគសញ្ញា

បែកពពុះមានឈាមហូរតាមច្រមុះ

-ស្រួចស្រាវបំផុតការសម្ងំជំងឺមានរយៈពេល១២ម៉ោង

-ក្អកខ្លីគឺ១ទៅ៣ដងក្នុងមួយពេល

-ពិបាកដកដង្ហើមខ្លាំង

-គ្រុនក្តៅលើសពី៤0អង្សាសេអស់កម្លាំងខ្លាំង

-សត្វងាប់



រូបភាពទី ៣.១៦ បែកពពុះមានឈាមហូរតាមច្រមុះ

### ៣.៤.៨. ការព្យាបាល

-ប្រើថ្នាំដូចជាអាម៉ុកស៊ីស៊ីលីន ទ្រីមេតូព្រីមជាមួយស៊ុលហ្វា អង់រ៉ូផ្លុកសាក់ស៊ីន

### ៣.៤.៩. ស្លាកស្នាមលើសួត

ស្លាកស្នាមលើសួតគឺខុសគ្នាសម្រាប់គ្រប់ប្រភេទជំងឺទាំងអស់។ ចាំបាច់ត្រូវត្រួតពិនិត្យសួតពេលជ្រូកងាប់ (ករណីរបស់ជំងឺសារទឹក(Pasteurellosis) និងករណីជំងឺអាក់ទីណូបាក់ស៊ីលុស

(Actinobacillus)។ ស្លាកស្នាមរបស់ជំងឺមីកូប្លាស្មាអាចឃើញក្នុងទីសត្តឃាត ព្រោះជាទូទៅ ជ្រូកមិនងាប់ដោយសារជំងឺមីកូប្លាស្មាទេ។




រូបភាពទី ៣.១៧ ការចេញដំបៅលើសួត

## ៣.៥. ជំងឺរលាកពោះវៀន(អង់តេរីត) ENTERIC DISEASES

### ៣.៥. ១. ជំងឺរាគ

- ❖ ជំងឺអ៊ីកូលីលើកូនជ្រូកទើបកើត E Coli in newborn piglets

### ៣.៥.២. រោគសញ្ញា

-កើតមុនរយៈពេល៥ថ្ងៃ?

-លាមករាគលឿង ខាប់លាយសំបោរ

-ប្រឡាក់សើម និងកខ្វក់ជុំវិញគូថ និងកន្ទុយ

-ក្រោយមកទៀតវានឹងខ្សោះជាតិទឹក



រូបភាពទី ៣.១៨ កូនជ្រូករាគដោយអ៊ីកូលី

### ៣.៥.៣. ការព្យាបាល

-ចំពោះកូនជ្រូកត្រូវព្យាបាលកូនជ្រូកទាំងអស់ក្នុងសំបុកជាមួយថ្នាំកូលីស្ទីន ជាមួយអំពីស៊ីលីន (Colistin+Ampicillin) ពេលព្រឹក និងល្ងាច

-ចំពោះមេជ្រូកត្រូវព្យាបាលដោយប្រើថ្នាំទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (TMP+Sulfa) ដើម្បីកាត់បន្ថយការចម្លងលើទឹកដោះដោយអ៊ីកូលី។

### ៣.៥.៤. ការការពារ

-ត្រូវជានាឲ្យមានការបៅទឹកដោះដំបូងគឺកសិករត្រូវជួយកូនជ្រូកបានបៅទឹកដោះដំបូងបានភ្លាម បន្ទាប់ពីកើត ព្រោះទឹកដោះមានអង្គការពារ(អង់ទីគ័រ) ដែលការពារប្រឆាំងនឹងអ៊ីកូលី

-បង្ការភាពត្រជាក់ និងខ្យល់បក់ខ្លាំង គឺពេលដែលពោះកូនជ្រូកត្រជាក់នោះអ៊ីកូលីនឹងបំបែកខ្លួនត្រូវរៀបចំធ្វើសំបុក និងពេលយប់ត្រូវរៀបចំប្រដាប់កំដៅកូនជ្រូក។

## ៣.៦. ជំងឺកុកស៊ីដ្យូស (coccidiosis)

### ៣.៦.១ រោគសញ្ញា

-ពី៧ទៅ២១ថ្ងៃបន្ទាប់ពីកើត

-រាគពីពណ៌លឿងទៅជាពណ៌ខៀវប្រផេះ

-រាគមានសភាពខាប់គឺលាយជាតិក្រែម និង doughy

-កូនជ្រូកស្គម ប៉ុន្តែការងាប់មិនកើតជាទូទៅទេ។



រូបភាពទី ៣.១៩ កូនជ្រូកកើតកុកស៊ីដ្យូស

### ៣.៦.២. ការព្យាបាល

មានការលំបាកក្នុងការព្យាបាល។ ត្រូវចាក់ថ្នាំដូចជាស៊ុលហ្វាឌីមីឌីន ឬស៊ុលហ្វាឌីមេតូស៊ីន (Sulfadimidine or sulfadimethoxine)។

### ៣.៦.៣. ការការពារ

វាគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតដោយប្រើថ្នាំដូចជា តុលត្រាស៊ុរីល Toltrazuril (អង់ទីកុកឬបេកុក anticoc, baycox) នៅបីថ្ងៃបន្ទាប់ពីកើត ដោយបញ្ច្រកម្តងតាមមាត់។

- ❖ រាគឈាមកូនជ្រូក/ ក្លូស្ទ្រីដ្យូម (Bloody diarrhea of piglets / Clostridium)

### ៣.៦.៤. រោគសញ្ញា

-កូនជ្រូករីវត្តយ៉ាងលឿនទៅជារាគមានក្លិនស្អុយអាក្រក់ ដែលជារឿយៗមានពណ៌ឈាមនៅអាយុ១ទៅ៧ថ្ងៃ

បន្ទាប់ពីកើត

-មានកូនជ្រូកជាច្រើនងាប់

-ជាទូទៅកើតលើជ្រូកដែលដើររកស៊ីចំណីតាមវាល




រូបភាពទី ៣.២០ ដើររកស៊ីចំណីតាមវាល

### ៣.៦.៥. ការព្យាបាល

ចាក់ថ្នាំអាម៉ុកស៊ីស៊ីលីន ឬជាការល្អប្រកតាមមាត់

❖ អឺកូលីចំពោះកូនជ្រូកផ្តាច់ដោះ E Coli in weaned piglets

### ៣.៦.៦. រោគសញ្ញា

-ជាទូទៅកើតមានក្នុងកំឡុងពេល៥ទៅ៧ថ្ងៃនៃពេលផ្តាច់ដោះ

-រាគមានសភាពស្អិតដោយផ្លាស់ប្តូរពីទឹកទៅជាម្សៅ

-លាមកមានផ្ទៃប្រែពណ៌សប្រផេះ លឿង និងបៃតង។ ពណ៌នេះមិនមែនមានន័យសំខាន់អ្វីមួយនោះទេ (គ្មានឈាម និងសំបោរ)

-ខ្សោះទឹកធ្វើឲ្យស្រកទម្ងន់លឿន។



រូបភាពទី ៣.២១ លាមកប្រផេះ និងលឿង

### ៣.៦.៧. ការព្យាបាល

ប្រើថ្នាំអង់ទីប៊ីយ៉ូទិកដូចជា កូលីស្ទីន ទ្រីមេតូព្រីមជាមួយស៊ុលហ្វា ហ្សង់តាមីស៊ីន អង់រ៉ូផ្លុកសាក់ស៊ីន(Colistin, TMP+Sulfa, Gentamycin, Enrofloxacin)

ការការពារបង្ការភាពត្រជាក់ពេលយប់៖ មុនពេលផ្តាច់ដោះកូនជ្រូកទទួល Armth ពីមេ និងជាទូទៅទ្រុងកើតកូនត្រូវមានរៀបចំការពារខ្យល់បក់ខ្លាំងបានល្អ។ នៅប៉ុន្មានថ្ងៃដំបូង ក្នុង ទ្រុងផ្តាច់ដោះពួកវារងារ ហើយជាការចាំបាច់ត្រូវផ្តល់កំដៅជាពិសេសនៅពេលយប់។

ផ្តល់ចំណីពិសេសសម្រាប់ការផ្តាច់ដោះ ៖ប្រដាប់រំលាយអាហាររបស់កូនជ្រូកផ្តាច់ដោះមិនទាន់ ធ្លាប់រំលាយវត្ថុធាតុដើមនោះទេ ដូច្នេះ៖

-ការដែលផ្តល់ឲ្យកូនជ្រូកផ្តាច់ដោះនូវចំណីពិសេសពីរោងចក្រនឹងជួយសម្រួលការរំលាយអាហាររបស់វា។

-លាយថ្នាំកូលីស្ទីនក្នុងចំណីនៅអាទិត្យទី១បន្ទាប់ពីផ្តាច់ដោះ អាចការពាររោគ។

❖ រាគប្រផេះ / អ៊ីលីទីស Ileitis

### ៣.៦.៨. រោគសញ្ញា

-ចំពោះជ្រូកសាច់ ឬមេជ្រូក

-រាកមានទឹករាំរ៉ៃ រាគពណ៌ប្រផេះប្រឡាក់ប្រឡូក

សត្វចុះស្គម ទិន្នផលធ្លាក់ចុះ

-ឬរាគមានឈាមស្រួចស្រាវដែលធ្វើឲ្យស្លេកស្លាំង

(ស្បែកខាងក្នុងភ្នែកឡើងស)



រូបភាពទី ៣.២២ រាគប្រផេះ/អ៊ីលីទីស

### ៣.៦.៩. ការព្យាបាល

ប្រើថ្នាំដូចជា ទីឡូស៊ីន ទីឡូស៊ីនជាមួយហ្សង់តាមីស៊ីន ទីយ៉ាមុយលីន (Tylosin, Tylosin + Gentamycin, Tiamulin)

## ៣.៧. ជំងឺសាល់ម៉ូណែឡូស Salmonellosis

ជារឿយៗគេឃើញថាវាជាការចម្លងជំងឺឱកាសនិយមលើជ្រូក ដែលកើតជំងឺប៉េស្តជ្រូក។រោគសញ្ញា

-រាគរាវដូចទឹកមានក្លិនស្អុយអាក្រក់ដែលអាចមានជាប់

ឈាមមកជាមួយ

-ដង្ហើម ក្អក មានការឈឺចាប់

-ស្បែកក្រហម និងស្បែកកន្ទុយ ត្រចៀកមានពណ៌ខៀវ



រូបភាពទី ៣.២៣ រាគសាលម៉ូណែឡូស

**ការព្យាបាល មានការលំបាក**

ប្រើថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វា ឬ អង់រ៉ូផ្លុកសាក់ស៊ីន

**៣.៧.១ ការការពារ**

-មិនត្រូវចាក់ថ្នាំការពារទេ

-ត្រូវមានអនាម័យល្អ រម្ងាប់មេរោគ និងត្រួតពិនិត្យកណ្ដុរ

**៣.៧.១.១ ការទល់លាមក Constipation**

ការទល់លាមកជាបរិមាណតិចតួចរបស់លាមកហើយលាមកស្ងួត។ មេជ្រូកធើមគឺជាប្រធានបទរបស់ការទល់លាមក រាល់ជំងឺទាំងអស់ដូចជា ប៉េស្តជ្រូក គ្រុចៀកខៀវ បណ្ដាលឲ្យកំដៅឡើងខ្លាំង ដែលធ្វើឲ្យសត្វបាត់បង់ចំណង់ស៊ីចំណី ហើយបន្ទាប់មក វានឹងទល់លាមក។



រូបភាពទី ៣.២៤ ការទុលលាមក

❖ **មុនពេលកើតកូន**

ជាទូទៅមេជ្រូកប្ដូរទៅទ្រុងពិសេសសម្រាប់កើតកូនពី៧ទៅ១០ថ្ងៃមុនពេលកើត។ វាបណ្ដាយឲ្យមេជ្រូកស្ត្រេសយ៉ាងខ្លាំង ហើយមេជ្រូកបាត់បង់ការស៊ីចំណីពីរបីថ្ងៃ

-កសិករខ្លះកាត់បន្ថយបរិមាណចំណីពីរបីថ្ងៃ មុនពេលកើត ព្រោះគាត់គិតថាវានឹងមាន

-ដំណើរការទៅយ៉ាងរលូន។ ជាការពិតការទល់លាមក អាចបង្កឲ្យមានការលំបាក

ក្នុងការកើតកូន ការចម្លងលើទឹកដោះដោយពួកអ៊ីកូលី គឺជាមូលហេតុចម្បងរបស់ជំងរលាកស្បូន លាសដោះ និងអត់ទឹកដោះ (MMA)។

-វាចាំបាច់ត្រូវផ្លាស់មេជ្រូកយ៉ាងហោចឲ្យបាន១០ថ្ងៃ មុនពេលកើតបន្ទាប់ពី៣ទៅ៤ថ្ងៃ វានឹងស៊ីចំណីធម្មតាហើយការទល់លាមកនឹងបាត់ទៅវិញ

-មិនត្រូវបន្ថយបរិមាណចំណីមុនពេលកើតកូនទេ ត្រូវបន្ថែមចំណីរហូតដល់៤គីឡូក្រាមជា ការប្រសើរ វាជួយការពារការទល់លាមក និងផ្ដល់ថាមពលបន្ថែម ដើម្បីប្រើការក្នុងពេលកើតកូន។ វាមិនល្អទេដែលមានមេជ្រូកធាត់មុនពេលកើតកូនប៉ុន្តែការងារនេះត្រូវត្រួតពិនិត្យពេញកំឡុងពេលធើមទាំងមូ

ល។ ការកាត់បន្ថយចំណីក្នុងអាទិត្យចុងក្រោយនៃការផើមនឹងមិនមានឥទ្ធិពលលើរាងកាយទេប៉ុន្តែវាជះឥទ្ធិពលដល់កូនជ្រូកទើបកើត និងធ្វើឲ្យការកើតកូនមានការលំបាក។

### ៣.៧.២. ការព្យាបាល

-មេជ្រូកត្រូវដើរ

-ត្រូវផ្តល់ចំណីស្រស់

-ផ្តល់ប្រេងប៉ារ៉ាហ្វីន (៣០០មីល្លីលីត្រក្នុងមួយថ្ងៃ)

- ❖ បញ្ហារបស់រូបមន្តផ្សំចំណី

បរិមាណជាតិសសៃក្នុងចំណីជាសន្ទស្សន៍សំខាន់ដើម្បីបង្ការការទល់លាមកចំពោះមេជ្រូក។ ពេលមេជ្រូកស៊ីធម្មតា តែវាជួបបញ្ហាទល់លាមកក្នុងពេលផើមជាការចាំបាច់ត្រូវពិនិត្យរូបមន្តចំណីថាតើវាមានផ្ទុកជាតិសសៃគ្រប់គ្រាន់ដែរទេ ប្រភពសំខាន់របស់ជាតិសសៃគឺកន្ទក់ ជាពិសេសកន្ទក់ស្រូវសាឡីគុណភាពលេខពីរ។


កន្ទក់ស្រូវសាឡីផ្តល់ជាតិសសៃច្រើនដែលមានគុណភាពល្អសម្រាប់មេជ្រូក

រូបភាពទី ៣.២៥ ការផ្សំចំណី

**មិនស៊ីចំណី**

- ❖ **សីតុណ្ហភាពឡើងខ្ពស់**

### ៣.៧.៣. រោគសញ្ញា

-ជ្រូកមិនអាចស៊ីចំណី

-គ្រុនក្តៅលើសពី៤០អង្សាសេនៅពេលព្រឹកព្រលឹម

-វាអាចកំណត់សញ្ញាផ្សេងទៀតរបស់ជំងឺ ប៉ុន្តែរោគសញ្ញាដ៏ទៃទៀតនឹងលេចឡើង បន្ទាប់ពី២ទៅ៣ថ្ងៃពេលដែលជំងឺវិវត្តក្នុងកសិដ្ឋាន។

### មូលហេតុញឹកញាប់

-ការចម្លងជំងឺក្នុងឈាម (Septicemia)គឺពេលដែលបាក់តេរីលូតលាស់ក្នុងដងខ្លួនទាំងមូលតាមរយៈចរន្តឈាមរត់ ការចម្លងទាំងនេះគឺស្រួចស្រាវ និងជារឿយៗសត្វបង្ហាញតែការចុះខ្សោយខ្លាំង សីតុណ្ហភាពខ្ពស់ និងមិនស៊ីចំណី។

-ការមិនធ្លាក់កូនជ្រូកងាប់ នៅពីរបីថ្ងៃបន្ទាប់ពីកើត មេជ្រូកមិនអាចស៊ី ហើយសីតុណ្ហភាពកើនឡើង។ ការហូរទឹកខ្ទុះនឹងសង្កេតឃើញពីរបីថ្ងៃ ប្រសិនបើការចម្លងជំងឺក្នុងឈាមមិនលូតលាស់មុន

-ការសេសសល់សុក សូមមើលរោគសញ្ញាខាងលើ

-បាក់តេរីបង្កជំងឺក្នុងឈាមដ៏ទៃទៀត ឧទាហរណ៍ដូចជាកញ្ច្រិល (Erysipelas)

-រលាកផ្លោកនោម (Cystitis)ពេលមានការចម្លងផ្លោកនោម (រលាកផ្លោកនោម) ទៅដល់ក្រលៀនក្នុងមេជ្រូក នោះការចម្លងជំងឺនឹងវិវត្តក្នុងឈាម។



កូនជ្រូកឬសុកចុងក្រោយមិនកើតចេញជាមូលហេតុនៃការចម្លងមេរោគក្នុងឈាមខ្លាំងក្លាចំពោះ



ការចម្លងលើតម្រងនោមអាចបង្កជាការឆ្លងមេរោគក្នុងឈាមធ្វើឲ្យងាប់ វាចាំបាច់ត្រូវពិនិត្យថាតើមេជ្រូកនោមល

រូបភាពទី ៣.២៦ រលាកផ្លោកនោម

ជំងឺប៉េស្តជ្រូក ខុសធម្មតា សីតុណ្ហភាពខ្ពស់ដែលកើតមានច្រើនថ្ងៃលើជ្រូកហើយសកម្ម ភាពរបស់ថ្នាំអង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធភាព ត្រូវនឹកឃើញថាជាជំងឺប៉េស្តជ្រូក។បសុពេទ្យត្រូវ ពិនិត្យ កសិដ្ឋានម្តងទៀត នៅពីរបីថ្ងៃបន្ទាប់ និងធ្វើការវះកាត់សាកសព ដើម្បីកំណត់ពីសញ្ញា ទូទៅរបស់ ជំងឺប៉េស្តជ្រូក។

### ៣.៧.៤ ការព្យាបាល

-ត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដែលមានទំហំសកម្មភាពទូលាយឲ្យបានលឿនតាម ដែលអាច ធ្វើទៅបាន

-ថ្នាំប៉ារ៉ាសេតាម៉ុលអាចចាក់ ដើម្បីបញ្ចុះកំដៅ ថ្នាំប៉ារ៉ាសេតាម៉ុលមិនធ្វើឲ្យខូចខាត ខ្លាំងក្លា ដល់ជញ្ជាំងក្រពះ

-ត្រូវចាក់កម្រិតទ្វេដងនូវថ្នាំអង់ទីប៊ីយ៉ូទិក ដែលមានទំហំសកម្មភាពទូលាយ (អង់រ៉ូផ្លុកសាក់ ស៊ីនតេត្រាស៊ីគ្លីន )ឲ្យបានលឿន តាមដែលអាចធ្វើទៅបាន។

❖ **ដំបៅក្រពះ**

**៣.៧.៥.រោគសញ្ញា**

-កើតមានជាទូទៅលើមេជ្រូក និងជ្រូកសាច់

-មិនស៊ីចំណី ប៉ុន្តែគ្មានគ្រុនក្តៅ

-ស្បែកស្លេកស្លាំង (ចេញឈាមក្នុងក្រពះ)

-ទល់លាមក លាមកពណ៌ខ្មៅ (រំលាយអាហារមានឈាម)

-ក្អួត

**មូលហេតុ**

-ជាតិសសៃមិនគ្រប់គ្រាន់ (ត្រូវបន្ថែមកន្ទក់ស្រូវសាឡី)

-គុណភាពវត្ថុធាតុដើមក្នុងចំណីមិនល្អ




រូបភាពទី ៣.២៧ ដំបៅក្រពះ

### ៣.៧.៦. ការព្យាបាល

-ផ្តល់ចំណី៤ទៅ៥ដងក្នុងមួយថ្ងៃ លាយជាមួយទឹកដើម្បីឲ្យចំណីទន់

-ផ្តល់ចំណីស្រស់

-ចាក់ថ្នាំកម្លាំង ដើម្បីបង្កើនចំណង់ស៊ីចំណី និងវីតាមីនបេ១២Vitamin B12 ដើម្បីកុំឲ្យខ្វះឈាមក្រហម(ស្លេកស្លាំង)។

❖ ព្រូន

### ៣.៧.៧. រោគសញ្ញា

-ពេលមានការចម្លងខ្លាំងក្លា វាអាចមើលឃើញព្រូនក្នុងលាមក ព្រូនមានបណ្តោយប្រវែងពី២៥០ទៅ៤០០មីលីម៉ែត្រ

-មានព្រូនជាច្រើនក្នុងពោះវៀនដែលស្រូបយកចំណី ដែលធ្វើឲ្យរាងកាយសត្វ

-ចុះអន់ថយ។

-ការបម្លាស់ទីរបស់កូនព្រូន (មើលក្នុងជំពូកស្តីពីបរាសិត) ក្នុងសួតបណ្តាលឲ្យក្អក។




រូបភាពទី ៣.២៨ ព្រូនអាស្ការីស

### ៣.៧.៨. ការព្យាបាល

ត្រូវចាក់ អ៊ីវ៉ែម៉ិចទិន ១% : ១មីល្លីលីត្រ/៣០គីឡូក្រាម (Ivermectine 1%: 1ml /30 kg)

ការការពារ

-ត្រូវចាក់ឲ្យមេជ្រូកនៅពីរអាទិត្យ មុនពេលកើតកូន

-ត្រូវចាក់ក្នុងកំឡុងផ្តាច់ដោះសម្រាប់កូនជ្រូក

**ខ្វិតជើង LAMENESS**

វាចាំបាច់ត្រូវតែយើងចូលក្នុងទ្រុងដើម្បីបង្ខំជ្រូក ឬមេជ្រូកទាំងអស់ឲ្យក្រោកឡើង នេះជាវិធី តែមួយគត់ ដើម្បីសង្កេតមើលការខ្វិតជើង។

ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលខ្វិតជើងវាសំខាន់ណាស់៖

-មេជ្រូកផឹកមិនគ្រប់គ្រាន់ វាបណ្តាលឲ្យកើតជំងឺរលាកផ្លោកនោម

-ជ្រូកស៊ីមិនគ្រប់គ្រាន់បណ្ដាលឲ្យក្លៀន និងការលូតលាស់មិនល្អ

-សត្វទទួលរងបញ្ហាមួយចំនួនដូចជាស្ត្រេសបណ្ដាលសត្វចុះខ្សោយ និងភាពស៊ាំ ធ្លាក់ទាបក្នុងការទប់ទល់នឹងជំងឺ។

### ៣.៧.៩. រលាកសន្លាក់ឆ្អឹង Arthritis

រលាកសន្លាក់ឆ្អឹងជាការរលាកនៅកន្លែងសន្លាក់ ដែលបង្កដោយបាក់តេរី

បាក់តេរីដែលកើតមានបំផុតលើកូនជ្រូកបៅដោះគឺពួកស្រ្តិបតូកុកគុស (streptococcus) ប៉ុន្តែមីក្រុបដ៏ទៃទៀតអាចបណ្ដាលឲ្យរលាកសន្លាក់ឆ្អឹងដូចជា៖ កញ្ជ្រិល។

-ខ្វកជើង ហើមសន្លាក់

-កូនជ្រូកបង្ហាញការឈឺចាប់

-វាវែកមិនចង់ក្រោក



រូបភាពទី ៣.២៩ រលាកសន្លាក់ឆ្អឹង

### ៣.៧.១១. ការព្យាបាល

ប្រើថ្នាំឡាំងកូមីស៊ីន(Lincomycin) អាម៉ុកស៊ីស៊ីលីន(Amoxicillin) ឲ្យលឿនតាមដែល អាចធ្វើទៅបាន ដើម្បីការពាររលាកសន្លាក់ឆ្អឹងរ៉ាំរ៉ៃ

ការការពារ ចំពោះកូនជ្រូក

ត្រូវចាក់អាម៉ុកស៊ីស៊ីលីន(Amoxicillin LA) ដែលមានសកម្មភាពវែង 0,៥មីល្លីលីត្រ មួយថ្ងៃបន្ទាប់ពីកើត។

### ពុកស្អុយជើង

វាជាការចម្លងកើតលើក្រចក ក្នុងជាលិកាចន្លោះចង្អែក និងកជើង។ កើតមានជាទូទៅលើមេជ្រូកចិញ្ចឹមលើកម្រាលមិនល្អ។

## រោគសញ្ញា

-មេជ្រូកឈឺជើង ហើមនឹងឈឺចាប់លើចង្វែកជើង

-ការហើមអាចមើលឃើញជុំវិញកជើង ហើយបង្កជាដំបៅ។



រូបភាពទី ៣.៣០ ហើម និងឈឺ

### ៣.៧.១១. មូលហេតុ

ជាទូទៅដោយសារកម្រាលទ្រុងធ្វើអំពីស៊ីម៉ង់ត៍មិនល្អ ឬទ្រុងមិនត្រូវតាមស្តង់ដា (Substandard cages)ធ្វើពីដែក ពេលដែល មេជ្រូកតែងមានបញ្ហាពុកស្អុយជើងដូចនេះ ត្រូវចាំបាច់ជួសជុលកម្រាលនោះចេញ។




វាមិនអាចចិញ្ចឹមជ្រូកលើកម្រាលទ្រុងដូចនេះទេ

### ៣.៧.១២ ការព្យាបាល

-ចាក់ឡាំងកូមីស៊ីន(Lincomycin) / ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា(TMP+Sulfa)

-ដាក់អង្កាមលើកម្រាលទ្រុងកម្រាស់២០សង់ទីម៉ែត្រ ដើម្បីការពារកុំឲ្យវាប៉ះជាមួយកម្រាលស៊ីម៉ង់ត៍

-បាញ់ថ្នាំអុកស៊ីតេត្រាស៊ីគ្លីន (OTC) លើដំបៅ ដើម្បីឲ្យឆាប់ជាសះស្បើយ

## ៣.៨. អុតក្តាម FMD

រោគសញ្ញាសំខាន់មួយរបស់ជំងឺអុតក្តាមលើជ្រូកគឺខ្វកជើងយ៉ាងដុនដាប និងឈឺចាប់លើសត្វជាច្រើនក្នុងទ្រុង។ ការពិនិត្យឲ្យបានជិតដល់លើជើង និងច្រមុះ អាចបង្ហាញស្លាកស្នាមជាក់លាក់។

### ៣.៨.១. រោគសញ្ញា



រូបភាពទី ៣.៣១ ខ្ទុកជើង

-ខ្ទុកជើងភ្លាមៗ

-សត្វចង់ទម្រេតខ្លួន

-ពេលដែលសត្វបម្លាស់ទីវាស្រែកខ្លាំង និងដើរខ្ទុកដោយការឈឺចាប់

-ពងដោរលើគែមក្រចក កន្លែងដែលស្បែកនិងជាតិស្នែង (ក្រចក)ជួបគ្នា

-ពងដោរវិវត្តលើច្រមុះផងដែរ។

### ៣.៨.២. ការព្យាបាល

សូមមើលក្នុងផ្នែកស្តីពីជំងឺអុតក្តាម

## ៣.៩. ប៉េស្តជ្រូក CSF

មានជំងឺជាច្រើនដែលធ្វើឲ្យសីតុណ្ហភាពឡើងខ្ពស់ ដែលអាចធ្វើឲ្យសត្វមិនចង់ដើរ ប៉ុន្តែជំងឺប៉េស្តជ្រូកបណ្តាលឲ្យសត្វមានការខ្ជិលច្រអូស បាត់បង់ថាមពលលើជើង។

### ៣.៩.១. រោគសញ្ញា

-ប្រសិនបើអ្នកលើកវាឲ្យឡើងវាអាចងាកចេញពីស្នូកចំណី ប៉ុន្តែវាស៊ីតិចតួច ឬមិនស៊ីសោះរួចងាកចេញជាថ្មី ដើម្បីក្រាបចុះ

-ដើរទ្រេតទ្រោត ខ្វិនមួយផ្នែកជើងក្រោយ ដើរដូចជាស្រវឹង និងមានសភាពចង់អង្គុយ ឬដេក។




រូបភាពទី ៣.៣២ រោគសញ្ញាប៉េស

**ការអង្គុយដូចឆ្កែ Dog sitting position**

**រោគសញ្ញា**

-មេជ្រូកអង្គុយដូចឆ្កែ ជើងញែកចេញ

-ពិបាកបត់ចុះឡើង ហើយរឹង

-ខ្វក់ជើងស្រួចស្រាវក្នុងពេលបំបៅដោះ ឬបន្ទាប់ពីផ្តាច់ដោះភ្លាមៗ។

**មូលហេតុ**



-មេជ្រូកមានទម្ងន់ធ្ងន់ពេក

-ផលិតទឹកដោះច្រើន

-ស៊ីចំណីតិចក្នុងពេលបំបៅដោះ

-កង្វះវីតាមីនដេ៣

-ជាតិកាល់ស្យូមទាប ក្នុងរបបចំណី

**ការព្យាបាល**

ត្រូវចាក់វីតាមីនដេ៣ជាមួយកាល់ស្យូម (កូហ្វាកាល់ស្យូម Cofacalcium)

**ការការពារ**

ផ្តល់ជាតិដេសេប៉េ (DCP) ៣០ក្រាមក្នុងមួយថ្ងៃ បន្ទាប់ពីកើតកូន។

### រោគសញ្ញា

-កូនជ្រូកមិនអាចក្រោកឈរ ជើងក្រោយកន្ធែកចេញពីគ្នា

-វាងាយស្រួលកិនពីលើដោយមេជ្រូក ព្រោះកូនជ្រូកមិនអាចងាកចេញ

-កូនជ្រូកកម្រនៅរស់ ។



ក្នុងសំបុកជាមួយគ្នាមានតែកូនជ្រូកមួយចំនួនកើតជំងឺស្បែក

កូនជ្រូកកន្ធែកជើងមិនអាចគេចចេញពេលមេជ្រូកអង្គុយ

រូបភាពទី ៣.៣៣ កូនជ្រូកកន្ធែកជើង

### ការព្យាបាល

-ត្រូវប្រើកៅស៊ូយឺតសំប៉ែតរុំចងជើងក្រោយ

-ត្រូវឈ្លីសាច់ដុំ(ម៉ាស្សា)

-ត្រូវជួយកូនជ្រូកបៅទឹកដោះ២ទៅ៣ដងក្នុងមួយថ្ងៃ

ការការពារ

ត្រូវចាក់វីតាមីនអឺ ជាមួយសេលីនីយ៉ូម Vitamin E+Selenium អាចចាក់ឲ្យមេជ្រូកម្តងក្នុងមួយអាទិត្យ កំឡុងពេលបីអាទិត្យមុនពេលកើត។

## ៣.១០. ជំងឺស្បែក SKIN DISEASES

### ស្បែកឡើងជាតប្រេងពណ៌ប្រផេះ

មូលហេតុបង្កដោយពួកស្តាភីឡូកុកគុស(Staphylococcus) វាគឺជាបាក់តេរី។ ពួកបាក់តេរីទាំងនេះទន្ទ្រាន(ឆ្លងចូល)ស្បែកដែលដាច់រលាត់ និងបង្កជាការចម្លងជំងឺ។

### ៣.១០.១. រោគសញ្ញា

-ចាប់ផ្តើមតូច ពណ៌ត្នោតចាស់ កន្លែងដែលចម្លងជុំវិញមុខ ឬលើជើង

-កន្លែងទាំងនេះបង្ហាញសភាពជាខ្លាញ់រងើម មើលទៅដូចជាកខ្វក់

-ពណ៌ត្នោតរីកធំឡើងពេញដងខ្លួនទាំងមូល

-ជ្រូកដែលកើតជំងឺនេះធ្ងន់ធ្ងរអាចងាប់បាន។




រូបភាពទី ៣.៣៤ ជំងឺរលាកស្បែកកូនជ្រូក

### ៣.១០.២. ការការពារ

-ចៀសវាងកម្រាលសើម កម្រាលដែលសឹកគ្រើម អាចធ្វើឲ្យមានស្លាកស្នាមដំបៅ

-លើជង្គង់

-កាត់ធ្មេញដោយប្រុងប្រយត្ន័កុំឲ្យមានរបួស

-រម្ងាប់មេរោគលើកន្សោមដោះរបស់មេជ្រូកពីរដងក្នុងមួយថ្ងៃជាមួយអ៊ីយ៉ូឌីន ព្រោះកន្សោមដោះជាកន្លែងផ្ទុកសម្រាប់ការចម្លង។

### ៣.១០.៣. ការព្យាបាល

-គ្មានអ្វីដែលមានប្រសិទ្ធភាពទេ

-ចាក់ថ្នាំដូចជាអាម៉ុកស៊ីស៊ីលីនដែលមានសកម្មភាពវែង(Amoxicillin LA) ថ្នាំឡាំងកូមីស៊ីន (lincomycin)

-បាញ់ថ្នាំរម្ងាប់មេរោគលើស្បែក (តេហាស់៤(TH4)លាយ២មីល្លីលីត្រក្នុងទឹកមួយលីត្រ)

**ការលេចឡើងចំណុចពណ៌ក្រហម / កញ្ច្រិល**

ជំងឺនេះបង្កដោយបាក់តេរី និងស្ថិតនៅស្ទើរគ្រប់កសិដ្ឋានទាំងអស់។ ជំងឺនេះមិនកើតជាទូទៅលើជ្រូកមានអាយុមុនបីខែទេ។

### ៣.១០.៣. រោគសញ្ញា



-ចំណុចរាងជាត្បូងពេជ្រលេចឡើងប្រែពីពណ៌ក្រហម ទៅជាខ្មៅ ជារឿយៗដុំពកនេះអាចស្ទាបដោយដៃក្នុង ដំណាក់កាលដំបូង មុនបានឃើញអ្វីផ្សេងទៀត

-ពេលខ្លះជ្រូកងាប់ភ្លាម ដោយសារមេរោគចម្លងក្នុងឈាម និងខូចបេះដូង

-សីតុណ្ហភាពឡើងខ្លាំងលើសពី(៤១អង្សាសេ) ឈប់ស៊ីចំណី

### ៣.១០.៣. ការការពារ

អាចចាក់ថ្នាំការពារមេបានៅអាយុ៤ខែគឺ២ដង ៤អាទិត្យពីគ្នា។ វ៉ាក់សាំងរុយវ៉ាក់(Ruvax)របស់ក្រុមហ៊ុនមេរីយ៉ាល់(Merial)មានលក់ក្នុងប្រទេសកម្ពុជា។

### ៣.១០.៤ ការព្យាបាល

ចាក់ថ្នាំប៉េនីស៊ីលីន(Penicillin) ឬអាម៉ុកស៊ីស៊ីលីន(Amoxicillin) ពីបីទៅ៥ថ្ងៃ។

## ៣.១១ កន្ទួលពណ៌ក្រហម / អង្កែRed pimples / Mange

វាបង្កឡើងដោយបរាសិតនិងប៉ះពាល់ដល់ការលូតលាស់របស់ជ្រូក

### ៣.១១.១ រោគសញ្ញា

-រោលរាលពណ៌ក្រហមលើស្បែកភាគ ច្រើនលើខ្នងនិងចង្កេះ

-ក្រហល់ក្រហាយនិងត្រដុស

-បក់ត្រចៀក មានវត្ថុពណ៌ត្នោតចាស់នៅខាងក្នុង។



រូបភាពទី ៣.៣៥ កន្ទួលស្បែក

### ៣.១១.២ ការការពារ

ត្រូវចាក់ថ្នាំឲ្យជ្រូករៀងរាល់៣ខែម្តង ដោយប្រើថ្នាំអ៊ីវែម៉ិចទីន(Ivermectin)។

### ការព្យាបាល

ចាក់ថ្នាំអ៊ីវែម៉ិចទីន(Ivermectin) ១មីល្លីលីត្រក្នុងទម្ងន់៣០គីឡូក្រាម ចំនួនពីរដងក្នុងពេល ២អាទិត្យ ព្រោះវដ្តរបស់បរាសិតគឺ១០ទៅ១៤ថ្ងៃ។ អ៊ីវែម៉ិចទីនត្រូវចាក់ក្រោមស្បែក

អ៊ីវែម៉ិចទីនអាចប្រើលាយក្នុងចំណីរៀងរាល់ថ្ងៃសម្រាប់រយៈពេល៧ថ្ងៃ។ វាគឺជាវិធីដ៏មានប្រសិទ្ធភាពបំផុតដើម្បីព្យាបាលអង្គែ។

## ៣.១២ ចំណុចពណ៌ក្រហម /ការខាំរបស់សត្វល្អិត Red spots / Insects' Bites

### ៣.១២.១ រោគសញ្ញា

-ចំណុចក្រហម និងស្បែករលាត់

-បាត់បង់ឈាម និងលូតលាស់យឺត



រូបភាពទី ៣.៣ ៦ចំណុចក្រហម និងករលាតស្អែក

### ៣.១២.២ ការការពារ

-សម្អាតកន្លែងស្នាក់នៅរបស់រុយ (ងាយស្រួលឃើញក្នុងរោងចិញ្ចឹម)

-កំណត់ទីបរិវេណបន្តពូជរបស់វា សម្អាតកាកសំណល់ចំណីក្នុង និងជុំវិញបរិវេណទ្រុង យកគ្រម៉ផ្នែកខាងលើកន្លែងស្តុកលាមកចេញ ដែលភាគច្រើនជាបរិវេណបន្តពូជរបស់វា ជួសជុលបេតុងស៊ីម៉ង់ត៍ព្រោះការបាក់បែក និងប្រហោងក្នុងជញ្ជាំងទាក់ទាញរុយឲ្យពងដាក់។

### ៣.១២.៣ ការព្យាបាល

-បាញ់ថ្នាំសម្លាប់សត្វល្អិត (ទ្រីក្លរ៉ហ្វុង Trichlorfon) កន្លែងស្នាក់នៅរបស់រុយ

-បាញ់ថ្នាំប៊ុយតុក (Butox) រៀងរាល់ពីរខែម្តងលើខ្លួនសត្វ

-ចាក់ថ្នាំដិចសាមេតាសូន Dexamethasone ប្រសិនបើរលាត់ធ្ងន់ធ្ងរ និងអាម៉ុកស៊ីស៊ីលីន Amoxicillin ប្រសិនបើចំណុចទាំងនោះត្រូវទទួលការចម្លងមេរោគ (ឡើងហើមពណ៌ស្វាយ ក្រមរ)។

## ៣.១៣. ស្បែកឡើងក្រហម / រោល(រលាក)ដោយពន្លឺព្រះអាទិត្យ

ការពិនិត្យបរិស្ថាន និងសាកសួរព័ត៌មានធាប់រហស់លើម្ចាស់នឹងបង្ហាញថាសត្វស្ថិតក្រោមកំដៅព្រះអាទិត្យ។

### ៣.១៣.១ រោគសញ្ញា

-ស្បែកក្រហម

-ស្បែកឡើងសើម

-ជ្រូកបង្ហាញការឈឺចាប់/នៅមិនសុខ

-គ្រុនក្ដៅ



រូបភាពទី ៣.៣៧ ស្បែកក្រហមដោយបន្លឺ

រលាកដោយពន្លឺព្រះអាទិត្យធ្ងន់ធ្ងរអាចធ្វើឲ្យសត្វងាប់គឺដោយការខ្សោះជាតិទឹកធ្ងន់ធ្ងរ និងពេលដែលសីតុណ្ហភាពលើសពី៤២អង្សាសេ។

### ៣.១៣.២ ការការពារ

ត្រូវជានាឲ្យមានម្លប់ក្នុងទ្រុង។

ការព្យាបាល

-ស្រោចទឹកលើដងខ្លួនជ្រូក ដើម្បីបញ្ចុះកំដៅ

-ត្រូវជានាឲ្យផឹកទឹកគ្រប់គ្រាន់ ព្រោះជ្រូកអាចខ្សោះជាតិទឹក

-ចាក់ថ្នាំប៉ារ៉ាសេតាម៉ុល( Paracetamol ) ដើម្បីបញ្ចុះកំដៅដងខ្លួន និងការរលាក

## ៣.១៤ ការប្រែបួរពណ៌ស្វាយ/ជំងឺប៉េស្ត Purple discoloration / CSF

សញ្ញារបស់ជំងឺត្រចៀកខៀវចំពោះជ្រូកសាច់អាចដូចគ្នាខ្លាំងនឹងការរលាកដោយពន្លឺព្រះអាទិត្យ ប៉ុន្តែភ្នែកវាឡើងហើម ជ្រូកក្អក និងខូចផ្លូវបន្តពូជ ត្រូវបានគេសង្កេតឃើញក្នុងកសិដ្ឋាន។

### ៣.១៤.១ រោគសញ្ញា

-ស្បែកឡើងពណ៌ស្វាយ ដំបូងពេញត្រចៀក និងកន្ទុយរួចតាមដោយចុងច្រមុះ ផ្នែកខាងក្រោមជើង ពោះ និងខ្នង

-សីតុណ្ហភាពឡើងខ្ពស់លើសពី៤០អង្សាសេក្នុងពេលច្រើនថ្ងៃ

-ដើរដូចស្រវឹង មានសភាពចង់ដួលរួចទៅជាអង្គុយ ឬសំងិលខ្លួន



រូបភាពទី ៣.៣៨ រោគសញ្ញាប៉េស្ត្រ

### ៣.១៤.២ ការព្យាបាល និងការការពារ

មើលក្នុងជំពូកស្តីពីជំងឺប៉េស្តជ្រូក។

## ៣.១៥ ជំងឺឡើងខៀវស្វាយ (ស៊ីយ៉ាណូស៊ីស Cyanosis )

- **ជំងឺសាល់ម៉ូណែឡូសៈ** បាក់តេរីសាល់ម៉ូណែឡាឆ្លងរាលដាលលើមនុស្ស និងហ្វូងសត្វ ប្រភេទសាល់ម៉ូណែឡាខ្លះអាចបង្កជាជំងឺលើជ្រូក។

ការចម្លងជំងឺធ្ងន់ធ្ងរនៃមេរោគសាល់ម៉ូណែឡា កូឡេរ៉ាស៊ីស (Salmonella Choleraesuis) កើតមានលើជ្រូកដែលមានអាយុពី១២ទៅ១៤អាទិត្យ។

### ៣.១៥.១ រោគសញ្ញា

-ស្បែកនៃផ្នែកខាងចុង (កន្ទុយ ត្រចៀក ច្រមុះ និងជើង)ប្រែជាពណ៌ខៀវ

-គ្រុនក្តៅលើសពី៤០អង្សាសេ

-ហើមសួត ដកដង្ហើមមានការឈឺចាប់

-រាគមានក្លិនស្អុយ

-កើតលើជ្រូកអាយុតិចជាង៦ខែ



រូបភាពទី ៣.៣៩ កន្ទុយ និងត្រចៀកខៀវ

### ៣.១៥.២ ការការពារ

-កែលំអអនាមយ័គឺត្រូវរម្ងាប់មេរោគឲ្យទៀងទាត់

-ត្រូវប្រុងប្រយត្ន័ចំពោះទឹកសម្រាប់ជ្រូកត្រាំក្នុងទ្រុងប្រសិនបើមានជំងឺកើតឡើងវាគឺបរិយាកាសល្អសម្រាប់ការលូតលាស់របស់ពួកសាល់ម៉ូណែឡា

-វ៉ាក់សាំងមិនមានប្រយោជន៍

### ៣.១៥.៣ ការព្យាបាល

ត្រូវចាក់ថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វា(TMP+Sulfa) អង់រ៉ូផ្លុកសាក់ស៊ីន(Enrofloxacine) (ប៉ុន្តែវាអាចបង្កើតភាពធន់បានយ៉ាងលឿន)។

## ៣.១៦ ជំងឺត្រចៀកខៀវ PRRS

ជំងឺនេះត្រូវបានគេស្គាល់ច្បាស់ក្នុងប្រទេសកម្ពុជា និងត្រូវបានគេហៅថា"ជំងឺត្រចៀកខៀវ"

ការប្រែពណ៌ខៀវរបស់ត្រចៀក (Cyanosis) អាចមើលឃើញលើមេជ្រូកនិងជ្រូកមួយចំនួន ប៉ុន្តែវាកម្រ ប៉ុន្តែវាមិនមែនជារោគសញ្ញាចម្បងរបស់ជំងឺទេ។ មិនស៊ីចំណី គ្រុនក្តៅ រលូតកូននិងខ្សោយ ឬកូនជ្រូកកើតមកងាប់គ្រៀមគឺជាសញ្ញាសំអាងសម្គាល់ជំងឺនេះជាងសញ្ញាត្រចៀកខៀវ។

សូមមើលផ្នែកដែលបរិយាយអំពីជំងឺត្រចៀកខៀវ

### ការងាប់ភ្លាមៗ



រូបភាពទី ៣.៤០ រោគជំងឺត្រចៀកខៀវ

-គេឃើញសត្វងាប់រហ័ស

-សត្វងាប់ក្នុងពេលប្រហែល២៤ម៉ោងដោយគ្មានរោគសញ្ញាជាក់លាក់

-សត្វងាប់ក្នុងពេលពីរបីរម៉ោង ដោយមានរោគសញ្ញាអាចកំណត់បាន

-ការព្យាបាលមិនអាចធ្វើបាន ប៉ុន្តែការធ្វើរោគវិនិច្ឆ័យឲ្យបានល្អវាមានសារៈសំខាន់ណាស់ដើម្បីការពារគោផ្សេងទៀតកុំឲប៉ះពាល់ជាមួយសត្វដែលងាប់

## ៣.១៧ ជំងឺឈាមខ្មៅ( អង់ត្រាក់ Anthrax )

បង្កដោយបាក់តេរីឈ្មោះថាបាក់ស៊ីលុស អង់ត្រាក់ស៊ីស គោឆ្លងមេរោគតាមរយៈដី ជំងឺនេះអាចចម្លងមកមនុស្សតាមការប៉ះពាល់ ដកដង្ហើម ឬតាមមាត់

### ៣.១៧.១ រោគសញ្ញា

-ពីការមើលឃើញសត្វមានសភាពធម្មតាទៅជាងាប់ក្នុងពេលពីរបីម៉ោង គេឃើញសត្វងាប់ទៅហើយ

មានហូរឈាមពណ៌ខ្មៅ ពីមាត់និងទ្វារធំបន្ទាប់ពីងាប់ភ្លាមដងខ្លួនគោ មានសភាព ទន់យូរជាងគក្នុងករណីមិនស្វរស្រួច ស្រាវ

-ចុះខ្សោយយ៉ាងខ្លាំង និងគ្រុនក្តៅរហូតដល់៤១,៥អង្សាសេ

-ពិបាកដង្ហើម

-មានឈាមក្នុងទឹកនោម ទឹកដោះ លាមក

-មានចលនាមិននឹង និងប្រកាច់




រូបភាពទី ៣.៤១ ជំងឺឈាមខ្មៅ

### ៣.១៧.១ ស្លាកស្នាម

មិនត្រូវវះកាត់សាកសពគោដែលងាប់ទេ ព្រោះឈាមរបស់សត្វដែលងាប់នឹងសាយភាយមេរោគយ៉ាងច្រើនក្នុងដី។ មេរោគ នឹងបំលែងជាស្ពរ៍ ហើយរស់ក្នុងដីបានច្រើនឆ្នាំ។ ការផ្ទុះជំងឺភាគច្រើនកើតក្នុងកន្លែងដែលសត្វធ្លាប់ងាប់ដោយជំងឺឈាមខ្មៅ ពីពេលមុន។

ការព្យាបាល ត្រូវព្យាបាលឲ្យលឿនជាមួយប៉េនីស៊ីលីន ប៉ុន្តែជាទូទៅពេលដែលរោគសញ្ញាត្រូវបានកំណត់វាយឺតពេលរួចទៅហើយ។

### ៣.១៧.២ ការការពារ

-ការចាក់ថ្នាំការពារមានប្រសិទ្ធភាពណាស់ ប៉ុន្តែដើម្បីឲ្យមានភាពស៊ាំពេញលេញត្រូវការពេលពី១០ទៅ១៤ថ្ងៃ

-គោដែលប្រឈមគ្រោះថ្នាក់(ដូចជាគោដែលស៊ីស្មៅនៅវាលដែលមានសត្វមួយបានងាប់ដោយជំងឺឈាមខ្មៅ) ត្រូវធ្វើការព្យាបាលជាបន្ទាន់ជាមួយនឹងអង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពវែងដើម្បីបញ្ឈប់ការជ្រៀតចូលរបស់មេ រោគ

-ការចាក់ថ្នាំការពារ ពី៧ទៅ១០ថ្ងៃបន្ទាប់ពីការព្យាបាលដោយអង់ទីប៊ីយ៉ូទិក (ថ្នាំអង់ទីប៊ីយ៉ូទិកមិនត្រូវប្រើក្នុងពេលដំណាលគ្នានឹងធ្វើវ៉ាក់សាំងទេ។

## ៣.១៨ ជំងឺបូសខ្យល់

មូលហេតុបង្កឡើងដោយបាក់តេរី ក្លូស្ទ្រីយ៉ូម សូវី(Clostridium Chauvei)

-ជំងឺនេះមិនអាចចម្លងពីសត្វមួយទៅមួយទៀតទេ

-បាក់តេរីត្រូវលេបចូលពេលដែលគោស៊ីស្មៅខ្លីប៉ះចំស្ពរ៍ (ទម្រង់របស់បាក់តេរីដែលរស់បានច្រើនឆ្នាំ) ដែលអាចលេចឡើង ឬគោស៊ីប៉ះចំដីជាមួយស្មៅ។



ស្មៅខ្លីៗពេលចាប់ផ្តើមខែភ្លៀងនៅកន្លែងដែលមានគោងាប់ភ្លាមពីពេលមុន= គ្រោះថ្នាក់ខ្ពស់

រូបភាពទី ៣.៤២ ជំងឺបូសខ្យល់

### ៣.១៨.១ រោគសញ្ញា



រូបភាពទី ៣.៤៣ ហើមពោះ

-ជំងឺនេះច្រើនកើតលើសត្វក្មេងអាយុពី៦ទៅ២៤ខែក្នុងលក្ខណ្ឌល្អ

-សត្វងាប់យ៉ាងលឿន ពី១២ទៅ៤៨ម៉ោងដែលជា រឿយៗគ្មានរោគសញ្ញា

-ក្នុងករណីជាច្រើន សត្វត្រូវបានគេឃើញងាប់ដោ យគ្មានសង្កេតឃើញមានឈឺពីមុន

-ករណីមិនសូវស្រួចស្រាវ

-ខ្វកជើងធ្ងន់ធ្ងរ

-ការហើមដែលមានឮសម្លេងប្រែសៗវិវត្តក្នុងសាច់ដុំត្រគៀក ក និងស្មារ

-ដំបូងការហើមមានទំហំតូច ក្តៅ និងមានការឈឺចាប់

-ដោយជំងឺនេះវិវត្តលឿន ការហើមរីកធំ មានសម្លេងប្រែសៗពេលយើងស្ទាបវា

-ស្បែកចាប់ផ្តើមត្រជាក់ និងស្ពឹក

### ៣.១៨.២ ស្លាកស្នាម

សាច់ដុំដែលទទួលផលប៉ះពាល់ផ្លាស់ប្តូរពណ៌ពីក្រហមចាស់ទៅជាខ្មៅនិងឡើងដូចអេប៉ុងដែលផ្តល់នូវអារម្មណ៍ដែលមានសម្លេងប្រែសៗពេលដែលសង្កត់លើសាច់ដុំ។



ជំងឺនេះគេហៅថាប្លូសខ្យល់ព្រោះសាច់ដុំក្លាយជាខ្មៅដោយមានការរាយលុករបស់មីក្រុប

រូបភាពទី ៣.៤៤ ស្លាកស្នាមលើសាច់ដុំ

ការព្យាបាល ត្រូវធ្វើឲ្យបានលឿនក្នុងដំណាក់កាលខ្វកជើងដែលមានការហើមក្តៅ និងឈឺចាប់ដោយចាក់ថ្នាំអំពីនីស៊ីលីន( Penicillin ) ឬអាម៉ុកស៊ីស៊ីលីន( Amoxicillin )កម្រិតខ្ពស់

### ៣ ១៨.៣.ការការពារ

-ការចាក់ថ្នាំការពារមានប្រសិទ្ធភាពដែលជាទូទៅកសិករប្រើវ៉ាក់សាំង“៧មុខ” ប្រឆាំងជំងឺបង្ករដោយក្លូស្ទ្រីឌីយ៉ូមដូចជាជំងឺបូសខ្យល់ តេតាណូស បូទុយលីស...

-គោដែលប្រឈមមុខនឹងគ្រោះថ្នាក់ (គោដែលស៊ីស្មៅនៅកន្លែងដែលធ្លាប់មានសត្វងាប់ដោយជំងឺបូសខ្យល់ពីមុន)។ ត្រូវធ្វើការព្យាបាលឲបានលឿនជាមួយនឹងថ្នាំអាម៉ុកស៊ីស៊ីលីនដែលមានសកម្មភាពវែង (Long – acting amoxicillin) ដើម្បីបញ្ឈប់ការចម្លងសម្ញំជំងឺដែលមានសក្តានុពល។

-ការចាក់ថ្នាំការពារអាចធ្វើទៅបានត្រឹមតែ៧ទៅ១០ថ្ងៃបន្ទាប់ពីការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក (ថ្នាំអង់ទីប៊ីយ៉ូទិកមិនត្រូវប្រើពេលជំណាលគ្នានឹងការធ្វើវ៉ាក់សាំងទេ)។

## ៣.១៩ ជំងឺសារទឹក (HS)

-បង្ករដោយបាក់តេរីប៉ាស្ទឺរ៉ែឡាមុលតូស៊ីដាប្រភេទបេ (Pasteurella multocida Type B)

-ក្របីងាយទទួលរងជំងឺនេះជាងគោ

-រយៈពេលសម្ញំមេរោគខ្លីគឺសត្វចាប់ ផ្តើមឈឺនៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចម្លងតាមរយៈការប៉ះជាមួយសត្វដែលឈឺ។



ក្របីមានភាពងាយទទួលជំងឺជាគោ

រូបភាពទី ៣.៤៥ ជំងឺសារទឹក

### ៣.១៩.១ រោគសញ្ញា

ការងាប់ចាប់ផ្តើមក្នុងពេល៦ទៅ២៤ម៉ោង ចំពោះជំងឺសារទឹកវាអាចសង្កេតឃើញរោគសញ្ញាពិសេសមុនពេលងាប់៖

- វារែកមិនចង់ដើរ
- គ្រុនក្តៅ
- ចេញទឹកមាត់ និងហៀរសំបោរ
- ពិបាកដកដង្ហើម ហូរឈាមចេញ
- ហើមក្បាល កនិងតំបន់សាច់ទ្រូង










រូបភាពទី ៣.៤៦ សត្វពិបាកដកដង្ហើម

**ស្លាកស្នាម**

ថ្គាមនិងកហើម ដែលមានជាតិ អន្ទិលពណ៌លឿងខ្ចី យ៉ាងច្រើន។




**៣ ១៩.២.ការព្យាបាល**

ជំងឺវិវត្តយ៉ាងលឿន និងវាមានការលំបាកក្នុងការព្យាបាលទាន់ពេលវេលា

-ប្រើថ្នាំពួកស៊ុលហ្វូណាមិត Sulfonamide (ចាក់សសៃវ៉ែន) ថ្នាំតេត្រាស៊ីគ្លីន Tetracyclyne ចាក់សសៃវ៉ែន) និងថ្នាំអង់រ៉ូផ្លុកសាក់ស៊ីន (Enrofloxacine) ត្រូវបានណែនាំឲ្យព្យាបាលជំងឺនេះ

-ចាក់លើកទី១ដោយប្រើកម្រិតទ្វេរដង (២០មីលីក្រាម/១គីឡូក្រាម)

-វាចាំបាច់ត្រូវព្យាបាលគោដែលប៉ះពាល់ជិតដិតនឹងសត្វដែលឈឺដើម្បីបញ្ឈប់ជំងឺនេះក្នុងដំណាក់កាលសម្ងំមេរោគ

### ៣ ១៩.៣.ការការពារ

ដោយការចាក់វ៉ាក់សាំង

- វ៉ាក់សាំងត្រូវធ្វើក្នុងចន្លោះរយៈពេល៦ខែ ជាពិសេសត្រូវចាក់មុនរដូវភ្លៀង
- មានការការពារបានល្អលើកូនគោដែលទទួលអង្គការពារពីមេរបស់វា។ មេគោត្រូវចាក់ថ្នាំការពារក្នុងកំឡុងខែចុងក្រោយនៃការផើម។

## ៣.២០ ការពុលអ៊ុយរ៉េ

គោត្រូវបានទាក់ទាញដោយក្លិនរបស់ជីអ៊ុយរ៉េ និងវាធ្លាប់ស៊ីបាវដែលមានសល់ថ្នាំគីមី



រូបភាពទី ៣.៤៧ ការពុលដោយអ៊ុយរ៉េ

### ៣ ២០.១.រោគសញ្ញា

-រយៈពេលពីពេលដែលស៊ីជីអ៊ុយរ៉េចូលទៅដល់ពេលចេញសញ្ញាគ្លីនិកមើលឃើញខាងក្រៅគឺ ២០ទៅ៦០នាទី

-ការងាប់នឹងកើតមានក្នុងកំឡុងពេល២ម៉ោង

### ៣.២០.២ សញ្ញាដំបូង

-កន្ត្រាក់ត្រចៀកនិងសាច់ដុំមុខ សង្កៀរធ្មេញ មានហៀរទឹកមាត់បែកពពុះ

-មិនអាចរក្សាលំនឹងនិងកន្ត្រាក់សាច់ដុំ និងមានអាកប្បកិរិយាឆេវឆាវ

-ហើមពោះ

-ដកដង្ហើមលឿននឹងខ្លាំង




រូបភាពទី ៣.៤៧ ហៀរទឹកម៉ាត់ និងបែកពពុះ

ការព្យាបាលបន្ទាន់ឲ្យគោផឹកទឹកខ្មេះពី២ទៅ៥លីត្រ (ឬអាស៊ីតអាសេទិកកម្រិត ៥%)

### ៣.២១ ជំងឺអុតក្តាម FMD

បង្ករដោយវីរុស ដែលថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពទេ។ វីរុសជំងឺនេ មាន ៧ ប្រភេទ ហើយប្រភេទវីរុសអូ អា និងអាស៊ី១ ត្រូវបានរកឃើញលើគោក្នុងប្រទេសកម្ពុជា។ វីរុសអាចសាយភាពពីជ្រូកទៅគោ ព្រោះជ្រូកបញ្ចេញបរិមាណវីរុសយ៉ាងច្រើនហើយគោងាយទទួលជំងឺនេះតាមរយៈការចម្លងតាមខ្យល់

#### ៣.២១.១ រោគសញ្ញា

- គ្រុនក្តៅ និងមិនឃ្លានចំណី។ មិនឃ្លានចំណីដោយសារគ្រុនក្តៅ និងពងដោរបែកក្នុងមាត់
- ដែលធ្វើឲ្យវាមានការឈឺចាប់ហើយធ្វើឲ្យសត្វមិនអាចស៊ីចំណីបាន

- ពងដោរលេចលើអណ្តាត អញ្ចាញធ្មេញ ជើងធ្មេញ បបូរមាត់ (កម្រឃើញលើជ្រូក) បណ្តាលឲ្យចេញទឹកមាត់យ៉ាងច្រើន

- ស្លាកស្នាមដំបៅត្រូវបានឃើញនៅជុំវិញគល់ក្រចកជើងសត្វដែលឆ្លងជំងឺ ផ្អៀងពីជើងមួយទៅមួយទៀតដោយសារការទន់ជើង

- ពងដោរអាចលេចចេញលើក្បាលដោះ និងកន្សោមដោះ
- ការងាប់ទូទៅកើតលើកូនគោព្រោះការខូចសាច់ដុំបេះដូង




រូបភាពទី ៣.៤៨ រោគសញ្ញាជំងឺអ៊ុតក្តាម

#### ៣ ២១.២.ការព្យាបាល

គោលបំណងនៃការព្យាបាលគឺបង្ការការចម្លង របស់បាក់តេរីដោយត្រូវចាក់៖

- ទ្រីមេតូព្រីមជាមួយស៊ុលហ្វា TMP+Sulfa ឬ អុកស៊ីតេត្រាស៊ីគ្លីន OTC ពី៥ទៅ៧ថ្ងៃ
- លាងដំបៅជើងជាមួយសាប៊ូ ឬសាច់ជូរ ម្ជូរ ជើងបាញ់ថ្នាំសំលាប់មេរោគ ដែលមាន
- ជាតិវីយូលេហ្សង់ត្យាន និងអុកសីតេត្រាសីគ្លីនលើជើង បន្ទាប់ពីសម្អាតរួច




រូបភាពទី ៣.៤៩ ដំបៅនៅខ្វកជើង

សត្វមិនអាចដើរ ស៊ីនិងផឹកបានដូច្នេះត្រូវ៖

- ឲ្យស្មៅ និងកន្ទក់ និងទឹក
- ដាក់សត្វក្នុងម្លប់ដើម្បីកាត់បន្ថយការខ្សោះជាតិទឹក

### ៣ ៣ .២១.ការការពារ

វ៉ាក់សាំងមានប្រសិទ្ធភាព ហើយវាមានប្រយោជន៍ក្នុងការធ្វើវ៉ាក់សាំងគោពីរដងក្នុងមួយឆ្នាំ ចាំបាច់ត្រូវប្រើវ៉ាក់សាំងដែលមានវីរុសបីប្រភេទគឺអូ អា អាស៊ី១។

គោអាចវិត្តភាពស៊ាំបានយ៉ាងលឿនបន្ទាប់ពីការចាក់វ៉ាក់សាំង។ វាមានប្រសិទ្ធភាពក្នុងការចាក់វ៉ាក់សាំងពេលដែលកសិករដឹងថាមានករណីសង្ស័យកើតជំងឺនេះនៅភូមិជិតគ្នា ឬក្នុងភូមិរបស់ខ្លួន។ ជាអកុសល វាមិនមានភាពងាយស្រួលក្នុងការទិញវ៉ាក់សាំងក្នុងសភាពបន្ទាន់ ហើយជារឿយៗអ្នកផ្គត់ផ្គង់អស់វ៉ាក់សាំងពីស្តុកយ៉ាងឆាប់រហ័សពេលដែលការផ្ទុះជំងឺអូសបន្លាយ




រូបភាពទី ៣.៥០ ការទុកដាក់ថ្នាំ

### ៣.២២ ជំងឺផ្លូវដង្ហើមជំងឺរលាកសួត ( Pneumonia )

សត្វពាហនៈទាំងអស់ងាយទទួលរងជំងឺផ្លូវដង្ហើម ប៉ុន្តែជាទូទៅវាចាប់ផ្តើមពេលដែលសត្វមានបញ្ហាស្រ្តេស។

### ៣.២២.១ បុព្វហេតុ

សភាពស្ត្រេសជាទូទៅរួមមានការផ្លាស់ប្តូរសីតុណ្ហភាព ធ្វើការអស់កម្លាំង ផ្តល់ចំណីនិងទឹកមិនគ្រប់គ្រាន់។ លក្ខខណ្ឌ័ស្ងួតនិងមានធូលីក៏អាចបង្កើនបញ្ហានេះផងដែរ។

មេរោគដែលជាប់ទាក់ទងនឹងជំងឺរលាកសួតគឺប៉ាស្ទឺរ៉ែឡា។ មេរោគនេះជាធម្មតារស់នៅក្នុងផ្លូវដង្ហើមផ្នែកខាងលើ (រន្ធច្រមុះ បំពង់អាហារ និងដើមក) ប៉ុន្តែមិននៅក្នុងបំពង់ខ្យល់និងសួតទេ។



គោក្មេងៗមានដងខ្លួនសូមស្ថិតក្រោមភ្លៀងនោះមេរោគប៉ាស្ទឺរ៉ែឡាអាចធក់ឪកាសដើម្បីបំបែកខ្លួន និងទន្ទ្រានសួត

រូបភាពទី ៣.៥១ ការស្រេស្រ្តនៃសត្វ

ចំពោះគោដែលមានសុខភាពល្អពួកប៉ាស្ទឺរ៉ែឡាបំបែកខ្លួនយឺតៗហើយកោសិកាមោក្រូហ្វា (Macrophage) និងអង់ទីគ័របំផ្លាញពួកវា។ ប៉ុន្តែក្នុងករណីសត្វមានបញ្ហាស្ត្រេសភាពស៊ាំនឹងចុះខ្សោយនិងមិនអាចគ្រប់គ្រងពតត្បាតរបស់ប៉ាស្ទឺរ៉ែឡាលើសួតបានទេ។ លើសពីនេះប្រសិនបើផ្លូវដង្ហើមត្រូវក្រហល់ក្រ ហាយដោយធូលីនេះមេរោគអាចវិវត្តបានយ៉ាងស្រួល។

លទ្ធផលគឺកើតជំងឺរលាកសួត

### ៣.២២.២ រោគសញ្ញា

ពេលដែលពួកប៉ាស្ទឺរ៉ែឡាត្រូវបានគេហៅវាថាប្រភេទបេ (Type B) វាបង្ករជាជំងឺសារទឹកដែលធ្វើសត្វងាប់លឿន (មើលក្នុងផ្នែកជំងឺសារទឹក)។ ប្រភេទផ្សេងទៀតរបស់ប៉ាស្ទឺរ៉ែឡាបង្កជារលាកសួតមិនសូវស្រួចស្រាវ ប៉ុន្តែជំងឺរលាកសួតគឺគ្រប់ពេលបង្ករជាការឈឺធ្ងន់ធ្ងរដែលត្រូវធ្វើការព្យាបាលភ្លាមៗ។

## ៣.២៣ ជំងឺរលាកសួតអាចធ្ងន់ធ្ងរក្នុងគោ និងគោធំ

- ស្ទឹង ឬញាក់ញីយ៉ាងខ្លាំងកើនឡើង
- គ្រុនក្តៅលើសពី៤០អង្សាសេនិង បាត់បង់ការស៊ីចំណី
- ក្អក
- ហៀរសំបោរ




រូបភាពទី ៣.៥២ ការក្អក និងផ្លូវដង្ហើម

### ៣.២៣.១ ស្លាកស្នាម

ការកើតដំបៅរលួយធ្ងន់ធ្ងរ (សួតលែងមានសភាពយឺតតទៅទៀត) សសៃធ្នារ Fibrinous (សារធាតុខាប់ស្អិត) នៃការរលាកសួតចាប់ផ្តើមវិវត្ត។







រូបភាពទី ៣.៥៣ ស្លាកស្នាមលើសួត

### ៣.២៣.២ ការព្យាបាល

ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជា តេត្រាស៊ីគ្លីន ឬ ផ្លរហ្វេនីកុល (Tetracycline, Florfenicol) ជាមួយថ្នាំប្រឆាំងនឹងការរលាកដូចជាប៉ារ៉ាសេតាម៉ុល តុលហ្វេឌីន គេតូផេន (Paracetamol, Tolfedine, Ketophen)

## ៣.២៤ ព្រូនក្នុងសួត

ព្រូននេះត្រូវបានគេហៅថា ឌីទ្យោកូលុស (Dictyocaulus) ព្រូនសួតបង្ករជាជំងឺសួតលើគោ ដែលមានសញ្ញាគ្លីនិកដូចគ្នានឹងជំងឺបង្ករដោយមីក្រុប។ ព្រូនសួតជំពេញវ័យរស់ក្នុងទងសួតហើយផលិតស៊ុតជាច្រើន។



រូបភាពទី ៣.៥៤ ព្រូនក្នុងស្បូត



រូបភាពទី ៣.៥៤ សត្វកើតស្បូត

### ៣.២៤.១ រោគសញ្ញា

-ក្អក

-សីតុណ្ហភាពអាចឡើងដល់៤០អង្សាសេក្នុងករណីការរំខានធ្ងន់ធ្ងរ

-ហៀរសំបោរ

-សត្វស្រេកថ្ងរ

-ជាទូទៅវាធ្វើឲ្យដងខ្លួនស្គមស្គាំង និងរោមបះ

### ៣.២៤.២ ការការព្យាបាល ត្រូវធ្វើ១ដង

- ថ្នាំអាល់បង់ដាសុល )Albendazole) ១០មីលីលីត្រក្នុង១០០គីឡូក្រាម
- ថ្នាំអ៊ីវែម៉ិចទីន (Ivermectine) ១មីលីលីត្រក្នុង៥០គីឡូក្រាម

ក្នុងករណីធ្ងន់ធ្ងរ( សីតុណ្ហភាពខ្ពស់ និងអស់កម្លាំង) ត្រូវប្រើថ្នាំប្រឆាំងនឹងបរាសិតរួមជាមួយថ្នាំអង់ទីប៊ីយ៉ូទិកដូចការព្យាបាលជំងឺរលាកស្បូតដែរ

## ៣.២៥ ជំងឺរលាកពោះវៀន

### ៣ ២៥.១.ដង្កូវថ្លើម

វាបង្ករឡើងដោយបរាសិតមួយប្រភេទគឺហ្វាស្យូឡា អេប៉ាទីកា(fasciola hepatica) ។ កូនដង្កូវត្រូវបានសត្វលេបចូលពេលស៊ីស្មៅ។ វដ្តរបស់ហ្វាស្យូឡាត្រូវការមានខ្យងមួយប្រភេទ ដែលហេតុដូច្នេះហើយតំបន់ដែលសើមហាក់ការចម្លងពួកហ្វាស្យូឡាច្រើន។

### ៣.២៥.២ រោគសញ្ញា

ជំងឺដង្កូវថ្លើមអាចស្រួចស្រាវ មិនសូវស្រួចស្រាវ ឬរ៉ាំរ៉ៃដែលសញ្ញាលើមេគោគឺការខូចខាតថ្លើមដែលមានរោគសញ្ញាប្រែប្រួលអាស្រ័យនឹងចំនួនដង្កូវមានក្នុងថ្លើម

ជំងឺនេះធ្វើឲ្យចេញឈាមហើយជាលិកាខូចខាតដោយសារការបម្លាស់ទីរបស់កូនដង្កូវមិនទាន់ពេញវ័យទៅក្នុងថ្លើម និងការខូចខាតបំពង់ទឹកប្រមាត់ (ស្ទះ)និងបាត់បង់ឈាមដោយសារដង្កូវពេញវ័យ។



ពួកហ្វាស្យូឡារាំងខ្ទប់បំពង់និងបង្កឲ្យចេញឈាម

រូបភាពទី ៣.៥៥ រលាកថ្លើម

**សញ្ញារួមមាន៖**

បាត់បង់ការស៊ីចំណី

- ស្រកទម្ងន់ និងស្គមសត្វស្លេកស្លាំង (ពណ៌ភ្នាសសើម ក្លាយជាពណ៌ស (ដែលជាធម្មតាវាមាន ពណ៌ផ្កាឈូក)

- រាគរ៉ាំរ៉ៃ
- ហើមថ្គាម
- បាត់បង់ការស៊ីចំណី






ពណ៌ធម្មតារបស់សន្ទានជាលិកាភ្នែក




រូបភាពទី ៣.៥៦ ព្រូនខាងក្នុង

### ៣ ២៥.៣.ការព្យាបាល

ត្រូវចាក់ថ្នាំដូចជា៖ ដូវេនិច(Dovenix) អាល់បង់ដាសុល (Albendazole) ពីរដងក្នុងមួយឆ្នាំ

### ក .ព្រូនខាងក្នុង

ព្រូនក្នុងពោះវៀនគោឆ្លងដោយសារការលេបកូនដង្កូវ(larva) ពេលស៊ីស្មៅ។ ព្រូនពេញវ័យក្នុងរាងកាយគោផលិតស៊ុតដែលឆ្លងកាត់ទៅក្នុងលាមក។ ស៊ុតញាស់ក្នុងស្មៅដែលវិវត្តជាកូនដង្កូវហើយបម្លាស់ទីក្នុងវាលស្មៅដែលគោស៊ីចំពួកវា។

- ស្រកទម្ងន់
- ការស៊ីចំណីថយចុះ ប៉ុន្តែគ្មានគ្រុនក្តៅ
- រាគមានពណ៌បៃតង
- រោមបះ






រូបភាពទី ៣.៥៧ ការះកើតព្រូន

### ៣ ២៥.៤.ការព្យាបាល

- ប្រើថ្នាំឡេវ៉ាមីសុល (Levamisole) អាល់បង់ដាសុល Albendazole...
- អ៊ីវែម៉ិចទីន ១គីឡូក្រាមដោយចាក់ក្រោមស្បែក៥០/មីលីលីត្រ១គី %

## ៣.២៦ ជំងឺកុកស៊ីដ្យូស៊ីស Coccidiosis

វាបង្កឡើងដោយបរាសិតដែលតូចមានកោសិកាតែមួយ។

កុកស៊ីដ្យូស៊ីសកើតមានជារឿយៗលើកូនគោអាយុពី១ទៅ៦ខែ

### ៣.២៦.១ រោគសញ្ញា

-បាត់បង់ការស៊ីចំណីនិងស្រកទម្ងន់ដែលជាទូទៅធ្វើឲ្យសត្វស្គម

-រាកខ្លាំងដែលអាចមានឈាមនិងសំបោរ

-ឈឺចាប់ពេលជុះលាមក (ឈឺពោះ) ក្នុងស្ថានភាពជំងឺមិនសូវស្រួចស្រាវ (កើតជាទូទៅ)

-ខូចរោម និងលក្ខណ្ឌទូទៅមិនល្អ

-រាគប្រែជាពណ៌ខ្មៅនិងមានដូចសំបោរហើយអាចបង្កើតជាការប្រឡាក់ជុំវិញកន្ទុយ។



រូបភាពទី ៣.៥៨ ការប្រែពណ៌

ការព្យាបាលគឺត្រូវចាក់ថ្នាំស៊ុលហ្វា៣៣ (Sulfa33) រយៈពេល៥ថ្ងៃ។

## ៣.២៧ ជំងឺអ៊ីកូលី E.Coli

កូនគោលេបចូលបាក់តេរីពេលដែលបៅដោះឬវាអាចចូលតាមរយៈទងផ្ចិត។ រាគបង្កដោយអ៊ីកូលីកើតមានក្នុងកំឡុងថ្ងៃដំបូងបន្ទាប់ពីកើត។

### ៣ ២៧.១.រោគសញ្ញា

- រាគមានពណ៌លឿង ស
- កូនគោចុះខ្សោយយ៉ាងខ្លាំង ឈប់បៅ
- ការចម្លងលើផ្ចិត សន្លាក់ និងការចម្លងមេរោគក្នុងឈាមទូទៅអាចកើតមានផងដែរ។



រូបភាពទី ៣.៥៩ រាគពណ៌ស និងលឿង

### ៣ ២៧.២.ការព្យាបាល

កូនគោដែលទើបកើតមកមានរាគត្រូវផ្តាច់ទឹកដោះជាបន្ទាន់ពេលដែលកូនគោបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (ភ្នែកឡើងរូង) វាចាំបាច់ត្រូវព្យួរសេរ៉ូមតាមសសៃវ៉ែន ឬត្រូវបញ្ច្រកតាមមាត់នូវទឹកដែលលាយជាមួយអេឡិចត្រូលីត (electrolytes) (ទឹកតែមួយមុខមិនមានប្រសិទ្ធភាពទេ)។ នៅជនបទគ្មានអេឡិចត្រូលីត ដូចនេះអាចលាយស្ករបើស្លាបព្រាធំនិងអំបិលកន្លះស្លាបព្រាធំក្នុងទឹកពីរលីត្រ។ កូនគោត្រូវផឹកទឹក១លីត្ររៀងរាល់៦ម៉ោងម្តង។ កូនគោដែលខ្សោះជាតិទឹកភាគច្រើនទទួលរងដោយសីតុណ្ហភាពដងខ្លួនចុះទាប និងត្រូវដាក់វានៅកន្លែងកក់ក្តៅជាពិសេសពេលយប់។

គួរចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជា កូលីស្ទីន ទ្រីមេតូព្រីមជាមួយស៊ុលហ្វា

### ៣ ២៧.៣.ការការពារ

កូនគោកើតមកដោយគ្មានអង់ទីគ័រប្រឆាំងនឹងជំងឺអ៊ីកូលី។ ពួកវានឹងទទួលអង់ទីគ័រនេះពីទឹកដោះមេវា។ ប៉ុន្តែមានតែទឹកដោះដំបូង (Colostrum) ដែលមានអង្គការពារច្រើននិងវាផលិតតែប៉ុន្មានម៉ោងបន្ទាប់ពីកើតតែប៉ុណ្ណោះ។ដូចនេះវាចាំបាច់បំផុតត្រូវឲកូនគោបៅទឹកដោះដំបូងនៅកំឡុងពេល១២ម៉ោងបន្ទាប់ពីកើត។




### ៣.២៨ ជំងឺសាល់ម៉ូណែឡា Salmonellosis

ក្នុងបរិដ្ឋានពួកសាល់ម៉ូណែឡារស់បានពី៤ទៅ៥ឆ្នាំក្នុងទឹក ដី ធូលី កន្លែងសើមដែលមិនប៉ះជាមួយពន្លឺព្រះអាទិត្យផ្ទាល់។ ការធ្វើអនាមយ័ជុំវិញផ្ទះនិងក្នុងភូមិជាមធ្យោបាយសំខាន់ក្នុងការគ្រប់គ្រងពួកសាល់ម៉ូណែឡា។



កន្លែងយ៉ាងល្អបំផុតសម្រាប់ការលូតលាស់របស់ពពួកសាល់ម៉ូណែឡា

រូបភាពទី ៣.៦០ ជំងឺសាល់ម៉ូណែឡា

#### ៣.២៨.១ រោគសញ្ញា

ការចម្លងអាចមានចាប់ពីការមើលទៅសត្វដែលផ្ទុក"មានសុខភាពល្អ"រហូតបង្ហាញសញ្ញាចម្លងស្រួចស្រាវ

- គ្រុនក្តៅខ្លាំង

- ចំពោះគោធំយើងអាចឃើញរាគធូន់ធូរនិងមានក្លិនស្អុយខ្លាំងព្រមទាំងបរិមាណឈាមនិងសំបោរប្រែប្រួលក្នុងលាមក និងបំណែកទ្រនាប់ខាងក្នុងពោះវៀន។ ការរលូតអាចកើតមានចំពោះគោដែលឆ្លងជំងឺ។ ក្នុងករណីរ៉ាំរ៉ៃដែលកើតមានតាមពីក្រោយដំណាក់កាលស្រួចស្រាវធ្វើឲគ្រុនក្តៅកើតឈប់ៗ រាគរាវដូចទឹកដែលធ្វើឲខ្សោះទឹក និងស្រកទម្ងន់។

ចំពោះកូនគោអាយុ២ទៅ១២អាទិត្យ ដែលជំងឺនេះច្រើនរាតត្បាលលើកូនគោដែលមិនបានបៅទឹកដោះដំបូង។ វាបង្កឲកើតជាគ្រុនក្តៅខ្លាំង រាគពណ៌លឿងច្រើនជាមួយ ឬគ្មានឈាម និងសំបោរ ហើយធ្វើឲ្យខ្សោះជាតិ ទឹកលឿន និងការងាប់អាចកើតមាន ក្នុងកំឡុងពេល២៤ទៅ៤៨ម៉ោង។



រូបភាពទី ៣.៦១ រាគធូន់ធូរ

### ៣ ២៨.២.ការព្យាបាល

- ដូចការព្យាបាលជំងឺអ៊ីកូលី ការធ្វើឲ្យមានជាតិទឹកឡើងវិញត្រូវអនុវត្តជាបន្ទាន់

- ការប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិកមិនសូវប្រាកដប្រជាព្រោះពួកសាល់ម៉ូណែឡាវិវត្តច្រើនធន់នឹងថ្នាំអង់ទីប៊ីយ៉ូទិក

- ការព្យាបាលត្រូវធ្វើយ៉ាងតិច៦ថ្ងៃ

- ថ្នាំដូចជាទ្រីមេតូព្រីម ជាមួយស៊ុលហ្វា កូលីស្ទីនជាមួយអំពីស៊ីលីន អង់រ៉ូផ្លុកសាក់ស៊ីន អាចប្រើបានប៉ុន្តែការធន់នឹងថ្នាំងទាំងនេះកើតមានយ៉ាងលឿន។ ជាទូទៅពួកសាល់ម៉ូណែឡាធន់នឹងថ្នាំតេត្រាស៊ីគ្លីន។

## ៣.២៩ ជំងឺរាគដោយឱកាស

ពេលខ្លះរាគគឺជារោគសញ្ញាតែប៉ុណ្ណោះ គោមិនបានបង្ហាញរោគសញ្ញាទូទៅប៉ុន្តែយើងអាចសង្កេតឃើញលាកមកវាដូចទឹក។




ជាទូទៅវាបង្កដោយកំហុសក្នុងការផ្តល់ចំណីដូចជា៖

រូបភាពទី ៣.៦២ រាគប្តូរចំណី

- ការផ្លាស់ប្តូរចំណីសត្វលឿន
- នៅដើមរដូវភ្លៀងគោស៊ីស្មៅខ្ចីច្រើនបណ្តាលឲ្យរាគ
- ចំណីចាស់ រលួយ ឡើងមេ (ពោត កន្ទក់)

### ៣.២៩.១ ការព្យាបាល

- ស្មៅឬចំណីថ្មីត្រូវផ្តល់ឲ្យវាបន្តិចម្តងៗ
- ដាក់គោក្រោមផ្ទះនិងផ្តល់ចំបើងដែលមានគុណភាពល្អ
- យកចំណីដែលខូចចេញ

## ៣.៣០ ជំងឺហើមពោះ

### ៣ ៣០.១.រោគសញ្ញា

-ជំងឺហើមពោះគឺជាប៉ោងផ្នែកខាងឆ្វេងរបស់មេគោ

-គោះពោះគោបង្ហាញថាមានឧស្ម័ន ឬពពុះពេញ

- គោមិនអាចភើរឧស្មន័ក្នុងពោះបានទេ

-ការទំពារអៀងឈប់

-ពោះឡើងធំដូចស្គរដែលសង្កត់លើសន្ទះទ្រូងធ្វើឲការដកដង្ហើមមានការលំបាកខ្លាំង





ហើមប៉ោងផ្នែកខាងស្តាំងដោយសារការដើម

រូបភាពទី ៣.៦៣ ការហើមពោះ

-ការស្ទះ វត្ថុផ្សេងៗ ជារឿយៗវាបង្ករដោយការស្ទះក្នុងបំពង់អាហារ (ស្នូលពោត ផ្លែឈើ...) បសុពេទ្យត្រូវស្ទាបបំពង់អាហារដោយស្បែកដើម្បីកំណត់កន្លែងស្ទះ





ការស្ទាបដើមកនិងបំពង់អាហារ

រូបភាពទី ៣.៦៤ ការស្លាក់នៃសត្វ

### ៣.៣០.១ ការព្យាបាល

បសុពេទ្យត្រូវយកចំណីដែលស្ទះចេញដោយដៃ។

ចោះពោះគោដោយប្រើត្រូការ Trocar ពេលដែលការហើមពោះធ្ងន់ធ្ងរដើម្បីបញ្ចេញខ្យល់។ គ្រប់ពេលត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដើម្បីបង្ការជំងឺអាប់សែស្រោមពោះ។

វាអាចកើតមានយ៉ាងលឿន ជាពិសេសពេលដែលសត្វស៊ីស្មៅលើវាលស្មៅដែលសើមនៅពេលព្រឹក។ គោស៊ីស្មៅខ្ចីច្រើនពេកពេលដែលរដូវភ្លៀងចាប់ផ្តើម។ វាអាចបណ្តាលឲ្យ សត្វងាប់ភ្លាមៗ។

### ៣.៣០.២ ការការពារ

មិនត្រូវឲ្យគោដែលឃ្លានខ្លាំងស៊ីស្មៅដែលមានគ្រោះថ្នាក់។

### ក .ការព្យាបាល

ប្រកប្រេង៣០០ទៅ៥០០មីលីលីត្រតាមមាត់

- ការពុលជីអ៊ុយរ៉េ




រូបភាពទី ៣.៦៥ សត្វស៊ីស្មៅខ្ចី

បន្ទាប់

វាអាចកើតមានពេលដែលគោលិចដីអ៊ុយរ៉េដែលនៅសល់ក្នុងបារ។

បុព្វហេតុទូទៅទីពីរគឺពេលដែលកសិករប្រើប្រាស់បច្ចេកទេសស្រោចដីអ៊ុយរ៉េដោយផ្ទាល់លើចំបើងដើម្បីបង្កើនគុណភាពចំណី បច្ចេកទេសនេះត្រូវការឲ្យមានកម្រិតសមរម្យ




រូបភាពទី ៣.៦៦ ផ្ទុកចំបើង

**ខ .រោគសញ្ញា**

-ហើមពោះធ្ងន់ធ្ងរ

-ញាក់ញ័រសាច់ដុំដែលធ្វើឲសត្វមិនអាចទប់លំនឹងបាន

-ការងាប់កើតមានក្នុងពេល២ម៉ោងការព្យាបាល ត្រូវប្រកទឹកខ្មេះ២ទៅ៥លីត្រតាមមាត់។

## ៣.៣១ បញ្ហាស្បែក

### ៣ ៣១.១.បរាសិតខាងក្រៅ

### ក. រុយ

មានរុយច្រើនប្រភេទអាចរំខានគោ។ ប្រភេទខ្លះគឺបឺតឈាមដែលបង្កជាអស់ឈាមជាពិសេសលើសត្វក្មេង មានស្លាកស្លាមរបស់ស្បែក និងការរំខានជាអចិន្ត្រៃពោះការខាំមានការឈឺចាប់។ ប្រភេទខ្លះមិនមែនបឺតឈាម បង្កជាការរំខានពេលដែលពួកវាមានចំនួនច្រើន (មានរុយច្រើនជាង១០០/សត្វមួយក្បាល )ពួកវាអាចសាយភាយបាក់តេរីឬវីរុសនិងពួកវាជាប្រភពធ្វើឲ្យមានភាពក្រហល់ក្រហាយពេលដែលពួកវាស៊ីចំណីលើភ្នាសសើមរបស់ភ្នែក។





រូបភាពទី ៣.៦៧ បញ្ហាស្វៃរក

**ការគ្រប់គ្រង**

មានផលិតផលពីរដែលមានសម្រាប់គ្រប់គ្រងរុយលើគោគឺៈ

- ពែរមេទ្រីន Permethrin (ប៊ុយតុកButox)
- គូម៉ាផូស Coumaphos (អាស៊ុនតុល Asuntol)

**ខ. មូស**

មូសបឺតឈាមពីគោ។ ពួកវាសម្រក់ឈាមក្នុងទឹកហើយជាទូទៅវាមានចំនួនច្រើននៅកន្លែងងងឹត ដែលគោតែងដេកជាធម្មតា។ ពួកវាបឺតឈាមពេលថ្ងៃរសៀល និងយប់បង្ករជាការរំខានដែលសត្វមិនអាចដេកនិងពេលថ្ងៃពួកវាអស់កម្លាំងដើម្បីស៊ីស្មៅពួកវាបាត់បង់លក្ខណ្ឌដងខ្លួនល្អ។

**ការគ្រប់គ្រង**

ដុតស្លឹកឈើ និងមែកឈើតូចៗដើម្បីបង្កើតជាផ្សែងធ្វើឲ្យមូសចេញឆ្ងាយពីសត្វ។

ដាក់មុងដើម្បីការពារឲ្យកន្លែងមានសុវត្ថិភាពក្នុងពេលយប់។

**គ. ដង្កែ**

ពេលដែលគោត្រូវរំខានខ្លាំងក្លា ដង្កែត្រូវបានឃើញគ្រប់កន្លែងលើដងខ្លួន។ ចំពោះសត្វដែលមានការរំខានតិចតួចពីដង្កែគឺយើងអាចមើលឃើញវាភាគច្រើននៅកន្ទុយ ពោះ ស្មានិងត្រចៀក

-ដង្កែបឺតឈាមពីសត្វ និងចំនួនដង្កែច្រើនអាចធ្វើឲបាត់បង់ឈាមនិងចុះខ្សោយពិសេសចំពោះកូនគោ

-ដង្កែមានមាត់វែងហើយអាចបង្ករជាខូចខាតធ្ងន់ធ្ងរដល់ស្បែក

-ដង្កែអាចចម្លងភ្នាក់ងារជំងឺដូចជាបាបេស្យា អាណាផ្លាស្មា









រូបភាពទី ៣.៦៨ បា៉ស៊ីតខាងក្រៅ

**ការគ្រប់គ្រង**

- ពែរមេទ្រីន Permethrin (ប៊ុយតុកButox)មានសកម្មភាពភ្លាមៗ
- គូម៉ាផូស Coumaphos (អាស៊ុនតុល Asuntol) មានសកម្មភាពភ្លាមៗ
- អ៊ីវែម៉ិចទីន Ivermectinទទួលបានប្រសិទ្ធភាពខ្ពស់បំផុត (អ៊ីវែម៉ិច) នៅពេលពី៤ទៅ ៥ថ្ងៃបន្ទាប់ពីការចាក់

**ឃ. ចៃ**

អង្កែបង្ករជាការត្រដុសយ៉ាងខ្លាំង អេះខ្វាច ស្បែកដែលកើតមានតាមក្រោយការបាត់បង់រោមនិង ស្បែកក្រម៉ក្រាស់។ ស្លាកស្នាមអាចគ្របដណ្តប់ដង ខ្លួនទាំងមូល



រូបភាពទី ៣.៦៩ សត្វកើតអង្គែ

**ការគ្រប់គ្រង**

វាមានការលំបាកព្រោះចៃចូលរូងលាក់ខ្លួន។

ការចាក់ថ្នាំអ៊ីវែម៉ិចទីនគឺជាបច្ចេកទេសគ្រប់គ្រងចៃល្អបំផុត។

ថ្នាំអាស៊ុនតុលអាចប្រើបានការចាក់លើកទី២ចាំបាច់ត្រូវធ្វើនៅ២ឬ៣អាទិត្យក្រោយមកអាស្រ យវដ្តរបស់បរាសិត។

## ៣.៣២ ចាញ់ពន្លឺថ្ងៃ

### ៣២ ១.សញ្ញា

- ស្បែកអាចឡើងក្រហម និងហើម

- រីរិត្តជាពងស្បែកហើយដែលបែក
- បំណែករបស់ស្បែកអាចជ្រុះចេញ



រូបភាពទី ៣.៧០ សត្វប្រតិកម្មថ្នាំ

**៣ ៣២.២.បុព្វហេតុ**

-ប្រតិកម្មថ្នាំដូចជាពពួកស៊ុលហ្វា

-ផ្សិតក្នុងស្មៅប្រាស្យារីយ៉ា )Brachiaria )

-ថ្លើមខូចដែលមិនអាចបំបាត់ជាតិពុលបាន( …ដោយហ្វាស្យូឡា )

-ការព្យាបាល

-ដាក់សត្វនៅក្នុងម្លប់

- ដំណាក់ដំបូងត្រូវចាក់ថ្នាំដិចសាមេតាសូន

-ប្រសិនបើមានក្រម៉ច្រើនត្រូវចាក់ថ្នាំដូចជាអាម៉ុកស៊ីលីនដែលមានសកម្មភាពវែង

**៣.៣២.៣ ការប្រែពណ៌**

រោមនិងស្បែកប្រែពណ៌ជារឿយៗជាប់ទាក់ទងនឹងសភាពរាងកាយមិនល្អ រោមប៉ះ។ មូលហេតុទូទៅគឺកង្វះវីតាមីនអា សង្ក័សី និងទង់ដែង។ មូលហេតុមួយទៀតគឺស្លាកស្នាមដែលបង្ករដោយសត្វល្អិតទិច( ខាំ )ឬការជាសះស្បែកណាមួយ។ រោមនឹងដុះឡើងវិញដែលមានពណ៌ផ្សេង។



រូបភាពទី ៣.៧១ ការប្រែពណ៌របស់សត្វ

ការព្យាបាល ចាក់មួយឬពីរម្ជុលថ្នាំវីតាមីនកម្រទទួលបានជោគជ័យ

- រាល់ពពួករ៉ែ និងវីតាមីនធ្វើការរួមគ្នា ការកែរខែការខ្វះខាតនេះមានភាពស្មុកស្មាញ
- វាត្រូវការស្រូបយកពពួករ៉ែនិងវីតាមីនដែលមានតុល្យភាពល្អ

- ជាការល្អបំផុតត្រូវចចំណីផ្សំរយៈពេល៣ទៅ៤អាទិត្យ។

## ៣.៣៣ ដំបៅ

ដំបៅគឺជាការដាច់ស្បែក ដំបៅជ្រៅអាចពាក់ពន្ធ័នឹងសាច់ដុំ សន្លាក់។ រាល់ដំបៅទាំងអស់ចេញឈាម មានការឈឺចាប់ និងអាចក្លាយជាចម្លងដោយមីក្រុបឬដង្កូវ

ប្រសិនបើដង្កូវទន្រ្ទានលើដំបៅ មានតែបាញ់ថ្នាំសម្លាប់សត្វល្អិតទៅក្នុងដំបៅ (ថ្នាំរេដ៏ Raid) និងពីរបីនាទីក្រោយមកត្រូវយកដង្កូវចេញ (វាចេញឈាម)ដោយប្រើដង្កៀបហើយព្យាបាលដូចដំបៅធម្មតា



រូបភាពទី ៣.៧២ សត្វដំបៅ

### ៣ ៣៣.១.ការព្យាបាល

សម្អាតដំបៅជាមួយទឹកចច្រើននិងដុសប្រាស់ថ្មមៗដែលនេះវាគឺជាការព្យាបាលដំបៅ ៩០%។

កាត់រោមលាបអ៊ីយ៉ូឌីន (ប្រសិនបើដំបៅស្អាត) ឬបាញ់ថ្នាំដែលមានថ្នាំតេត្រាស៊ីគ្លីននិងថ្នាំស្វាយ(Gentiane violet)។ ប្រសិនបើដំបៅជ្រៅត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាអាម៉ុកស៊ីលីន ដែលមានសកម្មភាពវែង ឬ អុកស៊ីតេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង។



រូបភាពទី ៣.៧២ ព្យាបាលសត្វដំបៅ

## ៣.៣៤ . ឬស្ស

ឬស្សបង្កដោយវីរុសដែលហៅថាប៉ាពីឡូម៉ាវីរុស(papillomavirus)។ វីរុសនេះអាចសាយភាយទៅគោផ្សេងទៀតពេលដែលស៊ីស្មៅនៅតាមគម្លោត (វីរុសស្ថិតលើផ្ទៃកច្រើន និងលេចចេញ

ស្លាកស្នាមលើស្បែក)។ ជាធម្មតាគោមិនឈឺទេ ហើយគ្មានការព្យាបាលជំងឺនេះទេ។ឬស្សលើគោតែង រួញនិងជ្រុះបន្ទាប់ពី៣ទៅ៦ខែ។





រូបភាពទី ៣.៧៣ សត្វកើតឫសលើខ្លួន

**ខ្វកជើង**

នៅប្រទេសកម្ពុជាគោត្រូវបានប្រើភាគច្រើនជាកម្លាំងអូសទាញដូចនេះជើងរឹងមាំគឺមានសារៈសំខាន់ដើម្បីធ្វើការក្នុងវាលស្រែ។

## ៣.៣៥ ជំងឺស្បែកក្រចកជើង

ជំងឺស្បែកក្រចកជើងគឺជាជំងឺស្បែករបស់គោដែលមានឥទ្ធិពលលើស្បែកផ្នែកខ្ពស់របស់កែងជើង។ ជំងឺស្បែកក្រចកជើងអាចឃើញមាននៅចន្លោះក្រចកជើងផងដែរ។



រូបភាពទី ៣.៧៤ ជំងឺខ្វកជើង

### ៣.៣៥.១ រោគសញ្ញា

គោដែលមានជំងឺស្បែកក្រចកជើងអាចបង្ហាញសញ្ញាខ្វកជើងពេលដែលក្រោកឈរ ឬពេលដែលផ្លាស់ទី។ ការបង្ហាញជាទូទៅភាគច្រើនគឺការឈររបស់សត្វមានភ្លាត់ជើងច្រើនដងដោយគ្មានមូលហេតុ។ គោមិនសូវមានកម្លាំងពេលធ្វើការក្នុងវាលស្រែដោយពួកវាឈឺជើង។ ជំងឺនេះភាគច្រើនត្រូវបានឃើញពេលដែលគោធ្វើការក្នុងដីភក់ វាកើតមានជាទូទៅចំពោះគោដែលភ្ជួរស្រែ។ ប្រសិនបើជំងឺស្បែកក្រចកជើងត្រូវបានព្យាបាលវាអាចស្ថិតនៅជាច្រើនខែ។ ដោយការត្រាំជើង កសិករត្រូវរកផើងលដើម្បីត្រាំ និងកាន់សត្វឲ្យត្រឹមត្រូវដើម្បីត្រាំជើងឲ្យបានពីរបីនាទីក្នុងទឹកដែលមាន៖

- ហ្វរម៉ាលីន (formalin) ៣ពីរដងក្នុងមួយថ្ងៃរយៈពេលបីថ្ងៃឬ%

- ទង់ដែងស៊ុលហ្វាត )Copper sulfate 5%)

ក្នុងករណីធ្ងន់ធ្ងរត្រូវចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទ្រីមេតូព្រីមជាមួយស៊ុលហ្វា ឬអុកស៊ី តេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង

### ៣ ៣៥.២.ការការពារ

ត្រូវប្រាកដថាកម្រាមមានសភាពទន់និងស្ងួតនៅជម្រកដែលដាក់គោ

### រលួយស្អុយជើង

រលួយស្អុយជើងគឺជាការចម្លងជំបៅរលួយ (ជាលិកាត្រូវបានចម្លងហើយបន្ទាប់មកត្រូវបានបំផ្លាញដែលមានក្លិនស្អុយ) នៃស្បែក(ចន្លោះក្រចកជើង)



រូបភាពទី ៣.៧៥ រលួយស្អុយក្រចកជើង

### ៣ ៣៥.២.បុព្វហេតុ

លាមកសើម និងភក់អាចធ្វើឲ្យស្បែកចន្លោះម្រាមទន់ដែលធ្វើឲ្យវាងាយមុត។ ភ្នាក់ងារចម្លងចូលតាមរយៈស្បែកដែលមានរបួសបង្ករដោយការមុតថ្ម ដែក ឈើ...ការធ្វើការរបស់គោក្នុងភក់គឺបញ្ជាក់យ៉ាងច្បាស់ពីមូលហេតុរបស់ជំបៅរលួយជើង

### ៣រោគសញ្ញា ៣៥.៣.

- ខ្វកជើងលេចឡើងយ៉ាងលឿន ដែលជាទូទៅមានជើងម្ខាងដែលទទួលរងគ្រោះ
- គ្រុនក្តៅ
- ហើមជើង
- ដាច់ដោចក្នុងស្បែកចន្លោះក្រចក អាចមានខ្ទុះតិចៗ

ការព្យាបាល

- ចាក់ថ្នាំស៊ុលហ្វា៣៣តាមសសៃរវ៉ែនមានប្រសិទ្ធភាព
- ចាក់ថ្នាំទ្រីមេតូព្រីមជាមួយស៊ុលហ្វារយៈពេលបីថ្ងៃ
- ចាក់ថ្នាំតេត្រាស៊ីគ្លីនដែលមានសកម្មភាពវែង

## ៣.៣៦ ជំងឺស្លាក់

វាគឺជាការរលាកនៅសន្លាក់ដែលជាទូទៅរួមនឹងការចម្លងជំងឺ។

បុព្វហេតុ

-ដំបៅសន្លាក់ ដែលជាទូទៅមានសន្លាក់តែម្ខាងទទួលរងគ្រោះ

-ការចម្លងទូទៅដ៏ទៃទៀតដែលវិវត្តក្នុងសន្លាក់ ជាពិសេសលើកូនគោ ការចម្លងមកពីផ្ចិត សួត ឬបំពង់រំលាយអាហារមានដូចជាពួកមីកូប្លាស្មា អ៊ីកូលី ឬសាល់ម៉ូណែឡា



រូបភាពទី ៣.៧៦ ដំបៅសន្លាក់

-មេគោបំបៅកូនដែលកង្វះជាតិកាល់ស្យូម ផូស្វ័ សមាសធាតុមីក្រូដ៏ទៃទៀត។ ចំពោះកូនគោវាបង្ករឲ្យក្រិន ជើងមុនខូចទ្រង់ទ្រាយនិងសន្លាក់កជើងធំ។

### ៣ ៣៦.១.រោគសញ្ញា

- ខូកជើងស្តែងចេញ
- ឈឺចាប់ពេលស្ទាបកន្លែងសន្លាក់ដែលហើម
- ចំណង់ស៊ីចំណីតិចតួច
- គ្រុនក្តៅ

### ៣ ៣៦.២.ការព្យាបាល

-ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទីឡូស៊ីនTylosin ឡាំងកូមីស៊ីនLincomycin តេត្រាស៊ីគ្លីន Tetracyclin រយៈពេល៥ទៅ៧ថ្ងៃ

-ថ្នាំដែលកាត់បន្ថយការឈឺចាប់ និងការរលាកដូចជាប៉ារ៉ាសេតាម៉ុលParacetamol ឌីពីរ៉ូន Dypirone (អាណាល់សាំងAnalgine កាល់ម៉ាស៊ីនCalmalgine)

## ៣.៣៧ ខ្វិន

ដេកខ្វិលប្រអូសរយៈពេលយូរ

-ខ្វិន(ជើងមុខ)ពេលដែលគោស្គម និងខ្សោយ គោមិនក្រោកឈរច្រើនថ្ងៃ

-សសៃរមិនត្រូវបានការពារដោយសាច់ដុំនិងត្រូវបានខូចខាតពេលដែលគោដេកទៅម្ខាងលើផ្ទៃដែលរឹង

## ៣.៣៧.១ ការព្យាបាល

-ជួយគោដែលខ្សោយឲ្យក្រោកពីរដងក្នុងមួយថ្ងៃ

-ត្រូវចាក់ថ្នាំលើកកម្លាំងដូចជាការ៉ាស៊ីល (Carasil) អេម៉ាតូប៉ែន ប៉េ១២ (Hematopen B12)

-ត្រដុសស្មា និងភ្លៅជាមួយចំបើង




រូបភាពទី ៣.៧៧ សត្វធ្លមដោយសាខ្វិល

លក្ខខណ្ឌដងខ្លួនដែលទទួលមហន្តរាយ DISASTROUS BODY CONDITION វាជាទូទៅឃើញក្នុងប្រទេសកម្ពុជានូវគោស្គមរោមប៉ះ និងរោមស្រអាប់ហើយមានសភាពអស់កម្លាំង។



រូបភាពទី ៣.៧៨ ដងខ្លួនសត្វមិនល្អ

វាមិនងាយស្រួលក្នុងការធ្វើឲ្យសត្វត្រឡប់មកមានសភាពដងខ្លួនស្តង់ដារវិញ មូលហេតុចម្បងគួរតែ៖

### ក. កង្វះ(ការចុះអន់ថយ)

កង្វះការផ្តល់ចំណី(គុណភាពនិងបរិមាណ)គឺជាមូលហេតុចម្បង។ ការចាក់ថ្នាំវីតាមីនច្រើនប្រភេទ ឬថ្នាំលើកម្លាំងមិនគ្រប់គ្រាន់ទេ។ ដាច់ខាតត្រូវផ្តល់ស្មៅដែលមានគុណភាពល្អ (ផ្តល់ប្រូតេអ៊ីន) និងឬចំណីផ្សំនៅផ្ទះ (មើលក្នុងផ្នែកការផ្តល់ចំណីគោ) វាត្រូវការពេលវេលាប្រហែល៦អាទិត្យ ដើម្បីធ្វើឲ្យដងខ្លួនវិលមកសភាពល្អត្រឹមត្រូវដោយប្រើរបបចំណីដែលមានថាមពល និងប្រូតេអ៊ីនគ្រប់គ្រាន់។ មានបច្ចេកទេសបីអាចគ្រប់គ្រាន់គឺះ










រូបភាពទី ៣.៧៩ ការផ្តល់ចំឱ្យសត្វ និងផ្អាប់ចំ

### ខ .ការបំបៅដោះ Milking




រូបភាពទី ៣.៨០ កូនគោផ្តាច់ដោះយូរ

## ៣.៣៨ បរាស៊ីត Parasitism

ការរំខានខ្លាំងក្លាដោយព្រូនជះឥទ្ធិពលដល់លក្ខណៈដងខ្លួនប៉ុន្តែដង្កូវថ្លើមអាចបណ្តាលឲលក្ខណ្ឌដងខ្លួនមហន្តរាយខណៈពេលដែលការស្លេកស្លាំងវិវត្ត។

វាមានសារៈសំខាន់ដើម្បីទម្លាក់ព្រូនគោពីរដងក្នុងមួយឆ្នាំ នៅដើមនិងចុងរដូវភ្លៀង ជាពិសេសចំពោះគោដែលស៊ីចំណីជាក្រុម និងស៊ីស្មៅនៅតំបន់សើម។



គោស្គម ស៊ីស្មៅជាក្រុម និងមានជំងឺរាគ ប្រើថ្នាំអាល់បង់ដាសុល នឹងមានប្រយោជន៍

រូបភាពទី ៣.៨០ សត្វកើតបរាសិត

### ៣.៣៨.១ បរាសិតក្នុងឈាម

បាបេស្យា(Babesia)ទ្រីប៉ាណូសូ(Trypanosoma) និងពួកអាណាប្លាស្មា(Anaplasma) គឺមាននៅប្រទេសកម្ពុជា។ ទ្រីប៉ាណូសូម៉ាជារឿយរកឃើញលើគោប៉ុន្តែវាមិនច្បាស់ថាមានឥទ្ធិពលលើសុខភាព និងលក្ខណ្ឌដងខ្លួនមិនល្អនោះទេ។

ក្នុងករណីលក្ខណ្ឌរាងកាយទទួលមហន្តរាយរួមមានគ្រុនក្តៅនិងហូរទឹកភ្នែកកើតឈប់ៗ ត្រូវចាក់ថ្នាំបេរើនីល(Berenil)ដើម្បីគ្រប់គ្រងទ្រីប៉ាណូសូម៉ា។



រូបភាពទី ៣.៨១ សត្វមានបរាសិតក្នុងឈាម

## ៣.៣៩ ជំងឺបន្តពូជ

### ៣.៣៩.១ រលាកស្បូន / ហូរទឹកតាមយោនី

មានហូរទឹកថ្លាតាមយោនីគឺជាការធម្មតាក្នុងកំឡុង ពេលរកឈ្មោលឬពីរបីថ្ងៃបន្ទាប់ពីកើតកូនប៉ុន្តែពេលខ្លះយើងឃើញខ្ទុះក្នុងទឹកដែលហូរដែលជាធម្មតាវាបណ្តាលមកពីការចម្លងលើស្បូននោះគេហៅថារលាកស្បូន



រូបភាពទី ៣.៨២ ជំងឺរលាកស្បូន

### ៣.៣៩.២ បុព្វហេតុ

-ស្បូនធម្មតាគឺជាកន្លែងដែលល្អស្អាត

-បន្ទាប់ពីកើតកូន ស្បូនត្រូវបានឆ្លងដោយមេរោគច្រើនមកពីរន្ធយោនី ប៉ុន្តែជាធម្មតាពីរបីថ្ងៃបន្ទាប់ស្បូននឹងអាចកំចាត់មេរោគទាំងនេះនិងការពារការចម្លង

-ពេលខ្លះការចម្លងនឹងស្ថិតនៅហើយបាក់តេរីនឹងវិវត្តព្រោះស្បូនមិនអាចកំចាត់បាក់តេរី ( សុកធ្លាក់មិនអស់ បញ្ហាលើផលិតកម្មអរម៉ូន...) វាផលិតជាខ្ទុះនិងបង្ករឲមានការហូរខ្ទុះ។

### ៣.៣៩.៣ រោគសញ្ញា




រូបភាពទី ៣.៨៣ រោគសញ្ញារលាកស្បូន

- ខ្ទុះឬវត្ថុដែលមិនល្អអាចត្រូវបានឃើញក្នុងយោនី
- ក្លិនស្អុយកើតមានជាទូទៅ
- ឃ្លានចំណីតិចតួច

### ៣.៣៩.៤ ការព្យាបាល

- ចាក់ថ្នាំប្រូស្តាក្លង់ឌីន ២ដងក្នុងពេលពី១១ទៅ១៤ថ្ងៃដើម្បីឲ្យហូរកំទិចកំទីចេញពីស្បូន វាបើកស្បូននិងជម្រុញការកន្ត្រាក់ វត្ថុដែលកខ្វក់នឹងរុញចេញ(ថ្នាំអុកស៊ីតុកស៊ីនមិនអាចប្រើបានទេព្រោះថ្នាំនេះមិន "បើក" ស្បូននិងអាចធ្វើឲមានការកន្ត្រាក់តែកំឡុងពេលកើតកូនទេ)

- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាតេត្រាស៊ីគ្លីន ឬទីឡូស៊ីនរយៈពេល៥ថ្ងៃ

- មិនត្រូវឲអនុសាសន៍ "លាង" ស្បូនជាមួយល្បាយអ៊ីយ៉ូឌីន ឬពែម៉ង់កាណាតទេ។ វាធ្វើឲក្រហល់ក្រហាយនិងបរិមាណច្រើនរបស់វត្ថុរាវនឹងធ្វើឲប៉ះពាល់ដល់ការមូលចូលក្នុង។

#### ៣.៣៩.៤.១ ការការពារ

មេគោដែលប្រឈមនឹងគ្រោះថ្នាក់គឺជាមេគោដែលធ្លាប់មានបញ្ហាក្នុងកំឡុងពេលកើតកូន ដែលត្រូវការលូកដើម្បីជួយវា ពេលដែលសុកមិនធ្លាក់ ពេលដែលលាសដោះកើតបន្ទាប់ពីកើតកូន។ ត្រូវចាក់ប្រូស្តាក្លងឌីននៅ២៤ម៉ោងបន្ទាប់ពីកើតកូនហើយចាក់ម្តងទៀតនៅ២អាទិត្យក្រោយមក។

#### ៣ ៣៩.៤.១.១.មិនរកឈ្មោល

ការមិនរកឈ្មោលមានន័យថាមេគោដែលមិនផើមមិនត្រូវការគោបា វាគឺជាការធម្មតាក្នុងកំឡុងពេលដំបូងនៃដំណាក់កាលបំបៅដោះកូនគោ។

#### ក. បុព្វហេតុ

បញ្ហាទូទៅខ្លះអាចធ្វើឲមានការមិនរកឈ្មោលរយៈវែងដែលយើងអាចនិយាយថាសត្វអាះ

- លក្ខណ្ឌដងខ្លួនមិនល្អ ដែលរាំងសកម្មភាពវដ្តរបស់មេគោ
- ការបៅដោះដោយកូនគោ
- មានគិសលើអូវែ










រូបភាពទី ៣.៨៤ ដងខ្លួនសត្វមិនល្អ   រូបភាពទី ៣.៨៥ ការរកឈ្មោលយូរ

### ខ. ការព្យាបាល

- ផ្តល់ចំណីឲ្យគ្រប់គ្រាន់ និងផ្តាច់ដោះទាន់ពេលនឹងជួយសម្រួលការរកឈ្មោល ប្រសិនបើគោស្ថិតក្នុងសភាពល្អ ត្រូវព្យាបាលបាល Luteal cysts ដោយប្រើប្រូស្តាក្លង់ឌីន ៥មីលីលីត្រ នៃលុយតាលីស (Lutalyse) ដើម្បីជម្រុញការរកឈ្មោក្នុងពេលពី៣ទៅ៥ថ្ងៃ។

### គ .ការរកឈ្មោលឡើងវិញ

មេគោបង្ហាញវដ្តរកឈ្មោលរៀងរាល់៣អាទិត្យប៉ុន្តែ មិនអាចផើមបន្ទាប់ពីបង្កាត់។ ការរកឈ្មោលឡើងវិញត្រូវបានកំណត់ថាមេគោ មិនមានគត៌បន្ទាប់ពីដាក់បាន៣ដង ឬលើសពីនេះពេលដែលវារកឈ្មោលពិតប្រាកដ។




រូបភាពទី ៣.៨៦ សត្វរកឈ្មោល

### បុព្វហេតុ

-រលោកស្បូន  វាគឺជាការចម្លងមិនដាក់លាក់របស់ស្បូនបង្ករដោយបាក់តេរីរាតត្បាលលើស្បូនបន្ទាប់ពីកើតកូន។  តាមពិតកូនមិនអាចវិវត្តបានត្រឹមត្រូវក្នុងស្បូនដែលឆ្លងជំងឺ។ការរលោកស្បូនពេលខ្លះមានការលំបាកក្នុងការធ្វើរោគវិនិច្ឆយ័ព្រោះគោបានបញ្ចេញខ្ទុះមកក្រៅ។

-គោបាអាចអា ដូចនេះត្រូវផ្លាស់ប្តូរបាផ្សេងពេលដាក់លើកក្រោយ។

### ការព្យាបាល

-ចាក់ថ្នាំប្រស្តាក្លង់ឌីន(Prostaglandins) ២ដងក្នុងពេលពី១១ទៅ១៤ថ្ងៃ

-ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាតេត្រាស៊ីគ្លីន ឬទីឡូស៊ីនរយៈពេល៥ថ្ងៃ

## ៣.៤០ លាសដោះ Mastitis

លាសដោះគឺជាការរលាកក្រពេញដោះ។ ការចម្លងជំងឺនិងលទ្ធផលរបស់វាធ្វើឲថយចុះផលិតកម្មទឹកដោះយ៉ាងច្រើន

បុព្វហេតុ

វាបង្ករដោយបាក់តេរី។ មេរោគអាចចូលតាមរយៈមុខរបួសឬតាមរយៈបំពង់របស់ក្បាលដោះ។




រូបភាពទី ៣.៨៧ បាតុរីនៅក្បាលដោះ

### ៣.៤០.១ រោគសញ្ញា

-ករណីលាសដោះភាគច្រើនជាប់ពាក់ពាក់ពន្ធ័ផ្នែក១ភាគ៤(លើក្បាលដោះ១)របស់កន្សោមដោះ ដែលមានផលិតកម្មទឹកដោះជាធម្មតាលើផ្នែក៣ភាគ៤ដ៏ទៃទៀត

-ក្នុងករណីស្រួចស្រាវភាគទាំងបួនហើម ក្តៅ និងឡើងក្រហមហើយមានផលិតកម្មទឹកដោះតិចតួច។ គ្រុនក្តៅ អស់កម្លាំង និងការញាប់ញរ័កើតជាទូទៅ។ មេគោអាចញែងខ្លួនចេញឬធាក់ពេលដែលប៉ះកន្សោមដោះព្រោះផ្នែកទាំងបួនភាគមានភាពងាយទទួល។

-ក្នុងករណីមិនសូវស្រួចស្រាវនិងទម្រង់រ៉ាំរ៉ៃ គ្មានគ្រុនក្តៅ ឬសញ្ញាទូទៅ ប៉ុន្តែផលិតកម្មទឹកដោះទាប ហើយផ្នែកទាំងបួនភាគអាចល្អ។ មេគោការពារពេលដែលកូនគោព្យាយាមបៅ កូនគោឃ្លាន និងមានស្ថានភាពមិនល្អ។







រូបភាពទី ៣.៨៨ កូនគោបាក់ទឹកដោះ

### ៣.៤០.២ ការព្យាបាល

ការព្យាបាលត្រូវអនុវត្តតាំងពីដំបូងដើម្បីទទួលជោគជយ័

- ត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន(Ocytocin) ៥មីលីលីត្រដើម្បីធ្វើឲកន្សោមដោះហូរទឹកដោះក្នុងផ្នែកមួយភាគបួនដែលឈឺត្រូវច្របាច់ចេញដោយដៃ(វាមានសារៈសំខាន់ក្នុងការដាក់គោក្នុងសាឡុងព្រោះវាមានការឈឺចាប់) ពីរដងក្នុងមួយថ្ងៃ។




រូបភាពទី ៣.៨៩ ការប្របាច់ទឹកដោះ

- ចាក់ថ្នាំអង់ទីប៊ីយ៉ូទិកដូចជាទ្រីមេតូព្រីម ជាមួយស៊ុលហ្វា ឬអាម៉ុកស៊ីលីនរយៈពេលបីថ្ងៃ

- ប្រសិនបើកន្សោមដោះរឹងត្រូវចាក់ថ្នាំដិចសាមេតាសូន ឬតុលហ្វេឌីនដើម្បីកាត់បន្ថយការរលាក។

# ជំពូក៤
# ដើមកំណើត និង សែន

**៤.១ ជម្ងឺចម្លងតាមស្តែម និងអូរ៉ុល** (Hereditary Disease): ជាជម្ងឺទាំងឡាយណាដែលធ្វើការចម្លងទៅឱ្យអំព្រើយ៉ុងតាមរយៈមេជីវិតឈ្មោល ឬញីរបស់មេ-បា ។

**៤.២ ជម្ងឺមានពីកំណើត** (Congenital Disease): ជាជម្ងឺ ដែលជួបប្រទះលើកូនសត្វទើបកើត ។ វាមានការចម្លងជាលក្ខណៈសមីជម្ងឺ នៃកូនសត្វ ដោយជួនកាលមានតាំងពីកូននៅក្នុងស្បូន ឬចាប់ពីកូន កើតមកភ្លាមមានជម្ងឺ "ឬជាជម្ងឺពីកំណើត" ។ ឧទាហរណ៍: Brucellosis,Pullorum, Puberculosis ។

**៤.៣ ជម្ងឺមានការចម្លងតាមរយៈមេជីវិត និងមានពីកំណើត** (Acquired Disease): ជាជម្ងឺដែលកើតមាន បណ្តាលពីករណីទាំងពីរខាងលើ ដោយជះឥទ្ធិពលទៅវិញទៅមក ។

## ៤.៤ ប្រព័ន្ធសរីរាង្គ

**ក. ជម្ងឺមានទីតាំងកំណត់** (Localized Disease) --ជាជម្ងឺមានការផ្លាស់ប្តូររោគសញ្ញាមានឥទ្ធិពលនៅក្នុងតំបន់ ឬសរីរាង្គ ឬប្រព័ន្ធសរីរាង្គច្បាស់លាស់ ។ ឧទាហរណ៍:Abscess ។

**ខ. ជម្ងឺមានលក្ខណៈទូទៅ** (Generalised Disease) ...ជាជម្ងឺដែលមានឥទ្ធិពលប៉ះពាល់ ដល់ស្ទើរគ្រប់សរីរាង្គ ក្នុងសាពាង្គកាយទាំងមូល។ ការប៉ះទង្គិចមានសណ្ឋានជាប្រព័ន្ធសរីរាង្គនិង ជម្ងឺមានការវិវត្តន៍ទូទៅពេញសាពាង្គកាយ ។ ឧទាហរណ៍ Toxaemia និងSepticaemia

**៤.៤.១ ការប្រែប្រួលនៅក្នុងសរីរាង្គ :**

**ក. ជម្ងឺប៉ះពាល់ដល់ទម្រង់ និងរូបផ្គុំសរីរាង្គ (Structural Disease):** ជម្ងឺជះឥទ្ធិពលបណ្តាល ឱ្យមានការផ្លាស់ប្តូររោគសាស្ត្រ លើសរីរាង្គមួយចំនួន ។ ឧទាហរណ៍: Pericarditis, Nephritis, Rickets, Osteomalacia ។

**ខ. ជម្ងឺធ្វើឱ្យប្រែប្រួលនាទីរបស់សរីរាង្គ (Functional Disease):** ជម្ងឺមានឥទ្ធិពលបណ្តាលឱ្យមានការប្រែប្រួលនាទីសរីរាង្គមួយចំនួន ដោយមិនបណ្តាលឱ្យមានការប្រែប្រួលទម្រង់ និងរូបផ្គុំរបស់សរីរាង្គនោះ ។ ឧទាហរណ៍ Arhythmia ។

**៤.៤.២ បុព្វហេតុពិសេសៈ**

**៤.៤.២.១ ជម្ងឺពិសេស (Specific Disease)**: ជាជម្ងឺ ដែលបង្កឡើងដោយមេរោគបង្ក ឬកត្តាពិសេស ។

គេចែកវាជា :

**៤.៤.២.២ ជម្ងឺឆ្លងដោយការបំបែក៖** (Contagious disease)៖ ជាជម្ងឺឆ្លងមួយប្រភេទ ដែលមានការ

ចម្លងកើត ឡើងតាមការប៉ះផ្ទាល់នៃសត្វជា ជាមួយសត្វឈឺ ។ ឧទាហរណ៍៖ Rinderpest, Foot and Mouth Disease ។ល។

**៤.៤.២.៣ ជម្ងឺឆ្លងដោយការជ្រៀតចូលនៃអតិសុខុមប្រាណបង្ករោគ** --ជាជម្ងឺដែលបណ្តាលអោយ អតិសុខុមប្រាណ ឬមីក្រូសាពង្គកាយបង្ករោគ ។ ឧទាហរណ៍៖ Viral diseases, Bacterial diseases, Protozoal diseases, Mycotic disease

**ដំណើរវិវត្តន៍ នៃការចម្លង** (Infectivity)

ជាប្រតិកម្មទៅវិញទៅមកនៃអតិសុខុមប្រាណបង្ករោគនិងសាពង្គកាយ ហើយដែលសាពង្គកាយ (Macro-Organism / Host) ស្ថិតនៅក្រោមការប៉ះទង្គិចពីបរិស្ថាន។ ជម្ងឺឆ្លងជាទម្រង់មួយ នៃដំណើរវិវត្តន៍ នៃការឆ្លង ដែលកើតឡើងក្រោមឥទ្ធិពលនៃការផ្លាស់ប្តូរលក្ខខ័ណ្ឌ ដ៏មានប្រសិទ្ធភាព នៅក្នុងបរិស្ថាន ដែលមាន អំពីទៅលើទាំងអតិសុខុមប្រាណ និងសត្វ ។

រយះពេលបង្កជម្ងឺ / ជម្ងឺគ្មានរោគសញ្ញាដំណាក់កាលត្រៀមឬ ដំណាក់កាលដំបូង

(Incubation Period or Stage of Latency) ⟶ (Prenormal Stage or Premonitory Symptoms)

ដំណាក់កាលលូតលាស់ជម្ងឺ (Development Stage) ⟶ ដំណាក់កាលស្ងប់នៃ (Subsidence Stage)

↓

ដំណាក់កាលជាសះស្បើយពីជម្ងឺ

Recovery / Convalescence

***ចំណាំ*** : Infectious Disease មិនមែនជា Contagious Disease ប៉ុន្តែ Contagious Disease គឺជា Infections Disease ។

**៤.៥ គំនូសបំព្រួញ ៤ ដំណាក់កាលនៃជម្ងឺឆ្លង**

**ជម្ងឺមិនពិសេស** (Non-Specific Disease)៖ ជាជម្ងឺទាំងឡាយណា ដែលបុព្វហេតុបង្ក

របស់វាពុំទៀងទាត់ និងពុំកំណត់ ឬមានច្រើនប្រភេទ ។ ឧទាហរណ៍: Diarrhoea, Dysentery

**៤.៥.១ របៀបចម្លង**

**ក-ជម្ងឺមូលដ្ឋាន** (Primary Disease) -- ជាជម្ងឺ ដែលកើតឡើង និង មានឬសគល់ច្បាស់លាស់ ហើយពុំមានការឡូកឡំដោយប្រភេទជម្ងឺផ្សេងៗ ។

**ខ- ជម្ងឺឱកាសនិយម** (Secondary Disease): ជាជម្ងឺ ដែលកើតឡើងលើសាព៌ាង្គកាយសត្វ ដែលកំពុងរាតត្បាតដោយជម្ងឺមូលដ្ឋាន "ដើម" ។ ជាញឹកញាប់បាក់តេរីដើរតួជា Secondary Infection ទៅលើ ជម្ងឺដើម ។ ឧទាហរណ៍ Secondary Pneumonia --ជាប្រភេទជម្ងឺដែលបន្សំពីជម្ងឺរាតត្បាត ដោយវីរុស ។ បាក់តេរី Bordetella roncho-Septica_បង្កឱ្យមាន Infectious Bronchitis បន្ថែម (Secondary) ទៅលើជំងឺ Canine Distemper ដែលជាជម្ងឺទី១ ។

**គ- ជម្ងឺបន្តពីជម្ងឺមូលដ្ឋាន** (Intercurrent Disease): ជាជម្ងឺ ដែលជាលទ្ធផលបណ្តោលពីជម្ងឺមូលដ្ឋាន។ ឧទាហរណ៍: ការកន្ត្រាក់សាច់ដុំពុំប្រក្រតី (Chorea) ដែលជាការបន្តពីជម្ងឺCanine Distemper ។

**៤.៥.២ ការបញ្ជារោគសញ្ញា តាមរយៈពេល និងភាពធ្ងន់ធ្ងរ:**

គេបែងចែកជម្ងឺ តាមលក្ខណៈធម្មជាតិនៃរបស់វា តើជម្ងឺកើតឡើងតាមរបៀបណា? សត្វឈឺរយៈពេល យូរឬឆាប់? និងមានសភាពយ៉ាងណា? ដូច្នេះជម្ងឺគេចែកជាសណ្ឋានតាមការរាតត្បាត និង សភាពធ្ងន់ ឬ ស្រាល ។

**ក. ជម្ងឺស្រួចស្រាវខ្លាំង** (Per-Accute Disease): ជាជម្ងឺធ្វើការរាតត្បាតយ៉ាងឆាប់រហ័ស និងបណ្តាលឱ្យ សត្វស្លាប់យ៉ាងទាន់ហន់ ជួនកាលសណ្ឋាននេះៈ សត្វឈឺពុំឃើញមានរោគសញ្ញាទេ ហើយ ជម្ងឺបន្ត រយៈពេល ខ្លីពី ១២-៣៦ម៉ោង ប៉ុណ្ណោះ ។ Per-acute Mastitis, Per-acute Haemorrhagic Septicemia។

**ខ- ជម្ងឺស្រួចស្រាវ** (Acute Disease) --ជម្ងឺប្រភេទនេះមានលក្ខណៈដោយមានរោគសញ្ញាមួយចំនួនបង្ហាញឱ្យឃើញស្រួចស្រាវ។ ជាទូទៅជម្ងឺបញ្ចេញរោគសញ្ញាពី ៣-១៤ ថ្ងៃ។ សត្វបង្ហាញរោគសញ្ញាទូទៅដូចជា រាគ ក្តៅខ្លួន សត្វផ្សៀរ មិនស៊ីចំណី។ ដូចជាជម្ងឺធំ Anthrax ។

**គ- ជម្ងឺស្រួចស្រាវមធ្យម** (Sub-Acute Disease): រយៈពេលជម្ងឺគឺវែងជាងជម្ងឺស្រួចស្រាវ ។ ជាទូទៅជម្ងឺប្រភេទនេះៈ អូសបន្លាយរហូតដល់ ២ ទៅ ៤អាទិត្យ ។ អាត្រាឈឺមានកំរិតទាបជាង

សណ្ឋានពីរខាងលើ។ ជួនកាលរោគសញ្ញាមានសភាពសាំញ៉ាំ។ ដូចជាSub-acute Mastitis ជាដើម។

**ឃ- ជម្ងឺរ៉ាំរ៉ៃ** (Chronic Disease): ជាជម្ងឺបណ្ដាលឱ្យសត្វអូសបន្លាយរយៈពេលយូរ ។ ជម្ងឺពុំមានរោគសញ្ញាច្បាស់លាស់ ប៉ុន្តែវាបញ្ជាក់ដោយរយៈពេលយូរនៃការឈឺរបស់សត្វ ។ សត្វឈឺបន្តរហូតដល់រយៈពេល ៤ អាទិត្យ ឬ ច្រើនជាងនេះ ។ សត្វចុះខ្សោយទ្រុឌទ្រោមហើយផ្ដល់លទ្ធភាព ដល់ការរាតត្បាតនៃជម្ងឺឱកាសនិយមផ្សេងៗទៀត (Secondaryl Infection)ប៉ុន្តែជួនកាលសត្វឈឺក្នុងសណ្ឋាននេះពុំមានរោគសញ្ញាពិសេសណាមួយទេ ដោយការវិវត្តន៍របស់ជម្ងឺ (Pathogenisis) ប្រព្រឹត្តទៅយឺត១។ សត្វមានជម្ងឺរាំរ៉ៃ ជាប្រភពរក្សាផ្ទុក និង រាតត្បាតជម្ងឺយ៉ាងសំខាន់ ។ ដូចជា ជម្ងឺដង្កូវថ្លើមមានរោគសញ្ញាក្នុងដំណាក់រាតត្បាតដំបូង ដោយកូនដង្កូវ ប៉ុន្តែបន្ទាប់ពីរយៈពេល មួយខែក្រោយមករោគសញ្ញាបានរលប់បាត់ទៅវិញ --នៅក្នុងដំណាក់កាលកូនដង្កូវពេញវ័យ (Mature Form) សត្វឈឺជម្ងឺរាំរ៉ៃ បំផ្លាញសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ដោយវាប៉ះពាល់ផ្ទាល់ ដល់ការ លូតលាស់-ធំធាត់របស់សត្វ និងជាប្រភពចំលងជម្ងឺ និង ធ្វើឱ្យមានការចំណាយទៅលើការព្យា បាល ។ ឧទាហរណ៍ ជម្ងឺរបេង ជម្ងឺ Para-Tuberculosis, Brucellosis ជាដើម ។

**ង- ការផ្ទុកជម្ងឺ** (Carrier): ជាសណ្ឋានមួយនៃជម្ងឺ ដែលសម្ដែងនូវទំនាក់ទំនងជាអន្តរអំពើ រវាងមីក្រូសាពាង្គកាយ និងសត្វ ដោយគ្មានការបង្ហាញឱ្យឃើញនូវលក្ខណៈ នៃសត្វឈឺ។ ដំណាក់កាលផ្ទុកជម្ងឺនេះអាចមានរយៈពេលរហូតដល់៣ខែ --ចាត់ទុកថាស្រួចស្រាវនៅ ពេលដំណាក់កាលផ្ទុកនេះមានរយៈពេលយូរជាងនេះ៖ វាគឺជាសណ្ឋានកុនៃការផ្ទុក មេរោគ ។ ប្រការនេះជាប្រភពរាត ត្បាតយ៉ាងគ្រោះថ្នាក់ ។

## ៤.៦- តាមទីកន្លែង និងល្បឿននៃការរាតត្បាត

**ក- ជម្ងឺស្ព័រ៉ាឌិច** (Sporadic Disease): ជម្ងឺប្រភេទនេះ៖ ផ្ទុះឡើងដោយចៃដន្យពុំមានកាលរដូវឬ ពេលវេលាច្បាស់លាស់ ។ ឧទាហរណ៍: ជម្ងឺគ្រុនបីថ្ងៃនៃគោក្របី (Three-day Sickness) លេចឡើងពុំទៀងពេលវេលាជួន២ឆ្នាំម្ដងជួន៣ ឬ ៥ ឆ្នាំម្ដងទើបសត្វឈឺម្ដងទៀតនិងជម្ងឺ រលាកស្រោមខួរក្បាលគោ (Sporadic Bovine Encephalemyelitis) ។

**ខ-ជម្ងឺអិនសូអូទិច** (Enzootic Disease): គឺជម្ងឺប្រភេទនេះ៖ បង្ហាញពីការផ្ទុះជម្ងឺនៅក្នុងចំណោមសត្វក្នុងតំបន់មួយច្បាស់លាស់ ឬ ស្រុកមួយច្បាស់លាស់ ហើយដែលបង្កឡើងចំពោះសត្វ ជាលក្ខណៈ ពិសេសទាក់ទងទៅនឹងតំបន់ ឬ ប្រទេស ឬ កត្តាអាកាសធាតុ និង រដូវកាលនៃការផ្ទុះជម្ងឺ។ គេជួបប្រទះជម្ងឺមិនសូអូទិចលើសត្វប្រភេទផ្សេងៗ ឬ ពូជផ្សេងៗគ្នា។ ដូចជាជម្ងឺខ្វះសារជាតុគីមី (Miniral Deficiency) ផ្ទុះឡើងក្នុងតំបន់ ដែលដីខ្វះសារធាតុគីមី --សត្វស៊ីស្មៅដែលដុះលើដីនោះបណ្ដាលឱ្យ ខ្វះសារជាតុគីមីទាំងនោះដែរ ។ មួយទៀតជម្ងឺគ្រុន (Tick Fever) ដែលបានត្រូវផ្ទុះឡើង

ចំពោះសត្វ ដែលមានសត្វល្អិតខាំ ឬ ទិច ។ ឧទាហរណ៍: Enzootic Haematuria in cattle, Anthrax, etc ។

**គ-ជំងឺអេពីសូអូទិច** (Epizootic Disease): ជាជម្ងឺ ដែលមានទំហំឆ្លងរាលដាលធំធេង នៅ ក្នុង តំបន់ ឬ កន្លែងមួយច្បាស់លាស់ ។ វាជាប្រភេទជម្ងឺ ដែលបណ្ដាលឱ្យសត្វប្រភេទដូចគ្នាមានការ ឆ្លង រាលដាលខ្លាំង ក្នុងពេលវេលា និង ទីកន្លែងច្បាស់លាស់ ។ ដូចជាជម្ងឺឈាមខ្មៅ និង សារទឹក ដែល ផ្ទុះ ឡើងក្នុងខេត្តនៅដើមរដូវភ្លៀង ។ល ។ ជម្ងឺមិនសូអូទិច អាចក្លាយជាអេពីសូអូទិច ក្រោមព្រឹត្តិ ការណ៍ ដែលសត្វអាចឆ្លងជម្ងឺជាចំនួនច្រើន និង រាតត្បាតនៅតំបន់ផ្សេងៗក្នុងប្រទេស ហើយក្នុង ពេលតែមួយ ឬខែដដែល ព្រមទាំងជម្ងឺមានសភាពរាតត្បាតយ៉ាងឆាប់រហ័ស ។ ឧទាហរណ៍ Rinderpest ។

**ឃ-ជម្ងឺប៉ាសូអូទិច** (Panzootic Disease): នៅពេលមានប្រភេទជម្ងឺអេពីឌែមម៉ិច រាតត្បាត

ក្នុងប្រទេសមួយ ហើយមានទ្រង់ទ្រាយធំខុសពីប្រក្រតី ព្រមទាំងរាតត្បាត ទៅប្រទេស ដទៃទៀត ឬទ្វីប ដទៃទៀត --ជម្ងឺប្រភេទនេះគេហៅថា ជម្ងឺប៉ាសូអូទិច ។ ឧទាហរណ៍ Influenza ។

**ង- ជម្ងឺអិនឌែម៉ិច** (Endemic Disease): វាជាប្រភេទជម្ងឺរាតត្បាត ដែលមានការចម្លង និង រាលដាលពិសេស ។ ក្នុងនានជម្ងឺធ្វើការរាតត្បាតរយៈពេលយូរ ហើយជះឥទ្ធិពលនៅក្នុងតំបន់ មួយ ចំនួន និង រាតត្បាតលើប្រភេទសត្វ ឬ ពូជសត្វជាក់លាក់ ។ ជម្ងឺគ្រុនញាក់ជាប្រភេទជម្ងឺ (Zoonose) គេ ហៅថា Endemic ។ ឧទាហរណ៍ Anthrax, Black leg ។

**ច-ជម្ងឺសូអូណូស** (Zoonose Disease): ជាជម្ងឺ ឬការរាតត្បាត ដែលចំលងជាលក្ខណៈធម្ម ជាតិពីសត្វឆ្អឹងកងទៅមនុស្ស និង ពីមនុស្សទៅសត្វ ។ ជម្ងឺសត្វទាំងឡាយ ដែលពុំចំលងទៅមនុស្ស ហៅថា Non-Zoonoses ។ ឧទាហរណ៍: Brucellosis, Anthracis, Rabies, Tuberculosis, Leptospirosis....

**ឆ-ជម្ងឺមិនមែនសូអូណូ** (Non-Zoonose Disease): ជាជម្ងឺមិនចំលងផ្ទាល់ទៅមនុស្សទេដូច ជាជម្ងឺ HS, Black Leg, FMD, Rinderpest, Swine Fever, Newcastle ។ មេរោគនៃជម្ងឺទាំង នេះពុំ មានឥទ្ធិពលផ្ទាល់មកពីមនុស្សទេ ប៉ុន្តែការបរិភោគសាច់សត្វឈឺជម្ងឺនេះដោយពុំបានចំអិនល្អ អាចប ណ្ដាលឱ្យមាន រាគ ក្អួត ចុកពោះ ជាដើម ។

**៤.៧ ទីកន្លែង និងដើមកំណើត :**

**ក- ជម្ងឺក្នុងស្រុក** (Indigenous Disease): ជម្ងឺដែលកើតឡើងមានប្រភពចម្លងនៅក្នុងស្រុក

ដូចជា Tuberculosis និង Filariasis ។

**ខ- ជម្ងឺមានដើមកំណើតពីបរទេស (Exotic Disease):** ជម្ងឺ ដែលបានបន្តចម្លងពីបរទេស មកក្នុងស្រុក ។ ដូចជា African Horse Sickness ។

**គ- ជំងឺលេចឡើងពុំធ្លាប់មានពីមុន (Emerging Disease):** ជាប្រភេទជម្ងឺ ដែលពុំធ្លាប់មានពីមុន នៅក្នុងស្រុក ប៉ុន្តែបានត្រូវគេជួបប្រទះនៅក្នុងស្រុកក្នុងពេលណាមួយ ។

**៤.៨ ប្រភព និងការចម្លង :**

**ក- ជម្ងឺបង្កដោយមេរោគក្រៅខ្លួន (Exogenous Disease):** ក្នុងករណីនេ សត្វទទួលការ ចម្លងមេរោគពីសត្វផ្សេងទៀត ពីចំណីអាហារ ទឹក ដី ខ្យល់ ដែលជាប្រភពចម្លង នៃមេរោគនៅ ក្រៅខ្លួនសត្វ ។

**ខ- ជម្ងឺបង្កដោយមេរោគក្នុងខ្លួន (Endogenous Disease ឬ Auto-infection):** ជម្ងឺមានដើមហេតុបណ្តលពីភាពសកម្មនៃមេរោគនៅក្នុងខ្លួនសត្វ ដែលបណ្តាលពីការខូចខាតនៃមជ្ឈដ្ឋាន សាពាង្គកាយ "ការថយភាពធន់ៗ និងកត្តាផ្សេងៗ ព្រមទាំងស្រ្តេស បណ្តាលពី ការប្រែប្រួល បរិស្ថាន ។ល ។ ការថយចុះនៃសីតុណ្ហភាពនៅក្នុងបរិស្ថាន ពពួកមីក្រូហ្វ៊្លរ៉ា (Microflora) នៃប្រព័ន្ធ ដង្ហើមក្លាយជាសកម្ម ហើយបង្កឱ្យមានការរលាកប្រដាប់ដង្ហើមដូចជា Pharyngitis និង Laryngitis 9

**៤.៩ ការខ្វះសារជាតុរ៉ែ និង ជីវជាតិ :**

**ក- ជម្ងឺខ្វះជីវជាតិ(Deficiency Disease)** -- ដូចជា Hypovitaminosis-A, B, D, E, K, ...

**ខ- ជម្ងឺខ្វះសារជាតុ (Nutritional Disease)** --ដូចជា Hypocalcaemia, Hypoglycemia

- **ការប្រែប្រួលសរីរៈសាស្ត្រ :**

**ក- Metabolitic Disease** --ដូចជា Mill-Fever

**ខ- Production Disease** --ដូចជា Fatty Syndrome

**៤.៩.១ តាមបុព្វហេតុបង្កជំងឺ**

ជម្ងឺអាចបង្កដោយពពួកអតិសុខុមប្រាណនៃក្រុមផ្សេងគ្នា ជម្ងឺបង្កដោយបាក់តេរី (Bacterial Disease) ជម្ងឺបង្កដោយវីរុស (Viral Desease) ជម្ងឺបង្កដោយពួកប៉ារ៉ាស៊ីត (ParasiticDisease) ។ ដូច្នេះការឱ្យឈ្មោះ នៃជម្ងឺ គឺគេហៅ ទៅតាមដើមកំណើតបង្កជម្ងឺ ។

**៤.៩.២ តាមឥទ្ធិពលនៃជំងឺ (Affectivity) :**

ជម្ងឺអាចបង្កឡើងជាលក្ខណៈទូទៅ ឬអាចចំលងរាតត្បាត អាស្រ័យទៅនឹងសភាពបង្ករោគរបស់មេរោគ (Virulent) ។ ជម្ងឺមួយចំនួនរាតត្បាតឆ្ពោះទៅលើសរីរាង្គខ្លះ ប៉ុន្តែមួយចំនួនមានលក្ខណៈធ្ងន់ធ្ងរ ហើយផ្តល់ គ្រោះ ថ្នាក់ដល់ជីវិតសត្វ ដូចជាជម្ងឺរលាកថ្លើម (Hepatitis) រលាកតំរងនោម (Nephritis) ដែលឆ្ពោះតែលើសរីរាង្គ ។ ប៉ុន្តែ ករណីខ្លះទៀត ដូចជាមហារីករាលដាល (Malignent Tumor) និង Septicemia បង្កឱ្យមាន ការរាតត្បាតពេញទាំងសព៌ាង្គកាយ ។

**៤.៩.២.១ តាមការរាតត្បាត (Infectivity) :**

តាមសភាពរាតត្បាតគេចែកជម្ងឺជាពីរក្រុម

**ក-ជម្ងឺឆ្លង (Infectious Disease):** ជាជម្ងឺដែលបង្កដោយអតិសុខុមប្រាណ ពិសេស ហើយធ្វើការរាលដាល ពីសត្វមួយ ទៅសត្វមួយទៀត ឥតឈប់ឈរ ។

**ខ- ជម្ងឺមិនឆ្លង (Non-Infectious Disease):** ជាលក្ខណៈសមីជម្ងឺពុំចំលងពីសត្វឈឺទៅសត្វដទៃទេ។ ដូចជា អាប់សែ (Absces) រលាក (Inflammation) បាក់ឆ្អឹង (Fracture) ជាដើម ។

**៤.៩.៣ តាមការរាតត្បាតពិសេសលើប្រភេទសត្វ (Species Affected) :**

ជម្ងឺមានលក្ខណៈពិសេសសំរាប់ប្រភេទនីមួយៗ ដូចជា ជម្ងឺចៀម គោ-ក្របី ពពែ ជ្រូក មាន់ ទា ។ល ។ មានជម្ងឺមួយចំនួនតូចមានឥទ្ធិពលលើស្ទើគ្រប់ប្រភេទសត្វដូចជា Anthrax, Salmonellosis, Brucellosis, ជា ដើម។ ជម្ងឺមួយភាគធំមានឥទ្ធិពលពិសេសសំរាប់ប្រភេទសត្វមួយ ឬពីរប៉ុណ្ណោះ ដូចជាជម្ងឺអុតក្ដាមឈឺចំពោន សត្វមានក្រចកជើងពីរ តែសត្វសេពុំឈឺជម្ងឺនេះទេ ។ ជម្ងឺសារទឹកឈឺជំពានគោ-ក្របី ជ្រូក ប៉ុន្តែ ជម្ងឺប៉េស្ត ជ្រូកមានឥទ្ធិពលតែលើសត្វជ្រូកប៉ុណ្ណោះ ។ ដូចគ្នានេះដែរ ជម្ងឺប៉េស្តគោក្របី មានឥទ្ធិពល តែទៅលើ គោក្របី ។

ដូច្នេះជម្ងឺអាចចែកជា :

- ជម្ងឺសត្វជ្រូក (Swine Diseases)
- ជម្ងឺសត្វគោ (Cattle Diseases)
- ជម្ងឺសត្វចៀម (Sheep Diseases)
- ជម្ងឺសត្វបក្សី (Poultry Diseases)
- ជម្ងឺឆ្កែ (Canine Diseases) ។ល ។

# ជំពូក៥

# ការការពារ និង ត្រួតពិនិត្យជម្ងឺ

Disease prevention and control

*៥.១ ការការពារជម្ងឺ (Diseas prevention )*

ការចាក់វ៉ាក់សាំង ជាវិធីបង្កការពារជម្ងឺយ៉ាងមានប្រសិទ្ធភាពបំផុត។ ប៉ុន្តែ កត្តាដែលប៉ះពាល់ដល់សុខភាព ដូចជា៖ការផ្តល់ចំណីរ ការថែទាំ អនាម័យ ការសម្អាតទ្រុង ការសំលាប់មេរោគ( DesinfecTion )។

***៥.២ អនាម័យ(Hygene)-*** - អនាម័យនាំមកនូវសុខភាព ការផ្តល់ចំណីអាហារ ទឹក មានអនាម័យល្អ បង្កអោយសត្វនូវលក្ខខ័ណ្ឌប្រកបដែលបញ្ចៀសសត្វអោយផុតពីការរាតត្បាតនៃមេរោគ និង ភាពទ្រុតទ្រោម។ បរិយាកាស និង ភាពអាប់អួរនៃទ្រុងសត្វ បង្កអោយសត្វស្រ្គេស។

***៥.៣ ការសំលាប់មេរោគ ( DesinfecTion )*** ការសំអាតសំលាប់មេរោគត្រូវបានគេធ្វើឡើងក្នុងបំណងទប់ស្កាត់ការរាតត្បាតនៃមេរោគ។ ការសំលាប់មេរោគមាន:

ការសំលាប់ដោយប្រើសារធាតុគីមី គេប្រើសារធាតុគីមីដូចជា: KMnO4 ; ហ្វ័រម៉ុល (Formol);ហ្វេណុល (Phenol); ក្លរ(Cl); បាស (Alkalin); អាស៊ីត (Acid)។ល។ការសំលាប់ដោយប្រើវិធីរូប មានដូចជាកំដៅ ;កាំរស្មីអ៊ុលត្រាវីអូលេ កាំរស្មីពន្លឺព្រះអាទិត្យ។ល។ ការសំលាប់មេរោគត្រូវតែធ្វើឡើង ដោយគ្មានការប៉ះពាល់ដល់សុខភាពសត្វ ប៉ុន្តែត្រូវធានានូវការសំលាប់មេរោគបានល្អ។

– ***កម្តៅ*** (Heat): កំដៅនៅកំរិតខ្ពស់និងក្នុងរយៈពេលកំណត់មួយអាចសំលាប់មេរោគបាន។ បាក់តេរីមួយចំនួនធន់នឹងអាកាសធាតុខ្ពស់ ដូចជាពពួកស្ព័ររបស់ )Bacillus clostridiumជាដើម ( ម៉ោង។ គេប្រើកំដៅតាមច្រើនរបៀប១អង្សារសេក្នុងរយៈពេល១០០អាចសំលាប់បាននៅសីតុណ្ហភាព ) ដូចជា៖ ការស្ងោរ ការដុត ការចំហុយនៅសម្ពាធខ្ពស់Autoclave)

– ***កាំរស្មីព្រះអាទិត្យ និង កាំរស្មីអ៊ុលត្រាវីអូលេ*** (Sun Ultraviolet Rays): កាំរស្មីព្រះអាទិត្យរួមមាន៖កាំរស្មី X កាំរស្មី អាលហ្វា និង កាំរស្មីផ្សេងៗទៀតជាពិសេស Ultravole ដែលអាចបង្អាកការលូតលាស់ និង ធ្វើការសំលាប់មេរោគយ៉ាងសកម្ម។ សព្វថ្ងៃគេបានបង្កើតអំពូលភ្លើងអគ្គិសនីដែលអាចបញ្ចេញកាំរស្មី Ultravole សំរាប់សំលាប់មេរោគក្នុងមន្ទីពិសោធន៍ និង បន្ទប់អនាម័យ។

**សារធាតុគីមីប្រើសំរាប់សំលាប់មេរោគ:**

សារធាតុគីមីត្រូវបានគេប្រើក្នុងកំហាប់ និង កំរិតច្បាស់លាស់ដើម្បីការពារនូវផលប៉ះពាល់ដល់បរិស្ថានជីវិត សត្វ និង រុក្ខជាតិនៅជុំវិញ។ សារធាតុគីមីដែលប្រើញឹកញាប់មានដូចជា៖

- សូលុយស្យុងផេណុល )Phenol ( 3-5 ភាគរយ
- Free chlorine 100-200 part/million
- Quaternary Ammonium compound 0.1-0.5%
- Solution $KMnO_4$ ( 4% )
- Solution Methanol 1-5%
- Solution Hydroxide ( caustic Acide )

សារធាតុគីមីប្រើសំរាប់លាងសំអាតប្រដាប់ប្រដាប្រើប្រាស់ ជាសូលុយស្យុងដែលជាទូទៅគេលាយក្នុងកំហាប់ពី 1-2%។

### *៥.៤ ការត្រួតពិនិត្យជម្ងឺ ( Disease Control ):*

ខាងក្រោមជាព័ត៌មានសំខាន់សម្រាប់ប្រើប្រាស់ត្រួតពិនិត្យជម្ងឺៈ

– ការសិក្សាភាពរាតត្បាតជម្ងឺ )Epidemiology(
– ការធ្វើរោគវិនិច្ឆ័យជម្ងឺ )Disease Diagnosis(
– ការធានាស្ថានភាពគ្មានជម្ងឺ ( Quarantine )

***៥.៥ ការសិក្សាភាពរាតត្បាតជម្ងឺ ( Epidemiology )*** ការផ្ទុះជម្ងឺឆ្លងក្នុងតំបន់មួយ ជាលក្ខណៈពិសេសនៃតំបន់នោះ ដែលតម្រូវអោយមានការកត់ត្រា និង ផ្សព្វផ្សាយដល់តំបន់ផ្សេងទៀតដែលមានព្រំប្រទល់ជាប់គ្នា។ ការកត់ត្រាត្រូវស្រង់យកមកអោយបានច្បាស់នូវអត្រាគ្រោះថ្នាក់ ( Incedene Rate ) អត្រាសត្វឈឺ ( Mobidity Rate ) អត្រាសត្វស្លាប់ ( Motality Rate ) អត្រាសត្វជាពីជម្ងឺ ( Recovery Rate ) ជាដើមដើម្បីធ្វើការផ្សព្វផ្សាយអំពីភាពមហន្តរាយនេះ និងដើម្បីចាត់វិធានការទប់ស្កាត់នៃការរាលដាលក្នុងតំបន់ជិតខាង។ គួរកត់សំគាល់ថា មេរោគអាចរក្សាជីវិតរស់នៅក្នុងសារពាង្គសត្វ ដែលជាសះស្បើយពីជម្ងឺឬអាចរស់នៅក្នុងដី ទឹក រុក្ខជាតិ និង ប្រដាប់ប្រដារប្រើប្រាស់ផ្សេងៗទៀតបានជាច្រើនឆ្នាំ។ វាទាមទាអោយមានវិធានការណ៍ពាក់ព័ន្ធដល់ជំងឺដែលកំពុងផ្ទុះដោយការវែកញែកប្រភេទជំងឺ ដូចជា ជំងឺអ្វី ? ជាប្រភេទជម្ងឺ Pendemic, Endemix ឬ Epidemix, Sporadic Diseases និងប្រសិនបើជម្ងឺត្រូវបាន គេសង្ស័យថាជាជម្ងឺ Zoonoses គេត្រូវមានវិធានការណ៍ជាមួយក្រសួងសុខាភិបាលជាបន្ទាន់។ វិធានការណ៍ដែលត្រូវអនុវត្តន៍មានដូចជាៈ ការចាក់វ៉ាក់សាំងហ៊ុំព័ន្ធតំបន់រាតត្បាត ការហាមឃាត់ដឹកនាំសត្វ និង ចរាចរណ៍ផលិតផលសត្វពីតំបន់ផ្ទុះជម្ងឺជាពិសេសបញ្ឈប់ការសំលាប់សត្វយកសាច់នៅតំបន់នោះ។ សត្វស្លាប់ត្រូវត្រួតពិនិត្យ និងអនុវត្តតាមបច្ចេកទេសឲ្យបានសមស្រប។

***៥.៦ ការធ្វើរោគវិនិច្ឆ័យជំងឺ ( DiSease Dignosis )*** ការធ្វើរោគវិនិច្ឆ័យជាវិធីយ៉ាងមានប្រសិទ្ធភាពសម្រាប់ការត្រួតពិនិត្យនិងការព្យាបាលជំងឺ។ ការធ្វើរោគវិនិច្ឆ័យត្រូវផ្អែកលើ

❖ **ការពិនិត្យតាមដានរោគសញ្ញា** (Clinical Examination) ជាការសិក្សារោគសញ្ញាសត្វឈឺ។ជាបឋមគេធ្វើការត្រួតពិនិត្យសភាពខាងក្រៅទូទៅ )Genaral Appearance)សត្វដូចជាសភាពរោម : ដំណើរ ការហូរទឹកសំបោរ ទឹកមាត់ ភ្នែក ច្រមុះ រន្ធភេទ។ល។ព័ត៌មានអំពីអាយុប្រវត្តិសត្វ ជាកត្តាយ៉ាងសំខាន់ជំនួយក្នុងការធ្វើរោគវិនិច្ឆ័យ។ ប្រវត្តិសត្វអាចឆ្លុះបញ្ចាំងឲ្យដឹងអំពីការចាក់វ៉ាក់សាំងប្រភពដើម : របស់សត្វ ធ្លាប់ឈឺជំងឺអ្វីខ្លះ? នៅពេលណា? ការប្រើប្រាស់ជាកំលាំងអូសទាញ យកសាច់ ឬទឹកដោះជាដើម។ បន្ទាប់មកការពិនិត្យសភាពប្រែប្រួលខ្លួនសត្វបានត្រូវគេធ្វើឡើងដូចខាងក្រោម :

- វាស់សីតុណ្ហភាពខ្លួនសត្វ សត្វក្តៅខ្លួនឬធម្មតា
- វាស់ជីបចរ ញាប់ខ្លាំងឬខ្សោយ
- មានស្នាមអ្វីខ្លះរលាក(Inflammation), rak (Diarrhoea), ក្តៀន (Constupation)
- សត្វមានការឈឺចាប់ក្នុងពោះ(Colic) ស្ទាប Palpation)
- សត្វមានបាក់ឆ្អឹង ក្រិច....
- មានក្អួត(Vomition) ក្អក (CaUgh)
- ការស៊ីចំណីផឹកទឹក ស៊ីមិនបាន (Anorexia)
- ការថប់ដង្ហើម(Dispnoae)

❖ **ការយកវត្ថុវិភាគ** )sampling)

វត្ថុវិភាគដែលត្រូវយកដើម្បីធ្វើតេស្តនៅមន្ទីរពិសោធន៍មាន:

- **វត្ថុវិភាគឈាម )Blood sample):** គេយកពីសរសៃឈាមវ៉ែនករចំពោះសត្វធំៗដូចជាគោ ក្របី ចៀម និងពពែ។ ចំពោះជ្រូកគេយកសរសៃវ៉ែននៅត្រចៀក ឬ កន្ទុយ។ ឈាមត្រូវបានគេយកដើម្បីសិក្សា ) ការប្រែប្រួលនៃលោហិតសាស្ត្រ :Hematology) ឈាមថ្លា )Serology) និងវិភាគគីមី )Chemical Test)។ ឈាមសម្រាប់ផ្នែកលោហិតសាស្ត្រត្រូវយកដោយប្រើថ្នាំការពារឈាមកក )Anticoagulant) ដើម្បីធ្វើការសិក្សាសភាពគោលិកាឈាមស )White Blodd cells) ឈាមក្រហម )Red Blood Cells) អេម៉ូក្លូប៊ីន)Hb) និង អេម៉ាតូគ្រីត )pack- Cell Volum)ជាដើម។ ឈាមសម្រាប់ផ្នែកសេរ៉ូមសាស្ត្រ )Serology) ត្រូវបានគេយកដោយគ្មានការលាយប្រើថ្នាំការពារឈាមកកទេ។ គេទុកឈាមនេះក្នុងបំពង់ទីបបន្ទាប់ពីបូមរួច ហើយទុកឲ្យរងបន្ទាប់មកគេចាក់យកផ្នែកថ្លានៅខាងលើដែលជាសេរ៉ូមឈាម។ សេរ៉ូមឈាមនេះត្រូវគេយកទៅធ្វើតេស្តដូចជា) កតេស្តរ :Aglutination Test) តេស្តរកអង់ទីករ )ELISA Test) ជាដើម។
- **គំនៀសឈាម**) Blood Smear) គំនៀសត្រូវធ្វើឡើងពីឈាមស្រស់ថ្មីៗយកពីសត្វហើយកៀសលើកញ្ចក់ មានកម្រាស់ស្តើងនិងស្មើល្អ។ គេរៀបចំធ្វើគំនៀសឈាមដើម្បីសិក្សារកវត្តមានបាក់តេរី ឬប្រូតូសូអា និងវិភាគសមាមាត្រគោលិកាឈាមសដូចជា :Neutrophile, Basophile, Eosinophile, Monocyte និង Lymphocyte។

- **ទឹករងៃ ) សំបោរ**.Secresion ) ទឹកសំបោរ ទឹកភ្នែក និងទឹករំអិលផ្សេងៗបានពីត្រចៀក

ប្រដាប់បន្តពូជត្រូវគេយកដោយជំបារសំឡីស្តេរីលដើម្បីធ្វើការបណ្តុះមេរោ )Bacterial Culture ) ឬធ្វើគនៀសលើកញ្ចក់ដើម្បីរកវត្តមាននៃបាក់តេរីឬប៉ារ៉ាស៊ីត។

- **លាមក** )Faeces ):លាមកសម្រាប់ពិនិត្យរកវត្តមានប៉ារ៉ាស៊ីតនិងដើម្បីធ្វើការបណ្តុះមេ

រោគ )Coproculture ) ត្រូវតែជាលាមកស្រស់យកចេញពីគូទសត្វឬត្រូវយកដោយជំបារសំឡីស្តេរីលពីផ្នែកខាងក្នុង។

- វត្ថុវិភាគផ្សេងទៀតដូចជា: ថ្លើម ផាល តំរងនោម បេះដូងសួតពោះវៀនខួរឆ្អឹង។ល។

បានត្រូវគេយកដើម្បីសិក្សា បាក់តេរីសាស្ត្រ( Bacteriology ) ឬ បម្រែបម្រួលជាលិកាវិទ្យា (Histo-pathology )។សរីរាង្គ និង ជាលិកាទាំងនេះបានមកពីការវះកាត់ សាកសពសត្វ( Autopsy )៕

***៥.៧ ការជានាស្ថានភាពសត្វគ្មានជម្ងឺ (Quarantine)--*** គោលការណ៍នៃ Quarantine នេះបានត្រូវប្រទេសជាច្រើនយកមកអនុវត្តសំរាប់ត្រួតពិនិត្យសុខភាពសត្វនាំចេញ និង នាំចូលQuarantine ពុំមែនអនុវត្តតែលើសត្វប៉ុណ្ណោះទេ ប៉ុន្តែគេក៏ធ្វើ Quarantine លើមនុស្សផងដែល នៅប្រទេសរីកចម្រើនទាំងឡាយក្នុងពិភពលោក។ មូលដ្ឋាននៃការហ៊ុំបិទ( Enclosure ) លទ្ធភាពរាលដាលនៃជម្ងឺបណ្តាមកពីការធ្វើចរាចរបានត្រូវគេចាត់ទុកជាវិធានការណ៍ទប់ស្កាត់ជម្ងឺឆ្លងយ៉ាងមានប្រសិទ្ធិភាព។ ការដឹកនាំសត្វពីតំបន់គ្មានជម្ងឺទៅតំបន់មានជម្ងឺ ឬ ផ្ទុយមកវិញអាចបង្កើតបរិមាណសត្វឈឺ និង ដូច្នេះពង្រីកតំបន់រាតត្បាតដោយជម្ងឺ។ ការដឹកនាំសត្វ និង ផលិតផលសត្វនៅក្នុងស្រុក និង ជាពិសេសពីប្រទេសមួយទៅប្រទេសមួយទៀតត្រូវតែមានការត្រួតពិនិត្យ និង ធានាតាមរយ:ការធ្វើតេស្ត និង ការចាក់វ៉ាក់សុំាងបង្ការរោគបានត្រឹមត្រូវ។ ជាទូទៅសត្វដែលត្រូវដឹកជញ្ជូលត្រូវបានគេរក្សាទុកនៅក្នុងតំបន់ Quarantine ពី ១៤ ទៅ ២១ថ្ងៃ ដើម្បីតាមដានពិនិត្យស្ថានភាព សុខភាព និង ការចាក់វ៉ាក់សុំាងការពារជម្ងឺ។

***៥.៨ ការវះកាត់សាកសពសិក្សាស្លាកស្នាមជម្ងឺ***( Autopsy/Postmortem Examination )--ជម្ងឺបង្កអោយមានស្លាកស្នាម រលាក ដំបៅ ឬប្រែប្រួលសើសពីសរីរាង្គខាងក្នុង ជាលក្ខណ:ប្រែប្រួលរបស់ ជាលិកា( Patho- Histology )និង កាតវិភាគ ( Patho-Anatony )។

***បច្ចេកទេសធ្វើ Autopsy***:មុនចាប់ផ្តើមធ្វើ ត្រូវសាកសួរ និង កត់ត្រាប្រវិត្តសត្វអោយបាច្បាស់លាស់( អាយុភេទ ការចាក់វ៉ាក់សុំាង? ឈឺពីពេលណា? ស្លាប់នៅពេលណា?។ បម្រែបម្រួលដែលពិនិត្យឃើញលើសសរីរាង្គពេលវះកាត់ ត្រូវកត់ត្រាតាមលំដាប់លំដោយ។

**សត្វធំ:** ត្រូវដាក់សត្វផ្សេងទៅចំហៀងខាងឆ្វេង និង សត្វបក្សី:ត្រូវដាក់ផ្ការពោះលើងលើ។

- ផ្សើមរោមដោទឹកចំពោះបក្សី ចំពោះសត្វធំៗលាង ដោយប្រើច្រាស់ដុះ

- ពន្លាត់ស្បែកសត្វចាប់ពីផ្ទៃពោះ
- កាត់យកឆ្អឹងសន្ទះទ្រូងចេញ
- បើកប្រអប់ទ្រូង: ពិនិត្យមើល សួត បេះដូង
- បើកប្រអប់ពោះ ពិនិត្យថ្លើម ផាល ពោះវៀន ក្រពះ ក្រពេញកូនកណ្តុល ក្នាសពោះ។ល។
- ពិនិត្យសាច់ដុំ សរសៃប្រសាទ សរសៃពួរ
- ពិនិត្យមើលជាលិកាខួរក្បាល ខួរឆ្អឹងខ្នង( Central Nervous System/CNS )

# ជំពូក៦
# គោលការណ៍ នៃ ការព្យាបាលជម្ងឺ
## PRINCIPALS OF TREATMENT

បន្ទាប់ពីមានការវាយតំលៃ និងធ្វើរោគវិនិច្ឆ័យបានត្រឹមត្រូវ ត្រូវការព្យាបាលបាន ត្រូវគេឱ្យអនុវត្តឡើយ ។ ករណីម្ចាស់សត្វពុំយល់ អំពីការប្រើប្រាស់ថ្នាំ ការផ្តល់ថ្នាំសត្វ ត្រូវធ្វើឡើងដោយបសុពេទ្យ។ ការព្យាបាល តំរូវឱ្យ មានការតាមដាន និង ដឹកនាំដោយបសុពេទ្យ។

ការផ្តល់ថ្នាំអោយសត្វ គេត្រូវយកចិត្តទុកដាក់លើ គោលបំណងនៃការព្យាបាល ដោយធ្វើការជ្រើសរើស ថ្នាំ និងវិធីផ្តល់ឱ្យសត្វ ។ ដូចជាសត្វក្អួត (Vomiting) ញឹកញាប់ ការផ្តល់ថ្នាំតាមមាត់ (Oral Medication) ពុំសូវផ្តល់លទ្ធផលល្អទេ ។ ថ្នាំនីមួយ១ មានវិធីផ្តល់ឱ្យសត្វដោយឡែកដូចជាៈ ចាក់តាមសសៃវ៉ែន (I.V) ចាក់សាច់ដុំ (I.M) elb (Oral) ។ល ។ ដូច្នេះ៖ មុនប្រើប្រាស់ថ្នាំគេត្រូវមើលបទបញ្ជាលើក្រដាលថ្នាំ ឬ ត្រូវមានភាពប្រាកដក្នុងខ្លួន។

### *៦.១ វិធីផ្តល់ថ្នាំ(Medication Methoks):*

វិធីផ្តល់ថ្នាំមានៈ

***៦.១.១ ការផ្តល់ថ្នាំតាមមាត់(លេប)*** (Oral Admiinistration) - ថ្នាំមួយចំនួនធំ បានត្រូវគេផ្តល់ឱ្យសត្វតាមមាត់ ។ ថ្នាំទាំងនេះអាចជាម្សៅ(Powder), គ្រាប់ (Tablet), សំបុកម្ជូល (Capsule) ។ ប្រភេទថ្នាំផឹក ឬ រាវ (liquid), ពងក្រពើ (Oval) ។ ការផ្តល់ថ្នាំតាមមាត់ (Per os /Oral ត្រូវបានគេធ្វើឡើងក្នុងបំណងការពារ ព្យាបាលជម្ងឺសត្វ មានជម្ងឺប្រដាប់រំលាយអាហារ ជម្ងឺរ៉ាំរ៉ៃ ការផ្តល់ថ្នាំតាមផ្លូវនេះ អាចមានគ្រោះថ្នាក់ ឬ ពុំសូវមានប្រសិទ្ធភាពល្អ ។

ការផ្តល់ថ្នាំតាមមាត់ ត្រូវយកចិត្តទុកដាក់លើប្រភេទថ្នាំ និងប្រតិកម្មរបស់វាមួយក្រពេញក្រពះ (Gastric Juice) ដូចជា Penicilline អាចបន្ថយប្រសិទ្ធិភាពដោយក្រពេញក្រពះ ។ ចំពោះសត្វទំពៀរអៀង ការផ្តល់ពួកពអង់ទីប៊ូទីច (Antibiotics) តាមមាត់ពុំសូវផ្តល់ល្អទេព្រោះថ្នាំអាច សំលាប់ពពួក Microflora នៅក្នុងពោះធំ (Rumen) ឬ បន្សាយនាទីរបស់វាក្នុងការបំបែកសែលុយឡូស (Cellulose). ជាទូទៅការផ្តល់ថ្នាំតាមផ្លូវមាត់ ចំពោះសត្វធំៗ ជួបប្រទះការលំបាកច្រើន គេប្រើចំពោសត្វតូចៗពិសេសសត្វមិន ទំពៀងអៀង(Monogastic) ។ វិធីនេះបានត្រូវ វគេប្រើយាងទូលំទូលាយ ចំពោះ សត្វឆ្កែ ឆ្មាំ ជ្រូក វិធីនេះមានប្រសិទ្ធភាពខ្ពស់បំផុត ចំពោះការព្យាបាល ប្រដាប់រំលាយអាហារ ហើយវិធីនេះពុំសូវផ្តល់គ្រោះថ្នាក់ខ្លាំងក្លាទេ ករណីមានការភ័ន្តច្រឡំ លើសកំរិតបន្តិចបន្តួច។

***៦.១.២ តាមការដេកដង្ហើម (Inhalation )*** ---ពពួកថ្នាំប្រភេទឧស្មន និង ថ្នាំលាយមួយចំនួនបានផ្តល់ឱ្យសត្វ តាមរបៀបបំភាយជាឧស្ម័នតាមការដេកដង្ហើមរបស់សត្វ (Aerosol) ដូចជាពពួកថ្នាំជំនួយផ្លូវដេកដង្ហើមផ្សេងៗ។

- Aerosol នៃ Ethyl Alcohol បានត្រូវគេប្រើសំរាប់សំអាតភ្នាសរំអិល នៃប្រដាប់ដកដង្ហើម និងព្យាបាល ជម្ងឺហើមសួត ( Pulmonary Edema / Emphysema ) Nacotie/ Anesthesia ។ គេអាចផ្តល់ឱ្យសត្វ ដោយប្រើបំពង់ច្របាច់បញ្ចូលតាមច្រមុះ ។

- Oxygen $O_2$ Carbondioxide, Chloroform , Ether, Fluotbane និង ក្រុមថ្នាំ Anesthesia ផ្សេងទៀតបានត្រូវគេប្រើតាមវិធីនេះយ៉ាងមានប្រសិទ្ធភាព ។ ដើម្បីធ្វើការសង្គ្រោះបន្ទាន់ វិធី Inhalation នេះផ្តល់នូវការចាំបាច់យ៉ាងធំធេងដូចជាការបញ្ចូល $O_2$ តាមរន្ធច្រមុះ( Nostril ) ឬ តាមបំពង់ខ្យល់ជាដើម ។ ប៉ុន្តែគេត្រូវយកចិត្តដាក់លើកំរិត ល្បឿន និង កំហាប់ ( Consentralion ) របស់ឧស្ម័ននោះ ។ ការបញ្ចូល $O_2$ ត្រូវមានល្បឿន២.៣ លីត្រក្នុង១នាទី ។

ការផ្តល់ថ្នាំតាមវិធីនេះ ប្រើជាសំខាន់សំរាប់ការព្យាបាលជម្ងឺប្រដាប់ដកដង្ហើម និងការពារជម្ងឺ។ប្រតិកម្មនិងជម្រាបថ្នាំទៅក្នុងសាពង្គកាយមានល្បឿនជាបង្គួរ។ គេក៏អាចប្រើពពួក (Antib-iotic) ជាប្រភេទឧស្ម័នដាក់ក្នុងបន្ទប់ ដើម្បីព្យាបាលសត្វ ឬ ការពារជម្ងឺប្រដាប់ដកដង្ហើមយ៉ាងមានប្រសិទ្ធភាព ។

**៦.១.៣ តាមផ្លូវផ្សេងទៀត** ( Parenteral Administration ): ក្រៅពីការផ្តល់ថ្នាំតាមផ្លូវខាងលើ (Oral , Inhalation) គេអាចផ្តល់ថ្នាំតាមវិធី Parenteral ។ វិធី នេះមានប្រតិកម្ម និង ប្រសិទ្ធភាពលឿនជាង ។

វិធីនេះបានត្រូវគេអនុវត្តយ៉ាងទូលំទូលាយ ប៉ុន្តែវាទាមទារនូវសំភារៈនិង ឧបករណ៍ ដូចជាំសេរាំង ម្ជុល ដង្កៀបចាប់ កន្ត្រៃ ។ ល ។ ដែលបានត្រូវធ្វើការរំងាប់មេរោគយ៉ាងត្រឹមត្រូវ ព្រមទាំងពិនិត្យកំរិត និងវិធីប្រើផ្សេងៗ ទៀត ព្រោះវាអាចបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងងាយដូចជាៈ បណ្តាលឱ្យសត្វសន្លប់ (Anaphylactic Choke) និងប្រតិកម្មផ្សេងៗ ដែលជាដើមហេតុអាចបណ្តាលឱ្យសត្វស្លាប់យ៉ាងងាយ ។ Parenteral Administration មានៈ

- **ការចាក់ក្រោមស្បែក** (Subcutanous Injection): វិធីនេះប្រើប្រាស់ សំរាប់ការផ្តល់សេរ៉ូមឬការចាក់វ៉ាក់សាំងមួយចំនួន ។ ម្ជុលដែលប្រើសំរាប់ចាក់ក្រោមស្បែក ត្រូវមានប្រវែងខ្លីល្មម ។ គេអាចចាក់តាមរបៀបមួយទៀត គឺចាក់ក្នុងស្បែក (Intradermal) ដូចក្នុងករណីធ្វើតេស្តជម្ងឺរបេង

(Tuberculin Test) ជាដើម ។

-**ការចាក់សាច់ដុំ** ( Intramusclar Injection ): ជាការចាក់ថ្នាំបញ្ចូលតាមសាច់ដុំ។ ការចាក់ថ្នាំតាមផ្លូវនេះត្រូវប្រម្ជុលវែង ហើយយកចិត្តទុកដាក់មិនឱ្យប៉ះពាល់ឆ្អឹង ឬ បណ្តាលឱ្យបាក់ម្ជុល ឬ រលាកសៃឈាម។ សត្វគោ - ក្របី គេអាចចាក់នៅផ្នែកសាច់ដុំធ្មា នៃត្រគៀកចំពោះ សត្វធំ ធ្មា នៅត្រង់សដុំ

ស្លាប។ វិធីនេះថ្នាំមានប្រតិកម្មយឺតល្មម ហើយពុំសូវមានភាពស្មុគ្រស្មាញ។ ប៉ុន្តែម្ជុលសេរ៉ាំងត្រូវធ្វើការរំងាប់មេរោគល្អ។ គួរចងចាំថា សេរ៉ាំង និង ម្ជុលមិនស្អាតអាចជាវិធីចំលងរោគ ដូច្នេះគេត្រូវសម្អាតកន្លែងចាក់ដោយសំឡីអាល់កុល ឬ អ៊ីយ៉ូត ៥ ភាគរយ មុន និងក្រោយការចាក់ ។

**- ការចាក់តាមវ៉ែន ( Intraveinous Infection ):** ជាការចាក់បញ្ចូលថ្នាំតាមវ៉ែន ។ តាមវិធីនេះថ្នាំមានប្រតិកម្មលឿន ហើយមានប្រសិទ្ធភាព ។ ម្ជុលប្រើសំរាប់ចាក់តាមសរសៃវ៉ែន ត្រូវមានទំហំតូច ។ ការបូមថ្នាំ និង បញ្ចូលថ្នាំទៅក្នុងសរសៃឈាម ត្រូវយកចចិត្តទុកដាក់មិនឱ្យមានមានពពុះខ្យល់ក្នុងសេរ៉ាំង។ ការចាក់ត្រូវចៀសវាង ការចាក់ធ្លុះសរសៃម្ខាងទៅសរសៃម្ខាងទៀត និង ការបាញ់ថ្នាំបញ្ចូលត្រូវរក្សាល្បឿនថេរ និង យឺតល្មម ។ ចំពោះសត្វ គេអាចចាក់សរសៃវ៉ែនទាំងឡាយណាដែលអាចមើលឃើញច្បាស់ និង មានទីតាំងងាយស្រួលចាក់: សត្វធំៗអាចចាក់តាមវ៉ែន (Jugular Veine) ជ្រូកតាមវ៉ែនត្រចៀក ឆ្កែឆ្មា-តាមវ៉ែនជើង។ ល ។ នៅពេលដកម្ជុលចេញពីសរសៃវ៉ែន ពុំគប្បីប្រើដៃញីលើមុខរបួសឡើយ វាបណ្តាលឱ្យមានជាឈាម (Heamotomia) គឺត្រូវប្រើសំឡីខ្ទប់ដោយម្រាមដៃលើមុខម្ជុល ដោយសង្កត់នៅនិងមួយកន្លែងរយៈពេលខ្លី ១០-១៥ វិនាទី ។

- ការចាក់បញ្ចូលក្នុងប្រអប់ពោះ (Intraperitoneal Injection): គេប្រើវិធីនេះក្នុងករណីៈ

- រលាកស្រោមពោះ ( Peritonitis )
- រលាកពោះវៀនស្រួចស្រាវ ( Acute Enteritis )
- ប៉ុន្តែការចាក់បញ្ចូលតាមផ្លូវនេះត្រូវប្រុងប្រយ័ត្ន មិនឱ្យប៉ះពាល់ដល់សរីរាង្គក្នុងប្រអប់ពោះ ។

- ការចាក់បញ្ចូលក្នុងប្រអប់ទ្រូង (Intrathoracis): គេប្រើជាពិសេសក្នុងបំណងព្យាបាលការរលាកនៃសរីរាង្គក្នុងប្រអប់ទ្រូង ដូចជា:

- រលាកសួត )Pncumonia)
- រលាកស្រោមសួត )Plcuritis)

តាមវិធីនេះថ្នាំជ្រាបចូលទៅដល់ជាលិកាសួត និងភ្នាសរំអិលក្នុងប្រអប់ទ្រូងបានលឿន។

**-ការបញ្ចូលថ្នាំតាមគូទ** (Rectal Medication): ថ្នាំដែលបញ្ចូលតាមគូទអាចជាប្រភេទ

សូលុលស្យុង ឬថ្នាំសម្របសម្រួលដល់ការកន្ត្រាក់ពោះវៀន និងធ្វើឲលាមកទន់នៅពេលសត្វគៀនលាមក។ វិធីនេះគេប្រើជាញឹកញាប់ក្នុងផ្នែកវេជ្ជសាស្ត្រ ប៉ុន្តែម្តងម្កាលក្នុងវិស័យបសុព្យាបាល។ ថ្នាំបានត្រូវជ្រាបនៅផ្នែក Colon និងផ្នែក Rectum នៃពោះវៀនធំ។ តែប្រើទឹករំអិលតាមផ្លូវនេះក្នុងការបញ្ចុះលាមក។

**-ការលាបលើស្បែក (Implantation):** ថ្នាំ និងសារធាតុមួយចំនួនត្រូវបានគេប្រើលើសត្វតាមកម្មវិធីនេះ ក្នុងករណីសត្វក្រិច ភ្លាត់រមួលសាច់ដុំ និងបញ្ចុំកម្តៅខ្លួនសត្វ។ ថ្នាំសម្រាប់លាបលើស្បែកជាវត្ថុរាវ

ប្រេង (oil) ម៉ូម៉ាត (Past) ដូចជា៖ វ៉ាស៊ីលីន (Vasilin) ថ្នាំសម្រាប់សម្លាប់ចៃតុកកែ និងថ្នាំលាបដំបៅជាដើម។

**- ការចាក់បញ្ចូលក្នុងកន្សោមដោះ** *(Mammary)* --ប្រើពិសេសដើម្បីចាក់បញ្ចូល៖

- ថ្នាំសម្លាប់មេរោគ
- ថ្នាំស្ពឹកដូចជា Novocaine

**-ការចាក់អេពីឌូរ៉ាល់** *(Epidural Injection)* --ជាការចាប់ពពួកស្ពឹក (Anesthesia) ក្នុងការវះកាត់ ឬព្យាបាល ការរលូតកូន (Metristis) ស្រុតស្បូន (Utrerus Colapse)។ វិធីនេះគឺចាក់នៅត្រង់ឆ្អឹងកងផ្នែកត្រគៀកដោយម្ជុលវែងល្មម។

**- ការចាក់ទំលុះពោះធំ** *(Ruminal Puncture)*: ជាការចាក់ដើម្បីយកឧស្ម័នចេញពីពោះធំរបស់សត្វពេលសត្វហើមពោះ (Bloat) ។ ការចាក់ត្រូវប្រើឧបករណ៍ Troaka ហើយគប្បី បញ្ចេញឧស្ម័ននេះបន្តិចម្តងៗ ដើម្បីជៀសវាង ការសន្លប់ ដែលអាចបណ្តាលឲសត្វស្លាប់។

ដើម្បីធ្វើឲការព្យាបាលបានត្រឹមត្រូវ និងមានប្រសិទ្ធភាពល្អ បសុពេទ្យគប្បីយកចិត្តទុកដាក់មិនគ្រាន់តែជ្រើសរើសប្រភេទថ្នាំ និងវិធីសាស្រ្តប្រើប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើការសម្អាត សម្លាប់មេរោគដោយប្រុងប្រយ័ត្ន។

### ៦.២ វិធីសាស្រ្ត នៃការព្យាបាល (Treatment/Therapeutic Methodology):

ការព្យាបាលជាសិល្ប: នៃការអនុវត្តប្រើប្រាស់ថ្នាំ និងទេពកោសល្យយ៉ាងសំាញ៉ាំ។ វាទាមទារឲមានការយកចិត្តទុកដាក់ និងគិតគូរឲបានច្បាស់លាស់ មុនជ្រើសរើសយកការព្យាបាលណាមួយ។

***គោលការនៃការព្យាបាលមានដូចជា៖***

***៦.២.១ ការព្យាបាលផ្អែកលើបុព្វហេតុបង្កជំងឺ (Causative Treatment)*** --ការព្យាបាលត្រូវបានគេអនុវត្តដោយមានទិដៅច្បាស់លាស់។ ក្នុងពេនេះការប្រើថ្នាំសម្លាប់មេរោគ (Antibiotics) គឺជាការចាំបាច់ដើម្បីបំបាត់ឫសគល់ នៃការរាតត្បាតពពួកបាក់ឲតេរី។ Antibiotics ពុំអាចសម្លាប់ពពួលវីរុសបានឡើយ។ ក្រុមថ្នាំ Sulfanilamide ពុំមាននាទី សម្លាប់មេរោគទេ ប៉ុន្តែវាទប់ស្កាត់ការលូតលាស់របស់មេរោគ។ ការព្យាបាលក្នុងបំណងសម្លាប់មេរោគបង្កជំងឺ ត្រូវតែធ្វើឡើងក្រោមកម្មវិធីព្យាបាលទៀងទាត់៖ រយ:ពេលព្យាបាលដោយអង់ទីប៊ីយ៉ូទិច ត្រូវមានរយ:ពី ៥ ទៅ ៧ ថ្ងៃ ហើយកំណត់កំរិតឲបានត្រឹមត្រូវ ព្រោះបាក់តេរីអាចធន់នឹងថ្នាំទាំងអស់នេះនៅពេលដែលយើងប្រើប្រាស់ពុំតាមកំរិតកំណត់ និងរយ:ពេលត្រឹមត្រូវទេនោះ។

*៦.២.២ ការព្យាបាលផ្អែកលើរោគសញ្ញា (Symptomatic Treatment)* -- ជាការព្យាបាលមានទិសដៅលុបបំបាត់រោគសញ្ញា។ ដូចជាសត្វក្អក ក្អួត រាគ ការផ្តល់ថ្នាំត្រូវធ្វើឡើងដើម្បីទប់ស្កាត់ និងបំបាត់រោគសញ្ញាទាំងនេះ។ ប្រសិនបើជំងឺសត្វបង្កដោយមេរោគ គេអាចអនុវត្តវិធីនេះជាមួយការប្រើថ្នាំសម្លាប់មេរោគព្រមគ្នាតែម្តង។ សត្វរាគខ្លាំង បណ្តាលឲសារពាង្គកាយសត្វបាត់បង់ជាតិទឹក ដូច្នេះគេផ្តល់ឲសត្វនូវសេរ៉ូមប្រៃ សត្វមិនចំណីគេផ្តល់ឲសត្វនូវអំបិល (Ca, P, Co) និង វីតាមីន$B_3$។ នៅពេលសត្វឡើងកម្តៅខ្លួនគេផ្តល់ថ្នាំបញ្ចុះកម្តៅ ដូចជា៖ Analgin, Paracetamol។ល។

*៦.២.៣ ការផ្តល់ថ្នាំជីវជាតិ (Stimulation Treatment)* -- ការព្យាបាលត្រូវគិតគូរដល់ការលើកស្ទួយផ្នែកសរីរាង្គ និងកាយសម្បទាន។ ការផ្តល់ឲសត្វនូវពពួកថ្នាំជីវជាតិ ដូចជា Vitamine A, D, E, B។ល។ ជួយជំរុញប្រសិទ្ធភាពពពួកថ្នាំសម្លាប់មេរោគ និងជួយឲ Metabolism នៃសារពាង្គកាយសកម្ម។ ពពួកថ្នាំសម្លាប់មេរោគមានអំពើបផ្លាញកោសិការ និងកោសិកាឈាមក្រហម ហើយធ្វើឲប៉ះពាល់យ៉ាងខ្លាំងដល់កម្លាំងការពារខ្លួនរបស់សត្វ ដូច្នេះការផ្តល់ថ្នាំជីវជាតិ ធ្វើឲមានតុល្យភាពសារពាង្គកាយ។

*៦.២.៤ ការថែទាំ និងបំប៉នចំណី (Care and Nutrition)* -- ដើម្បីធានាឲការព្យាបាលមានប្រសិទ្ធភាព ការថែទាំ និងបំប៉នចំណីជាកត្តាចាំបាច់បំផុត វារួមចំណែកដោយផ្ទាល់ក្នុងការលើកស្ទួយសារពាង្គកាយសត្វ។ ដូច្នេះក្នុងរយៈពេលព្យាបាល (Therapeutic Procedure) សត្វត្រូវតែទទួលការថែទាំ អនាម័យ

ពិសេស ក្នុងគោលបំណងការពារនូវការរាតត្បាតផ្សេងទៀត និងជួយបង្កើតនូវគុណភាពនៃ

ការព្យាបាល។

# ជំពូក៧

# ប្រភេទ នៃការព្យាបាល

## ៧.១ ការព្យាបាលទូទៅ (General Treatment)

គឺជាការព្យាបាលយ៉ាងសាំញ៉ាំ ដើម្បីសង្គ្រោះសត្វពីសេចក្ដីស្លាប់។ វាចាចជា៖

### ៧.១.១ ការព្យាបាលដោយថ្នាំ (Fluid Therapy)

ដូចជាការធ្វើ Infusion នៃប្រភេទថ្នាំទឹក។ ក្នុងករណីសារពាង្គកាយខ្វះទឹក (Dehydration) គេចាក់ Dextrose និង Sodium Cholride ទៅក្នុងសរសៃវ៉ាន និងបានត្រូវអនុវត្តជាញឹកញាប់ផងដែរ ក្នុងការព្យាបាល Acute Gastro Enteritis។

### ៧.១.២ ការព្យាបាលបែបមេកានិច (Mechanical)

ដូចជាការហាត់ប្រាណ(សាងសង)។ល។

### ៧.១.៣ ការព្យាបាលដោយសារកម្តៅ និងពន្លឺថ្ងៃ (Physical Therapy)

ការព្យាបាលដោយសារកម្តៅ ចរន្តអគ្គិសនី កាំរស្មីផ្សេងៗ ដូចជា កាំរស្មី X កាំរស្មី Ultra-violates ។ល។ បានត្រូវគេប្រើប្រាស់ ដើម្បីព្របាលប្រព័ន្ធសាច់ដុំ (Muscula Skeletal system) និងពន្លឺព្រះអាទិត្យ អាចប្រើសម្រាប់ព្យាបាលជំងឺ Ricket កូនគោ និងHypopigmentation ។

### ៧.១.៤ ការព្យាបាលដោយបំប៉នចំណី (Diettatic Therapy)

ជាវិធីព្យាបាលតាមរយៈចំណី ផ្តល់ឲសត្វ។ វារួមទាំងតម្រូវការ និងបន្ថែមចំណី បំប៉ន ពិសេសទៅតាមប្រភេទជំអឺ។

ឧទាហរណ៍: ជំងឺ Diabetes, Renal Discease, Hepatic Diseasc, Cardiac Discease ។ល។

### ៧.១.៥ ការព្យាបាលតាមអារម្មណ៍ (Psychologic Therapy)

ជាការព្យាបាលពាក់ព័ន្ធនឹងចិត្តសាស្រ្ត ការបង្ហាត់ហ្វឹកហ្វឺន និងការរៀបចំចចាត់ចែងសត្វដើម្បីការពារស្ត្រេសពីការផ្អើល ភ័យខ្លាច និងសំលេងផ្សេងៗ ។

### ៧.១.៦ ការព្យាបាលតាមរោគសញ្ញា ( symptomatic treatment )

ជាការព្យាបាលដោយផ្តល់ថ្នាំ ដើម្បីបន្ថយឬព្យាបាលរោគសញ្ញាមួយចំនួន ដែលបណ្តាលឲ្យសត្វកាន់តែចុះខ្សោយផ្នែកសុខភាព ។

ឧទាហរណ៍: ការព្យាបាល Gastroenteritis ដោយការផ្សំនៃថ្នាំ Astringent ជម្ងឺប្រព័ន្ធដង្ហើមដោយថ្នាំ Expectorant និងការព្យាបាលការហើមពោះធំនៃសត្វទំពារអៀងដោយ Carminative mixture។

### ៧.១.៧ ការព្យាបាលពិសេស ( specific treatment )

គឺជាការផ្តល់ឱសថពិសេសដើម្បីព្យាបាលជម្ងឺ ។ វិធីនេះត្រូវបានគេអនុវត្តនៅពេលដែលបុព្វហេតុបង្កជម្ងឺបានត្រូវគេដឹងច្បាស់ ។ ការព្យាបាលប្រភេទនេះមានបំណងបំផ្លាញ ឬ កាត់ផ្តាច់ភ្នាក់ងារបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពសត្វ ។

ឧទាហរណ៍

| ថ្នាំព្យាបាល | ប្រឆាំង | ជម្ងឺ |
|---|---|---|
| 1. specific Antidole | → | Aoisoning |
| 2. Anthelmintic | → | Helminthiasis |
| 3. Antibacterial drug | → | Bacteria |

ការព្យាបាលតាមវិធីនេះ បានត្រូវគេអនុវត្តដូចក្នុងករណី Axiological treatment ។

### ក. ការផ្តល់ថ្នាំ ដើម្បីសំរាប់ជម្ងឺ ( Paliative )

ការព្យាបាលប្រភេទនេះ ធ្វើឡើងពុំមានបំណងធ្វើឲ្យសុខភាពសត្វ វិវត្តមករកធម្មតាទាំងស្រុកនោះទេ ប៉ុន្តែគ្រាន់តែដើម្បីពន្យាពេលស្លាប់របស់សត្វតែប៉ុណ្ណោះ ។ ដូចជាការចាក់ Insulin (ជា Hormone បញ្ចេញដោយលំពែង ) ដែលជំនួយសារពាង្គកាយក្នុងការប្រើប្រាស់ carbohydrates ដើម្បីព្យាបាលជម្ងឺទឹកនោមផ្អែម Diabetes ( Insulin Deficiency ) ។

### ខ. ការផ្តល់ថ្នាំតាមរបបចំណី ( Rational Treatment )

ជាវិធីព្យាបាលដោយផ្តល់ថ្នាំលាយជាមួយរបបចំណី ដែលផ្តល់ឲ្យសត្វស៊ី ដែលផ្អែកទៅលើការយល់ដឹងនៃរោគសាស្ត្រសរីរៈវិទ្យា និងការវិវត្តន៍នៃជម្ងឺព្រមទាំងអំពីរបស់ថ្នាំ ។

ឧទាហរណ៍: ផ្តល់Sodium bicarbonate ដើម្បីបន្សាបអាស៊ីតក្រពះ ផ្តល់ Atropine Sulphate ដើម្បីសំរាលការចុកស្ទះឈាមពោះវៀនសត្វសេះ Spasmodic colic ។

**គ. ការផ្តល់ថ្នាំដើម្បីការពារជម្ងឺ** ( Propliylactive )

ជាការអនុវត្តន៍ ដើម្បីការពារការរាតត្បាតនៃជម្ងឺ នៅពេលមានលក្ខខ័ណ្ឌ មានការឆ្លងរាលដាលនៃជម្ងឺដូចជាការផ្តល់ Ant microbe, Anthelmine និងវីតាមីនទៅក្នុងចំណី ឬទឹកផ្តល់ឲ្យសត្វ ។ ការការពារមួយទៀតដ៏មានប្រសិទ្ធិភាពប្រឆាំងនិងជម្ងឺរាតត្បាត គឺការធ្វើ Immunization ដោយការចាក់វ៉ាក់សាំង General immunology

**៧.២ សេដ្ឋកិច្ច និងការព្យាបាល** ( Economic and treatment /therapy )

ក្នុងវិស័យចិញ្ចឹមសត្វ ការព្យាបាលត្រូវតែធ្វើការប៉ាន់ស្មាន ប្រៀបធៀបរវាងតម្លៃចំណាយលើការព្យាបាល និងតម្លៃសត្វដែលលក់ ។ ជូនកាលតម្លៃចំណាយលើការព្យាបាលខ្ពស់ជាងតម្លៃចំណូលបានពីការលក់សត្វ ករណីនេះគេថាការព្យាបាល ពុំគប្បីធ្វើឡើយ ។ វិធីតែមួយគត់ដែលប្រសើរ គឺការចាត់ចែងវិធានការណ៍គ្រប់គ្រងសមស្រប និង ការការពារ។ ខ្លឹមសារនៃការព្យាបាល គឺជាចំណេះដឹងស្តីពីការប្រើប្រាស់ឱសថក្នុងការព្យាបាលជម្ងឺ ។ បំណងនៃការព្យាបាលគឺ ដើម្បីសំរេចឲ្យបាននូវការនាំមកវិញនៃសុខភាពទៅឲ្យសត្វឈឺ ។

## ជំពូក៨

# គោលការណ៍ នៃការធ្វើរោគវិនិច្ឆ័យ

PRINCIPLES OF DIAGNOSIS

គឺជាវិធីសាស្ត្រ និងទេពកោសល្យដើម្បីធ្វើឲ្យយល់ដឹង និងបង្ហាញអំពីការបង្កនិងធម្មជាតិនៃជម្ងឺ ។

## ៨.១. ការបែងចែងនៃវិធីធ្វើរោគវិនិច្ឆ័យ:

**ក. ការថតឆ្លុះ** (Radiology) ជាវិធីធ្វើរោគវិនិច្ឆ័យ ដែលផ្តល់លទ្ធផលរហ័ស ប៉ុន្តែវាអាចផ្តល់នូវលទ្ធផលលំអៀងមិនសូវប្រាកដ ។

**ខ. រោគវិនិច្ឆ័យផ្ទាល់** ( Direct diagnosis) ជាការពិនិត្យផ្ទាល់ទៅលើសត្វដោយភ្នែក ដើម្បីរកឲ្យឃើញនូវទ្រង់ទ្រាយនៃស្លាកស្នាម និងស្លាកស្នាមដែលជារោគសាស្ត្រ ។

**គ. រោគវិនិច្ឆ័យប្រៀបធៀប** (Differential Diagnosis) ជាវិធីសាស្ត្ររកភាពខុសគ្នានៃជម្ងឺដោយធ្វើការប្រៀបធៀបជាមួយជម្ងឺស្រដៀងគ្នាផ្សេងទៀត ។

**ឃ. ការវិនិច្ឆ័យផ្អែកលើការដកចេញរោគសញ្ញា** (Method of Elimination) នេះជាវិធីវិនិច្ឆ័យរោគដោយធ្វើការដកចេញរោគសញ្ញាស្រដៀងគ្នានៃជម្ងឺផ្សេងៗ ដែលផ្អែកលើពត៌មាននិងហេតុផលច្បាស់លាស់ ។

**ង. រោគវិនិច្ឆ័យសាកល្បង** (Tentative Diagnosis) នេះជាវិធីបញ្ជាក់ជម្ងឺ ដោយផ្អែកលើមូលដ្ឋាននៃការផ្លាស់ប្តូរបុព្វបទជាក់ស្តែង ឆ្លងតាមការពិនិត្យគ្លីនិច ។ វិធីវិនិច្ឆ័យដ៏ប្រាកដមួយ ពុំអាចធ្វើទៅបានដូចជាគ្មានមន្ទីរពិសោធន៍ និងលទ្ធភាពធ្វើតេស្តផ្សេងទៀត ។

**ច. រោគវិនិច្ឆ័យផ្អែកលើរោគសញ្ញា** (symptomatic Diagnosis ) នៅពេលដែលការធ្វើរោគវិនិច្ឆ័យផ្អែកលើបុព្វហេតុបង្ករោគ ពុំមានលទ្ធផលធ្វើបាន ( Etiologically diagnosis is not Possible ) និង ការបញ្ចេញរោគសញ្ញាមានសក្ខណៈខ្សោយ ការវិភាគរោគវិនិច្ឆ័យត្រូវបានគេធ្វើឡើងដោយផ្អែកលើការប្រែប្រួលជាមូលដ្ឋាននៃរោគសាស្ត្រ ហើយប្រការនេះបានត្រូវគេវិភាគទៅតាមការវិនិច្ឆ័យរោគតាមបម្រែបម្រួលនៃរោគសញ្ញា ។

**ឆ. រោគវិនិច្ឆ័យផ្អែកលើហ្វូងសត្វ** (Herd Diagnosis ) ជម្ងឺអាចជះឥទ្ធិពលតៅលើហ្វូងសត្វទាំងមូល នៅកន្លែងមួយចំនួន ។ ក្នុងការវិភាគរោគវិនិច្ឆ័យជម្ងឺ គេផ្អែកលើការស្លាប់បាត់បង់ជីវិត ឬគ្រោះថ្នាក់ប៉ះពាល់ដល់ចំនួនសត្វមួយភាគធំក្នុងហ្វូង ។ ក្នុងករណីបែបនេះការស្ទាបស្ទង់ សាកសួរពត៌មានស្តី

ពីហ្វូងសត្វ ជាប្រការសំខាន់ណាស់ ។ ការធ្វើរោគវិនិច្ឆ័យផ្អែកលើការសិក្សាហ្វូងសត្វនេះត្រូវបានគេធ្វើឡើងតាមចំណុចដូចខាងក្រោម ៖

១. ការពិនិត្យពេញលេញ ទៅលើសត្វក្នុងហ្វូងដែលទទួលការរាតត្បាត និងមានសញ្ញាច្បាស់លាស់ជាងគេ។

២. ការស្រាវជ្រាវល្អិតល្អន់ ទៅលើបរិស្ថាននៅកន្លែងដែលសត្វរស់នៅដូចជា៖ វាលស្មៅ លក្ខខ័ណ្ឌទ្រុងសត្វ ចំណីនិងទឹកដែលផ្តល់ឲ្យសត្វ ។

៣. ការវះកាត់សាកសពសត្វ )post-mortem examination) ដើម្បីបញ្ជាក់ការប្រែប្រួលសរីរាង្គខាងក្នុងយ៉ាងឆាប់រហ័ស ។ សត្វដែលឈឺធ្ងន់អាចបានត្រូវគេសម្លាប់តាមរយៈការចាក់សម្លាប់ ដើម្បីធ្វើការសិក្សាជាបន្ទាប់ ឬកំទេចចោល ។

៤. យកវត្ថុវិភាគចាំបាច់ បញ្ជូលទៅមន្ទីពិសោធន៍ដើម្បីធ្វើតេស្តបញ្ជាក់ដូចជា លោហិតសាស្ត្រ )Hematology )ការបណ្តុះមេរោគក្នុងលាមក( Coprology ) ប៉ារ៉ាសិតសាស្ត្រ( Parasitology ) អតិសុខុមប្រាណសាស្ត្រ( Microbiology )សេរ៉ូមសាស្ត្រ( Serology )តុកូស៊ីនសាស្ត្រ( Toxicology ) និងរោគសាស្ត្រជាលិកាវិទ្យា( Histopathology ) ជាដើម ។

៥. សត្វទាំងអស់នៅក្នុងហ្វូង បានត្រូវរៀបចំគ្រប់គ្រងដោយអ្នកជំនាញផ្សេងៗ ដើម្បីកសាងឲ្យបាននូវ រោគវិនិច្ឆ័យច្បាស់លាស់មួយ និងដាក់ចេញនូវដំណោះស្រាយដ៏សមស្របជ្បើសង្គ្រោះ ហ្វូងសត្វឲ្យបានជោគជ័យ ។

### ជ. រោគវិនិច្ឆ័យនៅមន្ទីរពិសោធន៍

ជាការសិក្សាបញ្ជាក់ទៅលើវត្ថុវិភាគពីសត្វឈឺ ឬសង្ស័យថា ឈឺដើម្បីបង្ហាញនូវលទ្ធផលរោគវិនិច្ឆ័យ សមស្របនិងច្បាស់លាស់។ វត្ថុវិភាគអាជាឈាម )Blood ) ទឹកនោម ( Urine )ក្រមឬដំបៅលើស្បែក( skin scraping ) លាមក( Faeces ) សរីរាង្គក្នុង( Viseral organs ) ។ ល។ ឯកសារវិធីយក វត្ថុវិភាគ និងបញ្ជូនវត្ថុវិភាគទៅមន្ទីរពិសោធន៍ ។

## Scheme of Period and Course of Diseases




*គំនូសបំព្រួញ ៦: ការវិវត្ត នៃ ជំងឺ*

# ជំពូក៩
# ការសិក្សាអំពីនិមិត្តហេតុ SYMPTOMATOLOGY

ជាវិទាសាស្ត្រដែលសិក្សាទៅលើរោគសញ្ញានៃជម្ងឺមួយចំនួន ។

**៩ ១.រោគសញ្ញា** )symptom)

ជាការបញ្ជាក់អំបីភាពខុសប្រក្រតីនៃផ្នែកអារម្មណ៍ និងកាយសម្បទាសត្វ។ នៅក្នុងវេជ្ជបណ្ឌិតដោយឡែក វេជ្ជសាស្ត្របសុព្យាបាល ការរៀបរាប់ដោយសត្វឈឺបែបនេះពុំអាចប្រព្រឹត្តទៅបានឡើយ ប៉ុន្តែពេលខ្លះ ម្ចាស់សត្វ ឬអ្នកគ្រប់គ្រងសត្វអាចរៀបរាប់ និងបកស្រាយប្រការប្រែប្រួលចំពោះសត្វរបស់ខ្លួនបានខ្លះ ។

**៨២. សញ្ញា** (sign)

វាគឺជាការបញ្ជាក់នៃជម្ងឺ ដែលបានពិនិត្យតាមលទ្ធផលនៃគ្រោះថ្នាក់ ។ វាបានត្រូវធ្វើការពិនិត្យដោយបសុពេទ្យ គ្លីនិចដោយយកចិត្តទុកដាក់លើសត្វដូចជា ភាពស្លេកស្លាំងនៃអញ្ចាញធ្មេញ ភ្នាសស្តើង ទឹកនោមក្រហម គឺជាសញ្ញានៃ Anemia និង Haematuria ដែលជារោគសញ្ញា នៃជម្ងឺ ។




*គំនូសបំព្រួញ ៧: រោគសញ្ញានៃជម្ងឺ*

៨២..១. Subjective symptoms

បញ្ជាក់អំពីការចាប់អារម្មណ៍ និងការប្រែប្រួលក្នុងអារម្មណ៍របស់សត្វឈឺ ។ ប្រការនេះងាយអនុវត្តក្នុងវេជ្ជសាស្ត្រមនុស្ស ដែលអ្នកជម្ងឺអាចពន្យល់រៀបរាប់អំពីប្រការដែលខ្លួនកំពុងជួបប្រទះដល់គ្រូពេទ្យ

ដូចជាកន្លែងមានការឈឺចាប់ អំពើអាការៈប្រែប្រួលលើសរីរាង្គមួយចំនួនជាដើម ប៉ុន្តែវាជាប្រការដែលពុំអាចកើតឡើងក្នុងវេជ្ជសាស្ត្របសុពេទ្យ ។ ដូច្នេះដើម្បីយល់ដឹងអំពីពត៌មានទាំងនេះ ចំពោះសត្វតម្រូវឲ្យមានការយកចិត្តទុកដាក់ពិនិត្យ អង្កេតសត្វឈឺផ្ទាល់ដោយបសុពេទ្យ ឬសាកសួរម្ចាស់សត្វ ។ គឺជាការកត់សំគាល់រោគសញ្ញាដែលសត្វឈឺមាន តាមរយៈការពិនិត្យមួយចំនួន ។ ក្នុងការអនុវត្តន៍បសុពេទ្យបានប្រើប្រាស់ Objective symptoms នេះនៅពេលដែលSubjective sump toms ពុំអាចធ្វើបាន ។ ការពិនិត្យ Objective symptoms នោះត្រូវធ្វើយ៉ាងណា យកចិត្តទុកដាក់ដោយបសុពេទ្យទៅលើសត្វឈឺ ។

### ៨.២.៣. Premonitory or Precursory symptoms

គឺជារោគសញ្ញាដំបូង ឬមានលក្ខណៈជាបម្រែបម្រួលខាងអារម្មណ៍ និងសកម្មភាពរបស់សត្វ ។ តាមរយៈការប្រែប្រួលនេះនាំឲ្យសុខភាពសត្វចុះខ្សោយ និងឈានដល់ជម្ងឺដូចជាការល្វិតល្វៃដៃជើង ហៀរទឹកភ្នែកសំបោរ សត្វទ្រុតទ្រោម អន់ចំណី ។ ល។ បានត្រូវគេពិនិត្យឃើញមុនពេលសត្វបញ្ចេញ Objective symptoms ដូចជាក្តៅខ្លួន ស្នាមរលាក រាគឈាម ។ ល៕

### ៨.២.៤. Direct or Idiopathic symptoms

នេះបញ្ជាក់អំពីរោគសញ្ញាជាធម្មជាតិនៃសជម្ងឺ ហើយដែលឆ្លុះបញ្ចាំងពីការវិវត្តន៍របស់ជម្ងឺ ដែលជាជម្ងឺមូលដ្ឋាន ហើយមិនមែនជាជម្ងឺឱកាសនិយម (Secondary) ប៉ះពាល់លើសរីរាង្គមួយចំនួន ដូចជារោគមានសំបោរ និងឈាមជារោគសញ្ញាផ្ទាល់ (Direct symptoms ) របស់ជម្ងឺរាគមូល (Dysentry)។

### ៨.២.៥. Indirect or sympathetic symptoms

មានន័យថា រោគសញ្ញាទាំងឡាយណា ដេលចូលរួមក្នុងការស្រាយបញ្ជាក់មិនផ្ទាល់លើគ្រោះថ្នាក់នៃ សរីរាង្គមួយចំនួនប្រមទាំងការប្រែប្រួលក្នុងសាពាង្គកាយ ដូចជាក្អួត បណ្តាលពីការរលាកតម្រងនោម )Nephritis) សត្វឆ្កែ សញ្ញាថប់ដង្ហើម បញ្ហាពីការីកថ្លើម (Hyperthrphy of liver) ការខ្សោយនៃសាច់ដុំផ្នែកខាងស្តាំ បណ្តាលពីជម្ងឺតម្រងនោមខាងស្តាំជាដើម ។

### ៨.២.៦.Typical symptoms

ជារោគសញ្ញាដែលឆ្លុះបញ្ចាំងយ៉ាងខ្លាំង និងច្បាស់ចំពោះប្រភេទជម្ងឺណាមួយអ្នកពិនិត្យអាចធ្វើការសម្រេច រោគវិនិច្ឆ័យតាមរយៈ រោគសញ្ញាដ៏ច្បស់លាស់នេះ ។ ជូនកាលរោគសញ្ញា Typical នេះគេហៅថា ។ ឧទាហរណ៍ Septicemia ជាមួយការហើមសាច់ដុំ Crepitation គឺជា នៃជម្ងឺបូសខ្យល់ (BL)។

### ៨.២.៧. Atypical Symptoms

វារួចមានរោគសញ្ញាទាំងឡាយណាដែលពុំមានលក្ខណៈទៀងទាត់ និងច្បាស់លាស់សម្រាប់បញ្ជាក់ជម្ងឺណាមួយ បានប្រាកដ ។ ដូចជារោគសញ្ញាសរសៃប្រសាទនៃកូនគោ បណ្តាលពីជម្ងឺ Coccidiosis។

### ៨.២.៨. Periodical or Remittent Symptoms

ជារោគសញ្ញាដែលរលប់បំបាត់យ៉ាងឆាប់រហ័ស ហើយលេចចេញមកវិញម្តងទៀត បន្ទាប់ពីរយៈពេលមួយវែង ឬខ្លីពុំទៀងទាត់ ។ ដូចជារោគសញ្ញាគ្រុនសន្ទុម នៃជម្ងឺ Canine distemper និងរោគសញ្ញាគ្រុនក្តៅនៃជម្ងឺ Trypanosomiasis ( surrs )។

### ៨.២.៩. Diagnostic or Path gnomic symptoms

ជារោគសញ្ញាដែលបញ្ជាក់ច្បាស់លាស់ ចំពោះប្រភេទជម្ងឺណាមួយដោយផ្ទាល់ ហើយដែលបានត្រូវរកប្រើប្រាស់ជាមូលដ្ឋាន ដើម្បីវិភាគរោគវិនិច្ឆ័យនៃជម្ងឺដូចជារោគសញ្ញា រឹង និងកន្ត្រាក់ សាច់ដុំនៃជម្ងឺ Tetanus និងឈាមហូរចេញពីរន្ធធម្មជាតិក្នុងករណីជម្ងឺ Anthrax ជាដើម ។

### ៨.២.១០. Prognostic symptoms

ជារោគសញ្ញាទាំងឡាយណា ដែលបង្ហាញពីគ្រឹះនៃការវិភាគដល់បសុពេទ្យ ដើម្បីវិនិច្ឆ័យសភាប និងប្រភេទជម្ងឺ ។ ការព្យាករណ៍ )Prognosisនៃជម្ងឺមានសារៈសំខាន់ក្នុងការព្យាបាល ដេលតំរូវឲ្យ ( ព្យាបាលបន្ត ឬបញ្ឈប់ ។ ដូចជាHigh blood Ureaមាន ) Vrea Nitogen ខ្ពស់ក្នុងឈាមបង្ហាញអំពី ( ) ការអស់ សង្ឃឹមនៃការព្យាបាល គឺសត្វនឹងស្លាប់មួយទៀត បន្ទាប់ពីមានការឈឺចាប់ក្នុងពោះColiចុះ ( ថយចំពោះ សត្វសេះ បញ្ជាក់អំពីការរហែក នៃសរីរាង្គក្នុងមួយចំនួន ។

**ក) ចង្កោមរោគសញ្ញា** .Syndrom (ជាល័ក្ខខ័ណ្ឌ ដែលរួមបញ្ចូលដោយការវិវត្តនៃជម្ងឺ ។ ដូចជាអាស៊ីតមិនប្រើប្រាស់សម្រាប់រំលាយអាហារ អាចបណ្តាលឲ្យមានការខ្សោយនៃថ្លើម និងតំរងនោមខ្សោយ ( Renal Insufficiency )ប្រមទាំងចង្កោមរោគសញ្ញានៃការបំផ្លាញជាលិកាខួរក្បាល )polyence phalom alacia Syndrome )

**ខ) ស្លាកស្នាម** .lesion ជាបម្រែបម្រួលទ្រង់ទ្រាយកោសិកា (និងជាលិកាដេលបានត្រូវគេពិនិត្យឃើញនៅលើសរីរាង្គ ឬផ្នែកខ្លះនៃសរីរាង្គ ។ វាអាចមានសណ្ឋានសើលើផ្ទៃជាលិកាងាយពិនិត្យឃើញដោយភ្នែក ប៉ុន្តែស្លាកស្នាមជ្រៅនៅក្នុងជាលិកាទាមទារមានការពិនិត្យដោយប្រើឧបករណ៍។ ស្លាកស្នាមងាចត្រូវបានគេចាត់ថ្នាក់ជាស្លាក់ស្នាមដំបូង )Primនិងស្លាក់ស្នាមបន្ត ។ ស្លាកស្នាមដំបូងគឺជាការ ( ស្លាក់ស្នាមបន្ថែមបានត្រូវប្រែប្រួលជាគ្រោះថ្នាក់បន្តផ្ទល់ ទៅ ឆ្លុះបញ្ចាំងនៃបំរែបំរួលផ្ទាល់របស់ជម្ងឺ ។ លើស្លាកស្នាមដំបូង ។ ដូចជាការព្យាបាល ដោយប្រើថ្នាំពុំបានត្រឹមត្រូវ ដើម្បីព្យាបាលដំបៅ បណ្តាលឲ្យមានការហូរឈាមនៅក្ន◌ុងសាច់ដុំ ។ ល។

**គការព្យាករណ៍ .** គឺជាការវិភាគអំពីភាពមាន ឬអស់សង្ឃឹម ចំពោះប្រភេទជម្ងឺណាមួយ ។ វាមានសារៈសំខាន់ជា សេដ្ឋកិច្ចក្នុងការព្យាបាល ក៏ដូចជាការថែរក្សាសត្វឈឺ ។ សត្វឈឺអាចជាសះស្បើយពីជម្ងឺ ឬពុំអាចជាសះស្បើយបាន ។ ជូនកាលសត្វអាចស្បើយពីសណ្ឋានជម្ងឺស្រួចស្រាវ ប៉ុន្តែអាចជាបណ្តោះអាសន្ន ឬអាចជ្រះស្រឡះក្នុងករណីបែបនេះគេត្រូវយកមកពិចារណាក្នុងការព្យាបាល។ បន្ទាប់ពី ទៅលើជម្ងឺសត្វរួចមក ។ ការប៉ាន់ស្មាន នៃតម្លៃនៃការព្យាបាលត្រូវបានគិតគូរឲ្យបានសមស្រប ។

ទិដ្ឋភាពសេដ្ឋកិច្ចនៃការព្យាបាល មានសារៈសំខាន់បំផុតក្នុងវិស័យបសុព្យាបាល ។

**ការទស្សទាយគ្លីនិចនៃជម្ងឺអាស្រ័យទៅនឹង**

- ធម្មជាតិនៃជម្ងឺ
- បុព្វហេតុបង្កជម្ងឺ
- ជោគជ័យឬបរាជ័យក្នុងការព្យាបាល
- ដំណាក់កាលនៃការស៊ីចំណី
- ទំលាប់របស់សត្វ
- ល័ក្ខខ័ណ្ឌកាយសម្បទា និងប្រព័ន្ធសរីរាង្គ ឬភាពសាំញាំដែលកើតមានជាសញ្ញាដំបូង និងសញ្ញាស្លាកស្នាមនៅនឹងកន្លែង ឬ សញ្ញានៃការប្រែប្រួលនាទីសរីរាង្គ ។

ការសិក្សាទាំងនេះត្រូវបានគេកត់ត្រានិងចងក្រងឯកសារដើម្បីប្រើប្រាស់សម្រាប់ធ្វើ Prognosis ជំងឺ ។ ការបញ្ជាក់ Prognosis

- ដែលយល់ព្រមៈ (Favourable Prognosis )
- ឧទាហរណ៍ៈ Uncomplicated Traumatic Peritonitis in Cattle
- ដែលសង្ស័យមិនទុកចិត្តៈ ( Doubtful Prognosis )
- ឧទារហណ៍ៈ Traumatic Reticuloperitonitis ដោយមានការស្អិតជាប់គ្នានៃ Diaphragm ជាមួយ Abdominal Wall
- សង្ឃឹមតិចតួចៈ (Poor Progragmsis)
- ឧទាហរណ៍ៈ Traumatic Reticuloperitonitis ដោយមាន Abscess ក្នុងថ្លើម
- ឧទាហរណ៍ៈ Traumatic Pericarditis ដោយមានវត្ថុរឹងស្រួចនៅក្នុងនោះ ។

# ជំពូក ១០

# វិធីកត់ត្រាប្រវត្តិសត្វឈឺ

METHODS OF ANAMNESIS

## គំរោងសង្ខេបនៃការសាកសួរ និង កត់ត្រាប្រវត្តិសត្វឈឺ

(OUTLINE OF PATIEN´S HISTORY TAKING AND INVESTTIGATION)

### ១០.១ ការសាកសួរ និងកត់ត្រាប្រវត្តិសត្វ ( ANAMNESIS OR HISTORY TAKING )

កប្រវត្តិបច្ចុប្បន្ននៃសត្វឈឺ .

ខប្រវត្តិអតីតកាលនៃសត្វឈឺ .

ចំពោះសត្វស្លាប់ Anamnesis គេចែកជា:

១ ប្រវត្តិសត្វនៅពេលមានជីវិត .(Anamnesis)

២ ប្រវត្តិក្រោយពេលសត្វស្លាប់ .( Anamnesis Morbi )

### ១០.២ ការពិនិត្យទូទៅ (GENEREL EXAMINATION )

ក ការពិនិត្យដោយភ្នែក .( INSPECTION )

១ ការពិពណ៌នាអំពីសត្វឈឺ . ( ប្រភេទ ពូជ អាយុ ពណ៌សម្បុរ )

២ការពិនិត្យដោយភ្នែកលើរាងកាយសម្បទាទូទៅ សភាពខ្លួនសត្វ ចរិកសត្វ សភាពធំធាត់ . របស់សត្វ រោមស្បែក ការបន្ទោរបង់លាមក និងទឹកនោម ការស៊ីចំណី ផឹកទឹក ដំណើរ ។ល។

ខ ការត្រួតពិនិត្យគ្លីនិច .(CLINICAL ESAMINATION)

១សីតុណ្ហភាពខ្លួនសត្វ . (Temperature)

២ ចលនា និង ចំនួនដង្ហើម .( Pulse Rate )

៣ ចលនា និង ចំនួនដង្ហើម . ( Respiratory Rate )

៤ សភាព និង ពណ៌ភ្នាសស្ដើង ដែលអាចមើលឃើញ .(Visible mucous membrane )

### ១០.៣ ការត្រួតពិនិត្យពិសេសនៃប្រព័ន្ធសរីរាង្គមួយចំនួន(SPECIALEXAMINATION )

- ប្រព័ន្ធរំលាយអាហារ (Digestive System)
- ប្រព័ន្ធទឹកមាត់ (Urinary System)

- ប្រព័ន្ធឈាមរត់ ( Cardio- V ascular System )
- ប្រព័ន្ធសរសៃប្រសាទ ( Vervous System )
- ប្រព័ន្ធដង្ហើម ( Respiratory System )
- ប្រព័ន្ធបន្តពូជ ( Reproductive System )
- ប្រព័ន្ធសាច់ដុំ ( Muskuloskeletal System )
- ប្រព័ន្ធកោសិកា ( Lymphatic System )
- ត្រចៀក និង ភ្នែក ( O.R.L )
- ស្បែក និង រោម  ( Skin and appendage  )

## ១០.៤ ការវិភាគនៅមន្ទីរពិសោធន៍ ( LABORATORY ANALYSIS )

- ការពិនិត្យដោយមីក្រូទស្សន៍ នូវឈាម ក្រមរ ដំបៅ និង ស្បែក ទឹកដោះ ទឹកនោម សំបោរ ។ល។ ...
- ការវិភាគគីមីជីវសាស្ត្រនៃឈាម ទឹកមោត ។ល។
- ការធ្វើតេស្តសេរ៉ូមឈាម ( Serological test )
- ការធ្វើតេស្តជីវសាស្ត្រ ( Biological test )
- ការពិនិត្យជាលិកាវិទ្យា ( Radilogical Examination )
- ការធ្វើតេស្តសកម្ម ( Allergic Test )
- ការពិនិត្យជាលិកាវិទ្យា ( Radilogical Examination )
- ការធ្វើតេស្តសកម្ម ( Allergic Test )

បំម្រែបំម្រួលដោយការវះកាត់សាកសពសត្វ  ជាការសំខាន់ចាំបាច់  ដើម្បីបកស្រាយរោគវិនិច្ឆ័យជំងឺ ។ នៅពេលពិនិត្យឃើញមាន  បំម្រែបំម្រួល លើសរីរាង្គមួយចំនួន ការកត់ត្រាលក្ខណៈខុសប្រក្រតី ត្រូវបានគេកត់ត្រាលើក្រដាស បកស្រាយរោគវិនិច្ឆ័យ ផ្ទុយទៅវិញនៅពេលដែលបំម្រែបំម្រួល ពុំបានត្រូវពិនិត្យឃើញទេនោះការកត់ត្រា គឺគ្មានលក្ខណៈខុសប្រក្រតី ។

## ១០.៥ ការបកស្រាយរោគវិនិច្ឆ័យ INTERPRETATION

ការបកស្រាយរោគវិនិច្ឆ័យជំងឺ ពាក់ព័ន្ធទៅនិងកត្តា ២ ៖

### ក. ការធ្វើឲ្យសកម្មនៃសម្មតិកម្ម សំរាប់ការបកស្រាយ ( Activation of Hypothesis )

ជាការប្រមូលផ្តុំ និងពិចារណានៃលទ្ធផលពិនិត្យទិន្នន័យទាំងឡាយៈ រួមមាន ប្រភេទសត្វ ពូជសត្វ អាយុសត្វ ពណ៌សម្បុរ ព្រមទាំងប្រភេទផលិតកម្មរបស់សត្វ ។

### ខ. ការវាយតម្លៃ នៃលទ្ធផលសម្មតិ សំរាប់ការបកស្រាយ ( Hypothesis Evaluation )

ជាការវាយតម្លៃនៃលទ្ធផល ត្រួតពិនិត្យគ្លីនិចទាំងឡាយដើម្បីសម្រេលទទួលយកការបកស្រាយ លទ្ធផលគ្លីនិចការពិចារណាទៅលើលទ្ធផលសង្ខេបសភាពមាំមួន និងប្រាកដជដដែលអាចទុកចិត្តបានជាការចាំបាច់បំផុត ។ សម្រាប់ការវាយតម្លៃ និងសម្រាប់រោគវិនិច្ឆ័យនេះមានៈ ការបញ្ជាក់ ( Confirmation ) ការដកចេញ ឬកាត់ចោល ( Elinination )ការរកភាពខុសគ្នា ( Discrimination ) និងការត្រួតពិនិត្យ ( Exploratin ) នៃការរកឃើញរោគសញ្ញាគ្លីនិច ។

## ១០.៦ ការប៉ះទង្គិចនៃបរិយាកាស និង បរិស្ថានទៅលើសុខភាពសត្វ

IMPACT OF CLIMATE AND ENVIRONMENT TO THE HEALTH OF ANIMALS

បរោស្ថានស្ថិតនៅហុំព័ទ្ធជុំវិញ ជីវិតរបស់សត្វមានឥទ្ធិពលផ្ទាល់ ឬប្រយោលទៅលើសុខភាពសត្វ ។ ការពិនិត្យដោយល្អិតល្អន់ នៃបរិស្ថានសុខភាពសត្វ ។ ការពិនិត្យដោយល្អិតល្អន់ នៃបរិស្ថានផ្តល់នៅការដឹកនាំធ្វើរោគវិនិច្ឆ័យនៃជំងឺដែលកំពង់កើតមានលើសត្វណាមួយ ឬសត្វមួយចំនួននៅក្នុងហ្វូង ។ បរិស្ថានអាចជាខាងក្រៅ(outdoor) ឬបរិស្ថានវាលស្មៅ ឬបរិស្ថានក្នុងផ្ទះ (Housing environment ) ។

**ក.បរិស្ថានខាងក្រៅ( outdoor Environment )** : គឺជាតំបន់ដីវាលស្មៅ និងដីដាំដំណាំផ្សេងៗ ដែលត្រូវបានគេពិនិត្យ និងកំណត់ថាមានការពាក់ព័ន្ធទៅនិងជំងឺ ។ ដីសើមកង្វក់បង្កលក្ខខណ្ឌប្រកបដល់ការកេរកើត និងលូតលាស់នៃពពួករុ មូសដែលជាភ្នាក់ងារបង្កជំងឺ ដីកង្វក់ផ្តល់លទ្ធភាពបង្កជំងឺដូចជាៈ Leptospirosis ។ ទឹកបឹងត្រពាំងមិនហូរ (Stagnant pool ) ផ្តល់លទ្ធភាពរោគរាតត្បាតនៃពពួកដង្កូវថ្លើម ។ ខ្សាច់នៅឆ្នេរសមុទ្រ ( littoral sand ) បណ្តាលអោយសត្វរស់នៅទីនោះមានបញ្ហានៃកង្វះអីយ៉ុងទង់ដែក (Cu) និងកូបាល់ (Co) ។

វាលស្មៅបន្ទុកស្មៅ ទឹកដីនៅវាលស្មៅ ពេលខ្លះមានការប្រឡាក់ប្រឡូស ដោយភ្នាក់ងារចំលងរោគ និងសារជាតុពុលគីមី នៃកាកសំណល់ឧស្សាហកម្ម ។ ប្រវត្តិនៃប្រភពបែបនេះ គួរតែត្រូវបានគេកត់ត្រាយ៉ាងម៉ត់ចត់បំផុត។ ជួនកាលថ្នាំសម្លាប់កសិកម្មមួយចំនួន(Organo-phosphorous Compounds ) ក្លាយជាប្រភពធ្វើអោយប៉ះពាល់ល់សុខភាពសត្វ ។

**ខ. បរិស្ថានខាងក្នុង(Indoor Environment )** : ទ្រង់សត្វពុំមានខ្យល់ចេញចូលគ្រប់គ្រាន់ ពុំមានការផ្តល់ទឹកគ្រាប់គ្រាន់ ភាពកង្វក់នៃផ្ទៃទ្រុង អាចរួមចំណែកក្នុងការបំផ្លាញសុខភាពសត្វ ។ ការយកចិត្តទុកដាក់ត្រូវតែធ្វើឡើងដោយផ្អែកលើគោលការណ៍សាងសង់ទ្រុង ការធ្វើអនាម័យទ្រុង ។ សត្វដែលចិញ្ចឹមក្នុងទ្រុងតូចៗ ដើម្បីបំប៉នយកសាច់ងាយមានជំងឺមេតាប៉ូលីសដូចជា Keratosis in Cattle ជាដើម ។

បរិយាកាសនៃបរិស្ថានជះឥទ្ធិពលទៅលើផលិតកម្មទឹកដោះ ។ ល័ក្ខខណ្ឌបរិយាកាស ដែលសមស្របសម្រាប់គោ គឺៈ

| ប្រភេទគោ (%) | សីតុណ្ហភាពទ្រុង (អង្សាសេ) | សំណើម (% ) |
|---|---|---|
| គោអាយុ ៣ឆ្នាំឡើង (៧៨) | ១០ ទៅ១៥ | ៨៥ |
| គោជំទង់ (៧៨) | ១២ ទៅ ១៥ | ៨២ |
| កូនគោ (៦៨) | ១៥ ទៅ ២២ | ៧៨ |

**ផលវិបាកបណ្តាលពីការប្រែប្រួលបរិស្ថាន**

- ស្ត្រេសបណ្តាលមកពីអាកាសធាតុ បណ្តាលអោយសត្វពុំឃ្លានចំណី
- សីតុណ្ហភាពបរិស្ថានឡើងខ្ពស់ បណ្តាលអោយរុក្ខជាតិបាត់បង់ សារធាតុកាបូនច្រើន ។ សត្វស៊ីរុក្ខជាតិស្ងួតឬងាប់ បណ្តាលអោយមានជំងឺពកក (Goitre Hypertrophy of Thyroid gland )
- សីតុណ្ហភាពនៅជុំវិញខ្លួនសត្វ បន្ថយការប្រើប្រាស់ចំណី នៅក្នុងសារពាង្គកាយសត្វ ដូចជាបន្ថយទិន្នផលទឹកដោះសត្វ និងការជ្រាបជីវជាតិអាហារជាដើម ។
- សីតុណ្ហភាព និងសំណើមនៅក្នុងបរិស្ថានខ្ពស់ មានឥទ្ធិពលផ្ទាល់ទៅលើប្រព័ន្ធការពារនៃប្រដាប់ដកដង្ហើម និងរំលាយអាហារ ។
- ភាពត្រជាក់ធ្វើអោយប៉ះពាល់ដល់សួត ការបញ្ចេញនៃរំអិលនៃភ្នាសស្តើង បណ្តាលអោយមានការហើមប៉ោងនៅផ្នែកក្រោមភ្នាសរំអិល (Submacus Oedema)
- សីតុណ្ហភាពខ្ពស់ធ្វើអោយថយសកម្មភាព ភាពស៊ាំ សកម្ម និងប្រសិទ្ធភាពអង់ទីករ ដែលមាននៅក្នុងខ្លួនសត្វ ស្ត្រេសសបរិស្ថានខ្លាំងក្លា បណ្តាលអោយមានការរលាកកន្សោមដោះ ។ ទាំងនេះបណ្តាលពីចុះខ្សោយនៃការចាប់រោគ ( Recuction of Phagocytic Abilities) នៃគោលិកាឈាម Leucocyte ។
- ការរាតត្បាតដោយជំងឺដង្កូវថ្លើម ( Liver fluke) លើសត្វគោទាក់ទងនិងសីតុណ្ហភាពនិង ភ្លៀង ។
- ព្រូន Nematode ក្នុងក្រពះ ពោះវៀន និងព្រូនក្នុងសួត (Gastroenteritis) បណ្តាលអោយមានការរលាក ពោះវៀន ក្រពះ (Gastroenteritis) និងរលាកទងសួតនិងសួត (Parasitic Bronchopneumonia ) ជាញឹកញយដោយសារសីតុណ្ហភាព និងសំណើមបរិយាកាសខ្ពស់ ។
- ក្នុងកំឡុងពេលគ្មានភ្លៀង ឬស្ងួតយូរបណ្តាលអោយសត្វមានការលេចឡើងនូវរោគសញ្ញាខ្វះវីតាមីនអា Vitamin A ។
- នៅរដូវក្តៅហើយសើមគោ និងជ្រូករងនៅការបំផ្លាញ់ដោយកំដៅហើយសត្វសេះអាចរងនៅបាតុភូតដោយខ្វះទឹកក្នុងសារពាង្គកាយ ។

- ផ្សែងពុលនៃឧស្សាហកម្ម សារធាតុគីមី សារធាតុពុល ។ល។ គឺជាប្រភពប៉ះពាល់ដល់សុខភាពសត្វ
- ទឹកកង្វក់ ទឹកមានហ្លុយអរុស (F) និងនីត្រាត (NO3) អាចជាប្រភពបណ្តាលអោយសត្វឈឺ
- ពពួកវាវីរុក្ខជាតិ (Algae) ដែលដុះពាសពេញនៅក្នុងទឹកត្រពាំង បឹង អាងទឹក ដែលនៅនិងថ្កល់មិនហូរនៅពេលសត្វផឹកទឹកនោះ ដោយពពួក Algae សត្វអាចទទួលការបំផ្លាញ់ដោយសារធាតុពុល Neurotoxin និង Hepatotoxin របស់ពពួក Microtoxin នៃ Algae ទាំងនោះ ។

## ១០.៧ ប័ណ្ណពិនិត្យកាយសម្បទា SHEET FOR PHYSICAL EXAMINATION

លេខ/No: ........................................................................................ ថ្ងៃ ខែ /Date

........................................................ ម្ចាស់សត្វ/Owne.........................................

អាស័យដ្ឋាន/Addres.................................................................................

ប្រភេទសត្វ/Animal Spp ............................................... ប្រភេទ/Sex.................

អាយុ /Age ................................................................ ................................

ទំងន់/Weight.............................................................. ពូជ/Breed..................

ពណ៌ /Colur ............................................................... ................................

---

សីតុណ្ហភាព /Temp.......................................................................................

ជីពចរ/Pulse.................................................................................................

Rate.............................................................................................................

ចលនាដង្ហើម/Resp.......................................................................................

Rate.............................................................................................................

---

ទំលាប់..........................................................................ភាពសមា

មាត្រ.....................

សភាព..............................................................................................................

ទឹក...................................................................................................................

( Attitude )　　　　　( Conformity )　　　　　( Hydration )

---

- ភាពឃ្លានចំណី (Appetite status)..............ក្រពេញជលិកាក្រោមស្បែក(Super ficial lympg node)
- ប្រព័ន្ធសាច់ដុំ (Musculo skeletal system)........................ប្រព័ន្ធដង្ហើម (Respiratory syst)
- ពណ៌ភ្នាសស្លេីង(colout skeletal syst)...........ស្បែក(skin)...................ត្រចៀក (Ear). ភ្នែក (Eye)
- ប្រព័ន្ធឈាមរត់(Car diovassular syst )………………….. ប្រព័ន្ធរំលាយអាហារ ( Digestive syst)
- ប្រព័ន្ធទឹកមាត់(vrinary syst) ....................................ប្រព័ន្ធបន្តពូជ ( Genmetal syst)
- ប្រព័ន្ធប្រសាទ(Nervous syst)……………………………..ប្រព័ន្ធអង់ដូគ្រីន (Endocrine syst)

---

- កំណត់សំគាល់ /Remaks ………………………………………………………………………….
- រោគវិនិច្ឆ័យ/ Diagnosis ………………………………………………………………………..
- ព្យាបាល /Treatment .....................................................................................

- បសុពេទ្យ/Clinician……………………………..
- ថ្ងៃ ខែ /Date… ……………………………………..
- សំគាល់: N- Normal, A- Abnormal

( Diagnostic Report )

មហាវិទ្យាល័យផ.ប

ផ្នែករោគសាស្ត្រ

Faculty of Animal P.H (Division of Pathology)

ថ្ងៃ...............ខែ................ឆ្នាំ.......

ម្ចាស់ឈ្មោះ...........................................ClinicN$^0$.........................................................................

អាស័យដ្ឋាន.........................................បសុពេទ្យ..................................................................

........................................................អ្នកវិភាគរោគសាស្ត្រ....................................................

- ប្រភេទសត្វ៖ Cattle.......................ពូជ...ភេទ..................................................................
- អាយុ.............................................ស្នាមសម្គាល់...........................ទម្ងន់..........................
- សត្វស្លាប់ ឬសម្លាប់....................................?សត្វស្លាប់នៅពេលណា..................................?
- ធ្វើ Autopsy នៅពេលណា.......................................................................................?

១/ ប្រវត្តសត្វ (History Taken):..........................................................................

Symptom: Diarrhoea or Emaciation Sometime Animal may be Clinically normal.

២/ Macroscopic Finding៖ សណ្ឋានសាកសព (State of Carcass)Intergumentary System: Emaciated

- ស្បែក Gelatinous Atrophy
- រោម...............................................................................................

  Respiratory System

  - ច្រមុះ )Nose(: Ulceration/Mucopurulent Material
  - បំពងខ្យល(Trachea): Lesion start from bronchiol to alveolus
  - សួត(Lung): Broncho Pneumonia/Caseous lobular broncho pneumonia (whole lobes are affected)

Lymph node៖ Tubercular nodules Characteristic lesion

Gastro-Intestinal System

- Gastro-Intestinal System:
  - ធ្មេញ Teeth Lesion is enclosed with fibrous capsul
  - អណ្តាត Tongue..........................................................................................
  - បំពងអាហារ Oesophagus............................................................................ ......
  - ក្រពះ Stomach́:...............................................................................................
  - ពោះវៀន)Inteline(: Small........................Large.........................Nodule Gaseous

- ថ្លើម)Livre(: Mesenteric lymph gland affected when intestine was infected, Hematogenous infection nodular lesion thick Capsul/Yellow surface Abscess/

  Cirrhotic form
- ផាល)Spleen(:...................................................................................................

- Peritonitis: ..........................................................................................................
- Viseral Layer 3 Are thickened by granulation tissue
- Mostly in Calves adult always Secondary

  * Myco-Strain:

Human Strain (Myco-Tuberculosis) Infective to Human and Animal

Bovine Strain (Myco-bovis) - infected to man and Animals

Avian train (Myco- Avium)- infective to fowls and animals

Cold Blood Swain (Myco-Marinum)- infective to cold blood Animals

Vole bacillus (Myco-microti)- infective to Voles only

* Route of Infection:

a- Aerogenous or Inhalation

- By droplet infection

- Dush inhalation (feces, Urine…)

b- Enterogenous or ingestion

- Buccal Mucosa

- Pharygeal Mucosa

- Intestinal Mucosa

c- Usual Routes

- Cutaneous in Contact Case

- Congenital Via Plascenta, Umbilicus

- Genital by Copulation (ពាក់គ្នា)

- Mammary through the teats into the udder

| Cattle | Horse | Bovine | Avian |
|---|---|---|---|
| - Caseation and Calcification | - Rare, Lesions are chronic and proliferative | -Nodule is caseation and calcification and surrounded by fibrous capsules | - Lesion is prolife Rative-chronic |
| - Not so | - Appearance is like Sarcoma | - Caseation in hepatic lesion liquefies | -Hepatic lesion is not liquefy or calcify |
| - Zone of lymphocyte is present | - Not present | - Lymph node enlarge and caseation and calcification | - lymph node -slighthly enlarge |
| - Tuberculous organism be demonstrated in the lesion | - Difficult to find T. organism in the lesion | | |
| - sometime depend on congenital tuberculosis | - Spleen always affected | | |

- Cardiovascular System:
  - សរសៃឈាម (Blood Vessel)....................................................................................
  - បេះដូង (Heart).........................................................................................................
- Urinary System:
  - តម្រងនោម(Kidney) Start from interstitial tissue into the Cortex/Miliary form
  - ផ្លោកនោម(Urinary Bladder) Lesion Spread from Kidney is Possible
- Skeletal System:
  - ប្រពន្ធ័ខួរក្បាល និងខួរឆ្អឹងខ្នង (CNS) Meningitis (Cerebral)
  - ក្រពេញទឹករងៃ(Lymph Node) pulmonary lymph node Necrosis

- សភាពឆ្អឹង(Bone) Mostly in young ខួរឆ្អឹង.........(Bone Marrow)[3] Tubercular granuloma
- សាច់ដុំ (Muscle)..........................................................................................

- Reproductive System:
  - Mastitis: Increased in size and firm in consistency (Normal in section is garnish white and soft but in tuberculosis yellowish or brown and hard in consistency

---

Gross Diagnosis: Caseous lobular Broncho-pneumonia

Comment: Tuberculosis

Date of Report..........................................................Slide No..........................................

1- Microscopic Finding:

- បេះដូង(Heart)..........................................................................................
- ពោះវៀន (Intestine): Small (duodenum Jejunum, ileum)............................................... Large (Colon, Coecum, retum)...........................................................................
- សួត(Lung) Mycobacterium Organism is present
- ថ្លើម (Liver)..........................................................................................
- ផាល (Spleen)..........................................................................................
- តម្រងនោម(Kidney)..........................................................................................
- ខួរក្បាល(Brain)(Medular,Cerebrum,cerebellum).....................................................
..........................................................................................
- Nerve..........................................................................................

---

Final Diagnosis:

Date:..........................................................................

Signature........................................

Tuberculsis

Diagnosis:

1- Tuberculin Test (Cattle-Skin of neck region Pig-skin of ear, Fowl- Wattle

2- TB must be differentiated from asperation Pneumonia (Lung Absceses), Traumatic Reticulitis and contagious bovine Pneumonia

3- Find Charateristic lesion at Autopsy

4- Biological Test:

- Inaculation to Guinea-Pig
- Necropsy after 6-7 Weeks-Tuberculosis lesion

# របាយការណ៍រោគវិនិច្ឆ័យ

( Diagnostic Report )

មហាវិទ្យាល័យផ.ប ផ្នែករោគសាស្ត្រ

Faculty of Animal P.H (Division of Pathology)

ថ្ងៃ...............ខែ................ឆ្នាំ.......

ម្ចាស់ឈ្មោះ............................................

ClinicN$^0$..............................................................

អាស័យដ្ឋាន.........................................បសុពេទ្យ.....................................................

.......................................................អ្នកវិភាគរោគសាស្ត្រ..........................................

- ប្រភេទសត្វ៖ Cattle.......................ពូជ...ភេទ........................... .......................................
- អាយុ... .........................................ស្លាមសម្គាល់..........................ទម្ងន់..........................
- សត្វស្លាប់ឬសម្លាប់សត្វស្លាប់នៅពេ.................................?ណា.........................................?
- ធ្វើ Autopsy

នៅពេលណា...................................................................................................?

១/ ប្រវត្តសត្វ

(History Taken):.................................................................................................. ....

Symptom: Diarrhoea or Emaciation Sometime Animal may be Clinically normal.

២/ Macroscopic Finding៖ សណ្ឋានសាកសព (State of Carcass)

Intergumentary System: Emaciated

- ស្បែក Gelatinous Atrophy
- រោម...........................................................................................................

– Respiratory System
  - ច្រមុះ Nose: Ulceration/Mucopurulent Material
  - បំពងខ្យល(Trachea): Lesion start from bronchiol to alveolus
  - សួត(Lung): Broncho Pneumonia/Caseous lobular broncho pneumonia (whole lobes are affected)

Lymph node៖ Tubercular nodules Characteristic lesion

Gastro-Intestinal System

– Gastro-Intestinal System:
  - ធ្មេញ Teeth   Lesion is enclosed with fibrous capsul
  - អណ្តាត Tongue.......................................................................................
.......
  - បំពងអាហារ )Oesophagus(.........................................................................
..........
  - ក្រពះ Stomach:Mucosa...............................................................................
  - ក្រពះ Stomach  Mucosa Smooth
..................................................................
  - ពោះវៀន)Intestine( Small –Ileum................Large- thinckaned from 2 – 20 times
  - ថ្លើមLiver...........................................................................................

- ផាល Spleen.....................................................................................

- Peritonitis...........................................................................................
........

**Mycobacterium:**

- Para-tuberculosis (Strain):
  - Bovine- not affected to sheep
  - Ovine- affected in sheep of Scotland and Cattle also
- Route of Infection – Ingestion
- Diagnosis:

1- Symptom

2- 2- examination of Bowel Washings

3- Make smear from rectal Pinch to find acid- fast organism

4- Intradermal test by Johnin in the neck

5- Intravenous Johnin Test

6- Lesion of the Bowel at Postmortem and Microscopic demonstration of the Organisms in the epithelioid cells in Section

7- Lymphocyte blood Lymphocytes + antigen get Stimulated- Positive get not Stimulated- Normal

- **Cardiovascular System:**
  - សរសៃឈាម)Blood Vessel.........................................................................
  - បេះដូង Hea...........................................................................................
- **Urinary System:**
  - តម្រងនោម (Kidney) Start from interstitial tissue into the Cortex/Miliary form
  - ផ្លោកនោម (Urinary Bladder)[3] Lesion Spread from Kidney is Possible
- **Skeletal System:**

- ប្រពន្ធ័ខួរក្បាល និងឆ្អឹងខ្នង CNS
- ក្រពេញទឹករងៃ Lymph Node: Lymphangitis (Mesenteric lymph gland
- សភាពឆ្អឹង Bone:................................ខួរឆ្អឹង Bone Marrow(:................................
- សាច់ដុំMuscl ..........................................................................................

- Reproductive System:.........................................................................................

.....................................................................................................................

.....................................................................................................................

.....................................................................................................................

---

Gross Diagnosis........................

Comment...................................

Date of Report............................

Slide N$^0$: ....................................

3- Microscopic Finding:

- បេះដូង (Heart)៖ Arterisclerosis of Intestinal Vessel
- ពោះវៀន (Intestine): Small (duodenum, Jejunum, ileum):Thickened Villi and Intestinal Gland Disappear/Giant Cell Large (Colon, Coecum, rectum)៖ Tubercle Formation Mesenteric lymph node-Swollen and Jucy
- ថ្លើម (Liver)៖ Foci of Epithelioid Cell and lymphocyte
- ផាលឋ(Spleen)...........................................................................................
- តម្រងនោម (Kidney)...................................................................................
- ខួរក្បា(Brain)(Medular,Cerebrum,cerebellum)........................................

  ..................................................................................................

  ..................................................................................................
- Nerve: ..................................................................................................

---

Final Diagnosis:

Date:......................................

Johne´s Disease Signature

Paratuberculosis